
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ ២០១៥
លីអាហូណា
ទីបន្ទាល់ចុងក្រោយរបស់ប្រធានផាកកឺ ទំព័រ ១០
សម្រាប់គ្រូបង្រៀន ៖ សំណួរកាន់តែប្រសើរ ការរៀនកាន់តែប្រសើរ ទំព័រ ២០
អាពាហ៍ពិពាហ៍អស់កល្បជានិច្ច ៖ សេចក្តីសញ្ញានៅក្នុងសេចក្តីសញ្ញា ទំព័រ ២៤
រម្ងាប់ក្តីបារម្ភពីអនាគតរបស់អ្នក ទំព័រ ៣៤



*« ជាថ្មីម្ដងទៀត នគរស្ថានសួគ៌ក៏ប្រៀបដូចជាអ្នកឈ្មួញម្នាក់ដែលស្វែងរកកែវមុក្ដាយ៉ាងល្អ ៖*

*« កាលណាបានរកឃើញមួយដែលមានតម្លៃណាស់ នោះគាត់ទៅលក់របស់ទ្រព្យទាំងអស់ មកទិញកែវមុក្ដានោះ » ។*

ម៉ាថាយ ១៣:៤៥–៤៦ ។

# លីអាហូណា ខែ ធ្នូ ឆ្នាំ ២០១៥



១០

## សារលិខិត


៤ **សារលិខិតគណៈប្រធានទីមួយ: ចូរទុកពេលសម្រាប់ព្រះអង្គសង្គ្រោះ**
ដោយ ប្រធាន ថូម៉ាស អេស ម៉នសុន

៧ **សារលិខិតបង្រៀនសួរសុខទុក្ខ: លក្ខណៈសម្បត្តិដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ — សេចក្តីអាណិតអាសូរ និង សេចក្តីសប្បុរស**


## អត្ថបទពិសេសៗ


១០ **សាក្សីម្នាក់អំពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ**
ដោយ ប្រធាន បិយដ៏ យេ ផាកកឺ
*សាវកម្នាក់ដែលបានបម្រើអស់រយៈពេល ៤៥ ឆ្នាំថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ « ដោយភាពជឿជាក់ទាំងស្រុង » ។*

១៤ **យ៉ូសែប ស្ម៊ីធ និង គម្ពីរវិវរណៈ**
ដោយ ដេវីឌ អេ អេដវ្ជដ
*ហេតុអ្វីបានជា យ៉ូសែប ស្ម៊ីធ ហៅគម្ពីរវិវរណៈថាជា « គម្ពីរដ៏ច្បាស់បំផុតមួយ ដែលព្រះបានបណ្តាលឲ្យសរសេរទុក ? »*

២០ **សួរសំណួរត្រឹមត្រូវតាមរបៀបដែលត្រឹមត្រូវ**
ដោយ ស្កត់ អេច នីច
*សំណួរត្រឹមត្រូវអាចធ្វើឲ្យមានការផ្លាស់ប្តូរដ៏ធំ នៅពេលដែលយើងរៀន និង បង្រៀនដំណឹងល្អ ។*

២៤ **សេចក្តីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច**
ដោយ អែលឌើរ ម៉ាកឹស ប៊ី ណាស
*ដ្បិតអស់អ្នកដែលនៅជាប់នឹងលក្ខខណ្ឌទាំងនោះនៃសេចក្តីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនោះរង្វាន់របស់វាគឺជាសេចក្តីអំណរ និង សេចក្តីសុខសាន្តនៅក្នុងពិភពលោកនេះ និង ជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតបន្ទាប់ ។*

៣២ **« ខ្ញុំបានប្តេជ្ញាចិត្តចំពោះព្រះ »**
ដោយ ណេស្ទ័រ ខើរបេ៊ឡូ
*ការលះបង់របស់សមាជិកម្នាក់នៅក្នុងប្រទេសអេក្វាឌ័រ បានបង្ហាញពីឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងប្រវត្តិសាសនាចក្រនៅក្នុងប្រទេសនោះ ។*

៣៤ **ចូរមានសេចក្តីសុខសាន្តចុះ**
ដោយ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន
*សូមឆ្លៀតយក ឱកាសនៃបុណ្យគ្រីស្ទម៉ាស់នេះ ដើម្បីទទួលអារម្មណ៍នៃការលួងលោមរបស់ព្រះអង្គសង្គ្រោះ ។*


## ផ្នែកនានា


៨ **យើងនិយាយអំពីព្រះគ្រីស្ទ: អំណោយទាននៃជីវិត និង សេចក្តីស្រឡាញ់**
ដោយ ប្រាដ អលរ៉េត

៣៨ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

៨០ **លុះត្រាជួបទៀត: បុណ្យគ្រីស្ទម៉ាស់ដ៏ពិត**
ដោយ ប្រធាន ហារ៉ើដ ដបុលយូ ហ៊ឹនធើរ


**នៅលើក្របមុខ**
ខាងមុខ ៖ រចនាលម្អរូបថតដោយ ម៉ាថាយ រៀ ខាងក្នុងក្របមុខ ៖ រូបថតដោយ ផាទ្រីយ៉ូ ម៉ាតូរ៉ាណា/iStock/Thinkstock ។ ខាងក្នុងក្របខាងក្រោយ ៖ រូបថតដោយ ខ្លេបហើរ ថេក ។

## យុវមជ្ឈិមវ័យ





**៤៤ ការត្រឡប់មកផ្ទះវិញមុនកំណត់ពីបេសកកម្មរបស់ខ្ញុំ**
ដោយ ប្រីតានី រ៉ូម៉ានែឡូ ខាស្ត្រូ
*ខ្ញុំជឿលើរឿងនៃការព្យាបាលអ្នកឈឺរបស់ព្រះគ្រីស្ទ ហើយខ្ញុំបានជឿថា ទ្រង់នឹងធ្វើការណ៍នោះចំពោះខ្ញុំផងដែរ ។*

**៤៨ ទំព័រយុវមជ្ឈិមវ័យ: រស់នៅជាសាក្សីម្នាក់នៅក្នុងប្រទេស អាល្លឺម៉ង់**
ដោយ ចាស្ទីណា ម៉ាកខេនលេស
*ការយល់ដឹងពីរបៀបដែលព្រះវរបិតាសួគ៌គិតអំពីនាង បានជួយ អេស្ទើរ ក្នុងទំនាក់ទំនងរបស់នាងជាមួយនឹងមនុស្សដទៃ ។*




**ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើអ្នកបានរៀនអ្វីខ្លះពីឪពុកម្ដាយរបស់អ្នក ?**




## យុវវ័យ


**៥០ របៀបដើម្បីយល់ពីអត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់**
ដោយ ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ
*តើយើងអាចមានអារម្មណ៍ដឹងគុណចំពោះព្រះគ្រីស្ទ ហើយរំឭកការប្ដេជ្ញាចិត្តរបស់យើងដើម្បីធ្វើតាមទ្រង់ដោយរបៀបណា ?*

**៥១ អំណោយដែលផ្លាស់ប្ដូរជីវិត នៅឯហាងលក់របស់របរជជុះ**
ដោយ គានូ វិល្លាម
*ចម្លើយចំពោះការអធិស្ឋាននៅពេលបុណ្យគ្រីស្ទម៉ាស់ បាននាំទៅរកគ្រួសារជានិរន្តរមួយ ។*

**៥២ មនុស្សចំណូលថ្មី**
ដោយ ម៉ាធ្យូ ហ្វិតតុន
*ភាគច្រើនម៉ាធ្យូ នៅឯកោតែឯងក្នុងក្ឌុរ៉ុមរបស់ខ្លួន ប៉ុន្តែក្រោយមកគាត់បានឃើញថាពួកសង្ឃជាច្រើនត្រូវការការអញ្ជើញឲ្យមកចូលរួម ។*

**៥៤ ពួកគេបានស្គាល់យ៉ូសែប**
*ស្គាល់ព្យាការីយ៉ូសែប ស្ម៊ីធ តាមរយៈពាក្យសម្ដីរបស់មនុស្សដែលបានស្គាល់លោកដោយផ្ទាល់ ។*

**៥៦ តើអ្នកគឺជាអ្នកទទួល ឬ ជាអ្នកឲ្យ ?**
*សូមគិតឡើងវិញពីទស្សនវិស័យរបស់អ្នកក្នុងការគោរពតាមព្រះបញ្ញត្តិ និង បម្រើនៅក្នុងសាសនាចក្រ ។*

**៥៧ ប័ណ្ណប្រកាស: ប្រើវា ឬ បាត់បង់វា**

**៥៨ សំណួរ និង ចម្លើយ**
*ខ្ញុំមានអារម្មណ៍ថា អសមត្ថភាពធ្វើជាប្រធានថ្នាក់យុវនារី ។ តើខ្ញុំអាចក្លាយជាអ្នកដឹកនាំដ៏ល្អប្រសើរម្នាក់ដោយរបៀបណា ?*

**៦០ អ្វីៗដែលខ្ញុំបានរៀនក្នុងនាមជាអ្នកប្រែចិត្តជឿវ័យក្មេងម្នាក់**
ដោយ អែលឌើរ ជ័គ ក្លេប៊ីនហ្គាត
*ការអធិស្ឋាន និង ការអនុវត្តដង្វាយធួនជាប្រចាំអាចជួយអ្នកឲ្យមានទំនុកចិត្ត ហើយនៅស្អាតស្អំគ្រប់ពេលវេលា ។*

**៦៤ ការអភិវឌ្ឍន៍ខ្លួនជាមួយកម្មវិធី មែកធាងគ្រួសាររបស់ខ្ញុំ**
ដោយ រ៉ាយសា ម៉ាខុនដេស
*តាមរយៈការធ្វើពង្សប្រវត្តិរបស់ខ្លួន រ៉ាយសាបានឃើញថា នាងពុំមែនជាសមាជិកនៃសាសនាចក្រនេះតែម្នាក់ឯងឡើយនៅក្នុងគ្រួសាររបស់នាង ។*


## កុមារ





**៦៥ ព្រះគម្ពីរសម្រាប់ ស្ពែនស៊ើរ**
ដោយ អែលឌើរ ម៉ាកឹស ប៊ី ណាស
*ស្ពែនស៊ើរ ពុំដឹងពីមូលហេតុដែលគាត់ដេកមិនលក់ឡើយ នៅពេលឪពុកម្ដាយរបស់គាត់បានចេញទៅតាមខេត្តនោះ ។ តើមានរឿងអ្វីទៅ ?*

**៦៦ មេរៀនមួយពីឪពុកខ្ញុំ**
ដោយ អែលឌើរ ដាវីឌ អេ បែដណា
*ឪពុករបស់អែលឌើរ បែដណា ពុំមែនជាសមាជិកនៃសាសនាចក្រឡើយ ប៉ុន្តែគាត់នៅតែបង្រៀនលោកពីមេរៀនសំខាន់មួយអំពីបព្វជិតភាព ។*

**៦៧ រូបភាពពីព្រះគម្ពីរ: ព្រះគម្ពីរមរមន**

**៦៨ យប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ជាមួយគ្រួសារគ័រដូបាស់**
ដោយ ហាន់នី ថាលា កាបិល ឡូស្ទ
*ម៉ារីស៊ីឡូ និង ប្អូនស្រីរបស់នាងអាចឲ្យអ្វីផ្សេងទៀតដែលប្រសើរជាងអំណោយនានាដល់គ្រួសារគ័រដូបាស់ សម្រាប់បុណ្យគ្រីស្ទម៉ាស់ ។*

**៧០ ល្បែងផ្គុំរូបនៃការស្ដារឡើងវិញ**
ដោយ ហែឌី ផូលម៉ែន
*អានណា ត្រូវឡើងនិយាយនៅក្នុងថ្នាក់បឋមសិក្សា ។ តើនាងអាចពន្យល់អត្ថន័យនៃ*ការស្ដារឡើងវិញ *យ៉ាងដូចម្ដេច ?*

**៧២ ពេលវេលាសម្រាប់ខគម្ពីរ: ព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្ដងទៀត !**
ដោយ អេរិន សែនឌើរសិន

**៧៤ សម្រាប់កុមារតូចៗ: ដំណើររឿងនៃព្រះប្រសូតិកម្ម**

**ខែ ធ្នូ ឆ្នាំ ២០១៥ ភាគទី ១៤ លេខ ៦**
លីអាហូណា ១២៥៧២ ២៥៨
ទស្សនាវដ្ដីអន្ដរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រ៉ូប៊ឺត ឌី. ហេល, ជេហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនធិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** យ៉ូសែប ដបុលយូ. សុីតាទី
**អ្នកប្រឹក្សា ៖** ប៉ែនដល យេ. បេិននីត, ក្រាហ្គ អេ. ខ័រដុន, គ្រីស្តូហ្វឺល ហ្គូឌីន, ឡារី អរ. ឡរីន និង ជេមស៍ ប៊ី. ម៉ាទីណូ

**នាយកគ្រប់គ្រង ៖** យ៉ូសែប ដបុលយូ. សុីតាទី
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាសូ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** ប៉ែអិន ខារ
ជំនួយការផ្នែកបោះពុម្ព ៖ លីស្សា សុី ឡប៉េស្ស
**និពន្ធ និងកែសម្រួល ៖** ប្រ៊ិតថានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាថាយ ឌី ហ្វីតតុន, ឡារី ហ្វលើរ, ហ្វាប់ត អេច ហ្វាហ្វ, ឡាប៉ែន ផតទើរ ហ្គាន, ជីល ហាកឃីង, ឆាលឡូត ឡាកាបាល់, មីនឌី អាន លីវិត, ម៉ៃឃល អរ ម៉ូរីស, សាលី ចនសុន អូដេឃឹក, យ៉ូស្វេ ជេ ភឺគី, ចាន ភីនបូរ៉ាហ្វ, វីឆាត អិម រ៉ូមនី, ប៉ុល វ៉ាន់ឌិន បើហ្គ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ចាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនច័លី, សុី ឃីមបឺល បុត, ចូម៉ាស ឆាល, ណាត ហ្គិនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រើន, ស្កត អិម ម៉ូយ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉ែកឃិនហូស
**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នៃបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខន្នី បិវទូប ប្រ៊ីច, ជូលី ប៊ីដេត, ខេទី ដានខាន, ប្រែអិន ដ័បុលយូ ជីជី, ជិន្នីស ខឺប៊ី, ជីន្នី ជេ និលសុន, ហ្គេល ធេត រ៉ាហ្វឺជី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីគ
**នាយកផ្នែកចែកចាយ ៖** ស្តេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុន្មាន គឺប្រែប្រួលទៅតាមភាសា ) ។

© 2015 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
December 2015 Vol. 14 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store .lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# គំនិតនានាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



**« ចូរមានសេចក្ដីសុខសាន្តចុះ »** ទំព័រ ៣៤ ៖ អែលឌើរ គ្រីស្តូហ្វឺសិន អញ្ជើញយើងឲ្យឆ្លៀតយកឱកាសនៃរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះអង្គុយដោយស្ងាត់ស្ងៀម ហើយគិតអំពីព្រះឱរសយេស៊ូវ ។ សូមគិតពីការអានអត្ថបទនេះជាមួយក្រុមគ្រួសារ ហើយបន្ទាប់មកអញ្ជើញឲ្យមានស្មារតីនៃគារវភាពដោយការអានព្រះគម្ពីរ ច្រៀងទំនុកតម្កើង ឬទស្សនា Bible videos ( ដែលមាននៅគេហទំព័រ Biblevideos.org ) អំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ ។ បន្ទាប់មក សូមទុកពេលឲ្យមនុស្សម្នាក់ៗគិតអំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ ព្រមទាំងអត្ថន័យនៃការប្រសូតនោះចំពោះពួកគេ ។ អ្នកអាចគិតពីការផ្ដល់សៀវភៅកំណត់ហេតុ ឬ ក្រដាសដល់អស់អ្នកដែលមានបំណងកត់ត្រានូវគំនិតទាំងឡាយរបស់ខ្លួន ។ សូមឲ្យសមាជិកគ្រួសារចែកចាយគំនិតរបស់ខ្លួន បើសិនជាពួកគេចង់ ។

**វីដេអូបុណ្យគ្រីស្ទម៉ាស់** Mormon.org ៖ សូមគិតពីរបៀបនានា ដែលគ្រួសារអ្នកអាចប្រើវីដេអូបុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ ដើម្បីចែកចាយដំណឹងល្អជាមួយនឹងមនុស្សដទៃទៀត ។ អ្នកអាចធ្វើនំគ្រីស្ទម៉ាស់ផ្សេងៗចែកឲ្យមិត្តភក្ដិ ហើយផ្ញើនំនោះជាមួយនឹងប័ណ្ណមួយដែលមានអាសយដ្ឋាននៃគេហទំព័ររបស់វីដេអូនេះ ។ អ្នកក៏អាចចង់ដាក់ផែនការធ្វើយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គមមួយជាគ្រួសារ ហើយដាក់គោលដៅនានាថា តើអ្នកអាចចែកចាយវីដេអូនេះជាមួយនឹងមនុស្សប៉ុន្មាននាក់ ។ ជម្រើសមួយទៀតនោះគឺអញ្ជើញមិត្តភក្ដិឲ្យទស្សនាវីដេអូនេះជាមួយអ្នក ។

## ជាភាសារបស់អ្នក

*លីអាហូណា* និង ធនធានផ្សេងៗទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។

សូមមើលគេហទំព័រ **facebook.com/liahona.magazine** ដើម្បីទទួលបានគំនិតនានាអំពីរាត្រីជួបជុំក្រុមគ្រួសារ ជំនួយសម្រាប់មេរៀនថ្ងៃអាទិត្យ និង មាតិកាដែលអ្នកអាចចែកចាយជាមួយមិត្តភក្ដិ និង គ្រួសារ ។ ( មានជាភាសាអង់គ្លេស អេស្ប៉ាញ និង ព័រទុយហ្គាយ )

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយ គឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការគោរពប្រតិបត្តិ, ២៤, ៥៦*
*ការបង្រៀន, ២០*
*អាពាហ៍ពិពាហ៍, ២៤*
*ការបម្រើ, ៤, ៣៩, ៤១, ៥៦, ៥៨, ៦៨*
*ការបូជា, ៨, ៣២, ៣៩, ៤០, ៤៣, ៥៦, ៦០*
*ការយាងមកជាលើកទីពីរ, ៧២*
*ការរៀនសូត្រ, ២០*
*ការលះបង់, ៣២*
*ការសិក្សាព្រះគម្ពីរ, ៦៥*
*ការស្ដារឡើងវិញ, ៧០*
*ការអធិស្ឋាន, ៤១, ៤២, ៦០*
*កិច្ចការផ្សព្វផ្សាយសាសនា, ៣២, ៤៤, ៤៨, ៥១, ៥២*
*កិច្ចការព្រះវិហារបរិសុទ្ធ, ៤២, ៤៣, ៥៨*
*ដង្វាយធួន, ១០, ៤៤, ៦០*
*ថ្នាក់ដឹកនាំ, ៥៨*
*ទេពកោសល្យ, ៥៧*
*បព្វជិតភាព, ៦៦*
*បុណ្យគ្រីស្ទម៉ាស់, ៤, ៨, ៣៤, ៣៨, ៣៩, ៤០, ៤១, ៤២, ៤៣, ៥០, ៥១, ៦៨, ៧២, ៧៤, ៨០*
*ពង្សប្រវត្តិ, ៦៤*
*ព្រះគម្ពីរមរមន, ៦៧*
*ព្រះគម្ពីរសញ្ញាថ្មី, ១៤*
*សេចក្ដីសញ្ញា, ២៤*
*ព្រះយេស៊ូវ គ្រីស្ទ, ៤, ១០, ២៤, ៣៤, ៥០, ៦០, ៧២*
*ជីវិតអស់កល្បជានិច្ច, ២៤*
*សេចក្ដីសុខសាន្ត, ៣៤*
*សេចក្ដីស្រឡាញ់, ៨*
*សេចក្ដីសប្បុរស, ៧, ៤១, ៥៨*
*សេចក្ដីអាណិតអាសូរ, ៧*
*ស៊្មីធ, យ៉ូសែប, ១៤, ៥៤, ៧០*



ដោយ ប្រធាន
ថូម៉ាស អេស ម៉នសុន

## ចូរទុកពេលសម្រាប់

# ព្រះអង្គសង្គ្រោះ

រដូវកាលបុណ្យគ្រីស្ទម៉ាស់មកដល់ជាថ្មីទៀតហើយ ហើយវាក៏ជិតដល់បុណ្យចូលឆ្នាំថ្មីដែរ ។ វាហាក់បីដូចជាយើងទើបតែប្រារព្ធពិធីប្រសូតរបស់អង្គសង្គ្រោះ និង ធ្វើការតាំងចិត្តនានាកាលពីម្សិលមិញអញ្ចឹង ។

នៅក្នុងការតាំងចិត្តរបស់យើងសម្រាប់ឆ្នាំនេះ តើយើងបានតាំងចិត្តទុកពេលក្នុងជីវិត និង ដួងចិត្តរបស់យើងសម្រាប់ព្រះអង្គសង្គ្រោះឬទេ ? មិនថាយើងមានជោគជ័យខ្លាំងប៉ុណ្ណានោះទេ យើងប្រហែលជាបានធ្វើការតាំងចិត្តមួយបែបនោះ ខ្ញុំមានទំនុកចិត្តថា យើងទាំងអស់គ្នាមានបំណងចង់ធ្វើឲ្យបានកាន់តែប្រសើរឡើង ។ រដូវកាលបុណ្យគ្រីស្ទម៉ាស់នេះគឺជាពេលដ៏ល្អបំផុតដើម្បីពិនិត្យ និង រំឭកពីកិច្ចខិតខំនានារបស់យើងឡើងវិញ ។

នៅក្នុងជីវិតដ៏មមាញឹករបស់យើង ដែលមានកិច្ចការផ្សេងទៀតជាច្រើនដែលប្រទាញប្រទង់យកការផ្តោតចិត្តទុកដាក់របស់យើង វាចាំបាច់ថា យើងធ្វើការតាំងចិត្តដោយមានបំណងនាំយកព្រះគ្រីស្ទចូលមកក្នុងជីវិត និង គេហដ្ឋានរបស់យើង ។ ដូចជាហោរាដែលមកពីទិសខាងកើតដែរ វាចាំបាច់ថា យើងនៅតែបន្តដើរជាប់តាមផ្កាយរបស់ទ្រង់ ហើយ « មកថ្វាយបង្គំទ្រង់ » ។[១]

ពីមួយជំនាន់ទៅមួយជំនាន់ សារលិខិតអំពីព្រះយេស៊ូវគឺនៅតែដដែល ។ ទ្រង់បានមានបន្ទូលទៅពេត្រុស និង អនទ្រេ នៅក្បែរឆ្នេរសមុទ្រកាលីឡេថា « ចូរមកតាមខ្ញុំ » ។[២] ចំពោះភីលីពទ្រង់ហៅ « ចូរមកតាមខ្ញុំ » ។[៣] ចំពោះលេវីដែលអង្គុយនៅកន្លែងយកពន្ធបានផ្តល់ការណែនាំថា « ចូរមកតាមខ្ញុំ » ។[៤] ហើយចំពោះអ្នក និង រូបខ្ញុំ បើសិនយើងគ្រាន់តែស្តាប់ នោះយើងនឹងបានឮការកោះអញ្ជើញដូចគ្នាគឺ « ចូរមកតាមខ្ញុំ » ។[៥]

នៅពេលយើងដើរតាមដានព្រះបាទាទ្រង់នាពេលសព្វថ្ងៃនេះ ហើយនៅពេលយើងប្រឹងធ្វើតាមគំរូរបស់ទ្រង់ នោះយើងនឹងមានឱកាសប្រទានពរជ័យដល់មនុស្សដទៃជាច្រើនទៀត ។ ព្រះយេស៊ូវអញ្ជើញយើងឲ្យលះបង់ខ្លួនយើង ៖ « មើលចុះព្រះអម្ចាស់ទ្រង់តម្រូវចិត្ត និង គំនិតដែលស្ម័គ្រតាម » ។[៦]

តើមាននរណាម្នាក់ដែលអ្នកគួរតែបម្រើនៅពេលបុណ្យគ្រីស្ទម៉ាស់នេះឬទេ ? តើមាននរណាម្នាក់ដែលរង់ចាំអ្នកទៅសួរសុខទុក្ខឬទេ ?

ច្រើនឆ្នាំកន្លងមកហើយ ខ្ញុំបានទៅសួរសុខទុក្ខដល់ផ្ទះស្ត្រីមេម៉ាយចំណាស់ម្នាក់នៅពេលបុណ្យគ្រីស្ទម៉ាស់នោះ ។ ខណៈដែលខ្ញុំកំពុងនៅទីនោះ កន្ទឹងទ្វារបានរោទិ៍ឡើង ។ មានវេជ្ជបណ្ឌិតដ៏សែនរវល់ និង ល្បីល្បាញម្នាក់ឈរនៅមាត់ទ្វារនោះ ។ គេមិនបានហៅគាត់ឲ្យមកឡើយ ប៉ុន្តែគាត់គ្រាន់តែមានអារម្មណ៍បំផុសគំនិតថាចង់មកលេងអ្នកជំងឺដែលឯកោនេះ ។

អំឡុងពេលនៃរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ អស់អ្នកដែលឈឺនៅផ្ទះ ចង់ឲ្យគេជួយ និង ចង់ឲ្យគេទៅសួរសុខទុក្ខខ្លួន ។ មានបុណ្យគ្រីស្ទម៉ាស់ម្តងនោះ ខណៈខ្ញុំកំពុងទៅសួរសុខទុក្ខនៅមជ្ឈមណ្ឌលចាស់ជរា នោះខ្ញុំបានអង្គុយ ហើយជជែកគ្នាជាមួយស្ត្រីចំណាស់ៗប្រាំនាក់ ម្នាក់ដែលចាស់ជាងគេនោះអាយុ ១០១ ឆ្នាំ ។ គាត់ងងឹតភ្នែក ប៉ុន្តែគាត់ស្គាល់សំឡេងខ្ញុំ ។

គាត់បាននិយាយថា « ប៊ីស្សព លោកបានមកយឺតបន្តិចហើយឆ្នាំនេះ ! » ។ « ខ្ញុំគិតថាលោកនឹងពុំមកទេ » ។

យើងបានមានពេលវេលាដ៏រីករាយជាមួយគ្នា ។ ប៉ុន្តែ មានអ្នកជំងឺម្នាក់ដែលមើលទៅខាងក្រៅបង្អួចយ៉ាងយូរ ហើយនិយាយច្រំដែលៗថា « ខ្ញុំដឹងថាកូនប្រុសរបស់ខ្ញុំ នឹងមកលេងខ្ញុំថ្ងៃនេះ » ។ ខ្ញុំឆ្ងល់ថា តើកូនប្រុសនោះនឹងមកឬទេ ដ្បិតគាត់ពុំដែលមកលេងនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់ជាច្រើនដងមកហើយ ។

ប៉ុន្តែមានពេលវេលានៃឆ្នាំនេះដើម្បីឈោងជួយ បើកដួងចិត្តស្រឡាញ់ និង មានស្មារតីនៃឆន្ទៈ — និយាយម្យ៉ាងទៀតថា ធ្វើតាមគំរូដែលបានគូសដោយព្រះអង្គសង្គ្រោះ ព្រមទាំងបម្រើដូចដែលទ្រង់ចង់ឲ្យពួកយើងបម្រើ ។ នៅពេលយើងបម្រើទ្រង់ នោះយើងនឹងមិនបោះបង់ឱកាសរបស់យើង ដូចដែលម្ចាស់ផ្ទះសំណាក់កាល



ពីបុរាណបានធ្វើចំពោះទ្រង់ឡើយ ⁷ គឺយើងទុកពេលសម្រាប់ទ្រង់ឲ្យគង់នៅក្នុងជីវិតយើង និង ដួងចិត្តរបស់យើង ។

តើយើងអាចយល់ពីការសន្យាដ៏អស្ចារ្យ ដែលមាននៅក្នុងសារលិខិតរបស់ទេវតា ដែលបានប្រាប់ដល់ពួកអ្នកគង្វាលចៀមនៅទីវាលដែលថា « ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នាពីសេចក្ដីអំណរយ៉ាងអស្ចារ្យ ។ . . . ដ្បិតនៅថ្ងៃនេះ មាន . . . ព្រះអង្គសង្គ្រោះមួយអង្គ ប្រសូតដល់អ្នករាល់គ្នា គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ? »[8]

នៅពេលយើងប្ដូរអំណោយគ្នា នៅពេលបុណ្យគ្រីស្ទម៉ាស់នេះ សូមឲ្យយើងចងចាំ មានអំណរគុណ ហើយទទួលអំណោយដ៏អស្ចារ្យបំផុតជាងអំណោយផ្សេងទៀត — គឺអំណោយនៃព្រះអង្គសង្គ្រោះ និង ព្រះដ៏ប្រោសលោះរបស់យើង ដែលយើងអាចមានជីវិតដ៏នៅអស់កល្បជានិច្ច ។

« ដ្បិតតើមានប្រយោជន៍អ្វីដល់មនុស្ស បើសិនជាបានប្រទានអំណោយទានមកដល់គេ ហើយគេពុំទទួលយកអំណោយទានសោះ ? មើលចុះ អ្នកនោះពុំត្រេកអរចំពោះអ្វីដែលបានប្រទានដល់គេ ឬ ក៏ត្រេកអរចំពោះម្ចាស់ដែលប្រទានអំណោយទាននោះដែរ » ។[9]

ចូរយើងធ្វើតាមទ្រង់ បម្រើទ្រង់ គោរពទ្រង់ ហើយទទួលអំណោយទានរបស់ទ្រង់មកក្នុងជីវិតរបស់យើង ដែលយើងអាចបានដូចជាពាក្យរបស់លោកលីហៃ « ត្រូវបានឱបក្រសោបជាអង្វែងតទៅដោយព្រះពាហុនៃសេចក្ដីស្រឡាញ់របស់ទ្រង់ » ។[10] ■

កំណត់ចំណាំ
១. ម៉ាថាយ ២:២ ។
២. ម៉ាថាយ៤:១៩ ។
៣. យ៉ូហាន ១:៤៣ ។
៤. ម៉ាថាយ ៩:៩ ។
៥. គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២២ ។
៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៤ ។
៧. សូមមើល លូកា ២:៧ ។
៨. លូកា ២:១០–១១ ។
៩. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៣៣ ។
១០. នីហ្វៃទី ២ ១:១៥ ។

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រធាន ម៉នសុន អំពាវនាវឲ្យយើង « ធ្វើការតាំងចិត្តដោយមានបំណងនាំព្រះគ្រីស្ទចូលមកក្នុងជីវិត និងគេហដ្ឋានរបស់យើង » ។ សូមគិតពីការពិភាក្សាជាមួយនឹងអស់អ្នកទាំងឡាយណា ដែលអ្នកបង្រៀនអំពីរបៀបដែលពួកគេអាចធ្វើការតាំងចិត្តជាមួយនឹងបំណងនេះដោយផ្ទាល់ខ្លួន និង ជាគ្រួសារ ។ អ្នកអាចសួរពួកគេឲ្យគិតពីមនុស្ស ឬ គ្រួសារជាក់លាក់ណាមួយដែលពួកគេអាចទៅសួរសុខទុក្ខ ឬ បម្រើនៅពេលបុណ្យគ្រីស្ទម៉ាស់នេះ ។ « ប៉ុន្តែមានពេលវេលានៃឆ្នាំនេះដើម្បីឈោងជួយ បើកដួងចិត្តស្រឡាញ់ និង មានស្មារតីនៃធន្ទះ » ។

រូបថតដោយ ដារីន ស្មីធ



## វិធីនានាដើម្បីបម្រើនៅបុណ្យគ្រីស្ទម៉ាស់

ប្រធាន ម៉នសុន ឆ្លៀតពេលទៅសួរសុខទុក្ខមនុស្សចាស់ជរា និង អស់អ្នកដែលនៅក្នុងមជ្ឈមណ្ឌលចាស់ជរា ជាពិសេសនៅពេលបុណ្យគ្រីស្ទម៉ាស់ ។ លោកបានកត់សម្គាល់ឃើញថា មានមនុស្សដែលរីករាយដោយសារមានគេទៅសួរសុខទុក្ខខ្លួន ខណៈដែលមានអ្នកផ្សេងទៀតគ្រាន់តែសង្ឃឹមថា នឹងមានគេមកសួរសុខទុក្ខ តែគ្មានគេមកសួរសុខទុក្ខឡើយ ។ មានមនុស្សដែលរង់ចាំនរណាម្នាក់ — ប្រហែលជានៅពេលបុណ្យគ្រីស្ទម៉ាស់នេះ *អ្នក* អាចក្លាយជាបុគ្គលម្នាក់នោះ ។

ខាងក្រោមនេះជាបញ្ជីមួយ ដែលមានវិធីមួយចំនួនដែលអ្នកអាចជួយធ្វើឲ្យប្រាកដថា គ្មាននរណាម្នាក់ឡើយដែលនឹងមានអារម្មណ៍ថា ឯកោនៅពេលបុណ្យគ្រីស្ទម៉ាស់នេះ ។ សូមកុំខ្លាចធ្វើតាមវិធីជាច្រើនទៀត ដែលអ្នកគិតថា អ្នកអាចជួយនៅក្នុងសហគមន៍របស់អ្នកនៅអំឡុងពេលនៃរដូវកាលនេះ ។ « តើមាននរណាម្នាក់ដែលរង់ចាំអ្នកទៅសួរសុខទុក្ខឬទេ ? »

- សូមធ្វើប័ណ្ណបុណ្យគ្រីស្ទម៉ាស់ផ្ញើទៅអ្នកផ្សព្វផ្សាយសាសនា និង សមាជិកតែម្នាក់ឯង ឬ សមាជិកចាស់ជរាក្នុងវួដ ឬសាខារបស់អ្នក ។
- សូមស្ម័គ្រចិត្តជាមួយអង្គការសហគមន៍ក្នុងមូលដ្ឋាន ។
- សូមជូនព្រះគម្ពីរមរមន ជាអំណោយដល់មិត្តភក្តិ និង អ្នកជិតខាងរបស់ខ្លួនអ្នក ។
- សូមទៅសួរសុខទុក្ខមនុស្សចាស់ជរាក្នុងវួដ ឬ គ្រួសាររបស់អ្នក ។
- ធ្វើនំជូនដល់អ្នកជិតខាងរបស់អ្នក ។

សម្រាប់គំនិតបន្ថែមទៀតអំពីរបៀបដែលអ្នកអាចបម្រើនៅក្នុងសហគមន៍របស់អ្នក សូមចូលទៅកាន់គេហទំព័រ lds.org/topics/humanitarian-service/help ។



## ចូរដើរតាមពន្លឺ

បន្ទាប់ពី ព្រះយេស៊ូវ បានប្រសូត ពួកហោរាបាននាំយកអំណោយផ្សេងៗមកថ្វាយទ្រង់ ។ ពួកគេបានដើរតាមពន្លឺផ្កាយថ្មីដែលរះនៅលើមេឃដើម្បីជួបទ្រង់ ។

សូមដើរតាមផ្លូវនេះដើម្បីទៅជួបព្រះយេស៊ូវ ។ តើអំណោយអ្វីខ្លះដែលអ្នកអាចនាំយកទៅថ្វាយទ្រង់បាន ?



*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន ហើយព្យាយាមស្វែងយល់ឲ្យដឹងថាត្រូវចែកចាយអ្វី ។ តើការយល់ពីលក្ខណៈដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ នឹងបង្កើនដល់សេចក្ដីជំនឿរបស់អ្នកចំពោះទ្រង់ ហើយនិងផ្ដល់ពរជ័យដល់អ្នកទាំងឡាយដែលអ្នកថែទាំតាមរយៈការបង្រៀនសួរសុខទុក្ខដោយរបៀបណា ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# លក្ខណៈសម្បត្តិដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ ៖ សេចក្ដីអាណិតអាសូរ និង ចិត្តសប្បុរស



កូនស្រីរបស់យ៉ៃរ៉ុស ដោយ ឌែល ផាសុន

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនសួរសុខទុក្ខ ដែលឆ្លុះបញ្ចាំងពីលក្ខណៈដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ ។*

« នៅក្នុងព្រះគម្ពីរ សេចក្ដីអាណិតអាសូរ មានន័យត្រង់ថា ‹ អត់ធន់ជាមួយនឹងអ្វីមួយ › ។ វាក៏មានន័យថា បង្ហាញចិត្តអាណិតអាសូរ ចិត្តករុណា និង សេចក្ដីមេត្តាចំពោះអ្នកឯទៀត »។[១]

ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « ព្រះយេស៊ូវប្រទានគំរូជាច្រើនអំពីសេចក្ដីអាណិតអាសូរដល់យើង » ។ « បុរសខ្វិនជើងនៅឯស្រះបេថែសដា ស្ត្រីលួចសាហាយស្មន់ ស្ត្រីនៅអណ្ដូងទឹករបស់យ៉ាកុប កូនស្រីរបស់យ៉ៃរ៉ុស ឡាសារ ប្អូនប្រុសរបស់ ម៉ារី និង ម៉ាថា — ពួកគេម្នាក់ៗគឺដូចជាបុរសម្នាក់ដែលរងរបួសនៅតាមផ្លូវយេរីខូរដែរ ។ ម្នាក់ៗត្រូវការជំនួយ ។

« ចំពោះបុរសខ្វិនជើងនៅបេថែសដា ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ‹ ចូរក្រោកឡើង យកគ្រែអ្នកដើរទៅ › ។ ចំពោះស្ត្រីមានបាបនោះ ទ្រង់បានទូន្មានថា ‹ អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ › ។ ដើម្បីជួយនាងដែលបានមកដងទឹកនោះ ទ្រង់បានប្រទានអណ្ដូងទឹកមួយ ‹ ជារន្ធទឹកដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច › ។ ចំពោះកូនស្រីដែលស្លាប់របស់យ៉ៃរ៉ុសនោះទ្រង់បានបញ្ជាថា ‹ កូនស្រីអើយ យើងប្រាប់ឲ្យឯងក្រោកឡើង › ។ ចំពោះឡាសារដែលនៅក្នុងផ្នូរ « ឡាសារអើយចូរចេញមក › ។

« ព្រះអង្គសង្គ្រោះបានបង្ហាញពីគោលជំហរដែលគ្មានដែនកំណត់នៃសេចក្ដីអាណិតអាសូរ ។ . . . ចូរឲ្យយើងបើកទ្វារនៃដួងចិត្តរបស់យើង ដែលទ្រង់ — ជាគំរូដ៏រស់រវើកនៃសេចក្ដីអាណិតអាសូរដ៏ពិត — អាចយាងចូល » ។[២]

### *បទគម្ពីរបន្ថែម*

ទំនុកតម្កើង ១៤៥:៨; សាការី ៧:៩; ពេត្រុសទី ១ ៣:៨; ម៉ូសាយ ១៥:១, ៩; នីហ្វៃទី ៣ ១៧:៥–៧

### *សូមពិចារណាពីសំណួរនេះ*

តើនរណាខ្លះអាចទទួលបានពរជ័យ តាមរយៈសេចក្ដីអាណិតអាសូររបស់អ្នក ?

កំណត់ចំណាំ

១. សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « សេចក្ដីអាណិតអាសូរ » ។
២. ថូម៉ាស អេស ម៉នសុន « The Gift of Compassion » *Liahona,* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៤–៥, ៨ ។
៣. លីនដា អេស រីវ៉េស « ព្រះអម្ចាស់ពុំបំភ្លេចអ្នកឡើយ » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១២០ ។
៤. លីនដា អេស រីវ៉េស « ព្រះអម្ចាស់ពុំបំភ្លេចអ្នកឡើយ » ទំព័រ ១១៨ ។
៥. លីនដា អេស រីវ៉េស « ព្រះអម្ចាស់ពុំបំភ្លេចអ្នកឡើយ » ទំព័រ ១២០ ។

## សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ

### *ចេញពីព្រះគម្ពីរ*

លីនដា អេស. រីវ៉េស ទីប្រឹក្សាទីពីរក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅមានប្រសាសន៍ថា « ស្វាមីខ្ញុំ និង រូបខ្ញុំបានលុតជង្គង់នៅក្បែរកូនស្រីអាយុ ១៧ ឆ្នាំរបស់យើង ហើយបានទូលអង្វរសុំជីវិតរបស់នាង » ។ « គ្មានចម្លើយបានមកទេ ប៉ុន្តែ . . . យើងប្រែជាដឹង . . . ថា . . . [ ព្រះអង្គសង្គ្រោះ ] មានក្ដីអាណិតអាសូរដល់យើងចំពោះទុក្ខព្រួយរបស់យើង » ។[៣]

« រឿងមួយដែលខ្ញុំពេញចិត្តពីជីវិតរបស់ព្រះអង្គសង្គ្រោះនោះ គឺរឿងរបស់ឡាសារ ។ ព្រះគម្ពីរប្រាប់យើងថា ‹ ព្រះយេស៊ូវបានស្រឡាញ់ម៉ាថា . . . បងប្អូនស្រី [ ម៉ារី ] និង [ ប្អូនប្រុស របស់ពួកគេ ] ឈ្មោះឡាសារ › » ។[៤] នៅពេលឡាសារបានឈឺ ដំណឹងនោះបានឮដល់ព្រះយេស៊ូវ ប៉ុន្តែនៅពេលដែលទ្រង់បានទៅដល់ ឡាសារបានស្លាប់ទៅហើយ ។ ម៉ារីបានរត់មកឯព្រះយេស៊ូវ ក្រាបចុះនៅព្រះបាទទ្រង់ ហើយបានយំ ។ នៅពេលព្រះយេស៊ូវបានឃើញម៉ារីកំពុងយំ « ទ្រង់មានសេចក្ដីរំជួលក្នុងព្រះទ័យ ហើយ . . .ព្រះកន្សែង » ( យ៉ូហាន ១១:៣៣, ៣៥ ) ។

« នោះគឺជាទំនួលខុសត្រូវរបស់យើង ។ យើងត្រូវតែទទួលអារម្មណ៍ ហើយឃើញដោយខ្លួនឯង ហើយបន្ទាប់មកជួយកូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ឲ្យទទួលអារម្មណ៍ និងឃើញ ហើយដឹងថាព្រះអង្គសង្គ្រោះរបស់យើងពុំត្រឹមតែទទួលដាក់លើអង្គទ្រង់នូវអំពើបាបរបស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលយកការឈឺចាប់ និង ការរងទុក្ខ ព្រមទាំងសេចក្ដីវេទនារបស់យើង ដូច្នេះទ្រង់អាចយល់ពីអារម្មណ៍ និងរបៀបដើម្បីលួងលោមពួកយើង » ។[៥]

# អំណោយទាននៃជីវិត និង សេចក្តីស្រឡាញ់

ដោយ ប្រាដ អលរ៉េត

*អំណោយរបស់ម្តាយខ្ញុំ បានបង្ហាញយើងពីអត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់ ។*

ឪពុកមារបស់ខ្ញុំ ឈ្មោះ អេត មានសេចក្តីស្រឡាញ់ច្រើនចំពោះមនុស្សទូទៅជានិច្ច ។ ជាអកុសល តម្រងនោមទាំងគូរបស់គាត់ខ្សោយ ។ អស់បីបួនឆ្នាំមកហើយដែល អេតបានពន្យារកុំឲ្យខ្សោយតម្រងនោមតាមរយៈការលាងឈាម ។ ការព្យាបាលនោះមានការឈឺចាប់ និង ច្រើនដង ។ ការព្យាបាលម្តងៗ ធ្វើឲ្យគាត់អស់កម្លាំងពីខ្លួនរហូតដល់ការព្យាបាលបន្ទាប់ទៀត ហើយនៅរដូវស្លឹកឈើជ្រុះឆ្នាំ ១៩៩៥ គាត់ហាក់បីដូចជាបាត់បង់ភាពក្លាហានដែលគាត់ធ្លាប់មានពីមុន ។

ទីបំផុត វេជ្ជបណ្ឌិតបានប្រាប់អេតថា បើសិនគាត់មិនដាក់តម្រងនោមថ្មីភ្លាមៗទេ នោះគាត់នឹងពុំអាចរស់នៅបានយូរតទៅមុខទៀតឡើយ ។ ទោះបីការមានតម្រងនោមតែមួយ មានភាពចំបាច់ដើម្បីឲ្យជីវិតខ្លួនរស់ នោះអេតពុំចង់សុំនរណាម្នាក់ឲ្យបរិច្ចាគតម្រងនោមមួយរបស់ពួកគេឡើយ ដោយសារខ្លាចមានគ្រោះថ្នាក់ជាមួយនឹងការវះកាត់នោះ ។ ប៉ុន្តែវាគ្មានជម្រើសឡើយ ។ មិត្តភក្តិជិតស្និទ្ធ និង សមាជិកគ្រួសារបីបួននាក់បានធ្វើតេស្តដើម្បីដឹងថា តើតម្រងនោមរបស់ពួកគេត្រូវគ្នានឹងតម្រងនោមគាត់ឬអត់ ។ មានតែតម្រងនោមរបស់មនុស្សម្នាក់ប៉ុណ្ណោះដែលត្រូវគ្នាបំផុតត្រូវបានរកឃើញ ៖ គឺបងស្រីរបស់អេត ឈ្មោះ ដូទី — ជាម្តាយរបស់ខ្ញុំ ។

នៅថ្ងៃទី ៧ ខែ ធ្នូ មិត្តភក្តិជាច្រើន និង គ្រួសាររបស់អេតបានរួមគ្នាតមអាហារ និង អធិស្ឋានសម្រាប់ឪពុកមាខ្ញុំ និង ដូទី ។ សល្យពេទ្យដែលធ្វើការវះកាត់នោះគឺជាបងប្អូនភ្លោះនឹងគ្នា ។ រិតតែគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះគឺថា មានម្នាក់ក្នុងចំណោមពួកគេបានបរិច្ចាគតម្រងនោមឲ្យគ្នា ។ អេត និង ម្តាយរបស់ខ្ញុំមានការភ្ញាក់ផ្អើលដែលបានដឹងថាពេលវះកាត់ម្តងៗ វេជ្ជបណ្ឌិតទាំងពីររូបនេះបានប្រឹងប្រែងអស់ពីសមត្ថភាពខ្លួន និងឱនក្បាលរបស់ពួកគេអធិស្ឋាន ហើយទុកលទ្ធផលនៃការវះកាត់នោះនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។

នៅថ្ងៃវះកាត់ វេជ្ជបណ្ឌិតម្នាក់បានវះយកតម្រងនោមមួយរបស់ម្តាយខ្ញុំ ។ នៅពេលគាត់ដេរបិទខ្នងរបស់ម្តាយខ្ញុំ នោះបងប្រុសរបស់គាត់បានវះកាត់ភ្ជាប់តម្រងនោមដែលបានបរិច្ចាគនោះនៅក្នុងពោះរបស់អេត ។

ការវះកាត់បានទទួលជោគជ័យ ប៉ុន្តែត្រូវរង់ចាំមើលសិនថា តើរាងកាយរបស់អេតនឹងទទួលយកតម្រងនោមថ្មីនោះឬអត់ ។ អង់ទីគ័រនៅក្នុងប្រព័ន្ធការពារខ្លួនរបស់គាត់ត្រូវបានបង្ក្រាប ដើម្បីឲ្យឆាប់ជាសះស្បើយ ដូច្នេះអេតត្រូវបានដាក់ឲ្យនៅដោយឡែកក្នុងបន្ទប់ថែទាំអ្នកជំងឺ ដើម្បីការពារគាត់ពីមេរោគ ( វីរុស ) ។ ទោះបីជាបន្ទាប់ពីគាត់បានចេញពីមន្ទីរពេទ្យក្តី ក៏គាត់ត្រូវតែបន្តរស់នៅដាច់ដោយឡែកពីមនុស្សគ្រប់គ្នា លើកលែងតែសាច់ញាតិផ្ទាល់របស់គាត់ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក្តី នៅយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ អេតបានទទួលការអនុញ្ញាតពិសេសឲ្យចូលរួមពិធីបុណ្យយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ប្រចាំឆ្នាំរបស់ជីតា និងជីដូនខ្ញុំ ។

អេតបានដើរចូលតាមទ្វារ ដោយមានពាក់របាំងមុខតម្រង់ឆ្ពោះទៅរក ដូទី ហើយបានឱបគាត់យ៉ាងណែន ។ នៅពេលពួកគេបានឱបគ្នា គ្រប់គ្នានៅក្នុងផ្ទះបានយំ ។ គ្រប់គ្នាបានយល់ពីសេចក្តីស្រឡាញ់ដែលចេញមកពីពួកគាត់ ។ បងស្រី ម្នាក់បានរងការឈឺចាប់ដើម្បីផ្តល់អំណោយនៃជីវិតដល់ប្អូនប្រុសរបស់ខ្លួន ។ វាគឺជាអំណោយនៃសេចក្តីស្រឡាញ់ អំណោយនៃការបូជា អំណោយដែលគាត់មិនអាចផ្តល់ឲ្យខ្លួនឯងបាន ។

នៅពេលខ្ញុំមើលពួកគាត់ ទាំងទឹកភ្នែកខ្ញុំហូរ



« ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ។

« ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជម្រះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ » ។

យ៉ូហាន ៣:១៦-១៧



ស្រក់ចុះមកនោះ ខ្ញុំបានដឹងអ្វីមួយ ៖ ការណ៍នេះគឺដូចទៅនឹងពេលដែលយើងនឹងជួបព្រះភក្ត្រព្រះអង្គសង្គ្រោះផ្ទាល់ ។ ទ្រង់ បានធ្វើអ្វីៗជាច្រើនសម្រាប់យើង ដែលយើងមិនអាចធ្វើដោយខ្លួនឯងបាន ។ មានតែទ្រង់ដែលជាអង្គដ៏ទេវភាពប៉ុណ្ណោះ ដែលអាចស៊ូទ្រាំនឹងការបូជាយ៉ាងអស្ចារ្យ ដែលក្រឹត្យវិន័យនៃភាពយុត្តិធម៌នឹងត្រូវបានបំពេញ ។ ហើយមានតែទ្រង់ប៉ុណ្ណោះដែលជាអង្គដ៏ល្អឥតខ្ចោះ ដែលសក្តិសមធ្វើឲ្យធួននឹងអំពើបាបរបស់មនុស្សលោកទាំងអស់ ដូច្នេះក្រឹត្យវិន័យនៃសេចក្តីមេត្តាករុណាអាចពង្រីកដល់មនុស្សទាំងអស់ដែលទទួលទ្រង់ ថាជាព្រះអង្គសង្គ្រោះរបស់ពួកគេ ។

នៅពេលខ្ញុំគិតយ៉ាងយកចិត្តទុកដាក់អំពីគំនិតទាំងនេះ ខ្ញុំបានតាំងចិត្តខ្លួនឯងជាថ្មីដើម្បីធ្វើអ្វីទាំងអស់ដែលខ្ញុំអាចធ្វើបាន ដើម្បីបង្ហាញអំណរគុណរបស់ខ្ញុំចំពោះព្រះអង្គសង្គ្រោះ និង ការបូជារបស់ទ្រង់ ។ ខ្ញុំនឹងព្យាយាមរស់នៅក្នុងនាមជាកូនសិស្សម្នាក់ ដូច្នេះនៅថ្ងៃណាមួយខ្ញុំអាចមានភាពសក្តិសមដើម្បីចូលទៅក្នុងវត្តមានរបស់ទ្រង់ឱបទ្រង់ ហើយអរព្រះគុណទ្រង់ដោយផ្ទាល់ចំពោះការស្រឡាញ់ដល់រូបខ្ញុំគ្រប់គ្រាន់នឹងធ្វើការបូជាបែបនោះ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*

**ការចែកចាយអំណោយ**

តើការបូជានៃសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ មានន័យចំពោះអ្នកយ៉ាងដូចម្តេចដែរ ?

តើនរណាខ្លះអាចទទួលបានប្រយោជន៍ ពីអំណោយនៃសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ?

តើអ្នកអាចចែកចាយដំណឹងល្អ ផ្តល់សារលិខិតនៃសេចក្តីសង្ឃឹម ឬ ចែកចាយសេចក្តីអំណរនៃរដូវកាលនេះជាមួយនរណាខ្លះ ?

រចនាលម្អរូបថតដោយ ចន លូក ; ថតរូបដោយ MARIDAV/ISTOCK/THINKSTOCK





**ដោយប្រធាន បយដ៏ ឃេ ផាកកឺ**
ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# សាក្សីម្នាក់អំពីព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ

*អស់រយៈពេល ៥៨ឆ្នាំក្នុងនាមជាអ្នកមានសិទ្ធិអំណាចទូទៅ និង រយៈពេល ៤៥ ឆ្នាំក្នុងនាមជាសាវក ម្នាក់ និងជាសាក្សីពិសេស « អំពីព្រះនាមនៃព្រះគ្រីស្ទនៅពេញសព្វក្នុងពិភពលោក » ( គ. និង ស. ១០៧:២៣ ), ប្រធាន ផាកកឺ បានថ្លែងទីបន្ទាល់យ៉ាងរាបទាប ។ មិនយូរប៉ុន្មានពីមុនមរណភាពរបស់លោកនៅថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៥ ប្រធានផាកកឺបានស្នើសុំថាសេចក្ដីដកស្រង់ខាងក្រោម មកពីការបម្រើរបស់លោកគួរតែត្រូវចែកចាយនៅក្នុងលីអាហូណា ។ នៅក្នុងវិញ្ញាណនៃរដូវកាលនៃបុណ្យគ្រីស្ទម៉ាស់នេះ ការដកស្រង់នេះសង្កត់ធ្ងន់លើទីបន្ទាល់របស់លោកអំពីព្រះអង្គសង្គ្រោះ និង សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ ។*

### ខ្ញុំស្រឡាញ់ព្រះអម្ចាស់

« ខ្ញុំចូលចិត្តបុណ្យគ្រីស្ទម៉ាស់ ។ មានអារម្មណ៍ពិសេសក្នុងរដូវកាលបុណ្យគ្រីស្ទម៉ាស់ ។ វាបានចុះមកលើពិភពលោកនេះ — ពុំមែនគ្រាន់តែសម្រាប់សមាជិកនៃសាសនាចក្រនេះឡើយ ប៉ុន្តែសម្រាប់មនុស្សទូទាំងពិភពលោក — គឺជាទីបន្ទាល់មួយ និង សាក្សីមួយថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ។ . . . ក្នុងនាមជាអ្នកបម្រើម្នាក់របស់ព្រះអម្ចាស់ ក្នុងនាមជាសាវកម្នាក់ក្នុងពួកដប់ពីរនាក់ ខ្ញុំដឹងថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ . . .

« ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ។ ខ្ញុំស្រឡាញ់កិច្ចការរបស់ទ្រង់ ។ ខ្ញុំស្រឡាញ់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយថ្លែងជាសាក្សីអំពីទ្រង់ដែលជាចៅហ្វាយ និង មិត្តភក្តិរបស់យើង » ។[1]

### ខ្ញុំជាសាក្សីម្នាក់របស់ទ្រង់

« មានរឿងមួយចំនួនដែលវាពិសិដ្ឋជាខ្លាំង រហូតដល់មិនអាចយកមកពិភាក្សាបាន ។ . . .

« វាមិនមែនមកពីវាជាការណ៍សម្ងាត់នោះទេ ប៉ុន្តែវាជារឿងដ៏ពិសិដ្ឋ ដែលមិនត្រូវជជែកវែកញែកឡើយ ប៉ុន្តែវាតម្រូវឲ្យជឿ ហើយត្រូវតែការពារ និង កោតសរសើរដោយគារវភាពដ៏ជ្រាលជ្រៅបំផុត ។

« ខ្ញុំបានយល់អ្វីដែលព្យាការីអាលម៉ាបាននិយាយ ៖

« ‹ មានមនុស្សជាច្រើនដែលបានប្រទានឲ្យដឹងនូវសេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ ទោះជាយ៉ាងណាក៏ដោយ គង់តែគេបានទទួលបញ្ញាយ៉ាងតឹងរឹងថា គេពុំត្រូវប្រាប់នរណាឲ្យសោះ លើកលែងតែមួយភាគនៃព្រះបន្ទូលរបស់ព្រះអង្គ ដែលព្រះអង្គបានប្រទានដល់កូនចៅមនុស្សស្របតាមការយកចិត្តទុកដាក់ និង ការព្យាយាមរបស់គេចំពោះព្រះអង្គប៉ុណ្ណោះ ។

« ‹ ហេតុដូច្នេះហើយ នរណាដែលធ្វើចិត្តរឹងរូស អ្នកនោះហើយដែលនឹងទទួលព្រះបន្ទូលរបស់ព្រះអង្គមួយភាគតិចប៉ុណ្ណោះ ឯនរណាដែលពុំធ្វើចិត្តរឹងរូសទេ អ្នកនោះហើយដែលនឹងបានទទួលព្រះបន្ទូលរបស់ព្រះអង្គមួយភាគច្រើនជាង រហូត



« ទ្រង់បានជ្រើសទទួលយកទារុណកម្ម ជំនួស មនុស្សលោកទាំងអស់ ចំពោះអំពើទុច្ចរិតទាំងអស់ និង ចំពោះអំពើពុករលួយ អំពើឃោរឃៅ ភាពអសីលធម៌ អំពើខូចអាក្រក់ និង អំពើស្មោកគ្រោក ចំពោះការញៀន ចំពោះការកាប់សម្លាប់ និង ទារុណកម្ម ព្រមទាំងភាព ចលាចល — ចំពោះអ្វីៗទាំងអស់ដែលធ្លាប់កើតឡើង ឬ អ្វីៗទាំងអស់ដែលកើតមានឡើងនៅលើផែនដីនេះ ។ ក្នុងការជ្រើសរើសនោះ ទ្រង់បានស៊ូទ្រាំនឹងអំណាចដ៏ខ្លាំងក្លារបស់អារក្សដែលវាមិនមាននៅក្នុងដែនកំណត់នៃសាច់ឈាម ហើយក៏មិនចុះចូលនឹងការឈឺចាប់នៃជីវិតរមែងស្លាប់ដែរ ។ អ្វីដែលខ្ញុំរៀបរាប់នេះគឺកើតនៅសួនគែតសេម៉ានី !

« ដង្វាយធួនបានសម្រេចទៅបានយ៉ាងអស្ចារ្យ ដោយយើងមិនបានដឹងឡើយ ។ គ្មានជីវិតរមែងស្លាប់ណាដែលត្រូវបានមើលថាអាក្រក់បានបែរចេញ ឬ លាក់បាំងដោយអាម៉ាស់នៅចំពោះពន្លឺដែលជាគូអង្គដ៏បរិសុទ្ធនោះឡើយ ។ មនុស្សទុច្ចរិតទាំងអស់ពុំស្រេកឃ្លានពន្លឺនោះឡើយ ។ នៅពេលអ្វីដែលត្រូវធ្វើ បានធ្វើរួចហើយនោះ តម្លៃលោះត្រូវបានបង់ ។ ទាំងសេចក្ដីស្លាប់ និង ស្ថាននរកបានបោះបង់ការទាមទារយកអស់អ្នកដែលបានប្រែចិត្ត ។ នៅទីបំផុតមនុស្សមានសេរីភាព ។ បន្ទាប់មកទៀត គ្រប់ព្រលឹងដែលធ្លាប់បានរស់នៅអាចជ្រើសរើសធ្វើតាមពន្លឺនោះ ហើយត្រូវបានសង្គ្រោះ ។

« តាមរយៈការបូជាដ៏និរន្តរនេះ ‹ តាមរយៈដង្វាយធួន នៃព្រះគ្រីស្ទ [ នេះ ] នោះ មនុស្សលោកទាំងអស់អាចបានសង្គ្រោះ ដោយសារការគោរពតាមក្រឹត្យវិន័យ និង ពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ › ( មាត្រានៃសេចក្ដីជំនឿ ១:៣ ) » ។[៣]

ដល់អ្នកនោះអាចដឹងនូវសេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះរហូតដល់អ្នកនោះដឹងគ្រប់សេចក្ដី › ( អាលម៉ា ១២:៩–១០ ) ។ . . .

« ឥឡូវនេះខ្ញុំឆ្លល់ដូចជាអ្នកដែរថា ហេតុអ្វីបានជាមនុស្សដូចជារូបខ្ញុំគួរតែត្រូវបានហៅទៅកាន់តំណែងនៃភាពជាសាវកដ៏បរិសុទ្ធនេះ ។ មានលក្ខណៈសម្បត្តិជាច្រើនដែលខ្ញុំគ្មាន ។ មានកិច្ចខិតខំយ៉ាងច្រើនក្នុងការបម្រើដែលខ្ញុំកំពុងតែចង់ធ្វើ ។ នៅពេលខ្ញុំបានគិតអំពីរឿងនេះ ខ្ញុំមានចំណុចតែមួយគត់ គឺគុណសម្បត្តិមួយដែលអាចជាហេតុផល ដែលនោះគឺជាអ្វីដែលខ្ញុំមាននូវសាក្សី *នោះ* ។

« ខ្ញុំសូមប្រកាសដល់អ្នកថា ខ្ញុំដឹងថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ។ ខ្ញុំដឹងថាទ្រង់មានព្រះជន្មរស់ ។ ទ្រង់បានប្រសូតមកនៅក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ។ ទ្រង់បានបង្រៀនដំណឹងល្អរបស់ទ្រង់ បានទទួលការសាកល្បង និងត្រូវបានគេឆ្កាង ។ ទ្រង់បានមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។ ទ្រង់គឺជាផលដំបូងនៃការរស់ឡើងវិញ ។ ទ្រង់មានរូបកាយជាសាច់ និង ឆ្អឹង ។ ខ្ញុំសូមថ្លែងទីបន្ទាល់នេះ ។ ខ្ញុំជាសាក្សីម្នាក់អំពីទ្រង់ » ។[២]

## ទ្រង់បានទទួលយកទារុណកម្ម

« ពីមុន និងក្រោយការឆ្កាង មនុស្សជាច្រើនបានលះបង់ជីវិតខ្លួន ប្រកបដោយសុឆន្ទៈមិនគិតពីការធ្វើជាវីរជនអ្វីឡើយ ។ ប៉ុន្តែគ្មាននរណាម្នាក់បានជួបដូចអ្វីដែលព្រះគ្រីស្ទបានស៊ូទ្រាំឡើយ ។ បន្ទុកនៃអំពើរំលងរបស់មនុស្សទាំងអស់ ទោសរបស់មនុស្សទាំងអស់ត្រូវធ្លាក់លើទ្រង់ ។ ហើយត្រូវបានព្យួរឡើងដែលជាដង្វាយធួនដ៏អស្ចារ្យ ។ តាមរយៈព្រះឆន្ទៈរបស់ព្រះអង្គ សេចក្ដី មេត្តា ករុណា និង សេចក្ដីយុត្តិធម៌អាចត្រូវបានដោះស្រាយ ក្រឹត្យវិន័យដ៏អស់កល្បត្រូវបានបំពេញ ហើយការសម្រប សម្រួលបានសម្រេចថាគ្មានមនុស្សណាម្នាក់នឹងមិនអាចត្រូវបានប្រោសលោះឡើយ ។

## គ្រូបង្រៀនដ៏ឆ្នើម

« នៅក្នុងដំណើរការនៃកិច្ចខិតខំរបស់ខ្ញុំ ដើម្បីបង្រៀនដំណឹងល្អរបស់ទ្រង់ ខ្ញុំបានស្គាល់ទ្រង់ថាជា ព្រះយេស៊ូវគ្រីស្ទ ព្រះរាជបុត្រានៃព្រះ ជាបុត្របង្កើតតែមួយរបស់ព្រះវរបិតា ។ ខ្ញុំមានគារវភាពចំពោះទ្រង់ ដោយមានការកោត សរសើរយ៉ាងជ្រាលជ្រៅចំពោះអ្វីដែលទ្រង់បានបង្រៀន និង របៀបដែលទ្រង់បង្រៀន ។ វាមិនមែនមិនល្អទេ ចំពោះយើងម្នាក់ៗដែលព្យាយាមបង្រៀនដូចដែលទ្រង់បានបង្រៀន ។ វាមិនមែនមិនល្អទេ ចំពោះយើងម្នាក់ៗដែលប្រាថ្នាឲ្យបានដូចជាទ្រង់ ។ ទ្រង់មិនមែនគ្រាន់តែជាគ្រូបង្រៀនទេ ទ្រង់គឺជាគ្រូបង្រៀនដ៏ឆ្នើម » ។[៤]

## ការដឹងពីសេចក្ដីពិតដ៏មានតម្លៃបំផុត

« ព្រោះយើងជាមនុស្សរមែងស្លាប់ យើងអាចមិនយល់ទាំងស្រុងពី *របៀប* ដែលព្រះអង្គសង្គ្រោះទ្រង់បានបំពេញពលិកម្មដ៏ធួនរបស់ទ្រង់នោះទេ ។ ប៉ុន្តែសម្រាប់ពេលឥឡូវនេះ *របៀប* ដែលទ្រង់រងទុក្ខគឺមិនសំខាន់ដូចជា *មូលហេតុ* ដែលទ្រង់

ព័ត៌មានលម្អិតមកពី ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ ដោយ ហារី អែនឌើសុន

រងទុក្ខនោះទេ ។ តើហេតុអ្វីទ្រង់ធ្វើការណ៍នោះសម្រាប់អ្នកសម្រាប់ខ្ញុំ សម្រាប់មនុស្សគ្រប់រូប ? ទ្រង់បានធ្វើបែបនេះ ដោយព្រោះក្ដីស្រឡាញ់ចំពោះព្រះជាព្រះវរបិតា និងចំពោះមនុស្សគ្រប់គ្នា ។ ‹ គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិតជំនួសពួកសំឡាញ់របស់ខ្លួននោះទេ › ( យ៉ូហាន ១៥:១៣ ) ។

« ក្នុងសួនគែតសេម៉ានី ព្រះគ្រីស្ទបានចេញពីពួកសាវករបស់ទ្រង់ទៅអធិស្ឋាន ។ អ្វីដែលបានកើតឡើងគឺហួសពីអំណាចរបស់យើងដើម្បីយល់ដឹង ! តែយើងពិតជាដឹងថា ទ្រង់បានសម្រេចនូវដង្វាយធួន ។ ទ្រង់ព្រមលើកដាក់មកលើអង្គទ្រង់នូវអស់ទាំងកំហុស និងអំពើបាប មន្ទិលសង្ស័យ និងការភ័យខ្លាចនៃពិភពលោកទាំងមូល ។ ទ្រង់បានរងទុក្ខជំនួសយើង ដើម្បីយើងមិនបាច់ត្រូវរងទុក្ខ ។ មនុស្សរមែងស្លាប់ជាច្រើនបានរងទារុណកម្ម ហើយស្លាប់ ដែលជាការស្លាប់ដ៏ឈឺចាប់ និងគួរឲ្យខ្លាចក្រៃលែង ។ តែការឈឺចាប់របស់ទ្រង់លើសពីការឈឺចាប់ទាំងអស់នោះទៅទៀត ។ . . .

« ការរងទុក្ខរបស់ទ្រង់ គឺខុសពីការរងទុក្ខផ្សេងទៀតទាំងអស់ពីមុនមក ឬតាំងពីនោះមក ដោយព្រោះទ្រង់បានលើកដាក់មកលើអង្គទ្រង់ នូវទោសទាំងអស់ដែល [ ធ្លាប់ ] មានលើគ្រួសារមនុស្សជាតិ ។ សូមស្រមៃពីការណ៍នោះ ! ទ្រង់គ្មានជំពាក់បំណុលដើម្បីនឹងសងសោះឡើយ ។ ទ្រង់ពុំបានធ្វើខុសសោះឡើយ ។ ទោះយ៉ាងណា បន្ទុំនៃអស់ទាំងកំហុស ទុក្ខព្រួយ ការឈឺចាប់ និងសេចក្ដីប្រមាថទារុណកម្មទាំងខាងផ្លូវចិត្ត អារម្មណ៍ និង ផ្លូវកាយទាំងអស់ដែលមនុស្សលោកស្គាល់ — គឺទ្រង់បានភ្លក់នូវបទពិសោធន៍ទាំងអស់ ។ មានតែមួយអង្គគត់នៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រមនុស្សទាំងអស់ ដែលគ្មានទោសសោះដែលមានអំណាចនឹងធ្វើឲ្យធួនដល់បាប និងការរំលងរបស់មនុស្សទាំងអស់ ហើយអាចស៊ូនឹងការឈឺចាប់ ដែលបានបង្គ្រប់បន្ថែមដោយការបង់ថ្លៃជំនួសពួកគេ ។

*មានតែមួយអង្គគត់នៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រមនុស្សទាំងអស់ ដែលគ្មានទោសសោះដែលមានអំណាចនឹងធ្វើឲ្យធួនដល់បាប និងការរំលងរបស់មនុស្សទាំងអស់ ហើយអាចស៊ូនឹងការឈឺចាប់ ដែលបានបង្គ្រប់បន្ថែមដោយការបង់ថ្លៃជំនួសពួកគេ ។*

« ទ្រង់ព្រមលះបង់ជីវិតទ្រង់ ហើយមានបន្ទូលដ៏មានខ្លឹមសារថា « គឺយើងនេះហើយ ដែលទទួលយកអំពើបាបទាំងឡាយ នៃមនុស្សលោកមកលើខ្លួន » ( ម៉ូសាយ ២៦:២៣ ) ។ ទ្រង់ត្រូវបានគេឆ្កាង ទ្រង់បានសុគត ។ ពួកគេមិនអាចដកយកជីវិតពីទ្រង់បានឡើយ ។ គឺទ្រង់ទេតើដែលព្រមសុគតនោះ ។ . . .

« បើសិនអ្នកបានដួលចុះ ឬសូម្បីតែវង្វេងមួយរយៈ បើសិនអ្នកមានអារម្មណ៍ថាឥឡូវនេះបច្ចាមិត្តសង្កត់អ្នកជាប់នោះ អ្នកអាចឈានទៅមុខដោយជំនឿ និងដោយមិនវង្វេងទៅមកក្នុងលោកិយនេះទៀតឡើយ ។ មានពួកអ្នកដែលត្រៀមរួចជាស្រេចដើម្បីដឹកនាំអ្នកឲ្យត្រឡប់ទៅភាពសុខសាន្ត និងសុវត្ថិភាពវិញ ។ ដូចដែលបានសន្យាក្នុងព្រះគម្ពីរថា សូម្បីព្រះគុណនៃព្រះបានមក ‹ បន្ទាប់ពីអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន › ( នីហ្វៃទី ២ ២៥:២៣ ) ។ ចំពោះខ្ញុំ លទ្ធភាពក្នុងការសម្រេចបាននូវការណ៍នេះ គឺជាការដឹងពីសេចក្ដីពិតដ៏មានតម្លៃបំផុត ។

« ខ្ញុំសូមសន្យាថា ព្រឹកព្រលឹមដ៏ស្រស់បំព្រងនៃការអភ័យទោស អាចកើតមាន ។ ពេលនោះ‹ សេចក្ដីសុខសាន្តរបស់ព្រះដែលហួសលើសពីអស់ទាំងគំនិត › ( ភីលីព ៤:៧ ) ចូលមកក្នុងជីវិតអ្នកម្ដងទៀត ជាអ្វីមួយដែលដូចជាព្រះអាទិត្យរះ ហើយអ្នកដូចជាទ្រង់ដែរ ‹ នឹងលែងនឹកចាំពីអំពើបាបរបស់អ្នកទៀតជាដរាបទៅ › ( យេរេមា ៣១:៣៤ ) ។ តើអ្នកនឹងដឹងដោយរបៀបណា ? អ្នកនឹងដឹង ! ( សូមមើល ម៉ូសាយ ៤:១–៣ ) » ។[៥]

**ទីបន្ទាល់របស់ខ្ញុំ**

« បន្ទាប់ពីរាប់ឆ្នាំកន្លងទៅដែលខ្ញុំបានរស់នៅ និងបានបង្រៀន និងបានបម្រើ បន្ទាប់ពីរាប់រយគីឡូម៉ែត្រដែលខ្ញុំបានធ្វើដំណើរជុំវិញពិភពលោក ដោយបានពិសោធន៍នូវអ្វីៗទាំងអស់នោះវាមានសេចក្ដីពិតមួយដ៏អស្ចារ្យដែលខ្ញុំចង់ចែកចាយ ។ នោះគឺជាទីបន្ទាល់របស់ខ្ញុំអំពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។

« យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានកត់ត្រាដូចខាងក្រោម បន្ទាប់ពីមានបទពិសោធន៍ដ៏ពិសិដ្ឋមួយ ៖

« ‹ ហើយ ឥឡូវនេះបន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់នេះគឺជាទីបន្ទាល់ចុងក្រោយបង្អស់ដែលយើងខ្ញុំសូមថ្លែងអំពីទ្រង់ ៖ ថាទ្រង់មានព្រះជន្មរស់នៅ !

« ‹ ដ្បិតយើងបានឃើញទ្រង់ › ( គ. និង ស. ៧៦:២២–២៣ ) ។

« ប្រសាសន៍របស់ពួកលោកគឺជាពាក្យពេចន៍របស់ខ្ញុំ » ។[៦]

« នេះពិតជាឯកសិទ្ធិដ៏អស្ចារ្យ ដែលខ្ញុំមានពេញមួយជីវិតខ្ញុំ ដើម្បីថ្លែងទីបន្ទាល់ជាពិសេស ថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ព្រះរាជាបុត្រារបស់ព្រះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ដោយរាបសារបំផុត តែដោយភាពជឿជាក់ទាំងស្រុងថា ទ្រង់គឺជាព្រះរាជបុត្រាបង្កើតតែមួយរបស់ព្រះវរបិតា ។ នេះគឺជាសាសនាចក្ររបស់ទ្រង់ ទ្រង់ជាអធិបតីលើសាសនាចក្រនេះ ហើយដឹកនាំកិច្ចការនេះ ។ ទ្រង់គឺជាព្រះប្រោសលោះរបស់យើង ។ ខ្ញុំដឹងថាទ្រង់មានព្រះជន្មរស់នៅ ហើយខ្ញុំស្គាល់ទ្រង់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់អំពីការណ៍នេះនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន » ។[៧] ■

កំណត់ចំណាំ

១. « Our Witness of the Lord » General Authority training ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៧៤ ។
២. « The Spirit Beareth Record » *Ensign,* ខែ មិថុនា ឆ្នាំ ១៩៧១ ទំព័រ ៨៧ ៨៨ ។
៣. « តើព្រះយេស៊ូវគ្រីស្ទជានរណា ? » *Liahona,* ខែ មិនា ឆ្នាំ ២០០៨ ទំព័រ ១៥ ។
៤. *Mine Errand from the Lord: Selections from the Sermons and Writings of Boyd K. Packer* ( ឆ្នាំ ២០០៨ ) ទំព័រ ៣៣៧ ។
៥. « The Savior's Selfless and Sacred Sacrifice » *Liahona,* ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៣៧–៣៨; សូមមើលផងដែរ « Truths Most Worth Knowing » Church Educational System Devotional, ថ្ងៃទី ៦ខែ វិច្ឆិកា ឆ្នាំ ២០១១ ។
៦. « សាក្សី » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៩៧ ។
៧. ប្រធានផាកកឺបានសរសេរទីបន្ទាល់ចុងក្រោយនេះពីមុនមរណភាពរបស់លោក ។

# យ៉ូសែប ស្ម៊ីធ
## និង គម្ពីរវិវរណៈ

*ព្យាការី យ៉ូសែប ស្ម៊ីធ បាន ជួយដកយកអាថ៌កំបាំងមួយចំនួនទាក់ទងនឹងគម្ពីរវិវរណៈ ហើយបង្ហាញពីទំនាក់ទំនងរបស់វានៅក្នុងសម័យយើងនេះ ។*





**ដោយ ដេវីឌ អេ អេដវូដ**
ទស្សនាវដ្ដីសាសនាចក្រ

គម្ពីរវិវរណៈត្រូវបានសរសេរនៅសតវត្សទីមួយនៃ គ. ស., ប៉ុន្តែវាគឺជាគម្ពីរចុងក្រោយនៃព្រះគម្ពីរសញ្ញាថ្មីដែលត្រូវបានទទួលស្គាល់ថាជាកាណុង ( ព្រះគម្ពីរជាផ្លូវការ ) ។ អ្នកប្រាជ្ញគ្រីស្ទានមួយចំនួននៅសតវត្សក្រោយៗមកទៀត បានចោទជាចម្ងល់អំពីការនិពន្ធនៃគម្ពីរនេះ និងបានបដិសេធនឹងគោលលទ្ធិមួយចំនួនរបស់វា ( ឧទាហរណ៍ ការបង្រៀនរបស់គម្ពីរនេះអំពីសហស្សវត្សរ៍ ឬ ការបង្រៀនរបស់វាដែលថាមនុស្សនឹងត្រូវបានជំនុំជំរះតាមកិច្ចការរបស់ខ្លួន ) ហើយពួកគេបានឃើញថាឯកសារយោង និង ដំណើររឿងនៃការនិមិត្តទាក់ទងនឹងព្រះគម្ពីរសញ្ញាចាស់ ដូចជាចម្លែក និង ខុសគ្នាយ៉ាងខ្លាំងពីការសរសេរនានានៅក្នុងព្រះគម្ពីរសញ្ញាថ្មីផ្សេងទៀត ។

ប៉ុន្តែ ភាពពិតដែលមិនអាចបដិសេធបាននេះ បាននាំឲ្យមនុស្សទូទៅទទួលស្គាល់ព្រះគម្ពីរនេះ ។ ឧទាហរណ៍ មានពួកអ្នកនិពន្ធគ្រីស្ទានពីជំនាន់ដើមជាច្រើន បាននិយាយពីគម្ពីរវិវរណៈដែលបានចាត់តាំងឲ្យយ៉ូហានជាអ្នកសរសេរវា ព្រមទាំងដកស្រង់វាយ៉ាងច្រើន និង ដោយពេញចិត្តក្នុងការសរសេររបស់ខ្លួន ។ សៀវភៅមួយចំនួនផ្សេងទៀតដែលត្រូវបានទទួលស្គាល់ថាជាគម្ពីរ ពុំអាចបង្ហាញភស្តុតាងបែបនេះឡើយ ។

នៅដើមសតវត្សទី ១៩ នៅពេលដែលព្រះបានហៅយ៉ូសែប ស្ម៊ីធធ្វើជាព្យាការីនៃការស្ដារឡើងវិញ នោះគម្ពីរវិវរណៈត្រូវបានរួមបញ្ចូលស្ទើរតែ

រចនាឈុតរូបថតដោយ គ្រីស្ទីណា ស្មីធ *យ៉ូហាននៅលើកោះប៉ាត់ម៉ុស* ដោយម៉ាក់ ស្ទីរ៉ែរ © PROVIDENCE COLLECTION





ដោយសារយ៉ូសែប ស្ម៊ីធ នោះ យើងដឹងថានីហ្វៃបានដឹងថា យ៉ូហានជាអ្នកបើកសម្តែងត្រូវបានចាត់ ហើយបានតែងតាំងពីមុនផែនដី ដើម្បីសរសេរការនិមិត្តនានាអំពីថ្ងៃចុងក្រោយដែលឥឡូវនេះមាននៅក្នុងគម្ពីរវិវរណៈ ( សូមមើល នីហ្វៃទី ១ ១៤:១៩–២៩ ) ។

ទាំងអស់នៅក្នុងគ្រប់កំណែនៃព្រះគម្ពីរប៊ីប និង ត្រូវបានអានយ៉ាងទូលំទូលាយ ។ ការស្រមៃអំពីការនិមត្តរបស់យ៉ូហានជះឥទ្ធិពលដល់ការគិតរបស់មនុស្ស និង ផ្តល់លទ្ធផលជាច្រើនដល់អ្នកបកប្រែផ្សេងៗ ដូចដែលវាបន្តមកដល់ជំនាន់របស់យើងនេះផងដែរ ។

ក្នុងនាមជាព្យាការីនៅសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នេះ យ៉ូសែប ស្ម៊ីធ មានមុខងារមួយដ៏ពិសេសដើម្បីបើកបង្ហាញពន្លឺនៃគម្ពីរវិវរណៈនេះ ហើយជួយបន្ថយការភ័យខ្លាចក្នុងការអាន និង ស្វែងយល់ពីវា ។ យ៉ាងហោចណាស់ លោកបានធ្វើការណ៍នេះតាមរយៈរបៀបពីរយ៉ាង ៖ ( ១ ) លោកបានពន្យល់ផ្នែកពិសេសៗនៃគម្ពីរវិវរណៈ ហើយបានបើកបង្ហាញបរិបទរបស់វាទាំងអស់ និង ( ២ ) លោកបានពន្យល់បំភ្លឺវាកាន់តែច្បាស់ ។

**ពន្យល់ និង ពង្រីកការយល់ដឹង**

គំរូដ៏ល្អបំផុតនៃការពន្យល់របស់យ៉ូសែប ស្ម៊ីធអំពីគម្ពីរវិវរណៈគឺនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧ ។ ដោយបានទទួលនៅក្នុងខែ មិនា ឆ្នាំ ១៨៣២ វិវរណៈនេះរួមមានសំណួរ និងចម្លើយអំពីខគម្ពីរជាក់លាក់នៅក្នុងគម្ពីរវិវរណៈជំពូក ៤–១១ ។ ព្យាការីបានមានប្រសាសន៍ថា ការពន្យល់នេះត្រូវបានបើកសម្តែងដល់លោកអំឡុងពេលដែលលោកបានបកប្រែព្រះគម្ពីរប៊ីបប្រកបដោយការបំផុសគំនិត ( សូមមើល គ. និង ស. ៧៧ សេចក្តីណែនាំកណ្ឌ ) ។

សំណួរត្រង់ៗទាំងនោះបានចោទសួរឡើងជាពិសេសថា « តើការណ៍នេះ មានន័យដូចម្តេច ? » និង « តើនៅពេលណាការណ៍នេះនឹងកើតឡើង ? » ចម្លើយទាំងនោះបានទទួលភ្លាម ទោះបីជាវាមិនពេញលេញទាំងស្រុងជានិច្ចក៏ដោយ ។ ចម្លើយនានាដែលព្យាការីយ៉ូសែប ស្ម៊ីធ បានស្វែងរក និង បានទទួលបាននាំមកនូវភាពប្រាកដប្រជាដល់ការបកប្រែទាំងឡាយ ដែលបានធ្វើដោយការប៉ានស្មាននោះ ហើយជាទូទៅជួយយើងឲ្យយល់ពីរបៀបដែលការនិមិត្តរបស់យ៉ូហានទាក់ទងនឹងកិច្ចការថ្ងៃចុងក្រោយ ។

ឧទាហរណ៍ វិវរណៈនេះជួយយើងឲ្យឃើញថា ត្រាទាំងប្រាំពីរនៅក្នុងគម្ពីរនេះដែលបានពិពណ៌នាដោយយ៉ូហានចាប់ផ្តើមពីជំពូក ៥ នៃវិវរណៈ តំណាងឲ្យរយៈពេលសំខាន់ៗទាំងប្រាំពីរនៅក្នុងប្រវត្តិសាស្ត្រនៃផែនដីនេះ ហើយថាត្រាពីរចុងក្រោយគឺជាត្រាដែលជាប់ពាក់ព័ន្ធនឹងសម័យរបស់យើងនេះ និង សម័យក្រោយៗទៀត ( សូមមើល គ. និង ស. ៧៧:៦–៧ ) ដែលជួយយើងឲ្យយល់ពីមូលហេតុ ដែលការនិមិត្តរបស់យ៉ូហានប្រើរយៈពេលយ៉ាងច្រើនជាមួយនឹងត្រាទីប្រាំមួយ និង ទីប្រាំពីរ ។ បន្ទាប់មកវិវរណៈរបស់យ៉ូសែប ស្ម៊ីធ បន្តពន្យល់ពីរបៀបដែលរូបមួយចំនួននៅក្នុងត្រាទីប្រាំមួយ ( ទេវតាបួនអង្គ អ្នកបម្រើបិទត្រា១៤៤,000ចេញពីគ្រប់ពូជអំបូរអ៊ីស្រាអែល ) ទាក់ទងនឹងកិច្ចការនៃការស្តារឡើងវិញ និង ការប្រមូលផ្តុំនៅថ្ងៃចុងក្រោយ ( សូមមើល គ. និង ស. ៧៧:៩–១១ ) ។

ពិតណាស់ ការពន្យល់អំពីវិវរណៈនេះ មិនគ្រាន់តែជាការរួមចំណែករបស់ព្យាការី យ៉ូសែប ស្ម៊ីធ ដើម្បីឲ្យយើងយល់ពីគម្ពីរវិវរណៈចេញពី ការបកប្រែព្រះគម្ពីរប៊ីបរបស់លោកប៉ុណ្ណោះទេ ។ ខណៈដែលលោកបានបកប្រែ នោះមានពេលខ្លះ លោកត្រូវបានបំផុសគំនិតឲ្យបញ្ជាក់អត្ថបទនោះកាន់តែច្បាស់,[១] ប៉ុន្តែជាញឹកញាប់ លោកក៏ត្រូវបានបំផុសគំនិតឲ្យបន្ថែម ឬ បន្ថយអត្ថបទដើម្បីធ្វើឲ្យវាភ្ជាប់ទៅនឹងខគម្ពីរផ្សេងទៀត ដើម្បីឲ្យវាបញ្ជាក់ន័យដល់គ្នាទៅវិញទៅមក ។[២] ក្រោយមក ផ្នែកមួយនៃការបកប្រែព្រះគម្ពីរប៊ីបរបស់យ៉ូសែប ស្ម៊ីធនោះ បង្ហាញពីការបង្កើតទំនាក់ទំនងរួមរវាងខគម្ពីរផ្សេង ដើម្បីបង្ហាញពីដំណើររួមគ្នានៃការបង្រៀន និង ការព្យាករណ៍នានា ព្រមទាំងគោលការណ៍នេះក៏អនុវត្តចំពោះគម្ពីរវិវរណៈនេះដែរ ។

ក្រៅពីនេះ តាមរយៈវិវរណៈ និង ការបកប្រែផ្សេងទៀត យ៉ូសែប ស្ម៊ីធ បានពង្រីកបរិបទនៃគម្ពីរវិវរណៈ ដោយបង្ហាញថាវាធ្វើតាមគំរូនៃការនិមិត្តជាច្រើនដែលបានប្រទានឲ្យព្យាការីនានាទូទាំងសម័យកាល ។ នៅក្នុងព្រះគម្ពីរមរមន និង មុក្តាដ៏មានតម្លៃមហិមា យើងរៀនថានីហ្វៃ បងប្រុសយ៉ារេឌ ម៉ូសេ និង អេណុក ទាំងអស់គ្នានេះ មានការនិមិត្តស្រដៀងគ្នាដែលបង្ហាញពីដំណើរទូទៅនៃប្រវត្តិសាស្ត្រមនុស្ស រួមទាំងចុងបញ្ចប់នៃពិភពលោកផងដែរ ។ យើងក៏បានរៀនផងដែរថា ទោះបីជាព្យាការីផ្សេងទៀតបានឃើញពីចុងបំផុតនៃពិភពលោកក្តី ក៏ពួកលោកត្រូវបានហាមប្រាមមិនឲ្យចែកចាយវាជាមួយពិភពលោកឡើយ ដោយសារយ៉ូហានត្រូវបានតែងតាំងពីមុនផែនដីដើម្បីសរសេរវា ( សូមមើល នីហ្វៃទី ១ ១៤:២៥–២៦ ) ។ ដូច្នេះ ព្រះគម្ពីរមរមន ត្រូវបាននាំចេញមកតាមរយៈព្យាការី



**ការដកស្រង់មួយដែលយ៉ូសែប ស្ម៊ីធចូលចិត្តពីគម្ពីរវិវរណៈ**

« ការធ្វើបន្ទាល់ពីព្រះយេស៊ូវ នោះហើយជាវិញ្ញាណនៃសេចក្តីទំនាយ » ( វិវរណៈ ១៩:១០ ) ។

សេចក្តីថ្លែងការណ៍អំពីទេវតាចំពោះយ៉ូហានត្រូវបាននិយាយច្រំដែលៗដោយព្យាការី យ៉ូសែប ស្ម៊ីធ ។ វាគឺជាគន្លឹះមួយដើម្បីយល់ពីលក្ខណៈនៃទីបន្ទាល់ ព្រមទាំងសេចក្តីត្រូវការសម្រាប់ការព្យាករណ៍ និង វិវរណៈនៅក្នុងសាសនាចក្រ ព្រមទាំងក្នុងជីវិតរស់នៅផ្ទាល់ខ្លួនយើងផងដែរ ។ ឧទាហរណ៍ យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ ៖

« សេចក្តីសង្គ្រោះពុំអាចកើតបានដោយគ្មានវិវរណៈឡើយ វាគ្មានប្រយោជន៍សម្រាប់មនុស្សម្នាក់ដែលបម្រើដោយគ្មានវិវរណៈទេ ។ គ្មានព្យាការីណាម្នាក់ដែលមិនមែនជាអ្នកបម្រើរបស់ព្រះយេស៊ូវគ្រីស្ទឡើយ ។ គ្មាននរណាអាចក្លាយជាអ្នកបម្រើរបស់ព្រះយេស៊ូវគ្រីស្ទឡើយ លុះត្រាគាត់មានទីបន្ទាល់ពីព្រះយេស៊ូវ ហើយនេះគឺជាវិញ្ញាណនៃសេចក្តីទំនាយ » ( *ប្រវត្តិសាសនាចក្រ* ៣:៣៨៩ ) ។

យ៉ូសែប ស្ម៊ីធ បង្រៀនយើងថា យើងត្រូវបានប្រាប់ពីការពិពណ៌នារបស់យ៉ូហានអំពីព្រឹត្តិការណ៍នានាដែលនាំទៅរកការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ហើយថាវាសក្តិសមនឹងការសិក្សារបស់យើង ។

ដោយសារការបើកសម្តែងពន្លឺបន្ថែមតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ នោះយើងមើលឃើញប្រធានបទសាមញ្ញៗនៃវិវរណៈ ៖ ថា« នៅទីបំផុត នឹងមានជោគជ័យរបស់ព្រះអម្ចាស់នៅលើផែនដីនេះ យកឈ្នះលើអារក្ស ជាជ័យជំនះដ៏និរន្តរមួយនៃសេចក្តីល្អលើសេចក្តីអាក្រក់ នៃពួកបរិសុទ្ធលើពួកបៀតបៀនពួកគេ នៃនគរព្រះលើនគរមនុស្ស និងសាតាំង ។ . . . ជ័យជំនះ [ នឹង ] ត្រូវបានសម្រេចតាមរយៈព្រះយេស៊ូវគ្រីស្ទ » ។[៣] លើសពីនេះទៅទៀត យ៉ូសែប ស្ម៊ីធ បានគូសបញ្ជាក់ថា សារលិខិតនៃគម្ពីរវិវរណៈផ្តោតលើព្រះយេស៊ូវគ្រីស្ទដូចជាការផ្តោតលើសេចក្តីសង្ឃឹមរបស់យើង ហើយបង្រៀនយើងថា តាមរយៈការស្មោះត្រង់របស់យើងចំពោះទ្រង់ និងកិច្ចការរបស់ទ្រង់នៅថ្ងៃចុងក្រោយ នោះយើងអាចយកឈ្នះពិភពលោកបាន ។

### ពន្យល់បំភ្លឺកាន់តែច្បាស់

នៅក្នុងសន្និសីទសាសនាចក្រនៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ មានប្រសាសន៍ថា « គម្ពីរវិវរណៈគឺជាគម្ពីរដ៏ច្បាស់លាស់បំផុតដែលព្រះបានបណ្តាលឲ្យសរសេរឡើង » ។[៤] សេចក្តីថ្លែងការណ៍នេះអាចធ្វើឲ្យអ្នកស្តាប់ភ្ញាក់ផ្អើល ដោយសារវាពិតជាផ្ទុយទាំងស្រុងទៅនឹងបទពិសោធន៍ផ្ទាល់ខ្លួនដែលពួកគេមាន ។ តើព្យាការីមានប្រសាសន៍បែបនេះចង់មានន័យថាដូចម្តេច ?

ខណៈដែលយ៉ូសែប ស្ម៊ីធ បានបើកសម្តែងអាថ៌កំបាំងមួយចំនួននៃគម្ពីរវិវរណៈ នោះនៅក្នុងសុន្ទរកថានេះលោកហាក់បីដូចជាមានបំណងចង់ពន្យល់បំភ្លឺវាឲ្យកាន់តែច្បាស់ ។ លោកបានធ្វើបែបនេះ តាមរយៈការបង្ហាញថា ភាពអាថ៌កំបាំងនៃគម្ពីរមិនមែននៅអាថ៌កំបាំងដូចដែលយើងតែងតែធ្លាប់គិតនោះទេ ហើយថាកាលដែលយើងមើលព្រះគម្ពីរពុំយល់នោះ ពុំមានន័យថាវាគ្មានសារៈសំខាន់ ឬ គ្មានន័យចំពោះយើងនោះឡើយ ។

ឧទាហរណ៍ មានកន្លែងផ្សេងទៀតនៅក្នុងសុន្ទរកថានេះ យ៉ូសែប ស្ម៊ីធ បានបង្ហាញថាការអានគម្ពីរវិវរណៈដោយយកចិត្តទុកដាក់អាចកំណត់ពីរបៀបដែលវាត្រូវបានបកស្រាយ ។ លោកបានគូសបង្ហាញថា នៅជំពូកបីដំបូងនៃគម្ពីរទាក់ទងនឹងសម័យរបស់យ៉ូហាន និង « អស់ទាំងការណ៍ ដែលបន្តិចទៀតត្រូវកើតមាន » ( វិវរណៈ ១:១ ) ហើយថាផ្នែកដែលនៅសល់ទាំងអស់នៃគម្ពីរនេះទាក់ទងនឹង « ការណ៍ ដែលត្រូវមកខាងក្រោយទៀត » ( វិវរណៈ ៤:១ ) ឬ សម័យក្រោយពីសម័យយ៉ូហានទៀត ។[៥] តាមរយៈការដាក់កំណត់លើអ្វីដែលការនិមិត្តនៅក្នុងផ្នែកទាំងឡាយនៃគម្ពីរនេះអាចអនុវត្តបាន នោះពេលវេលាទាំងនេះធ្វើឲ្យខគម្ពីរទាំងបន្ថយនូវភាពអាថ៌កំបាំងរបស់វា ។

បន្ថែមលើនោះ យ៉ូសែប ស្ម៊ីធ បានបង្រៀនថា ពេលខ្លះពាក្យតួមានជីវិតគឺពុំតំណាងឲ្យអ្វីឡើយ ។ លោកបានពន្យល់ថា នៅពេលយ៉ូហានបាននិយាយថាលោក

ដកស្រង់ចេញពី *THE REVELATION OF ST. JOHN THE DIVINE* ដោយ ផល យ៉ាន ដកស្រង់ចេញពី *ព្រះគ្រីស្ទនៅវាលស្រែ* ដោយ ថូម៉ាស ហ្វ្រានស៊ីស ឌីកស៊ី

# អ្វីៗដែលយើងដឹងពី គម្ពីរវិវរណៈ
## *គឺដោយសារ យ៉ូសែប ស្ម៊ីធ*



*ដោយសារតែបានពន្លឺបន្ថែម ដែលបានបើកសម្ដែងតាមរយៈយ៉ូសែប ស្ម៊ីធ នោះយើងអាចយល់បានប្រសើរជាងមុនពីកម្មវត្ថុនៃប្រធានបទនៃវិវរណៈ អំពីជ័យជំនះរបស់ព្រះគ្រីស្ទ និងពួកបរិសុទ្ធរបស់ទ្រង់លើអារក្ស និង ពិភពលោក ។*




**វិវរណៈ ៥–៨**

**គ. និង ស. ៧៧:៦–៧, ១២**

គ្រាទាំងប្រាំពីរតំណាងឲ្យរយៈពេលទាំងប្រាំពីរ ។ គ្រាពីរដំបូងទាក់ទងនឹងជំនាន់របស់យើង និង ជំនាន់ក្រោយៗទៀត ។

*បន្ទាប់ពីត្រាទីប្រាំពីរបើក នោះព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញ ហើយពួកទុច្ចរិតនឹងត្រូវបំផ្លាញចោល ។*

**វិវរណៈ ៧:១–៨**

**គ. និង ស. ៧៧:៨–១១**

ទេវតាបួនអង្គ អ្នកបម្រើបិទត្រា១៤៤,០០០ចេញពីគ្រប់ពូជអំបូរអ៊ីស្រាអែល ទាក់ទងនឹងកិច្ចការនៃការស្ដារឡើងវិញ និងការប្រមូលផ្ដុំនៅថ្ងៃចុងក្រោយ ។

*ផែនដីនេះនឹងត្រូវសម្អាត ហើយសហស្សវត្សរ៍នឹងត្រូវចាប់ផ្ដើម* ( *សូមមើល គ. និង ស. ៨៨:៨៩–១១០* ) ។

**វិវរណៈ ២០:២**

**នីហ្វៃទី ១ ២២:២៦**

សាតាំងនឹងត្រូវបានចាប់ចងអំឡុងពេលនៃសហស្សវត្សរ៍ « ដោយសារតែសេចក្ដីសុចរិតនៃរាស្ត្រ [ របស់ព្រះគ្រីស្ទ ] » ។

*« ផែនដីនឹងកន្លងផុតទៅដូចត្រូវភ្លើងឆេះ »* ( *សូមមើល គ. និង ស. ៤៣:៣២–៣៣* ) ។

**វិវរណៈ ១២:៤, ៧–៩**

**គ. និង ស. ២៩:៣៦–៣៧; ៧៦:២៥–២៩**

ការនិមិត្តរបស់យ៉ូហានបង្ហាញត្រួសៗពីសង្គ្រាមនៃមុនជីវិតលើផែនដីនៅលើឋានសួគ៌ ដើម្បីបញ្ជាក់ពីសង្គ្រាមដែលកំពុងតែបន្តនៅលើផែនដីរវាងទ័ពរបស់ព្រះ និង សាតាំង ។

**វិវរណៈ ២០:៥**

**គ. និង ស. ៧៦:៨១–៨៥**

អស់អ្នកដែលនឹងមិនទាន់រស់ឡើងវិញរហូតដល់សហស្សវត្សរ៍ គឺជាអ្នកដែលនឹងគ្រងមរតកនៃនគរសេឡេស្ទាល ។

*« ហើយយ៉ូហានខ្ញុំក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មកពីព្រះ »* ( *វិវរណៈ ២១:២* ) *។ ការណ៍នេះអាចសំដៅលើការត្រឡប់មកវិញនៃទីក្រុងអេណុក* ( *សូមមើល ម៉ូសេ ៧:៦៣* ) ។



**វិវរណៈ ២០:១១–១៣**

**គ និង ស ១២៨:៦–៧**

បញ្ជី ( នៅលើផែនដី និង ឋានសួគ៌ ) ដែលមនុស្សនឹងត្រូវជំនុំជម្រះតាមអំពើដែលពួកគេប្រព្រឹត្តិរៀងៗខ្លួន រួមទាំងទាក់ទងនឹងសេចក្ដីសង្គ្រោះនៃមរណជន ។

**វិវរណៈ ១៧:៥**

**នីហ្វៃទី ១ ១៣:៦; ១៤:១០**

កម្មវត្ថុដែលបានបង្ហាញដោយយ៉ូហានដែលថា « បាប៊ីឡូនដ៏ធំ ជាម្ដាយនៃពួកស្រីសំផឹង និងអស់ទាំងសេចក្ដីគួរខ្ពើម » គឺជាសាសនាចក្រនៃអារក្ស ។ សាសនាចក្រនេះរួមមាននូវក្រុមដែលប្រឆាំងនឹងព្រះយេស៊ូវគ្រីស្ទ ដំណឹងល្អ និង សាសនាចក្រទ្រង់ ដ្បិតមានតែសាសនាចក្រពីរប៉ុណ្ណោះ ៖ សាសនាចក្រកូនចៀមនៃព្រះ និង សាសនាចក្រនៃអារក្ស ។



បានឃើញតួមានជីវិតនៅលើឋានសួគ៌ ( សូមមើល វិវរណៈ ៤:៦ ) អ្វីដែលលោកពិតជាឃើញនោះគឺ . . . សត្វនៅលើឋានសួគ៌ ។ ព្យាការីបានបង្ហាញដូច្នេះថា យ៉ាងហោចណាស់ការពិពណ៌នាមួយចំនួនរបស់យ៉ូហានអំពីការនិមិត្តរបស់លោកថាខ្លះមានន័យត្រង់ ឯខ្លះទៀតជាការប្រៀបធៀប ។[៦] លោកក៏បានពន្យល់ពី គោលការណ៍មួយដែលទាក់ទងនឹងការប្រៀបធៀបនោះ ៖

« នៅពេលណាក៏ដោយដែលព្រះបានប្រទានការនិមិត្តអំពី រូបភាព ឬ សត្វ ឬ រូបអ្វីក៏ដោយ នោះទ្រង់មានទំនួលខុសត្រូវចំពោះអង្គទ្រង់ផ្ទាល់ដើម្បីប្រទានវិវរណៈ ឬ ការបកស្រាយអំពីអត្ថន័យនៃរូបទាំងនោះ បើមិនដូច្នោះទេយើងពុំទទួលខុសត្រូវចំពោះជំនឿរបស់យើងលើការនិមិត្តនោះឡើយ ។ សូមកុំខ្លាចថាត្រូវបានដាក់ទោសដោយព្រោះពុំដឹងពីអត្ថន័យនៃការនិមិត្ត ឬ រូបអ្វីមួយឡើយ បើសិនព្រះពុំបានប្រទានវិវរណៈ ឬ បកស្រាយពីប្រធានបទទេនោះ » ។[៧]

ការដឹងពីការបកស្រាយគ្រប់ជំហានលម្អិតអំពីការនិមិត្តអាថ៌កំបាំង គឺពុំសំខាន់នៅក្នុងការសិក្សាព្រះគម្ពីររបស់យើងឡើយ ។ អាថ៌កំបាំងនៃភាសាប្រៀបធៀបរបស់ព្យាការីគឺពុំដូចជាអាថ៌កំបាំងនៃព្រះឡើយ អាថ៌កំបាំងនៃព្រះត្រូវបានប្រទានដល់មនុស្សដែល « បានប្រែចិត្ត ហើយអនុវត្តសេចក្ដីជំនឿ ហើយបញ្ចេញមកនូវកិច្ចការល្អៗ ហើយអធិស្ឋានរហូតដោយឥតឈប់ឈរ » ។ ( អាលម៉ា ២៦:២២ ) ។

ដោយការពន្យល់បំភ្លឺកាន់តែច្បាស់អំពីគម្ពីរវិវរណៈ ព្យាការីបានដកចេញនូវការរំខានទាំងឡាយដែលនឹងអាចមានមកពីគោលលទ្ធិជ្រៅៗនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ពិតណាស់ ការនិមិត្តរបស់យ៉ូហានផ្ដល់នូវព័ត៌មានសំខាន់ដល់យើងអំពីថ្ងៃចុងក្រោយ ៖ ការក្បត់សាសនា និង ការស្ដារឡើងវិញ ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ជ័យជំនះរបស់ទ្រង់លើអារក្ស រជ្ជកាលនៃសហស្សវត្សរ៍របស់ទ្រង់ និង ការរស់ឡើងវិញ ព្រមទាំងការជំនុំជម្រះចុងក្រោយ ។ ការណ៍ទាំងនេះអាចជួយយើង នៅពេលយើងព្យាយាមស្វែងរកសេចក្ដីពិត និង ធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។ ប៉ុន្ដែ បើសិនយើងផ្ដោតយកចិត្តទុកដាក់ខ្លាំងពេកលើការបកស្រាយជាក់លាក់អំពីរូបដែលបានពិពណ៌នាក្នុងការនិមិត្តនោះ នោះយើងប្រហែលជានឹងខកខានមិនបានដឹងពីរឿងដែលសំខាន់បំផុតហើយ ។[៨]

នៅពេលយើងសិក្សាគម្ពីរវិវរណៈ ហើយទទួលយកប្រយោជន៍ពីការបើកសម្ដែងដែលវាមានតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ នោះយើងអាចយល់ពីគោលជំហរផ្ទាល់របស់ខ្លួនជាមួយនឹង ទស្សនវិស័យដ៏ទូលំទូលាយអំពីប្រវត្តិសាស្ត្រពិភពលោក និង ទំនាក់ទំនងរបស់ព្រះជាមួយកូនចៅរបស់ទ្រង់ ។ ការដឹងពីការណ៍នេះនាំឲ្យយើងអាចឃើញពីសារៈសំខាន់នៃទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើងអំពីព្រះយេស៊ូវគ្រីស្ទ និង ការចូលរួមពេញលេញនៅក្នុងកិច្ចការរបស់ទ្រង់នៅថ្ងៃចុងក្រោយ ។ បន្ទាប់មកយើងអាចយកឈ្នះលើពិភពលោក ហើយជាមួយព្រះគ្រីស្ទ គ្រងមរតកនៃអ្វីៗទាំងអស់ពីព្រះវរបិតា ( សូមមើល វិវរណៈ ៣:២១; ២១:៧ ) ។ ■

**កំណត់ចំណាំ**

១. សូមមើល ឧទាហរណ៍ វិវរណៈ ២:១, លេខយោង *ក*; ឬ វិវរណៈ ៦:១៤, លេខយោង *ក* ។
២. ឧទាហរណ៍ ការប្រាប់របស់ព្យាការីយ៉ូសែប ស្ម៊ីធអំពី វិវរណៈ ១:៧ ( នៅក្នុង Bible appendix ) អានថា « មើល ទ្រង់យាងមក *តាម* ពពក *ជាមួយនឹងពួកបរិសុទ្ធទ្រង់ទាំងសល់សែននៅក្នុងនគរ បំពាក់ដោយសិរីល្អនៃព្រះវរបិតាទ្រង់* ។ នោះគ្រប់ទាំងភ្នែកនឹងឃើញទ្រង់ ព្រមទាំងពួកអ្នកដែលចាក់ទ្រង់ផង រួចគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងយំសោក ដោយព្រោះទ្រង់ » ។ ពាក្យបន្ថែមដោយយ៉ូសែប ស្ម៊ីធ ( អក្សរទ្រេត ) ភ្ជាប់ខគម្ពីរនេះជាមួយនឹងការបង្រៀនពីខគម្ពីរពីរផ្សេងទៀតអំពីការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ — ឧទាហរណ៍ ម៉ាថាយ ១៦:២៧ ( « សិរីល្អនៃព្រះវរបិតា » ) និង យូដាស ១:១៤ ( « ពួកបរិសុទ្ធទ្រង់ទាំងសល់សែន » ) ។
៣. Bible Dictionary, « Revelation of John » ។
៤. *ប្រវត្តិសាសនាចក្រ* ៥:៣៤២ ។
៥. ពិតណាស់ ដូចជាអ្វីដែលយ៉ូសែប ស្ម៊ីធ បានដឹង ត្រាប្រាំដំបូងនៃត្រាទាំងប្រាំពីរទាក់ទងនឹងព្រឹត្តិការណ៍ពីអតីតកាល ប៉ុន្ដែចំណុចនេះគឺជាប្រធានបទសំខាន់នៃគោលបំណង ឬ ចំណុចបញ្ចប់នៃប្រវត្តិសាស្ត្រមនុស្ស ដែលបញ្ចប់ដោយព្រឹត្តិការណ៍ដែលនាំទៅការយាងមកជាលើកទីពីរ — ក្រោយពីសម័យរបស់យ៉ូហាន ។
៦. នៅក្នុងឧទាហរណ៍ពិសេសនេះ ពាក្យសត្វនេះគឺមានន័យត្រង់ ដែលតំណាងឲ្យសត្វបួនក្បាល ខណៈដែល *ការពិពណ៌នា* របស់យ៉ូហានអំពីពួកវាថាមានអ្វីៗប្រៀបធៀបជាច្រើន ( ភ្នែក និង ស្លាបច្រើន ) តំណាងឲ្យលក្ខណៈអរូបីរបស់វាជាជាងរូបរាងពិតរបស់វា ( សូមមើល វិវរណៈ ៤:៦–៨; គ. និង ស. ៧៧:៤ ) ។
៧. *ប្រវត្តិសាសនាចក្រ* ៥:៣៤៣ ។
៨. យ៉ូសែប ស្ម៊ីធ មានអារម្មណ៍ថានេះជាការពិតដ៏ពិសេសមួយសម្រាប់អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ។ លោកបានមានប្រសាសន៍ ៖ « ឱ ពួកអែលឌើរនៃអ៊ីស្រាអែល ចូរស្ដាប់តាមពាក្យយើងចុះ នៅពេលអ្នកត្រូវបានបញ្ជូនឲ្យបង្រៀនដល់ពិភពលោក ចូរប្រាប់នូវរឿងទាំងនោះដែលអ្នកត្រូវបានបញ្ជូនឲ្យប្រាប់ បង្រៀន ហើយស្រែកឲ្យឮៗ ‹ ចូរប្រែចិត្តឡើង ដ្បិតនគរស្ថានសួគ៌ជិតដល់ហើយ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ › ។ សូមប្រកាសគោលការណ៍ដំបូង ហើយចូរទុកអាថ៌កំបាំងនោះមួយឡែកចុះ បើមិនដូច្នោះទេអ្នកនឹងត្រូវដួលចុះ ។ ចូរកុំខ្វល់ខ្វាយពីការនិមិត្តនៃសត្វ និង ប្រធានបទដែលអ្នកពុំយល់នោះឡើយ » ( *ប្រវត្តិសាសនាចក្រ* ៥:៣៤៤ ) ។

[illegible] © PROVIDENCE COLLECTION; [illegible] © ISTOCK/THINKSTOCK

# សួរសំណួរត្រឹមត្រូវតាមរបៀបដែលត្រឹមត្រូវ

ដោយ ស្កត់ អេច នីច
ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថាន

*ក្នុងការរៀនពីរបៀបដើម្បីរៀបចំ បង្កើត សួរ និង ឆ្លើយទៅនឹងសំណួរនានាអាចមានការផ្លាស់ប្ដូរដល់របៀបដែលយើងរៀន និង បង្រៀនដំណឹងល្អ ។*

មានអ្វីៗជាច្រើនដែលអ្នកអាចប្រើបានដើម្បីបង្កើតមេរៀនដ៏អស្ចារ្យ ឬ ការសន្ទនាដ៏អស្ចារ្យក្នុងគ្រួសារ ។ សកម្មភាព ការសិក្សាស្ងាត់ស្ងៀម និង ការធ្វើការជាក្រុមគឺជារបៀបមួយចំនួនដែលគ្រូបង្រៀនដំណឹងល្អ — ទោះវាជាមួយនឹងអស់អ្នកដែលមានការបម្រើជាផ្លូវការ គ្រូបង្រៀនស្ម័គ្រចិត្តពីថ្នាក់សិក្ខាសាលា ឬ ថ្នាក់វិទ្យាស្ថាន ឬ ឪពុកម្ដាយក្ដី — អាចត្រូវបានប្រើប្រាស់ដើម្បីពង្រីកការបង្រៀនរបស់ខ្លួន ។

ប៉ុន្តែរួមជាមួយនឹងជំនាញចាំបាច់ចម្បងៗពីរ ឬ បី ដែលគ្រូបង្រៀនទាំងអស់គួរតែមាននោះគឺជាសមត្ថភាពដ៏ពូកែជាមួយសំណួរ ៖ បង្កើតសំណួរ ឆ្លើយសំណួរ និង លើកទឹកចិត្តឲ្យឆ្លើយសំណួរដ៏មានអត្ថន័យ ។ ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ មានប្រសាសន៍ថា « ដើម្បីសួរ និង ឆ្លើយសំណួរគឺជាចំណុចសំខាន់នៃគ្រប់ការរៀនសូត្រ និង ការបង្រៀនទាំងអស់ » ។[1] ដើម្បីក្លាយជាគ្រូម្នាក់ដ៏មានប្រសិទ្ធិភាព វាចាំបាច់តម្រូវឲ្យមានជំនាញនេះ ។ នេះគឺជាយោបល់ប្រាំយ៉ាងសម្រាប់ការធ្វើបែបនោះ ។

**ស្វែងរកចម្លើយដែលមានប្រសិទ្ធិភាពបំផុត**

អង្គុយនៅក្នុងថ្នាក់ធ្វើជាសិស្ស ហើយស្ដាប់សំណួរអស្ចារ្យរំញ័កយើងពីអនុភាពនៃការបង្រៀនដ៏ល្អឥតខ្ចោះ ។ ប៉ុន្តែរបៀបបង្កើត និង សួរសំណួរដែលមានប្រសិទ្ធិភាពគឺមានភាពស្មុគស្មាញ ហើយអាចមានការពិបាកចំពោះគ្រូបង្រៀនជាច្រើន ។ សំណាងល្អ វាគឺជាជំនាញមួយដែលគ្រូបង្រៀនគ្រប់រូបអាចរៀនបាន ។

នៅពេលអ្នកបង្កើតសំណួរ សូមព្យាយាមគិតពីលទ្ធផលនៃប្រភេទចម្លើយដែលសំណួរនោះនឹងមាន ។ សំណួរមួយចំនួនទាមទារចម្លើយមួយបែបដែលជាក់លាក់ — ជាចម្លើយមួយដែលឆ្លើយតបចំៗនឹងសំណួរដែលបានសួរ ។ សំណួរទាំងនោះប្រើបានយ៉ាងល្អសម្រាប់ថ្នាក់គណិតវិទ្យា ( « តើក្រឡាផ្ទៃនៃការ៉េនេះមានប៉ុន្មាន ? » ) ឬ នៅក្នុងថ្នាក់វិទ្យាសាស្ត្រ ( តើទឹកពុះនៅសីតុណ្ហភាពប៉ុន្មាន ? » ) ពីព្រោះ វាមានតែចម្លើយមួយប៉ុណ្ណោះដែលអាចត្រូវបានរកឃើញ និង បញ្ជាក់ ។ សំណួរទាំងនោះក៏មានប្រយោជន៍ក្នុងការសិក្សាដំណឹងល្អផងដែរ ក្នុងរបៀបមួយដែលទទួលសេចក្ដីពិតនៅពេលចាប់ផ្ដើមការពិភាក្សាមួយ ប៉ុន្តែវាពុំសូវធ្វើឲ្យមានការពិភាក្សាច្រើនឡើយ ។ ទោះជាយ៉ាងណា សំណួរទាំងនោះមានប្រយោជន៍បំផុតដោយសារវាស្រួលរៀបចំ ។

យើងសួរសំណួរដូចជា « តើយើងបានរៀនអ្វីខ្លះកាលលើកមុន ? » ឬ « សូមប្រាប់ខ្ញុំពីឈ្មោះរបស់ . . . » ជាញឹកញាប់ សំណួរទាំងនេះ បណ្ដាលឲ្យអស់អ្នកដែលអ្នកបង្រៀននៅទ្រឹងស្ងៀម ។ ពួកគេគិតថាពួកគេដឹងពីចម្លើយ ប៉ុន្តែពុំប្រាកដ ហើយដូច្នេះពួកគេខ្លាចមិនហ៊ានចង់ទាយទេ ។ គ្រូបង្រៀនតែងយល់ថាភាពស្ងាត់នេះគឺជាសញ្ញាមួយថាសំណួរនោះពិបាកពេក ខណៈ

រូបភាពដោយ Digitalstorm/iStock/Thinkstock



ដែលភាពពិតនោះគឺថាសំណួរនេះវាសាមញ្ញពេក ដើម្បីទទួលបានអ្វីដែលមានអត្ថន័យកាន់តែច្រើនពីអ្នករៀនជាជាងគ្រាន់តែបានចម្លើយភ្លាមៗ ។

ដើម្បីបង្កើតឲ្យមានការពិភាក្សាក្នុងថ្នាក់ សំណួរដែលមានប្រយោជន៍ខ្លាំងជាងនេះ គឺជាការអញ្ជើញឲ្យមានចម្លើយផ្សេងៗប្រកបដោយការសញ្ជឹងគិត ។ នៅពេលអ្នកសួរសំណួរបែបនេះ អ្នកអាចស្វែងយល់ដឹងពីប្រធានបទដែលអស់អ្នកដែលអ្នកសួរនោះកំពុងគិត ឬ អ្វីដែលពួកគេកំពុងឆ្ងល់អំឡុងពេលការពិភាក្សានោះ ។ ឧទាហរណ៍ ម៉ូរ៉ូណៃជំពូក ១ មានខគម្ពីរបួនដែលខគម្ពីរនិមួយៗពោរពេញដោយអារម្មណ៍ដ៏ជ្រាលជ្រៅ ។ តើមានអ្វីកើតឡើង បើសិនអ្នកអានខគម្ពីរទាំងបួននោះជាមួយអស់អ្នកដែលអ្នកកំពុងបង្រៀន ហើយបន្ទាប់មកសួរ « តើខគម្ពីរណាមួយដែលបណ្ដាលឲ្យអ្នកកាន់តែស្ពុងអារម្មណ៍ខ្លាំងនោះ ? » សូមទុកពេលឲ្យពួកគេចាប់ផ្ដើមជជែកគ្នា ។ ដោយសារអ្នក ពុំសួរដើម្បីចង់បានចម្លើយជាក់លាក់នោះស្ទើរតែអ្វីៗទាំងអស់ដែលពួកគេនិយាយគឺសំខាន់ទាំងអស់ ។ ខ្ញុំធ្លាប់ប្រើជំពូកនោះជាមួយសំណួរបែបនោះ ហើយបានទទួលចម្លើយយ៉ាងអស្ចារ្យ ដែលបង្កើតឲ្យមានការពិភាក្សាកាន់តែស៊ីជម្រៅ ។

ទាំងនោះគឺជាសំណួរដែលអញ្ជើញឲ្យមានការគិត និង មានអារម្មណ៍ វាផ្ទុយនឹងសំណួរដែលតម្រូវឲ្យចាំអ្វីមួយ ឬ ថ្លែងសេចក្ដីពិតសាមញ្ញ ។ មានពេល និង កន្លែងដែលត្រូវចងចាំ ប៉ុន្តែគ្រូបង្រៀនអាចនិយាយច្រើនពីអ្វីដែលត្រូវតែចងចាំ ដូចជា « ចាំថាកាលពីលើកមុនយើងបាននិយាយគ្នាពី ម៉ូរ៉ូណៃ ១ និងរបៀបដែលខគម្ពីរនិមួយៗមាននូវមេរៀនដ៏មានអនុភាព . . . » ។ គ្រាន់តែខ្ញុំនិយាយបែបនេះ វានឹងរំជួលគំនិត ហើយអ្នករៀននឹងហាក់ដូចជាចង់ចូលរួម ហើយបន្តការពិភាក្សានោះ ។ ទោះជាយ៉ាងណាក៏ដោយ បើសិនខ្ញុំនិយាយថា « តើយើងបាននិយាយអ្វីខ្លះកាលពីលើកមុន ? » ខ្ញុំតែងតែឃើញមានការស្ងាត់ស្ងៀម និង ការធ្វើព្រងើយ ។

**សួរសំណួរទីពីរ**

សំណួរដែលគ្រូបង្រៀនដំណឹងល្អច្រើនប្រើគឺសំណួរមួយចំនួននេះ ៖ « ដូច្នេះ តើសេចក្ដីជំនឿសំខាន់ប៉ុណ្ណានៅក្នុងជីវិតអ្នក ? » ស្ដាប់ដំបូង វាហាក់បីដូចជាសំណួរដ៏មានអត្ថន័យមួយ ប៉ុន្តែនៅពេលអ្នកគិតអំពីវា វាមានចម្លើយតែមួយប៉ុណ្ណោះគឺ « សំខាន់ណាស់ » ។ ពិតណាស់ សេចក្ដីជំនឿ ( និង គោលការណ៍ផ្សេងៗទៀតនៃដំណឹងល្អ ) *គឺ* សំខាន់ណាស់ ប៉ុន្តែជាទូទៅសំណួរបែបនោះវាមិនដឹកនាំទៅណាទៀតទេ ដោយសារអ្នកនៅតែត្រូវការសួរសំណួរតាមដានដូចជា ៖ « ហេតុអ្វីបានជាសំខាន់ ? » ឬ « តើអ្នកនឹងផ្ដល់ឧទាហរណ៍មួយដល់យើងថាតើពេលណាវាសំខាន់នៅក្នុងជីវិតអ្នក ? » សំណួរទាំងនោះអាចធ្វើឲ្យថ្នាក់រៀនមានការពិភាក្សាល្អ ដូច្នេះ សូមសួរសំណួរបែបនោះចំៗតែម្ដងទៅ ហើយរំលងសំណួរដំបូងនោះ ។ សួរសំណួរទីពីរមុននឹងចំណេញពេល ហើយរក្សាការពិភាក្សាឲ្យបន្តកាន់តែល្អ ។

**សូមសរសេរសំណួរជាមុន**

វាពិតជាមានប្រយោជន៍ដែលត្រូវធ្វើចំណុចពីរយ៉ាងនៅពេលអ្នករៀបចំមេរៀន ។ ទីមួយ សរសេរសំណួរលើក្រដាស ។ កុំគ្រាន់តែគិតពីសំណួរនោះឡើយ ត្រូវតែសរសេរវា ។ ជ្រើសរើសពាក្យដោយយកចិត្តទុកដាក់ ហើយអានវាពីរបីដងដើម្បីប្រាកដថាសំណួរដែលអ្នកសួរនោះគឺជាអ្វីដែលអ្នកចង់សួរក្នុងរបៀបមួយដ៏ច្បាស់លាស់ ។

ទីពីរ សួរខ្លួនឯង តើអស់អ្នកដែលខ្ញុំបង្រៀននឹងធ្វើអ្វីនៅពេលខ្ញុំសួរសំណួរនោះ ? មានពេលជាច្រើនដងដែលខ្ញុំគិតថា ខ្ញុំពិតជាមានសំណួរល្អមួយបានកត់ទុក បន្ទាប់មកខ្ញុំអានវាឮៗ ហើយពេលខ្ញុំគិតពីសិស្សក្នុងថ្នាក់ នោះខ្ញុំបានដឹងថាវាមិនដឹកនាំឲ្យមានការពិភាក្សាល្អឡើយ ។ សំណួរនេះអាចប្រើបាននៅក្នុងថ្នាក់ផ្សេងមួយទៀត ប៉ុន្តែសម្រាប់ថ្នាក់របស់ខ្ញុំ ខ្ញុំដឹងថាវាបានបរាជ័យ ដូច្នេះខ្ញុំបានចាប់ផ្ដើមវាម្ដងទៀត ។ ខ្ញុំដឹងថានៅពេលខ្ញុំបានគិតយ៉ាងហ្មត់ចត់ពីសំណួរពីរ ឬ បីនោះហើយសរសេរយ៉ាងល្អនៅក្នុងប្លង់មេរៀនរបស់ខ្ញុំ នោះខ្ញុំអាចចាប់ផ្ដើមការពិភាក្សាបាន ។ សំណួរផ្សេងទៀតនឹងកើតមានឡើងដោយឯកឯង ប៉ុន្តែខ្ញុំត្រូវតែរៀបចំចំណុចចាប់ផ្ដើមដំបូងឲ្យបានល្អ ។

យុទ្ធសាស្ត្រនេះក៏អាចធ្វើនៅផ្ទះបានផងដែរ ។ យើងហាក់បីដូចជាមានការពិភាក្សាអំពីដំណឹងល្អដោយឯកឯងជាច្រើននៅក្នុងផ្ទះរបស់ខ្ញុំ នៅពេលដែលសំណួរ និង ចម្លើយឆ្លងឆ្លើយគ្នា ប៉ុន្តែក៏មានពេលខ្លះដែលមានអ្វីមួយដែលប្រាកដប្រជា និង ចំៗដែលត្រូវនិយាយចំពោះកូនណាម្នាក់ ។ នៅក្នុងករណីទាំងនោះខ្ញុំបានរៀនថា បើសិនខ្ញុំបានរៀបចំសំណួរជាក់លាក់អនុវត្តការសួរសំណួរទាំងនោះ ហើយធ្វើតាមស្ថានភាព





ដែលលទ្ធផលអាចទទួលបាន នោះអ្វីៗនឹងបានល្អប្រសើរច្រើន ។ សំណួរទាំងនោះពុំបានសរសេរលើក្រដាសទេ សំណួរទាំងនោះត្រូវបានសរសេរនៅក្នុងដួងចិត្តខ្ញុំ ហើយខ្ញុំអាចប្រើវានៅពេលដែលចាំបាច់ ។

**សូមកុំខ្លាចចំពោះការស្ងៀមស្ងាត់**

បើសិនអ្នកបានបង្កើតសំណួរដែលពិតជាល្អមែននោះ ជាសំណួរដែលបណ្ដាលឲ្យមានគំនិត ហើយធ្វើឲ្យមានចម្លើយដ៏ទូលំទូលាយ នោះសូមកុំភ្ញាក់ផ្អើលឡើយ បើសិនវាត្រូវចំណាយពេលបន្តិចដើម្បីឲ្យមនុស្សឆ្លើយនោះ ។ គួរតែមានភាពស្ងៀមស្ងាត់ សូមកុំបារម្ភ ។ សំណួរស្រាលៗ — សំណួរដែលគ្រាន់តែតម្រូវឲ្យមានចម្លើយជាក់លាក់ ( ឧទាហរណ៍ « តើមាត្រានៃសេចក្ដីជំនឿមានប៉ុន្មានខគម្ពីរ ? » ) — ទទួលបានចម្លើយភ្លាមៗ ។ សំណួរពិបាកៗ — សំណួរទាំងនោះតម្រូវឲ្យមានចម្លើយ — ជាញឹកញាប់វាត្រូវការពេលវេលាឲ្យសិស្សគិតមុននឹងឆ្លើយ ។ នៅក្នុងករណីនេះ ភាពស្ងៀមស្ងាត់មានប្រយោជន៍សម្រាប់អ្នក ។ ចូរឲ្យកើតឡើងចុះ ហើយនៅពេលអស់អ្នកដែលអ្នកកំពុងបង្រៀនចាប់ផ្ដើមឆ្លើយ នោះអ្នកនឹងភ្ញាក់ផ្អើលដោយក្ដីរីករាយចំពោះចម្លើយដែលពួកគេឆ្លើយ ។

**សូមសួរអំពីខគម្ពីរទាំងឡាយ**

បើសិនអ្នកពិតជាចង់ពង្រីកសមត្ថភាពរបស់ខ្លួនដើម្បីបង្កើត ហើយសួរសំណួរប្រកបដោយប្រសិទ្ធិភាព នោះអ្នកត្រូវតែរៀនសួរសំណួរអស្ចារ្យនានាពីខគម្ពីរអំឡុងពេលការសិក្សា និង ការរៀបចំរបស់អ្នក ។

របៀបមួយនៃវិធីសាស្ត្រក្នុងការអានខគម្ពីរ គឺធ្វើវាសម្រាប់ជាការបំផុសគំនិតផ្ទាល់ខ្លួន ។ យើងអានជំពូក និង ខគម្ពីរទាំងឡាយដើម្បីរីករាយនឹងភាពអស្ចារ្យដែលមាននៅក្នុងនោះ ហើយដើម្បីត្រូវបានស្អាងឡើងជាមួយគោលលទ្ធិ និង សេចក្ដីពិត ។ វិធីសាស្ត្រផ្សេងមួយទៀត ដែលកាន់តែល្អសម្រាប់ឪពុកម្ដាយ ឬ គ្រូបង្រៀនដែលរៀបចំមេរៀន គឺអានខគម្ពីរ និង ស្រាវជ្រាវខគម្ពីរជាមួយនឹងសំណួរ ។ ខ្ញុំធ្វើដូច្នេះដើម្បីដាស់គំនិតខណៈដែលខ្ញុំព្យាយាមសម្រេចពីរបៀបដ៏ល្អបំផុតដើម្បីជួយអស់អ្នកដែលខ្ញុំបង្រៀនឲ្យយល់ពីខគម្ពីរ ។ នេះគឺជាឧទាហរណ៍ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០ មានឃ្លាមួយដែលស្គាល់ច្បាស់ និង លើកតម្កើងវិញ្ញាណរបស់យើង « ចូរចាំថាតម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ » ។ ខ្ញុំចូលចិត្តគំនិតនោះថា បើសិនការបំផុសគំនិតមានមកលើខ្ញុំ នោះវានឹងមិនមានប្រយោជន៍ចំពោះថ្នាក់រៀនឡើយ ។

បើសិនខ្ញុំបានពិចារណាពីសំណួរនេះនៅពេលខ្ញុំបានសិក្សា និង រៀបចំ ៖ « ដូច្នេះតើអ្វីទៅគឺជាតម្លៃនៃព្រលឹងនោះ ? ខ្ញុំដឹងថាវាអស្ចារ្យ ប៉ុន្តែតើយើងអាចផ្ដល់តម្លៃឲ្យវាបានទេ ? » យប់មួយពេលអាហារល្ងាចកូនស្រីម្នាក់របស់ខ្ញុំបានសួរសំណួរនោះ ហើយវាបានធ្វើឲ្យមានការពិភាក្សាយ៉ាងច្រើន ។ នេះគឺជាអ្វីដែលយើងបានពិភាក្សាគ្នា ៖ តម្លៃនៃព្រលឹងគឺជាអ្វីមួយដែលបុគ្គលម្នាក់នឹងបង់ថ្លៃសម្រាប់វា ហើយតើព្រះវរបិតារបស់យើងបានបង់ថ្លៃអ្វីខ្លះសម្រាប់ព្រលឹងយើង ? ទ្រង់បានបង់ថ្លៃដោយព្រះលោហិតរបស់ព្រះរាជបុត្រាដ៏ល្អឥតខ្ចោះរបស់ទ្រង់ ។ វាធ្វើឲ្យព្រលឹងយើងម្នាក់មានតម្លៃលើសពីអ្វីដែលអាចពិពណ៌នាបាន ។ យើងប្រហែលជាមិនអាចឈានមកដល់ការបញ្ចប់នោះដោយគ្មានសំណួរផ្ទាល់ទៅនឹងអត្ថបទនោះឡើយ ។

ការសន្ទនានៅតុអាហារល្ងាចនោះ អាចយកទៅប្រើនៅក្នុងការបង្រៀនផ្សេងទៀតជាច្រើនបាន ។ បើសិនអ្នកចង់សួរសំណួរកាន់តែប្រសើរអំពីអស់អ្នកដែលអ្នកបង្រៀន សូមសួរសំណួរពិតៗពីខគម្ពីរនៅពេលអ្នកសិក្សា និង អាន ហើយរៀបចំនោះ ។ ចូរពោរពេញដោយចម្ងល់ ហើយសូមកុំខ្លាចនឹងស្រាវជ្រាវឡើយ ។ ព្រះគម្ពីរកាន់តែពិតនៅពេលយើងពិនិត្យពិច័យវា ។ កាលណាអ្នកកាន់តែពូកែសួរសំណួរអំពីព្រះគម្ពីរខណៈដែលអ្នកកំពុងសិក្សានោះ អ្នកនឹងកាន់តែពូកែសួរសំណួរដ៏អស្ចារ្យដូចគ្នានោះដល់អស់អ្នកដែលអ្នកបង្រៀន ។

**បន្តពង្រីកសមត្ថភាពនៃការបង្រៀនរបស់អ្នក**

មានភាពលំអៀងមួយដែលឃើញពីគ្រូបង្រៀនល្អ ហើយគិតថាពួកគេបានកើតមកជាមួយទេពកោសល្យនោះ ។ ពួកគេមានអំណោយទានមួយដែលមនុស្សមធ្យមៗពិបាកទទួលបាន ។ ពិតណាស់ សមត្ថភាពបង្រៀនគឺជាអំណោយទានមួយនៃព្រះវិញ្ញាណ ( សូមមើល ម៉ូរ៉ូណៃ ១០:៩–១០ ) ដូច្នេះជំនាញមួយចំនួនដែលអ្នកកំពុងឃើញអាចជាអំណោយទានមួយមកពីឋានសួគ៌ — ប៉ុន្តែវាគឺជាអំណោយទានមួយដែលបើកទូលាយដល់មនុស្សទាំងអស់ដែលស្វែងរកវា ។ មានអ្វីជាច្រើនដែលគ្រូបង្រៀនដ៏អស្ចារ្យធ្វើ ក៏មានសម្រាប់អ្នកផងដែរតាមរយៈការសិក្សា និង ការអនុវត្តន៍ ។ ការរៀនសួរសំណួរដែលប្រកបដោយប្រសិទ្ធិភាពគឺជាជំនាញមួយ ។ នៅពេលអ្នកស្វែងរកសមត្ថភាពនោះប្រកបដោយការអធិស្ឋាន ដើម្បីធ្វើការណ៍នេះ នោះអ្នកនឹងឃើញថាវាពិតជាមានតម្លៃក្នុងការបង្កើតសំណួរដែលជម្រុញចិត្តនៃអស់អ្នកដែលអ្នកបង្រៀនឲ្យគិត ហើយសមត្ថភាពរបស់អ្នកក្នុងការធ្វើការណ៍នេះនឹងរីកចម្រើនឡើង ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។*

**កំណត់ចំណាំ**

១. អែលឌើរ ហ៊ិនរី ប៊ី អាវិង « The Lord Will Multiply the Harvest » ( សុន្ទរកថាចាក់ផ្សាយតាមផ្កាយរណបទៅកាន់គ្រូបង្រៀនសាសនានៅក្នុងប្រព័ន្ធអប់រំសាសនាចក្រ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ) ទំព័រ ៥–៦ ។

រូបភាព © ISTOCK/THINKSTOCK



ជាផ្នែកមួយនៃផែនការរបស់ទ្រង់ ព្រះវរបិតាបានបង្កើតសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ដែលធ្វើឲ្យបុត្រា និង បុត្រីរបស់ព្រះអង្គត្រឡប់ទៅកាន់ទីវត្តមានរបស់ទ្រង់វិញ ហើយគ្រងមរតកនៃជីវិតអស់កល្បជានិច្ច ។

រចនារូបថតនៃពិធីបញ្ជាក់ដោយ សារ៉ា ខារ៉ាប៊ីន ជេនសុន រូបថតរបស់គូស្វាមីភរិយានៅមុខព្រះវិហារបរិសុទ្ធ ឡូស អាន់ជេឡែស ដោយ ជើរី ហ្គូន រូបភាពផ្ទៃខាងក្រោយមកពី ISTOCK/THINKSTOCK



ដោយ អែលឌើរ
ម៉ាកឹស ប៊ី ណាស

នៃពួកចិតសិបនាក់

# សេចក្ដីសញ្ញា ថ្មី ហើយអស់កល្ប អស់កាលជានិច្ច

*នៅពេលយើងយល់ ហើយរស់នៅតាមសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច នោះយើងនឹងគ្រងមរតកនៃជីវិតដ៏នៅអស់កល្បជានិច្ច ។*

**គោលបំណងនៃជីវិតនេះ**

មនុស្សម្នាក់ៗគឺជាបុត្រា ឬ បុត្រីដ៏ជាទីស្រលាញ់របស់ព្រះមាតាបិតាសួគ៌ ។[១] ផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ផ្ដល់ឱកាសដល់បុគ្គលម្នាក់ៗឲ្យទទួលជីវិតដ៏នៅអស់កល្បជានិច្ច ដែលជាជីវិតដែលមានព្រះដឹកនាំ ។[២] គ្មានអំណោយទានណាមហិមាជាងនេះឡើយ ។[៣] ចំណេះដឹងនៃផែនការនៃសេចក្ដីសង្គ្រោះពន្យល់ពីគោលបំណងនៃជីវិតនេះ បើសិនយើងជ្រើសរើសធ្វើដូច្នេះ នោះយើងនឹងត្រូវបានដឹកនាំឲ្យធ្វើការសម្រេចចិត្ត ដោយមានទស្សនវិស័យអស់កល្បជានិច្ចមួយ ។

ផែនការនេះ និង អ្វីៗដែលទាក់ទងនឹងជីវិតរមែងស្លាប់ត្រូវបានពន្យល់ប្រកបដោយអានុភាពនៅក្នុងអត្ថបទ *លីអាហូណា* ខែ តុលា ឆ្នាំ ២០១៥ ស្ដីពីប្រធានបទនេះដោយអែលឌើរ រ៉ូបឺត ឌី ហែល នៃកូរ៉ុមនៃពួកដប់ពីរនាក់ ។[៤] ជាផ្នែកមួយនៃផែនការរបស់ទ្រង់ ព្រះវរបិតាបានបង្កើតសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ដែលធ្វើឲ្យបុត្រា និង បុត្រីរបស់ទ្រង់ត្រឡប់ទៅកាន់វត្តមានរបស់ទ្រង់ ហើយគ្រងមរតកនៃជីវិតដ៏អស់កល្បជានិច្ច ។

នៅក្នុងបុព្វកថារបស់ទ្រង់ចំពោះព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាព្រះអម្ចាស់មានបន្ទូល ៖ « ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ ដោយជ្រាបនូវគ្រោះដែលនឹងមានមកលើ បណ្ដាជនទាំងឡាយនៅលើផែនដីនោះបានហៅយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបម្រើរបស់យើង ហើយបាននិយាយមកកាន់លោកពីលើស្ថានសួគ៌ . . .

« ដើម្បីឲ្យសេចក្ដីសញ្ញាដ៏អស់កល្បអស់កាលជានិច្ចរបស់យើងអាចបានតាំងឡើង » ។[៥]

ជាញឹកញាប់សេចក្ដីសញ្ញានេះគឺព្រះអម្ចាស់សំដៅលើ « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » ដែល



ដាក់បញ្ចូលនូវភាពពោរពេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ រួមមានទាំងពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងអស់ដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះនៃមនុស្សលោក ។[៦] ទោះបីជាការតាំងឡើងនូវសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចលើផែនដីនេះ គឺជាគោលបំណងចម្បងនៃការស្ដារឡើងវិញក្ដី ក៏ពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួនពុំយល់ពីសារៈសំខាន់នៃសេចក្ដីសញ្ញា និង ការសន្យាអំពីអ្វីៗដែលល្អដែលប្រទានមកដល់អស់អ្នកដែលនៅជាប់នៅក្នុងសេចក្ដីសញ្ញាទាំងនោះឡើយ ។ គោលបំណងនៃអត្ថបទនេះគឺដើម្បីជួយយើងម្នាក់ៗឲ្យយល់ ហើយរស់នៅតាមសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចដើម្បីឲ្យយើងអាចនឹងគ្រងមរតកនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ អត្ថបទនេះក៏នឹងពន្យល់ផងដែរពីរបៀបមួយនៃពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃដំណឹងល្អដែលសំខាន់បំផុត — អាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច — ដែលជាផ្នែកមួយនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃដំណឹងល្អ ។

*សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនេះ « គឺជាលទ្ធផលសរុបនៃសេចក្ដីសញ្ញា និង កាតព្វកិច្ចទាំងឡាយនៃដំណឹងល្អ » ។*

### អត្ថន័យ និង គោលបំណងនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច

អត្ថន័យនៃសេចក្ដីសញ្ញានៅក្នុងដំណឹងល្អមានន័យថា ជាការព្រមព្រៀងមួយ ជាកិច្ចសន្យា ឬ ជាការយល់ព្រមមួយរវាងព្រះ និង មនុស្សម្នាក់ ( ឬ ច្រើននាក់ ) ដែលទទួលពិធីបរិសុទ្ធនៃបព្វជិតភាពដែលធ្វើឡើងដោយនរណាម្នាក់ ដែលមានសិទ្ធិអំណាចបព្វជិតភាព ហើយយល់ព្រមតាមលក្ខខណ្ឌនៃសេចក្ដីសញ្ញាដែលពាក់ព័ន្ធ ។ លក្ខខណ្ឌទាំងនេះត្រូវបានតាំងឡើងដោយព្រះ ។[៧]

សេចក្ដីសញ្ញាថ្មី ហើយដ៏នៅអស់កល្បអស់កាលជានិច្ចនេះ « គឺជាលទ្ធផលសរុបនៃសេចក្ដីសញ្ញា និង កាតព្វកិច្ចទាំងឡាយនៃដំណឹងល្អ »[៨] ដែលបានប្រទានឲ្យតាំងពីបុរាណ[៩] ហើយត្រូវបានស្ដារឡើងវិញម្ដងទៀតនៅលើផែនដីនៅថ្ងៃចុងក្រោយនេះ ។ ការណ៍នេះបានពន្យល់នៅក្នុង គោលលទ្ធិនិងសេចក្ដីសញ្ញា ៦៦:២ ៖ « យើងបាប្រ់អ្នកជាប្រាកដថា អ្នកមានពរហើយ ដែលបានទទួល *សេចក្ដីសញ្ញាដ៏អស់កល្បអស់កាលជានិច្ចរបស់យើង គឺជាភាពពោរពេញនៃដំណឹងល្អរបស់យើង* ដែលបានចាត់ឲ្យចេញទៅដល់កូនចៅមនុស្សប្រយោជន៍ឲ្យពួកគេអាចមានជីវិត ហើយអាចបានទៅជាពួកអ្នកមានចំណែកក្នុងសិរីល្អទាំងឡាយដែលនឹងត្រូវបានបើកសម្ដែងនៅក្នុងគ្រាចុងក្រោយបង្អស់ដូចដែលបានសរសេរទុកដោយពួកព្យាការី និង ពួកសាវកសម័យបុរាណ » ។[១០] ដោយសារសេចក្ដីសញ្ញានេះត្រូវបានស្ដារឡើងវិញនៅក្នុងសម័យកាន់កាប់ត្រួតត្រាចុងក្រោយនេះ ដូច្នេះវាគឺជាសេចក្ដីសញ្ញា « ថ្មី » ហើយ

ដោយសារវាគ្មានទីបញ្ចប់[១១] នោះវាគឺ « នៅអស់កល្បជានិច្ច » ។

នៅក្នុងព្រះគម្ពីរ ព្រះអម្ចាស់មានព្រះបន្ទូលទាំងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច « នេះ » និង សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច« មួយ » ។ ឧទាហរណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២២:១ទ្រង់បានមានព្រះបន្ទូលសំដៅលើពិធីបុណ្យជ្រមុជទឹកថាជាសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច*មួយ* ដែលមានតាំងពីដើមដំបូងមកម្ល៉េះ » ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤ព្រះអម្ចាស់ក៏សំដៅលើអាពាហ៍ពិពាហ៍អស់កល្បជានិច្ចថាជា « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច*មួយ* ដែរ » ។ នៅពេលទ្រង់មានបន្ទូលពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច « មួយ » ទ្រង់មានបន្ទូលពីសេចក្ដីសញ្ញាមួយនៃសេចក្ដីសញ្ញាជាច្រើនដែលបានបញ្ចូលដោយដំណឹងល្អរបស់ទ្រង់ ។

នៅពេលព្រះអម្ចាស់មានបន្ទូលជាទូទៅអំពី សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច « នេះ » នោះទ្រង់កំពុងមានព្រះបន្ទូលពី ភាពពោរពេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលមានក្ដោបទាំងពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងនៃមនុស្សលោក ។ ពិធីបុណ្យជ្រមុជទឹក និង អាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចពុំមែនជាសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច « នេះ » ឡើយ ផ្ទុយទៅវិញវាគឺជាផ្នែកមួយៗនៃសេចក្ដីសញ្ញាទាំងមូល ។

**ពរជ័យដ៏មហិមា និង ដ៏អស់កល្បជានិច្ចត្រូវបាន សន្យាថានឹងប្រទានដល់អស់ អ្នកណាដែលទទួលពិធីបរិសុទ្ធ នានានៃដំណឹងល្អ ។**

**អស់អ្នកទាំងឡាយណាដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុត នៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនេះទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**

ពរជ័យដ៏មហិមា និង អស់កល្បជានិច្ចត្រូវបានសន្យាប្រទានដល់អស់អ្នកណាដែលទទួល ពិធីបរិសុទ្ធនៃដំណឹងល្អដែលបានធ្វើឡើងដោយសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ ហើយផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសញ្ញា[១២] ហើយជាអ្នកដែលបានរក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋដែលទាក់ទងជាមួយពិធីបរិសុទ្ធទាំងនោះ ។ ពរជ័យទាំងនេះរួមមានការអភ័យទោសពីអំពើបាប[១៣] អំណាចនៃព្រះ[១៤] និង មានភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ[១៥] រួមគ្នាជាមួយនឹងសេចក្ដីណែនាំ ការបំផុសគំនិត ការលួងលោម សេចក្ដីសុខសាន្ត សេចក្ដីសង្ឃឹម និង ការញែកចេញជាបរិសុទ្ធដែលអមមកជាមួយនឹងអំណោយនោះ ។[១៦]

ពរជ័យ និង អំណោយទានដ៏ធំមហិមាបំផុតរបស់ព្រះនោះគឺ ជីវិតដ៏នៅអស់កល្បជានិច្ច — ដែលវាគឺជាជីវិតដែលព្រះរស់នៅ ![១៧] អំណោយទាននេះត្រូវបានប្រទានឲ្យតែអស់អ្នកដែលទទួលបានពិធីបរិសុទ្ធទាំងអស់នៃដំណឹងល្អ ហើយរស់នៅតាមសេចក្ដីសញ្ញាដែលមានបញ្ចូលនៅក្នុងសេចក្ដីសញ្ញាថ្មី ហើយដ៏អស់កល្បអស់កាលជានិច្ច ។[១៨] នៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់ ៖ « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច . . . នោះត្រូវបានបង្កើតឡើង សម្រាប់ភាពពោរពេញនៃសិរីល្អរបស់យើង » ។[១៩] ពិតណាស់ អស់អ្នកដែលចូលក្នុងសេចក្ដីសញ្ញាថ្មី ហើយដ៏អស់កល្បអស់កាលជានិច្ច ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះ « នឹងត្រូវបានក្រោកឡើងនៅក្នុងដំណើររស់ឡើងវិញលើកទីមួយ . . . ហើយនឹងបានគ្រងបល្ល័ង្កទាំងឡាយ នគរទាំងឡាយ ក្សត្របុរីទាំងឡាយ និងអំណាចទាំងឡាយ អំណាចគ្រប់គ្រងទាំងឡាយ គ្រប់ទីកំពស់ និង ជម្រៅទាំងអស់ » ។[២០] ព្រះអម្ចាស់ថ្លែងយ៉ាងដាច់អហង្កាថា « នោះនឹងបានសម្រេចដល់ពួកគេ ចំពោះគ្រប់ការណ៍ទាំងអស់ ដែលអ្នកបម្រើរបស់យើងបានភ្ជាប់ទៅលើពួកគេ ក្នុងកាលវេលា និង រហូតដល់អស់ទាំងភាពអស់កល្បជានិច្ចផង ហើយនឹងមានប្រសិទ្ធិភាពពេញលេញ កាលពួកគេចាកចេញពីលោកិយទៅ ហើយពួកគេនឹងបង្ហួសទេវតាទាំងឡាយ និង ព្រះទាំងឡាយដែលបានចាត់ឲ្យនៅទីនោះ ដើម្បីទៅរកភាពតម្កើងឡើង និង សិរីល្អរបស់ពួកគេ ក្នុងអ្វីៗគ្រប់ទាំងអស់ ដូចដែលបានភ្ជាប់លើក្បាលពួកគេ គឺជាសិរីល្អដែលនឹងបានពូនដ៏បរិបូរ និង បន្តបន្ទាប់ជារៀងដរាបទៅ ។ ខណៈនោះពួកគេនឹងទៅជាព្រះ » ។[២១]

សរុបមកវិញ អស់អ្នកដែលចូលក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ហើយស៊ូទ្រាំដោយស្មោះត្រង់រហូតដល់ទីបំផុតនោះនឹង ( ១ ) ទទួលភាពពោរពេញនៃសិរីល្អនៃព្រះ ( ២ ) រីករាយនឹងអំណាចនៃព្រះសម្រាប់វេលាកាល និង អស់ទាំងភាពអស់កល្បជានិច្ច[២២] ( ៣ ) ត្រូវបានតម្កើងឡើង ( ៤ ) រីករាយនឹងអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ព្រមទាំងបន្តរីកចម្រើន និង ( ៥ ) ក្លាយទៅជាព្រះ ។ រួមគ្នាមក ពរជ័យទាំងនេះរួមបញ្ចូលដើម្បីតម្កើងឡើងអំណោយទាននៃជីវិតដ៏នៅអស់កល្បជានិច្ច ។

**យើងត្រូវតែគោរពតាមសេចក្ដីសញ្ញានិមួយៗនៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច**

ព្រះអម្ចាស់ថ្លែងយ៉ាងច្បាស់ថា យើងនឹងទទួលនូវពរជ័យដ៏ទេវភាពទាំងនេះបានលុះត្រាតែ នៅពេលយើងធ្វើតាមក្រឹត្យវិន័យនានារបស់ទ្រង់ ដែលបានកំណត់មកនៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនេះ ៖ « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច . . . ត្រូវបានបង្កើតឡើងសម្រាប់ភាពពោរពេញនៃសិរីល្អរបស់យើង ហើយអ្នកណាដែលទទួលនូវភាពពោរពេញនៃសិរីល្អនោះ នោះត្រូវហើយគួរនៅជាប់នឹងក្រឹត្យវិន័យ បើពុំនោះសោតទេ អ្នកនោះនឹងជាប់ទោស ព្រះអម្ចាស់ដ៏ជាព្រះទ្រង់មានព្រះបន្ទូលថាដូច្នោះ » ។[២៣] ទ្រង់ក៏បានថ្លែងដែរថា « ដ្បិតអស់អ្នកណាដែលបានព្រះពរពីព្រះហស្តរបស់យើង នោះនឹងនៅជាប់នឹងក្រឹត្យវិន័យដែលបានតាំងសម្រាប់ព្រះពរនោះ និង លក្ខខណ្ឌនៃក្រឹត្យវិន័យនោះ ដូចដែលបានបង្កើតឡើងតាំងពីមុនកំណើតលោកិយមកម្ល៉េះ » ។[២៤] នៅក្នុងកណ្ឌដែលនោះនៃគោលលទ្ធិ និងសេចក្ដីសញ្ញា ព្រះអម្ចាស់បានលើកពីគោលការណ៍នេះ ៖ « ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា លើកលែងតែអ្នករាល់គ្នានៅជាប់នឹងក្រឹត្យវិន័យរបស់យើង នោះអ្នករាល់គ្នាពុំអាចបានសិរីល្អនេះឡើយ » ។[២៥]

តម្រូវការត្រង់នេះ ដែលថាយើងត្រូវតែគោរពធ្វើតាមក្រឹត្យវិន័យនៃព្រះ ដើម្បីទទួលបានសិរីល្អដែលទ្រង់ប្រទានឲ្យដល់ពួកអ្នកស្មោះត្រង់នោះ អនុវត្តចំពោះពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងអស់នៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាល

ជានិច្ចនេះ ។ ឧទាហរណ៍ បើសិនខ្ញុំពុំទទួលពិធីបរិសុទ្ធ ហើយរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹកទេ នោះខ្ញុំនឹងជាប់ទោស មានន័យថា ខ្ញុំពុំអាចរីកចម្រើន — ខ្ញុំពុំអាចគ្រងមរតកដ៏ពេញលេញនៃសិរីល្អរបស់ទ្រង់បានឡើយ ។ ដូចគ្នានេះដែរ បើសិនខ្ញុំពុំបានទទួលពិធីបរិសុទ្ធនានាក្នុងព្រះវិហារបរិសុទ្ធ ហើយរក្សាសេចក្ដីសញ្ញាដែលទាក់ទង ឬថាបើសិនខ្ញុំបដិសេធពុំព្រមទទួលពិធីបរិសុទ្ធណាមួយនៃដំណឹងល្អ ឬ បើសិនខ្ញុំបដិសេធមិនព្រមនៅជាប់នឹងសេចក្ដីសញ្ញាណាមួយ ដែលជាប់ទាក់ទងនោះទេ នោះខ្ញុំនឹងពុំត្រូវបានតម្កើងឡើងឡើយ ។ ផ្ទុយទៅវិញ ខ្ញុំនឹងជាប់ទោស ដែលមានន័យថាការរីកចម្រើនរបស់ខ្ញុំនឹងត្រូវបានបញ្ចប់ ។ សរុបមក ខ្ញុំត្រូវតែទទួលគ្រប់ពិធីបរិសុទ្ធនៃដំណឹងល្អ ហើយនៅជាប់នឹងគ្រប់ទាំងសេចក្ដីសញ្ញាដែលទាក់ទង បើសិនខ្ញុំប្រាថ្នាចង់ជីវិតដ៏នៅអស់កល្បជានិច្ច ។

ក្នុងនាមយើងជាពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងយល់ព្រមរស់នៅតាមលក្ខខណ្ឌនៃសេចក្ដីសញ្ញាដែលអាចត្រូវបានចែកជាបួនក្រុម ៖ ( ១ ) លើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះអង្គសង្គ្រោះ ចងចាំទ្រង់ជានិច្ច ហើយធ្វើតាមគំរូរបស់ទ្រង់ ( ២ ) គោរពព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ( ៣ ) មានឆន្ទៈបម្រើកូនចៅរបស់ព្រះដែលជាផ្នែកមួយនៃកិច្ចការនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ សូម្បីតែជាការបូជាផ្ទាល់ខ្លួនក្ដី និង ( ៤ ) ការថ្វាយខ្លួន និង អ្វីៗទាំងអស់ដែលជារបស់យើងចំពោះកិច្ចការរបស់ព្រះអម្ចាស់ ។

យោងតាមក្រឹត្យវិន័យរបស់ព្រះ នោះដំណឹងល្អ ( និង សិរីរុងរឿងដែលដំណឹងល្អបានផ្ដល់ឲ្យ ) គឺត្រូវបានទទួលដោយការធ្វើពិធីបរិសុទ្ធពិសេសៗតាមរយៈសិទ្ធិអំណាចនៃបព្វជិតភាព ។ តាមរយៈពិធីបរិសុទ្ធនៃបព្វជិតភាព នោះអំណាចនៃព្រះត្រូវបានបើកបង្ហាញនៅក្នុងជីវិតរបស់យើង — ប៉ុន្តែលុះត្រាតែយើងរក្សាសេចក្ដីសញ្ញាដែលទាក់ទង ។ សេចក្ដីសញ្ញាធ្វើឲ្យមានអំណាច ឬ ផ្ដល់អំណាចដល់ពិធីបរិសុទ្ធ គឺដូចជាម៉ាស៊ីនដែលធ្វើឲ្យឡានដំណើរការ ហើយអាចដឹកមនុស្សពីកន្លែងមួយទៅកន្លែងមួយទៀតបាន ។ សរុបសេចក្ដីមក គឺវាទៅតាមកម្រិតដែលយើងរក្សាដោយចេះគិតគូរ និង ស្មោះត្រង់ចំពោះសេចក្ដីសញ្ញាដែលទាក់ទងជាមួយពិធីបរិសុទ្ធដែលយើងទទួលបាន នោះយើងនឹងរីកចម្រើននៅក្នុងចំណេះដឹងរបស់យើងអំពីព្រះ និង បទពិសោធន៍នៃ « អំណាចនៃព្រះ »[២៦] ដោយព្រះគុណនៃព្រះតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ ។[២៧]

តាមរយៈពិធីបរិសុទ្ធនៃបព្វជិតភាព នោះអំណាចនៃព្រះត្រូវបានបើកបង្ហាញនៅក្នុងជីវិតរបស់យើង ។

**តួនាទីនៃអាពាហ៍ពិពាហ៍នៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច**

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤ព្រះអម្ចាស់បានថ្លែងថា ទ្រង់នឹងបើកសម្ដែងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច « មួយ » ហើយទ្រង់បានបន្ថែមថា « បើសិនជា អ្នកមិនកាន់សេចក្ដីសញ្ញានោះជាប់ទេ ខណៈនោះអ្នកជាប់ទោស ដ្បិតគ្មានអ្នកណាមួយអាចបដិសេធសេចក្ដីសញ្ញានេះ ហើយអនុញ្ញាតឲ្យចូលក្នុងសិរីល្អរបស់យើងបានឡើយ » ។ ព្រះបន្ទូលទាំងនេះសំដៅលើសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច[២៨] ដែលធ្វើឡើងយ៉ាងត្រឹមត្រូវដោយសិទ្ធិអំណាចបព្វជិតភាព[២៩] ដែលជាផ្នែកមួយសំខាន់ និង ចាំបាច់នៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច « នេះ » ( ភាពពោរពេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ) ។[៣០] ព្រះអម្ចាស់បានគូសបញ្ជាក់ពីសារៈសំខាន់ដ៏ធំបំផុត នៃសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ដោយប្រាប់ពួកយើងថា អស់អ្នកណាដែលបដិសេធសេចក្ដីសញ្ញានេះ នោះនឹងពុំអាចទទួលជីវិតដ៏នៅអស់កល្បជានិច្ចឡើយ ។[៣១]

មនុស្សមួយចំនួន រួមទាំងសមាជិកនៃសាសនាយើងខ្លះដែរ អានដោយយល់ខុសថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤ ចង់និយាយថាអាពាហ៍ពិពាហ៍ពហុពន្ធភាពគឺ ចាំបាច់សម្រាប់ភាពតម្កើងឡើង ដែលនាំឲ្យពួកគេជឿថា អាពាហ៍ពិពាហ៍ពហុពន្ធភាពគឺជាតម្រូវការចាំបាច់សម្រាប់ភាពតម្កើងឡើងនៅក្នុងភាពអស់កល្បជានិច្ច ។ ប៉ុន្តែចំណុចនេះមិនត្រូវបានគាំទ្រនៅក្នុងវិវរណៈទាំងនេះឡើយ ។ ដូចដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ និង ១៣២ព្រះអម្ចាស់បានណែនាំក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចដោយការសំដៅយ៉ាងច្បាស់ទៅលើការផ្សារភ្ជាប់រវាងបុរសម្នាក់ និង ស្ត្រីម្នាក់ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤–៧, ១៥–២៥ ) ។

តាមរយៈការដាក់ចេញនូវក្រឹត្យវិន័យ នៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដែលមានភរិយា ឬ ស្វាមីតែមួយ នោះព្រះអម្ចាស់បានគូសបញ្ជាក់ថាពរជ័យនៃភាពតម្កើងឡើង ត្រូវបានប្រទានដល់បុរស និង ស្ត្រីម្នាក់ៗដែលសក្តិសមចូលទៅក្នុងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ដែលធ្វើឡើងដោយសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ គឺមិនអាស្រ័យលើថាតើវាជាអាពាហ៍ពិពាហ៍ពហុពន្ធភាព ឬ ជាអាពាហ៍ពិពាហ៍ដែលមានភរិយា ឬ ស្វាមីតែមួយនោះឡើយ ។[៣២]

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩ បានពន្យល់ច្បាស់ថា ជីវិតដ៏នៅអស់កល្បជានិច្ចគឺត្រូវបានសន្យាដល់គូស្វាមីភរិយាណាដែលមានស្វាមី ឬ ភរិយាតែមួយដែលបានផ្សារភ្ជាប់ដោយសិទ្ធិអំណាចនៃបព្វជិតភាព ហើយជាអ្នកដែលនៅជាប់ក្នុងសេចក្ដីសញ្ញានោះ — ដែលគ្មានលក្ខខណ្ឌ ឬ តម្រូវការណាបន្ថែមទៀតឡើយ ។ បុរស និង ស្ត្រីណាក៏ដោយដែលបានផ្សារភ្ជាប់តាមរបៀបនេះ ហើយនៅជាប់នឹងសេចក្ដីសញ្ញានោះនឹងត្រូវបានតម្កើងឡើង ។[៣៣] ការអនុវត្តន៍នៃអាពាហ៍ពិពាហ៍ក្នុងព្រះវិហារយើងពីបុរាណគឺ វាស្របគ្នាជាមួយនឹងគោលលទ្ធិនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចដូចដែលបានពន្យល់នៅក្នុងអត្ថបទនេះ ។[៣៤] ពិធីបរិសុទ្ធដែលផ្សារភ្ជាប់គូស្វាមីភរិយាសម្រាប់ភាពអស់កល្បជានិច្ច រួមមាននូវសេចក្ដីសញ្ញា និង ពរជ័យដែលដូចគ្នាសម្រាប់អាពាហ៍ពិពាហ៍ដែលមានស្វាមី ឬ ភរិយាតែមួយ និង សម្រាប់អាពាហ៍ពិពាហ៍ពហុពន្ធភាពដែលបានអនុញ្ញាតដែលធ្វើឡើងកាលពីអតីតកាល ។ សេចក្ដីសញ្ញា និង ពរជ័យដូចគ្នាទាំងនេះ នឹងត្រូវផ្ដល់ឲ្យដល់អ្នកស្មោះត្រង់បន្ទាប់ពីជីវិតនេះ ដែលពុំមានឱកាសផ្សារភ្ជាប់នៅក្នុងជីវិតមែងស្លាប់ ។[៣៥]

បន្ទាប់ការបើកសម្ដែងក្រឹត្យវិន័យ និង សេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចរវាងបុរសម្នាក់ និង ស្ត្រីម្នាក់ នោះព្រះអម្ចាស់បានបង្រៀន



រូបថតនៅព្រះវិហារបរិសុទ្ធ រ៉េចប៊ើក អៃដាហូ

យ៉ូសែប ស្ម៊ីធ ថា បុរសម្នាក់អាចរៀបអាពាហ៍ពិពាហ៍ប្រពន្ធច្រើនជាងម្នាក់ ដោយស្មោះត្រង់ជាមួយនឹងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច នៅពេលត្រូវបានអនុញ្ញាត ឬ បញ្ជាដោយព្រះអម្ចាស់តាមរយៈព្យាការីដែលបានតាំងយ៉ាងត្រឹមត្រូវ ( ដែលកាន់កូនសោបព្វជិតភាពដែលទាក់ទងនោះ ) ។[៣៦] ការអនុញ្ញាត និង ការបញ្ជាឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានប្រទានដោយព្រះអម្ចាស់ដល់អ័ប្រាហាំ និងព្យាការីផ្សេងទៀតកាលពីជំនាន់បុរាណ[៣៧] ក៏ដូចជាបានប្រទានដល់ព្យាការីយ៉ូសែប ស្ម៊ីធផងដែរ ៖ « យើងប្រទានដល់អ្នកគឺយ៉ូសែប ជាអ្នកបម្រើរបស់យើង នូវតំណែងមួយ ហើយសាងឡើងវិញនូវការណ៍គ្រប់យ៉ាង » ។[៣៨]

ច្រើនឆ្នាំក្រោយមក ព្រះអម្ចាស់បានលុបចោលនូវការអនុញ្ញាត និង ការបញ្ជារបស់ទ្រង់សម្រាប់សមាជិកសានាចក្រឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ( ឬ និយាយម្យ៉ាងទៀតថា គឺពុំឲ្យផ្សារភ្ជាប់លើសពីភរិយា ឬ ស្វាមីម្នាក់ដែលកំពុងរស់នៅនេះឡើយ ) នៅពេលប្រធាន វិលហ្វូឌ វូឌ្រុព្វ ( ១៨០៧–៩៨ ) បានចេញសេចក្ដីប្រកាសឆ្នាំ ១៨៩០ ។[៣៩] សេចក្ដីប្រកាសនេះបាននាំឲ្យឈប់មានការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាព មានន័យថាគ្មានសមាជិកសាសនាចក្រណាម្នាក់អាចរៀបអាពាហ៍ពិពាហ៍ ឬ ផ្សារភ្ជាប់ជាមួយនឹងភរិយា ឬ ស្វាមីលើសពីម្នាក់ដែលកំពុងរស់នៅ

*« អាពាហ៍ពិពាហ៍សេឡេស្ទាលគឺចាំបាច់ចំពោះភាពពោរពេញនៃសិរីល្អនៅក្នុងពិភពខាងមុខ »* ។

ឡើយ ។ វាចាំបាច់ដើម្បីចាំថា សេចក្ដីប្រកាសនោះពុំបានហាមប្រាមបុរសសក្ដិសមណាម្នាក់ដែលត្រូវបានផ្សារភ្ជាប់នឹងភរិយាម្នាក់ដែលបានស្លាប់ទៅហើយ ថាកុំឲ្យផ្សារភ្ជាប់នឹងភរិយាម្នាក់ទៀតដែលកំពុងរស់នៅឡើយ ។ គោលការណ៍នេះ ស្របជាមួយនឹងគោលលទ្ធិដែលបានបើកសម្ដែងថាការរៀបអាពាហ៍ពិពាហ៍ស្វាមី ឬភរិយាមួយគឺជាច្បាប់បទដ្ឋានរបស់ព្រះអម្ចាស់សម្រាប់អាពាហ៍ពិពាហ៍ លុះត្រាតែទ្រង់ប្រកាស ហើយអនុញ្ញាតឲ្យធ្វើដូច្នោះតាមរយៈអ្នកតំណាងដែលបានតែងតាំងឡើងយ៉ាងត្រឹមត្រូវរបស់ទ្រង់ មានន័យថាជាប្រធាន និងព្យាការីនៃសាសនាចក្រ ។[៤០]

ជំនួសមុខឲ្យគណៈប្រធានទីមួយ និង ការឆ្លើយចំពោះសំណួរដែលសួរថា « តើអាពាហ៍ពិពាហ៍ពហុពន្ធភាព ឬ អាពាហ៍ពិពាហ៍សេឡេស្ទាលចាំបាច់ចំពោះភាពពោរពេញនៃសិរីល្អនៅក្នុងពិភពខាងមុខដែរឬទេ ? » ប្រធាន ឆាលលេស ដ័បុលយូ ផេនរូស ( ១៨៣២–១៩២៥ ) បានសរសេរ ៖ « អាពាហ៍ពិពាហ៍សេឡេស្ទាលគឺចាំបាច់ចំពោះភាពពោរពេញនៃសិរីល្អនៅក្នុងពិភពខាងមុខ ដូចដែលបានពន្យល់នៅក្នុងវិវរណៈទាក់ទងនឹងវា ប៉ុន្តែ *វាពុំបានថ្លែងថាអាពាហ៍ពិពាហ៍ពហុពន្ធភាពវាចាំបាច់ដូច្នោះឡើយ* » ។[៤១]

នៅឆ្នាំ ១៩៣៣ គណៈប្រធានទីមួយបានថ្លែង ៖ « អាពាហ៍ពិពាហ៍សេឡេស្ទាល — គឺជាការរៀបការសម្រាប់វេលាកាល និង អស់ទាំងភាពអស់កល្បជានិច្ច — ហើយ



អាពាហ៍ពិពាហ៍ដែលមានប្រពន្ធច្រើន ឬ អាពាហ៍ពិពាហ៍ពហុពន្ធភាពគឺជាពាក្យដែលមិនមានន័យដូចគ្នានោះទេ ។ អាពាហ៍ពិពាហ៍ដែលមានភរិយាតែមួយសម្រាប់វេលាកាល និង អស់ទាំងភាពអស់កល្បជានិច្ចធ្វើឡើងជាឱឡារិកនៅក្នុងព្រះវិហារបរិសុទ្ធរបស់យើងស្របទៅតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ និង ក្រឹត្រវិន័យរបស់សាសនាចក្រគឺជាអាពាហ៍ពិពាហ៍សេឡេស្ទាល » ។[៤២]

ស្របតាមសេចក្ដីថ្លែងការណ៍ទាំងនេះ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ( ១៩១៥–៨៥ ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានសរសេរ ៖ « *អាពាហ៍ពិពាហ៍ពហុពន្ធភាព គឺពុំចាំបាច់ចំពោះសេចក្ដីសង្គ្រោះ ឬ ភាពតម្កើងឡើងឡើយ* ។ នីហ្វៃ និង ប្រជាជនរបស់លោកត្រូវបានបដិសេធអំណាច ដើម្បីមានប្រពន្ធច្រើនជាងម្នាក់ ប៉ុន្តែពួកគេអាចបានទទួលគ្រប់ពរជ័យទាំងអស់នៅក្នុងភាពអស់កល្បជានិច្ចដែលព្រះអម្ចាស់ពុំធ្លាប់បានប្រទានដល់មនុស្សណាម្នាក់ឡើយ ។ *នៅក្នុងសម័យរបស់យើងនេះ ព្រះអម្ចាស់បានសង្ខេបដោយវិវរណៈនៃគោលលទ្ធិទាំងមូលនៃភាពតម្កើងឡើង ហើយបានផ្អែកគោលលទ្ធិនេះលើអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ជាមួយស្ត្រីម្នាក់ ។ ( គ. និង ស. ១៣២:១–២៨ )* ។ បន្ទាប់ពីលើនេះ លោកបានបន្ថែមគោលការណ៍ទាក់ទងនឹងការមានភរិយាច្រើន ដោយបង្ហាញពីលក្ខខណ្ឌជាក់លាក់ថា ការរៀបអាពាហ៍ពិពាហ៍បែបនោះមានប្រសិទ្ធិភាពបានលុះត្រាតែ ទទួលបានការអនុញ្ញាតពីប្រធានសាសនាចក្រតែប៉ុណ្ណោះ ។ ( គ. និង ស. ១៣២:៧, ២៩–៦៦ ) » ។[៤៣]

*ដ្បិតអស់អ្នកដែលនៅជាប់នឹងលក្ខខណ្ឌទាំងនោះនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនោះរង្វាន់របស់វាគឺជាសេចក្ដីអំណរ និង សេចក្ដីសុខសាន្តនៅក្នុងពិភពលោកនេះ និងជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតបន្ទាប់ ។*

សព្វថ្ងៃនេះ ដូចដែលបានដឹកនាំដោយព្រះអម្ចាស់តាមរយៈព្យាការីរបស់ទ្រង់ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពុំអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពទៀតឡើយ ហើយបុគ្គលម្នាក់ៗដែលអនុវត្តវានោះមិនត្រូវបានអនុញ្ញាតឲ្យចូលរួម ឬ ធ្វើជាសមាជិកនៃសាសនាចក្រនេះទៀតទេ ។ សាសនាចក្របញ្ជាក់ថា អាពាហ៍ពិពាហ៍ដែលមានភរិយាតែមួយគឺជាបទដ្ឋានរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍ លើកលែងតែនៅពេលមានការអនុញ្ញាត ឬ បញ្ជាដោយប្រការណាមួយតាមរយៈព្យាការីរបស់ទ្រង់ប៉ុណ្ណោះ ។ សាសនាចក្រពុំបានបង្រៀនថា ការចូលរួមក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាពគឺចាំបាច់សម្រាប់ភាពតម្កើងឡើងឡើយ ។

**សេចក្ដីបញ្ចប់**

មានអ្វីៗជាច្រើនដែលយើងពុំបានដឹងអំពីជីវិតបន្ទាប់ពីជីវិតនេះ ទោះជាយ៉ាងណាក៏ដោយ យើងដឹងយ៉ាងច្បាស់ថាការទទួល និង នៅជាប់ក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចគឺចាំបាច់សម្រាប់ការគ្រងមរតកនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ យើងក៏ដឹងផងដែរថាអស់អ្នកដែល « មានទំនាក់ទំនងនៅក្នុង

ចំណោមពួកយើងនៅទីនេះ » — នៅក្នុងជីវិតរមែងស្លាប់នេះ — « នោះក៏នឹងមាននៅក្នុងចំណោមពួកយើងនៅទីនោះ » — នៅក្នុងជីវិតបន្ទាប់ — យ៉ាងនោះដែរ « គ្រាន់តែរួបរួមដោយសិរីល្អដ៏នៅអស់កល្បជានិច្ច » ប៉ុណ្ណោះ ។[៤៤]

ពរជ័យដ៏ទេវភាពដែលអាចទទួលបានតាមរយៈសេចក្តីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចគឺ សំខាន់ចំពោះគោលបំណងដ៏ធំនៃផែនការរបស់ព្រះវរបិតា និងការស្តារឡើងវិញនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅក្នុងជំនាន់ចុងក្រោយនេះ ។ « ដោយមានការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះ »[៤៥] សេចក្តីសញ្ញាដ៏រុងរឿងនេះបំផុសគំនិតដល់អ្នកស្មោះត្រង់ ផ្តល់ « ជាយុថ្កាមួយដល់ព្រលឹងមនុស្ស ដែលនឹងធ្វើឲ្យពួកគេស្ថិតស្ថេរ នៅនឹងធឹង ហើយខ្ជាប់ខ្ជួន គឺនៅក្នុងកិច្ចការល្អដ៏បរិបូរជាដរាបដែលនាំឲ្យសរសើរតម្កើងដល់ព្រះ » ។[៤៦] ដ្បិតអស់អ្នកដែលនៅជាប់នឹងលក្ខខណ្ឌទាំងនោះនៃសេចក្តីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច នោះរង្វាន់របស់វាគឺជាសេចក្តីអំណរ និង សេចក្តីសុខសាន្តនៅក្នុងពិភពលោកនេះ និង ជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតបន្ទាប់ ។[៤៧] ■

**កំណត់ចំណាំ**

១. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩, សូមមើលផងដែរ *God Loveth His Children* ( កូនសៀវភៅ ឆ្នាំ ២០០៧ ) ទំព័រ ១ ។
២. សូមមើល រ៉ូបឺត ឌី ហែល « ផែនការនៃសេចក្តីសង្គ្រោះ ៖ A Sacred Treasure of Knowledge to Guide Us » *Liahona,* ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ៣២–៣៩ ។
៣. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៤:៧ ។
៤. សូមមើល រ៉ូបឺត ឌី ហែល « ផែនការនៃសេចក្តីសង្គ្រោះ ៖ A Sacred Treasure of Knowledge to Guide Us » ទំព័រ ៣២–៣៩ ។
៥. គោលលទ្ធិ និង សេចក្តីសញ្ញា ១:១៧, ២២ ។
៦. គោលលទ្ធិ និង សេចក្តីសញ្ញា ៦៦:២ ។
៧. សូមមើល Bible Dictionary « Covenant » ។
៨. យ៉ូសែប ហ្វីលឌិង ស្ម៊ីធ *Doctrines of Salvation* បានបោះពុម្ព ប្រូស អ័រ ម៉ាក់ខន់ឃី ភាគទី ៣ ( ១៩៥៤–៥៦ ) ១:១៥៦ ។
៩. សូមមើល យេរេមា ៣២:៤០; គោលលទ្ធិ និង សេចក្តីសញ្ញា ២២:១ ។
១០. ការគូសបញ្ជាក់ត្រូវបានបន្ថែម, សូមមើលផងដែរ គោលលទ្ធិ និង សេចក្តីសញ្ញា ៣៩:១១; ៤៥:៩; ៤៩:៩; ៨៨:១៣១, ១៣៣; ១០១:៣៩ ។
១១. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៧ ។
១២. ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ( ១៨៧៦–១៩៧២ ) បានបង្រៀន ៖ « *ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសញ្ញាគឺជាព្រះវិញ្ញាណបរិសុទ្ធ* ដែលបោះត្រាការយល់ព្រមលើគ្រប់ពិធីបរិសុទ្ធ ៖ បុណ្យជ្រមុជទឹក ពិធីបញ្ជាក់ ពិធីតែងតាំង អាពាហ៍ពិពាហ៍ ។ *ការសន្យានោះគឺថាពរជ័យនានានឹងត្រូវបានទទួលតាមរយៈភាពស្មោះត្រង់* ។ បើសិនបុគ្គលម្នាក់រំលងសេចក្តីសញ្ញាមួយ ទោះវាជាពិធីបុណ្យជ្រមុជទឹក ពិធីតែងតាំង អាពាហ៍ពិពាហ៍ ឬ ពិធីបរិសុទ្ធផ្សេងទៀតក៏ដោយក្តី នោះព្រះវិញ្ញាណនឹងដកត្រានៃការយល់ព្រមចេញ ហើយពរជ័យនានានឹងមិនបានទទួលឡើយ ។ គ្រប់ពិធីបរិសុទ្ធទាំងអស់ត្រូវបានផ្សារភ្ជាប់មកជាមួយនឹងការសន្យាមួយនៃពរជ័យដោយផ្អែកលើសេចក្តីស្មោះត្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងដកត្រានៃការយល់ព្រមចេញនៅពេលណាសេចក្តីសញ្ញាត្រូវបានរំលង » ( *Doctrines of Salvation* ១:៤៥ សូមមើលផងដែរ គោលលទ្ធិ និងសេចក្តីសញ្ញា ៧៦:៥២–៥៣; ១៣២:៧ ) ។
១៣. សូមមើល កិច្ចការ ២:៣៨; នីហ្វៃទី ២ ៣១:១៧; មរ៉ូណៃ ៨:២៥ ។
១៤. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:១៩–២១, សូមមើលផងដែរ មរ៉ូណៃ ១០:៣២–៣៣ ។
១៥. សូមមើល យ៉ូហាន ១៤:២៦; គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:៤៥–៤៦ ។
១៦. សូមមើល នីហ្វៃទី ២ ៣២:៥; នីហ្វៃទី ៣ ២៧:២០; មរ៉ូណៃ ៨:២៦; គោលលទ្ធិ និង សេចក្តីសញ្ញា ១១:១៣; ម៉ូសេ ៦:៥៩–៦១ ។
១៧. « Eternal life is God’s life, or life with God » ( ហារ៉ូល ប៊ី លី នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៥៦ ទំព័រ ៦១ ) ។ « អស់អ្នកដែលបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់វេលាកាល និង អស់ទាំងភាពអស់កល្បជានិច្ចទទួលបានពរជ័យនៃ *ជីវិតអស់កល្បជានិច្ច* ។ ខ្ញុំសង្កត់ធ្ងន់លើ *ជីវិតអស់កល្បជានិច្ច* ។ ជីវិតដ៏នៅអស់កល្បជានិច្ចគឺជាជីវិតរបស់ព្រះ នោះគឺជាជីវិតដែលដូចជាទ្រង់ » ( យ៉ូសែប ហ្វីលឌិង ស្ម៊ីធ *Answers to Gospel Questions* ចងក្រងដោយ យ៉ូសែប ហ្វីលឌិង ស្ម៊ីធ ជុញ្ញ័រ., ភាគទី ៥. [ ១៩៥៧–៦៦ ] ៤:១៩៧ ) ។
១៨. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៤:៧ ។
១៩. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៦ ។
២០. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:១៩ ។
២១. គោលលទ្ធិ និងសេចក្តីសញ្ញា ១៣២:១៩–២០ ។
២២. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:១៩–២១ ។
២៣. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៦ ។
២៤. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៥ ។
២៥. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:២១ ។
២៦. គោលលទ្ធិ និងសេចក្តីសញ្ញា ៨៤:២០–២១ ។
២៧. សូមមើល មរ៉ូណៃ ១០:៣២–៣៣ ។
២៨. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៤, ១៥ ។
២៩. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៧, ១៨ ។
៣០. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៦–៧; សូមមើលផងដែរ គោលលទ្ធិ និង សេចក្តីសញ្ញា ៦៦:២ ។
៣១. សូមកត់ចំណាំថា ជីវិតដ៏នៅអស់កល្បជានិច្ចគឺត្រូវបានបដិសេធដល់អស់អ្នកដែល « បដិសេធ » សេចក្តីសញ្ញានេះ ។ ផ្ទុយទៅវិញ អស់អ្នកដែលពុំមានឱកាសសម្រាប់អាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតនេះ នឹងត្រូវបានប្រទានឱកាសសម្រាប់អាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតបន្ទាប់ ។ សូមមើលលេខយោងទី ៣៥ ខាងក្រោមនេះ ។
៣២. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:១៥–២៥ ។
៣៣. សម្រាប់ឧទាហរណ៍បន្ថែមមួយទៀត ដើម្បីបញ្ជាក់ថាអាពាហ៍ពិពាហ៍ដែលមានភរិយា ឬ ស្វាមីតែម្នាក់ដែលត្រូវបានផ្សារភ្ជាប់សម្រាប់ភាពអស់កល្បជានិច្ច ហើយរក្សាសេចក្តីសញ្ញាដែលទាក់ទងនឹងទទួលបានភាពតម្កើងឡើង សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣១ ។
៣៤. សូមមើលប្រធានបទដំណឹងល្អ « អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » នៅគេហទំព័រ topics.lds.org ។
៣៥. « គ្មានពួកបរិសុទ្ធថ្ងៃចុងក្រោយណាម្នាក់ដែលស្លាប់ទៅ បន្ទាប់ពីបានរស់នៅយ៉ាងស្មោះត្រង់ត្រូវបាត់បង់នូវអ្វីគ្រប់យ៉ាង ដោយសារតែពុំបានធ្វើកិច្ចការជាក់លាក់មួយចំនួនព្រោះមិនបានទទួលនូវឱកាសដែលគួរត្រូវបានផ្តល់ឲ្យពួកគេនោះឡើយ ។ និយាយម្យ៉ាងទៀតថា បើសិនយុវជន ឬ យុវនារីណាម្នាក់គ្មានឱកាសរៀបអាពាហ៍ពិពាហ៍ ហើយពួកគេរស់នៅយ៉ាងស្មោះត្រង់រហូតដល់ពេលស្លាប់ នោះពួកគេនឹងទទួលនូវពរជ័យទាំងអស់នៃភាពតម្កើងឡើង និង សិរីល្អ ដូចដែលបុរស និង ស្ត្រីរាល់រូបដែលមានឱកាសនេះ ហើយបានអភិវឌ្ឍវាដែរ ។ ការណ៍នោះគឺពិតប្រាកដ ហើយមានការធានាអះអាង » ( *Teachings of Presidents of the Church: Lorenzo Snow* [ ២០១១ ] ទំព័រ ១៣០ ) ។
៣៦. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៣៤–៣៥, ៣៧–៣៩ ។
៣៧. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៣៤–៣៩ ។
៣៨. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៤០ ។
៣៩. សូមមើល សេចក្តីប្រកាសជាផ្លូវការទី ១ ។
៤០. សូមមើល យ៉ាកុប ២:២៧–៣០ ។ ទោះបីជាព្រះអម្ចាស់ពុំបានពន្យល់ពីហេតុផលទាំងអស់ចំពោះការបញ្ជា ឬ ការអនុញ្ញាតឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២ ក្តី ក៏ ព្រះអម្ចាស់បានប្រទានហេតុផលពីរយ៉ាង ៖ ( ១ ) ដើម្បីបំពេញការសន្យាស្របតាមសេចក្តីសញ្ញារបស់អ័ប្រាហាំ និង ( ២ ) « ដើម្បីបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដី » ( គ. និង ស. ១៣២:៦៣; សូមមើលផងដែរ ខ ៣៤ ) ។ យ៉ាកុប ២:៣០ ប្រហែលជាផ្តល់សេចក្តីថ្លែងការណ៍ដ៏ខ្លឹមបំផុតនៃមូលហេតុ នៅពេលខ្លះដែលព្រះអម្ចាស់បានបញ្ជាឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ៖ « ដ្បិតព្រះអម្ចាស់នៃពួកពលបរិវារទ្រង់មានព្រះបន្ទូលថា បើសិនជាយើងនឹងចិញ្ចឹមពូជមួយសម្រាប់យើង នោះយើងនឹងដាក់បញ្ញត្តិដល់រាស្ត្រយើង បើពុំនោះសោតទេគេនឹងត្រូវបុង្រស្តាប់រឿងទាំងនេះ » ។ សូមមើលផងដែរប្រធានបទដំណឹងល្អ « អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » នៅលើគេហទំព័រ topics.lds.org ។
៤១. ឆាលលេស ដ័បុលយូ ផេនរូស « Peculiar Questions Briefly Answered » *Improvement Era,* ខែ កញ្ញា ឆ្នាំ ១៩១២ ទំព័រ ១០៤២ ការគូសបញ្ជាក់បានបន្ថែម ។
៤២. នៅក្នុង ជេម អ ក្លាក ចងក្រងដោយ *សារលិខិតគណៈប្រធានទីមួយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* ភាគទី ៦. ( ឆ្នាំ ១៩៦៥–៧៥) ៥:៣២៩ ។
៤៣. ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Mormon Doctrine* បោះពុម្ពលើកទី ២ ( ឆ្នាំ ១៩៦៦ ) ទំព័រ ៥៧៨–៧៩ ការគូសបញ្ជាក់បានបន្ថែម ។ សូមមើលផងដែរ សេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ មែលវិន ជេ បាឡឺដ ( ១៨៧៣–១៩៣៩ ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « អស់អ្នកដែលពុំអាចទទួលការរីកចម្រើននៃភាពគ្មានទីបញ្ចប់ ពុំអាចក្លាយដូចជាព្រះឡើយ ដោយសារអ្វីៗដែលទាក់ទងទាំងនោះធ្វើឲ្យគាត់ក្លាយជាព្រះ ។ *ភាពអស់កល្បជានិច្ចនៃសេចក្តីសញ្ញាអាពាហ៍ពិពាហ៍ ត្រូវតែបានយល់ដឹងដោយពួកបរិសុទ្ធថ្ងៃចុងក្រោយឲ្យបានច្បាស់ថា ពួកគេត្រូវតែបានផ្សារភ្ជាប់យ៉ាងហោចណាស់ស្ត្រីម្នាក់ទៅនឹងបុរសម្នាក់ក្នុងកាលវេលា និងរហូតដល់អស់ទាំងភាពអស់កល្បជានិច្ច ។ បន្ទាប់ពីនោះសុំកុំយល់ច្រឡំនៅលើចំណុចនោះ ហើយគិតស្រមៃថាវាមានន័យយ៉ាងចាំបាច់ថាត្រូវមានស្ត្រីច្រើនជាងម្នាក់ឡើយ* ។ ពិតណាស់ប្រហែលវាអាចដូចអញ្ចឹង ប៉ុន្តែវាពិតជាមានន័យថា យ៉ាងហោចណាស់បុរស និងស្ត្រីម្នាក់ត្រូវបានផ្សារភ្ជាប់ជាមួយគ្នា ដោយអំណាចដ៏បរិសុទ្ធនៃបព្វជិតភាព និង តាមរយៈការផ្សារភ្ជាប់ដែលបានអនុញ្ញាតពីព្រះវិញ្ញាណបរិសុទ្ធក្នុងកាលវេលា និងអស់ទាំងភាពអស់កល្បជានិច្ច ហើយបន្ទាប់មកថាពួកគេរក្សាសេចក្តីសញ្ញារបស់ខ្លួន ពីមុនពួកគេអាចនឹងទទួលកម្រិតដ៏ខ្ពស់បំផុតនៃសិរីល្អសេឡេស្ទាល ហើយមានតែកូនចៅនៃព្រះវរបិតារបស់យើងបែបនេះទេដែលត្រូវបានសន្យាឲ្យទទួលបានការរីកចម្រើនដ៏គ្មានទីបញ្ចប់ ឬ អស់កល្បជានិច្ចនេះ » ( *The Three Degrees of Glory* ៖ ការថ្លែងបញ្ចេញយោបល់ ដោយ មែលវិន ជេ បាឡឺដ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩២២ ទំព័រ ១០ ការគូសបញ្ជាក់បានបន្ថែម ) ។
៤៤. គោលលទ្ធិ និង សេចក្តីសញ្ញា ១៣០:២ ។
៤៥. នីហ្វៃទី ២ ៣១:២០ ។
៤៦. អេធើរ ១២:៤ ។
៤៧. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ៥៩:២៣ ។

# « ខ្ញុំបាន ប្ដេជ្ញាចិត្ត ចំពោះព្រះ »

*សាសនាចក្រត្រូវបានបង្កើតឡើងនៅក្នុង ហ្គោយ៉ាខាណា អេក្វាឌ័រ ដោយសារមាន ការខិតខំដ៏ខ្លាំងពី វើរជីលីអូ ស៊ីម៉ារ៉ុន ដែលបាន ធ្វើការសម្រេចចិត្តដ៏លំបាកដើម្បីបន្តស្មោះត្រង់ ចំពោះទីបន្ទាល់របស់លោក ។*

**ដោយ ណេស្ទ័រ ខើរបើទ្យូ**
អ្នកប្រឹក្សាខាងប្រវត្តិសាស្ត្រសាសនាចក្រ
តំបន់ខាងត្បូងនៃអាមេរិកខាងត្បូង

វើរជីលីអូ ស៊ីម៉ារ៉ុន សាលាស្សា គឺជាអ្នកដឹកនាំម្នាក់ក្នុងតំបន់ ឆាឈីដែលជាសហគមន៍កំណើតរបស់លោកនៅប្រទេស អេក្វាឌ័រ ភាគខាងជើង ។ មកដល់សព្វថ្ងៃនេះ តំបន់ឆាឈី រក្សារបៀបពិសេសនៃជីវិតរបស់ពួកគេ ព្រមទាំងប្រព័ន្ធយុត្តិធម៌ផ្ទាល់របស់ពួកគេជាមួយនឹងក្រុមប្រឹក្សាឃុំ អភិបាល និង តុលាការ ។ ជាទូទៅ តួនាទីនៃថ្នាក់ដឹកនាំទាំងនេះគឺជាមុខងារដ៏មានកិត្តិយស ដល់ក្រុមគ្រួសារដែលបន្តកាន់តំណែងជាច្រើនជំនាន់ ហើយដែលត្រូវបានស្ថាបនាឡើងលើគោលការណ៍ដ៏ស៊ីជម្រៅមួយនៃការគោរព និងការកោតសរសើរពីសហគមន៍ ។ ការគោរពដល់មុខតំណែងគឺជាទំនុកចិត្តមួយដែលត្រូវយកចិត្តទុកដាក់ ហើយបន្តទៅដល់ជំនាន់ក្រោយៗទៀត ។

ប៉ុន្តែផែនការរបស់វើរជីលីអូ ស៊ីម៉ារ៉ុន សម្រាប់ជីវិតរបស់គាត់ត្រូវបានផ្លាស់ប្ដូរនៅឆ្នាំ ១៩៩៦ នៅពេលកូនប្រុសរបស់គាត់ វិលសុន បានត្រឡប់ពីការសិក្សានៅ គ្វីនីនដេ ដោយមានព្រះគម្ពីរមរមន ព្រមទាំងទីបន្ទាល់ដ៏រឹងមាំអំពីសាសនាថ្មីរបស់គាត់ ។ ពោរពេញដោយសេចក្ដីជំនឿ និង ការរំភើបរបស់មនុស្សម្នាក់ដែលបានរកឃើញសេចក្ដីពិត វិលសុន បានចែកចាយសារលិខិតនៃដំណឹងល្អជាមួយគ្រួសារខ្លួន ហើយពួកគេបានជ្រមុជទឹកភ្លាមនៅក្នុងទឹកទន្លេ កាណានដេ ។

នៅពេល ស៊ីម៉ារ៉ុនបានចែកចាយដំណឹងល្អជាមួយមិត្តភក្ដិ និងអ្នកជិតខាងនៅតំបន់ ឆាឈីនោះបណ្ដាលឲ្យមានជម្លោះដ៏ខ្លាំងក្លាមួយបានកើតមានឡើង ។ មនុស្សនៅក្នុងតំបន់ ឆាឈីនោះមានអារម្មណ៍ថា ជំនឿរបស់វើរជីលីអូ ស៊ីម៉ារ៉ុន បានធ្វើឲ្យគាត់ក្លាយជាជនមានជំនឿក្លែងក្លាយ ហើយថែមទាំងគិតចង់ធ្វើបាបលោកទៀតផង ។ មនុស្សផ្សេងទៀតយល់ថា ក្នុងនាមជាអភិបាលម្នាក់ លោកពុំគួរចូលរួមក្នុងជំនឿសាសនាថ្មីដែលអាច



*តាមរយៈកិច្ចការផ្សព្វផ្សាយសាសនារបស់គ្រួសារស៊ីម៉ារ៉ុន នោះមនុស្ស ៦០ នាក់បានទទួលបុណ្យជ្រមុជទឹកនៅក្នុងទន្លេ កាណានដេ ខែ ឧសភា ឆ្នាំ ១៩៩៩ ។*

ធ្វើឲ្យប្រជាជនមានការបែងចែកបក្សពួកឡើយ ។ ដោយសារកង្វល់នេះ នោះពួកគេបានយកគាត់ទៅជំនុំជម្រះនឹងក្រុមប្រឹក្សាឃុំ ។ វាគឺជាបទពិសោធន៍មួយដ៏លំបាកបំផុតនៅក្នុងជីវិតរបស់ ផីរជីលីអូ ។

វិលសុនបាននិយាយពីអ្វីដែលបានកើតឡើង ៖ « ក្រុមប្រឹក្សាទាំងមូល បានប្រាប់ឪពុកខ្ញុំថា ‹ អ្នកនឹងនៅតែបន្តធ្វើជាអភិបាលរបស់យើងទៀត បើសិនអ្នកបោះបង់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនោះចោល អ្នកត្រូវតែដកពាក្យសម្ដីរបស់អ្នកវិញទៅ › ។ ឪពុករបស់ខ្ញុំបាននិយាយថា ‹ ខ្ញុំបានប្ដេជ្ញាចិត្តចំពោះព្រះ ហើយនៅពេលមនុស្សម្នាក់បានធ្វើការតាំងចិត្តចំពោះព្រះ នោះការតាំងចិត្តនោះពុំអាចប្រែក្រឡាស់វិញបានទេ ។ ខ្ញុំពុំអាចបោះបង់សាសនាចក្រចោលបានឡើយ ។ បើសិនអ្នកគិតថាខ្ញុំគឺជាអភិបាលម្នាក់ដែលបានធ្វើឲ្យប្រជាជន ឆាលឈីបាក់បែកគ្នានោះ ឱ បងប្អូនទាំងអស់របស់ខ្ញុំអើយ សូមបងប្អូនជ្រើសរើសមនុស្សម្នាក់ទៀតជំនួសតំណែងខ្ញុំក្នុងថ្ងៃនេះចុះ › ។ បន្ទាប់មកខ្ញុំបានឃើញឪពុកខ្ញុំយំ ។ ក្រុមប្រឹក្សានោះនៅស្ងៀមឈឹងអស់ពេលជាងប្រាំនាទី — ដោយគ្មាននរណាម្នាក់និយាយអ្វីឡើយ ។ បន្ទាប់មកមានម្នាក់បាននិយាយថា ‹ អញ្ជើញសូមលោកអភិបាល ដើរចេញទៅ › ។ ឪពុកខ្ញុំបានក្រោកឈរឡើងយឺតៗ ទាំងម្ដាយ បងស្រីខ្ញុំ និង ខ្ញុំបានដើរចេញទៅ ហើយចាកចេញពីក្រុមប្រឹក្សានោះ » ។

បន្ទាប់ពីបងប្រុស ស៊ីម៉ារ៉ុនត្រូវបានដកហូតចេញពីតំណែងរបស់ខ្លួនមក នោះមានការលំបាកជាច្រើនបានធ្លាក់មកលើគ្រួសារលោក ។ ដោយមានអារម្មណ៍ពីការមិនចូលចិត្តពីមនុស្សជាច្រើន ដែលធ្លាប់តែគោរពពួកគេ នោះក្រុមគ្រួសារនេះបានបែរទៅរកសេចក្ដីជំនឿដែលពួកគេបានទទួលយក និង ផ្សព្វផ្សាយដំណឹងល្អដោយការតាំងចិត្តដ៏មុតមាំ ។ ប្រធានស្ដេករបស់ពួកគេ អូម៉ា អ៊ីនក្រាយអាហ្គោសេសា ពន្យល់ ៖ « ពួកគេបានចាប់ផ្ដើមផ្សព្វផ្សាយដំណឹងល្អពីផ្ទះមួយទៅផ្ទះមួយទៀត ដល់គ្រួសារនិមួយៗក្នុងសហគមន៍នេះ ។ សាខា ហ្គោយ៉ាខាណាណ បានចាប់ផ្ដើមជាមួយនឹង ផីរជីលីអូ ស៊ីម៉ារ៉ុន និង កូនប្រុសរបស់លោកឈ្មោះ វិលសុន ។ សាសនាចក្រត្រូវបានស្ថាបនាឡើងដោយសារតែសេចក្ដីជំនឿ កម្លាំង និង ទីបន្ទាល់របស់លោក » ។

គ្រាន់តែរយៈពេលពីរបីឆ្នាំប៉ុណ្ណោះ កិច្ចខិតខំរបស់គ្រួសារ ស៊ីម៉ារ៉ុន បានទទួលផ្លែផ្កាយ៉ាងអស្ចារ្យ ។ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៩ គឺជាថ្ងៃប្រារព្ធពីធីបុណ្យជ្រមុជទឹកដ៏ធំមួយនៅហ្គោយ៉ាខាណា ។ ប្រធាន អ៊ីនក្រាយអាហ្គោ បានប្រាប់ថា « យើងបានទៅដល់ទីនោះជាមួយប្រធានបេសកកម្ម រ៉ូប៊ើតូ ហ្គាសៀ ហើយយើងទាំងពីរនាក់បានចូលរួមនៅក្នុងថ្ងៃដ៏រុងរឿងនោះ ដែលនៅលើឆ្នេរនៃទន្លេ កាណានដេ មានអ្នកផ្សព្វផ្សាយសាសនាពីរនាក់ជ្រមុជទឹកមនុស្ស៦០នាក់ ។ បន្ទាប់មកប្រធាន ហ្គាសៀ និង ខ្ញុំឈរម្ខាងម្នាក់ធ្វើពិធីបញ្ជាក់ដល់អស់អ្នកដែលបានជ្រមុជទឹកហើយនោះជាសមាជិកនៃសាសនាចក្រ ។ វាគឺជាឯកសិទ្ធិមួយដែលខ្ញុំនឹងមិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់ខ្ញុំឡើយ » ។

ទោះបីជា ផីរជីលីអូ បានបោះបង់តំណែងជាអភិបាលរបស់លោក ដើម្បីបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់ខ្លួនក្ដី ក៏លោកអាចបន្តមរតកមួយផ្សេងទៀតដល់ជំនាន់ក្រោយៗ ៖ នោះគឺការបម្រើមនុស្សដោយការស្ថាបនាដំណឹងល្អនៅក្នុងចំណោមពួកគេ ។ លោកបានរស់នៅឃើញ វិលសុន បម្រើបេសកកម្មពេញម៉ោង ហើយបន្ទាប់មកបានត្រឡប់មកហ្គោយ៉ាខាណា វិញរៀបការជាមួយនឹង រុស ហើយមានកូនជាច្រើននាក់ ។ ជាច្រើនឆ្នាំក្រោយមក ផីរជីលីអូ បានទទួលមរណភាពទាំងភក្ដីភាពចំពោះសាសនាចក្រ ។ ភរិយារបស់លោក លោកស្រីម៉ារៀ ជូណា អាប៉ា បានរស់នៅឃើញការហៅបម្រើរបស់កូនប្រុសខ្លួននៅឆ្នាំ ២០១៤ បម្រើជាប្រធានសាខានៅហ្គោយ៉ាខាណា ។

វិលសុន ដឹងយ៉ាងច្បាស់ពីកេរមរតកដែលឪពុករបស់ខ្លួនចង់ឲ្យលោកមានជានិច្ច ។ លោកនិយាយថា « ជីដូនជីតារបស់ខ្ញុំសុទ្ធតែធ្លាប់ធ្វើជាអភិបាលមេបញ្ជាការទាហាន ពលទាំពដ៏ខ្លាំង » ។ « ខ្ញុំមានអារម្មណ៍ថាលក្ខណៈដែលជីដូនជីតាទាំងអស់របស់ខ្ញុំមាន គឺវានៅតែមាននៅក្នុងខ្លួនខ្ញុំ ។ ឥឡូវនេះ ខ្ញុំជាសមាជិកសាសនាចក្រម្នាក់ ភាពរឹងមាំទាំងអស់នោះបានជួយខ្ញុំឲ្យក្លាយជាទាហានដ៏ល្អម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ » ។ ■






*ខាងលើ ៖ អ្នកដឹកនាំជំនាន់ថ្មី រុស និង វិលសុន ស៊ីម៉ារ៉ុននៃសាខាហ្គោយ៉ាខាណា ( ជាមួយសមាជិកសាខានៅខាងឆ្វេងដៃ ) ។*



**ដោយអែលឌើរ**
**ឌី ថត គ្រីស្តូហ្វឺសិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ចូរមាន សេចក្ដីសុខសាន្តចុះ

*ខ្ញុំសង្ឃឹមថាអ្នកនឹងឆ្លៀតយកឱកាសបុណ្យគ្រីស្ទម៉ាស់នេះ អង្គុយយ៉ាងស្ងប់ស្ងាត់មួយស្របក់ ហើយទុកឲ្យព្រះវិញ្ញាណរបស់ព្រះអង្គសង្គ្រោះលួងលោមអ្នក ហើយធានាដល់អ្នកអំពីភាពសក្តិសមនៃការបម្រើ ការថ្វាយ និង ជីវិតរបស់អ្នក ។*

វាតែងតែលើកទឹកចិត្តដល់ខ្ញុំនៅពេលខ្ញុំសញ្ជឹងអំពីការថ្វាយដោយការបម្រើ និង ការធ្វើពលិកម្មដែលពួកបរិសុទ្ធថ្ងៃចុងក្រោយបានធ្វើចំពោះគ្រួសារ វួដ និង ចំពោះព្រះវរបិតាសួគ៌របស់ពួកគេ ។ វាគឺជាការថ្វាយមួយ ជារឿងដ៏ពិសិដ្ឋមួយ ។ ខ្ញុំពុំជឿថាមានកិត្តិយសណាដែលប្រសើរជាងនេះដែលអាចផ្ដល់ដល់យើង ជាងការដែលព្រះអម្ចាស់ចាត់ទុកការថ្វាយរបស់យើងថាសក្តិសម ហើយសមរម្យ ព្រមទាំងថាទ្រង់នឹងគោរព និង ទទួលវាឡើយ ។

នេះគឺជាការសរសើរដ៏អស្ចារ្យមួយរបស់ព្រះវរបិតាចំពោះព្រះរាជបុត្រា នៅពេលទ្រង់ហៅព្រះបុត្រាទ្រង់ថាជា « បុត្រាដ៏ជាទីស្រលាញ់របស់យើង ដែលយើងគាប់ចិត្តណាស់ » ( នីហ្វៃទី ៣ ១១:១៧; សូមមើលផងដែរ ម៉ាថាយ ៣:១៧; ម៉ាកុស ១:១១; លូកា ៩:៣៥; គ. និង ស. ៩៣:១៥; យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:១៧ ) ។ នោះគឺជាព្រះនាមដ៏អស្ចារ្យអ្វីម្ល៉េះ ។ ឱ វាជាកិត្តិយសដ៏ប្រសើរអ្វីម្ល៉េះ ដែលព្រះនឹងមានបន្ទូលមកអ្នកថា « បុត្រាដ៏ជាទីស្រលាញ់របស់យើងអើយ » ឬ « បុត្រីដ៏ជាទីស្រលាញ់របស់យើងអើយ » ហើយថាអ្នកនឹងទទួលបានការកោតសរសើរពីទ្រង់ ថាទ្រង់ទទួលយកការថ្វាយរបស់អ្នក « ដែលយើងគាប់ចិត្តណាស់ » ។

ខ្ញុំសូមអធិស្ឋាននៅក្នុងឱកាសបុណ្យគ្រីស្ទម៉ាស់នេះថា អ្នកអាចមានអារម្មណ៍នៃការកោតសរសើររបស់ព្រះអម្ចាស់សម្រាប់ការថ្វាយរបស់អ្នក អារម្មណ៍ដែលថាអ្នកមានតម្លៃក្នុងព្រះនេត្រទ្រង់ អារម្មណ៍នៃស្ថានភាពនៃក្ដីស្រឡាញ់ដែលអ្នកជាបុត្រា ឬ បុត្រីរបស់ទ្រង់ ។ ហើយខ្ញុំសូមអធិស្ឋានថាចំណេះដឹងនៃស្ថានភាពនោះអាចផ្ដល់ដល់អ្នកនូវការលួងលោម ការធានាអះអាង និង ទំនុកចិត្តដ៏អស្ចារ្យមួយ ដែលថាអ្នកត្រូវបានទទួលយកនៅក្នុងព្រះនេត្រទ្រង់ ។





**អំណោយនៃសេចក្តីសុខសាន្តរបស់ព្រះអង្គសង្គ្រោះ**

« ទ្រង់ជាមនុស្សទុទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់ ដល់អស់អ្នកដែលមានដួងចិត្តខ្វាយខ្វល់ ហើយប្រទានអំណោយទាននៃសេចក្តីសុខសាន្ត ។ ‹ ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ ។ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ › [ យ៉ូហាន ១៤:២៧ ] » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « **Treasured Gifts** » *Liahona*, ខែ ធ្នូ ឆ្នាំ ២០០៦ ទំព័រ ៥ ។

**កំណើតរបស់ព្រះអង្គសង្គ្រោះ**

នៅពេលយើងនិយាយអំពីកំណើតរបស់ព្រះយេស៊ូវគ្រីស្ទ យើងប្រហែលជាគិតអំពីអ្វី ដែលបានកើតឡើងបន្ទាប់ទៀត ។ កំណើតរបស់ទ្រង់អស្ចារ្យបំផុត ដោយសារអ្វីដែលទ្រង់បានជួប និង រងទុក្ខ ដូច្នេះទ្រង់អាចជួយយើងបានកាន់តែប្រសើរ — អ្វីៗទាំងអស់ត្រូវបានបញ្ចប់នៅក្នុងការឆ្កាង និង ការរស់ឡើងវិញរបស់ទ្រង់ ( សូមមើល អាលម៉ា ៧:១១–១២ ) ។ ប៉ុន្តែបេសកកម្មរបស់ទ្រង់ក៏រួមមាននូវការបម្រើ អព្ភូតហេតុនៃកិច្ចការបម្រើរបស់ទ្រង់ អារម្មណ៍ធូរស្បើយដែលទ្រង់បាននាំមកដល់អ្នករងទុក្ខ និង សេចក្តីអំណរដែលទ្រង់បានប្រទានឲ្យ — និងនៅតែប្រទានឲ្យ — ដល់អស់អ្នកដែលទូញយំ ។

ខ្ញុំក៏ចូលចិត្តគិតពីអ្វីដែលនឹងកើតឡើងបន្ទាប់ទៀតផងដែរ ។ ខគម្ពីរពីរដែលខ្ញុំចូលចិត្ត ដែលរៀបរាប់ពីពេលវេលានោះ មាននៅចុងបញ្ចប់នៃជំពូកទី ៧ នៅក្នុងគម្ពីរវិវរណៈ ។

« គេនឹងមិនឃ្លាន ឬស្រេកទៀត ក៏មិនត្រូវថ្ងៃចាំងមកលើគេ ឬចំហាយណាទៀតឡើយ ។

« ពីព្រោះកូនចៀមដែលនៅកណ្តាលបល្ល័ង្ក ទ្រង់នឹងឃ្វាល ហើយនាំគេ ទៅដល់រន្ធទឹកនៃជីវិត ហើយព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែកគេចេញ » ( វិវរណៈ ៧:១៦–១៧; សូមមើល ផងដែរ ២១:៤ ) ។

នោះវាធ្វើឲ្យខ្ញុំចាប់បានសេចក្តីសង្ឃឹមដ៏ពិសិដ្ឋពីអ្វីដែលនឹងកើតឡើង ពីអ្វីដែលវានឹងប្រែក្លាយអំឡុងពេលសហស្សវត្សរ៍ដ៏អស្ចារ្យ ហើយការសោយរាជ្យនៃគរសេឡេស្ទាលរបស់ព្រះគ្រីស្ទដែលនឹងកើតឡើង ។

ជាមួយនឹងអ្វីៗដែលនឹងកើតឡើង នោះខ្ញុំគិតថាវាគឺជាពេលដ៏សមរម្យនៃឆ្នាំនេះដើម្បីគិតពីទារកតូចនៅក្នុងស្នូកនោះ ។ សូមកុំគិតពីអ្វីដែលស្មុគស្មាញ ឬ អ្វីផ្សេងទៀតដែលនឹងកើតឡើងឡើយ សូមគិតតែពីទារកតូចនោះប៉ុណ្ណោះ ។ សូមឆ្លៀតពេលដ៏មានភាពសុខសាន្តបន្តិចដើម្បីគិតពីការចាប់ផ្តើមនៃព្រះជន្មរបស់ទ្រង់ — គឺជាអ្វីដែលបានបញ្ចប់នៃការព្យាករណ៍សួគ៌ា ប៉ុន្តែគឺជាការចាប់ផ្តើមនៃជីវិតផែនដីរបស់ទ្រង់ ។

សូមឆ្លៀតពេលសម្រាក ចូរមានសេចក្តីសុខសាន្តចុះ ហើយសូមមើលព្រះឱរសតូចនេះនៅក្នុងចិត្តអ្នកចុះ ។ សូមកុំព្រួយបារម្ភ ឬស្មុគស្មាញខ្លាំងពេកជាមួយអ្វីដែលនឹងកើតឡើងនៅក្នុងជីវិតរបស់ទ្រង់ ឬ ជីវិតរបស់អ្នកឡើយ ។ ផ្ទុយទៅវិញ សូមឆ្លៀតពេលនៃភាពសុខសាន្តដើម្បីសញ្ជឹងពីឱកាសដ៏ស្ងប់ស្ងាត់បំផុតនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក — នៅពេលពលទ័ពនៃឋានសួគ៌រីករាយនឹងសារលិខិត « សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ » ( លូកា ២:១៤ ) ។

**ចូរឲ្យព្រះវិញ្ញាណលួងលោមអ្នកចុះ**

ប៉ុន្មានឆ្នាំមុន ខ្ញុំបានស្តាប់ការសម្ភាសន៍តាមវិទ្យុពិសេសមួយរបស់ប៊ីស្សព ដេសម៉ុន ទូទូ ជាប្រធានអាចារ្យនៃសាសនាអង់គ្លីកង់ នៅអាហ្វ្រិកខាងត្បូង ។ គាត់បានចេញផ្សាយសៀវភៅមួយក្បាលជាមួយនឹងកូនស្រីរបស់ខ្លួនអំពីការផ្សះផ្សារគ្នាដែល



បានកើតឡើងនៅអាហ្វ្រិកខាងត្បូង បន្ទាប់ពីមានការបែងចែកពូជសាសន៍ ។[1] ពិតណាស់ សារលិខិតនៅក្នុងសៀវភៅនោះគឺថាមានចំណុចល្អៗនៅក្នុងមនុស្សគ្រប់រូប ។

អំឡុងពេលសម្ភាសពិធីករបានសួរសំណួរដែលរសើប ដ៏បំផុសគំនិតមួយដល់ប៊ីស្សព ទូទូ ៖ « តើលោកបានឃើញទេថាទំនាក់ទំនងរបស់លោកចំពោះព្រះបានផ្លាស់ប្តូរនៅពេលលោកកាន់តែចម្រើនវ័យដែរឬទេ ? »

ប៊ីស្សព ទូទូ ឈប់មួយសន្ទុះ ហើយឆ្លើយថា « បាទ » ។ ខ្ញុំកំពុងរៀនឲ្យមានភាពស្ងប់ស្ងាត់នៅក្នុងវត្តមានរបស់ព្រះ » ។

គាត់បាននិយាយថា នៅពេលគាត់បានអធិស្ឋានកាលពីប៉ុន្មានឆ្នាំ មុននោះ គាត់បានធ្វើវាដោយមានបញ្ជីស្នើសុំ និងកង្វល់ផ្សេងៗ ។ គាត់បានឈោងទៅរកឋានសួគ៌ជាមួយអ្វីដែល

ដកស្រង់ចេញពី *ព្រះគ្រីស្ទព្យាបាលអ្នកខ្វាក់ភ្នែក* ដោយ ជូវ៉ែនរីកូ ប៊ូអាំសែលវូ ទេពាលមុខផ្តល់ដោយ JOHN AND MABLE RINGLING MUSEUM OF ART; ស្តាំ ៖ *មេរីដល់សុខសាន្ត* ដោយ ខាល ហេនរិក ប្លូ



សូមឆ្លៀតពេលនៃភាពសុខសាន្ត ដើម្បីសញ្ជឹងគិតពីឱកាសដ៏ស្ងប់ស្ងាត់បំផុតនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក — នៅពេលពលទ័ពនៃឋានសួគ៌រីករាយនឹងសារលិខិត « សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដី នៅកណ្ដាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ » ។

គាត់ហៅថា « បញ្ជីទិញទំនិញមួយបែប » ។ ប៉ុន្តែឥឡូវនេះគាត់និយាយថា « ខ្ញុំគិតថា [ ខ្ញុំកំពុង ] ព្យាយាមខិតកាន់តែជិតទ្រង់ ។ ដូចជាពេលអ្នកអង្គុយនៅមុខឡកំដៅនៅរដូវរងា អ្នកអង្គុយនៅទីនោះគឺនៅមុខភ្លើង ហើយអ្នកមិនចាំបាច់ឆ្លាត ឬ ពូកែអ្វីឡើយ ។ ភ្លើងនោះ នឹងធ្វើឲ្យអ្នកកក់ក្ដៅ » ។[២]

ខ្ញុំគិតថានោះគឺជារឿងប្រៀបធៀបមួយដ៏អស្ចារ្យ — គឺអង្គុយជាមួយព្រះអម្ចាស់ ហើយឲ្យទ្រង់លួងលោមអ្នកដូចជាឡកំដៅនៅក្នុងរដូវរងាអញ្ចឹងដែរ ។ អ្នកមិនចាំបាច់ត្រូវតែល្អឥតខ្ចោះ ឬ ជាមនុស្សដែលអស្ចារ្យបំផុតដែលរស់នៅលើផែនដីនេះទេ ឬ អ្នកត្រូវតែពូកែខាងអ្វីមួយដើម្បីនៅជាមួយទ្រង់ឡើយ ។

ខ្ញុំសង្ឃឹមថាអ្នកនឹងឆ្លៀតយកឱកាសនៃបុណ្យគ្រីស្ទម៉ាស់នេះ អង្គុយស្ងប់ស្ងាត់មួយស្របក់ ហើយទុកឲ្យព្រះវិញ្ញាណរបស់ព្រះអង្គសង្គ្រោះលួងលោមអ្នក ហើយធានាដល់អ្នកអំពីភាពសក្ដិសមនៃការបម្រើ ការថ្វាយ ជីវិតរបស់អ្នក ។ សូមអង្គុយដោយស្ងប់ស្ងាត់ជាមួយព្រះឱរសតូចនោះ ហើយបន្សល់ទុកភាពរឹងមាំខាងវិញ្ញាណ និង ការរៀបចំកាន់តែប្រសើរសម្រាប់អ្វីៗទាំងអស់ដែលនឹងកើតឡើងពេលក្រោយទៀត ។ ចូរឲ្យឱកាសនោះក្លាយជាពេលមួយនៃការសម្រាក ដួងចិត្តស្រស់ថ្លា ព្រមទាំងបានទទួលការអះអាង និង ការខំប្រឹងជាថ្មី ។

ព្រះប្រទានពរជ័យដល់អ្នកនាបុណ្យគ្រីស្ទម៉ាស់នេះ នៅពេលអ្នក ជាមួយនឹងខ្ញុំថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ — ទ្រង់មានសារៈសំខាន់ចំពោះយើង ចំពោះមនុស្សទាំងអស់ និង ចំពោះគោលបំណងដ៏ច្បាស់លាស់នៃជីវិតនេះ ។

យើងថ្វាយបង្គំទ្រង់ យើងបម្រើទ្រង់ ហើយយើងស្រឡាញ់ទ្រង់ ។ សូមឲ្យជីវិតរបស់អ្នកឆ្លុះបញ្ចាំងពីសេចក្ដីស្រឡាញ់នោះតាមរយៈការថ្វាយរបស់អ្នកក្នុងរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ និង រហូតតទៅ ។ ■

កំណត់ចំណាំ

១. ដេសម៉ុន ទូទូ និង ហ្វូ ទូទូ *Made for Goodness: And Why This Makes All the Difference* ( ឆ្នាំ ២០១១ ) ។

២. ដេសម៉ុន ទូទូ នៅក្នុង « Desmond Tutu, Insisting We Are ‹Made for Goodness› » ( ការសម្ភាសន៍ NPR ដោយ Renee Montagne ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០១០ ) គេហទំព័រ npr.org ។

# រត់ទៅព្រះវិហារបរិសុទ្ធ

កាលពីខែ ធ្នូ ឆ្នាំ ១៩៩៩ យើងបានរៀបចំខ្លួនសម្រាប់ការធ្វើដំណើរប្រចាំឆ្នាំសម្រាប់បុណ្យគ្រីស្ទរបស់យើងទៅព្រះវិហារបរិសុទ្ធ ប៊ឺន ប្រទេសស្វីស ។ ការធ្វើដំណើរនោះគឺជាប្រពៃណីពិសេសមួយ ដែលយើងបានចាប់ផ្ដើមធ្វើវាមិនយូរប៉ុន្មានបន្ទាប់ពីអាពាហ៍ពិពាហ៍របស់យើង គឺជារបៀបមួយដែលយើងរំឭកដល់ការប្រសូតរបស់ព្រះអង្គសង្គ្រោះ ។

ពីកន្លែងដែលយើងនៅទៅដល់ព្រះវិហារបរិសុទ្ធត្រូវចំណាយពេលប្រាំបីម៉ោងដោយជិះឡាន ហើយយើងបានចាប់ផ្ដើមចេញដំណើរ ដោយមានអាកាសធាតុមិនអំណោយផលឡើយនៅពេលនោះ ។ ដើមឈើដួលរលើងគល់ ខ្យល់បក់ខ្លាំង មានទឹកកកនៅលើផ្លូវអាចធ្វើឲ្យការធ្វើដំណើរមានគ្រោះថ្នាក់ ។

ខ្ញុំបានមានអារម្មណ៍ថាពុំប្រាកដប្រជា ហើយពុំយល់ពីមូលហេតុដែលយើងជួបនូវឧបសគ្គដ៏ច្រើនបែបនេះ នៅពេលយើងដឹងថាព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងទៅព្រះវិហារបរិសុទ្ធ ។ តើទ្រង់នឹងពុំបើកផ្លូវឲ្យយើងទេឬ ?

ស្វាមីរបស់ខ្ញុំ អែនតូនីអូ និង ខ្ញុំបានលុតជង្គង់អធិស្ឋានជាមួយកូនៗ ហើយទូលទៅកាន់ព្រះវរបិតាសួគ៌ថាលុះត្រាតែទ្រង់ប្រាប់យើងអ្វីផ្សេងទៀត មិនដូច្នេះទេយើងនឹងធ្វើដំណើរទៅទីក្រុង ប៊ឺន នៅថ្ងៃស្អែក ។

អែនតូនីអូ បាននិយាយបន្ទាប់ពីការអធិស្ឋានរបស់យើងថា « បើសិនជាផ្លូវពិបាកធ្វើដំណើរ នោះយើងនឹងត្រឡប់មកវិញ » ។

ខ្ញុំមានអារម្មណ៍ថាការសម្រេចចិត្តរបស់យើងនោះគឺត្រឹមត្រូវណាស់ ប៉ុន្តែខ្ញុំនៅតែភ័យខ្លាច ។ នៅព្រឹកបន្ទាប់ទៀតដោយនៅតែមានចម្ងល់ខ្ញុំចង់អធិស្ឋានម្ដងទៀត ។ អែនតូនីអូបានប្រាប់ខ្ញុំថាយើងបានទទួលចម្លើយរួចហើយ ប៉ុន្តែគាត់បានលុតជង្គង់ដោយសេចក្ដីស្រឡាញ់ និង អត់ធ្មត់នៅក្បែរខ្ញុំ ។

នៅពេលយើងចេញពីផ្ទះ នោះព្រះអាទិត្យរៀបនឹងរះ ហើយពពកខ្មៅបានសំកាំងនៅលើពួកយើង ។ នៅពេលយើងបើកបរនោះ ខ្ញុំអាចឃើញតែផ្ទៃមេឃពណ៌ខៀវបន្តិចបន្តួចប៉ុណ្ណោះនៅជិតភ្នំ ។ ព្រះអាទិត្យចាំងរស្មីព្រាលៗកាត់ដុំពពកទាំងនោះ ។

ពន្លឺព្រឹមៗរបស់ព្រះអាទិត្យនោះបានពង្រឹងសេចក្ដីជំនឿដែលរេរារបស់ខ្ញុំ ។ ជាអព្ភូតហេតុព្រះអាទិត្យបានលេចមក ហើយសីតុណ្ហភាពបានកើនឡើង ។ គ្មានអ័ព្ទ គ្មានទឹកកក គ្មានខ្យល់ — វាស្រទន់ ហើយក្លាយជាថ្ងៃមួយដែលមានកម្ដៅល្មមនារដូវរងារ ។ ខ្ញុំបានយំ ។ វាហាក់បីដូចជាព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់យើង ។

បន្ទាប់ពីយើងបានទៅដល់ទីក្រុង ប៊ឺន វាបានចាប់ផ្ដើមធ្លាក់ព្រិលយ៉ាងខ្លាំង ហើយបន្តធ្លាក់ព្រិលអស់មួយរយៈពេលដែលយើងស្នាក់នៅទីនោះ ។ នៅពេលយើងបានដើរទៅព្រះវិហារបរិសុទ្ធពីមុនព្រះអាទិត្យរះនៅព្រឹកបន្ទាប់នោះ ព្យុះបានក្លាយជាព្យុះព្រិលយ៉ាងខ្លាំង ។ ខ្ញុំមានការភ័យខ្លាចមួយសន្ទុះ ហើយខ្ញុំបានចាប់ផ្ដើមរត់តាមផ្លូវសម្រាប់អ្នកថ្មើរជើង រហូតដល់ព្រះវិហារបរិសុទ្ធ ។

បន្ទាប់មកមានគំនិតមួយបានផុសឡើងក្នុងចិត្តខ្ញុំ ៖ « នេះគឺជាអ្វីដែលគួរតែធ្វើ ។ ពិភពលោកនេះមានសម្រែក



នៃបញ្ហានានាដល់យើង ប៉ុន្តែយើងត្រូវតែត់ទៅកន្លែងសុខសាន្តរបស់ព្រះអម្ចាស់ដែលមាននៅក្នុងព្រះដំណាក់របស់ទ្រង់ » ។

យើងមានភាពរីករាយជាខ្លាំង អំឡុងពេលនៅព្រះវិហារបរិសុទ្ធនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់នោះ ប៉ុន្តែយើងបារម្ភអំពីការធ្វើដំណើរត្រឡប់ទៅផ្ទះវិញរបស់យើង ។ ព្រិលនៅតែបន្តធ្លាក់ ហើយកូនប្រុសពៅរបស់យើងបានក្តៅខ្លួនយ៉ាងខ្លាំង ។ ទោះជាយ៉ាងណានៅថ្ងៃដែលយើងចេញដំណើរ ព្រិលនោះបានឈប់ធ្លាក់ដោយអព្ភូតហេតុ ហើយកម្តៅក្នុងខ្លួនកូនប្រុសរបស់យើងបានបាត់វិញបន្ទាប់ពីបានទទួលការប្រសិទ្ធពរនៃបព្វជិតភាព ។

ខណៈភាពសុខសាន្តនៃព្រះវិហារបរិសុទ្ធបានផ្តល់ដល់យើង នោះខគម្ពីរព្រះគម្ពីរប៊ីបមួយបានផុសក្នុងគំនិតខ្ញុំ ៖ « តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើតដែរឬអី ? » ( លោកុប្បត្តិ ១៨:១៤ ) ។ ដោយមានអំណរគុណ នោះខ្ញុំបានដឹងថា គ្មានទេ គ្មានអ្វីដែលទ្រង់មិនអាចធ្វើបាននោះឡើយ ។ ■

អែនតូនេឡា ត្រេវីសាន អ៊ុយឌីន ប្រទេស អ៊ីតាលី



នៅពេលយើងបានដើរទៅព្រះវិហារបរិសុទ្ធពីមុន ព្រះអាទិត្យរះនៅព្រឹកបន្ទាប់នោះ ព្យុះបានក្លាយជាព្យុះព្រិលយ៉ាងខ្លាំង ។

# អព្ភូតហេតុនៃបុណ្យគ្រីស្ទម៉ាស់របស់ខ្ញុំ

អំឡុងពេលនៃរដូវស្លឹកឈើជ្រុះ ឆ្នាំ ១៩៦៨ បីស្សពរបស់យើងបានសួរឪពុកម្តាយរបស់ខ្ញុំ បើសិនពួកគេយល់ព្រមបរិច្ចាគប្រាក់ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ប្រូវ៉ូ យូថាហ៍ ។ វួដផ្សេងពុំធ្វើដូច្នេះឡើយក្នុងសម័យយើងនេះ ប៉ុន្តែសម័យនោះគឺគេធ្វើដូច្នេះ ។ ឪពុកខ្ញុំបានយល់ព្រមបរិច្ចាគ ១០០០ ដុល្លារអាមេរិក ។ ទឹកប្រាក់នោះហាក់បីដូចជាពុំច្រើនឡើយ ប៉ុន្តែសម្រាប់ពួកយើងគឺវាច្រើនណាស់ ។ ឪពុករបស់ខ្ញុំបានធ្វើការងារពីរ ដើម្បីជួយឧបត្ថម្ភកូនប្រុសម្នាក់ឲ្យរៀនមហាវិទ្យាល័យ កូនប្រុសម្នាក់ទៀតកំពុងបម្រើបេសកកម្ម និង កូនប្រាំនាក់ផ្សេងទៀតនៅផ្ទះ ។

នៅពេលឪពុកខ្ញុំបានអង្គុយប្រឹក្សាជាមួយគ្រួសារ ហើយបានប្រាប់យើងថាគាត់បានយល់ព្រមបរិច្ចាគទឹកប្រាក់ ១០០០ដុល្លារទៅកាន់ព្រះវិហារបរិសុទ្ធ ខ្ញុំចាំថាខ្ញុំបានគិតថា « ប៉ាអាចត្រូវបានសុំឲ្យបរិច្ចាគ ១ លានដុល្លារផងដែរដោយសារចំនួនទឹកប្រាក់ទាំងពីរនេះពុំអាចរកបានឡើយ » ។ ខ្ញុំមិនគិតថាគាត់ហ៊ានបរិច្ចាគច្រើនបែបនោះឡើយ ហើយយើងមានពេលតិចជាងបួនខែដើម្បីរកប្រាក់បរិច្ចាគនោះ ។

យើងបានរើសយកផ្លូវបួនយ៉ាងដើម្បីប្រមូលប្រាក់ ៖ យើងនឹងមិនទិញអំណោយដែលត្រូវជូននៅបុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះទេ ហើយបរិច្ចាគប្រាក់ដែលយើងនឹងចំណាយលើអំណោយទាំងនោះ ប្អូនស្រីខ្ញុំ និង រូបខ្ញុំត្រូវបរិច្ចាគប្រាក់ដែលរកបានពីការមើលក្មេង ប្អូនប្រុសពៅរបស់ខ្ញុំត្រូវធ្វើការផ្សេងៗដើម្បីរកប្រាក់ ហើយយើងនឹងត្រូវទៅកសិដ្ឋានមួយកន្លែងក្នុងមូលដ្ឋានជាក្រុមគ្រួសារ បេះផ្លែប៉ោមរាល់ថ្ងៃរយៈពេលពីរបីសប្តាហ៍ ហើយបរិច្ចាគប្រាក់ដែលរកបាននោះ ។

យើងបានធ្វើប្រអប់មួយដាក់អំណោយដែលអាចដាក់ប្រាក់បញ្ញើនោះ បិទរូបព្រះវិហារបរិសុទ្ធ និង រូបព្រះយេស៊ូវគ្រីស្ទលើវា ហើយដាក់ប្រអប់នោះនៅលើតុតូចមួយ ។ ក្តីរំភើបបានកើតមាន នៅពេលប្រាក់បរិច្ចាគរបស់យើងបានកើនឡើង ។ ការផ្តោតយកចិត្តទុកដាក់របស់យើងបានប្តូរពីអំណោយដែលយើងចង់បានទៅជាអំណោយសម្រាប់ព្រះអង្គសង្គ្រោះវិញ ។ ខ្ញុំពិតជាមានអំណរគុណចំពោះអំណោយដែលទ្រង់បានប្រទានដល់កូនចៅរបស់ព្រះ — ជាព្រះជន្មរបស់ទ្រង់ — ដែលខ្ញុំចង់ថ្វាយអ្វីមួយត្រឡប់ទៅទ្រង់វិញ ។

ការបេះផ្លែប៉ោមបានក្លាយជាការណ៍មួយយ៉ាងលំបាកបំផុត និង មិនគួរឲ្យពេញចិត្តក្នុងការរកប្រាក់ទេ ។ វាមានការនឿយហត់ណាស់ ប៉ុន្តែយើងត្រូវបានពង្រឹង និង ទទួលរង្វាន់ នៅពេលយើងចំណាយពេលជាមួយគ្នាជាគ្រួសារ ។ យើងបានចាប់ផ្តើម « មានចិត្តចងក្រងរួមគ្នាដោយសាមគ្គី ហើយស្រឡាញ់គ្នាទៅវិញទៅមក » ( ម៉ូសាយ ១៨:២១ ) ។

នៅពេលបុណ្យគ្រីស្ទម៉ាស់មកដល់ ខ្ញុំបានមើលទៅក្នុងប្រអប់បរិច្ចាគនោះ ប៉ុន្តែខ្ញុំតែងខកចិត្តជានិច្ច ។ ទោះបីជាយើងខិតខំយ៉ាងណាក្តី យើងនៅតែពុំមានប្រាក់គ្រប់គ្រាន់តាមគោលដៅរបស់យើងឡើយ ។

ប៉ុន្តែខ្ញុំមានអារម្មណ៍ថា វាអស្ចារ្យចំពោះការសម្រេចរបស់យើងដើម្បីលះបង់អំណោយទាំងនោះ ។ ខ្ញុំដឹងថាការពលិកម្មរបស់យើងគឺតិចតួចណាស់ ប៉ុន្តែខ្ញុំមានសេចក្តីជំនឿថាព្រះអង្គសង្គ្រោះនឹងសព្វព្រះហឫទ័យ ។

នៅថ្ងៃមួយឪពុករបស់ខ្ញុំបានប្រកាសថា យើងបានសម្រេចគោលដៅរបស់យើង ហើយថាគាត់បានបរិច្ចាគប្រាក់នោះហើយ ។ ខ្ញុំពុំបានដឹងថាតើយើងបានប្រាក់មកបង្គ្រប់បានយ៉ាងលឿនដោយរបៀបណានោះទេ ។

ការបំពេញតាមការយល់ព្រមបរិច្ចាគរបស់ឪពុកខ្ញុំនៅបុណ្យគ្រីស្ទម៉ាស់នោះគឺជាអព្ភូតហេតុ ។ ប៉ុន្តែសម្រាប់ខ្ញុំ អព្ភូតហេតុពិតគឺថាតាមរយៈការផ្តល់ឲ្យជាជាងការទទួលយក ខ្ញុំបានខិតកាន់តែជិតទ្រង់ ។ នោះគឺជាអំណោយនៃបុណ្យគ្រីស្ទម៉ាស់ដែលល្អជាងគេដែលខ្ញុំធ្លាប់បានទទួល ។ ប្រាំពីរឆ្នាំក្រោយមកអំណោយនោះបានប្រទានត្រឡប់មកដល់ខ្ញុំវិញ នៅពេលខ្ញុំបានលុតជង្គង់ចុះលើអាសនានៅក្នុងព្រះវិហារបរិសុទ្ធ ប្រូវ៉ូ ដើម្បីផ្សារភ្ជាប់សម្រាប់ពេលវេលា និង អស់ទាំងភាពដ៏អស់កល្បជានិច្ចជាមួយនឹងស្វាមីរបស់ខ្ញុំ ។ ■

ចូអាន បើគុន ស្កត់ ដេ្ម កាលីហ្វ័រញ៉ា ស.រ.អា.

# នៅពេលខ្ញុំបើកកាដូនោះខ្ញុំបានឃើញអៀមដែលដេរដោយផ្ទាល់ដៃដែលធ្វើពីក្រណាត់បុណ្យគ្រីស្ទម៉ាស់ ។



# ខ្សែនៃការបូជា

មានបុណ្យគ្រីស្ទម៉ាស់មួយកាលពីប៉ុន្មានឆ្នាំមុន ដែលធ្វើឲ្យខ្ញុំមានបន្ទុកជាច្រើន ស្ទើរតែមិនអាចរីករាយបាននៅរដូវនោះ ។ ស្វាមីរបស់ខ្ញុំ អែនឌី បានក្អកខ្លាំងឡើងៗដែលតម្រូវឲ្យធ្វើតេស្តវេជ្ជសាស្ត្រភ្លាមៗ រហូតដល់វាបានរាលដាលធ្វើឲ្យសួតខូច វះកាត់ ត្រូវកែបំពង់អាហាររបស់គាត់ឡើងវិញ និងច្រឹបសាច់ទៅពិសោធន៍ — « ដើម្បីរក្សាសុវត្ថិភាព » ។ ការវះកាត់របស់គាត់បានធ្វើឡើងមួយសប្ដាហ៍មុនពេលយើងបានប្ដូរទីលំនៅទៅផ្ទះថ្មី ។

ពីរបីសប្ដាហ៍មុនបុណ្យគ្រីស្ទម៉ាស់ ខ្ញុំបានទៅលេងអ្នកជិតខាងខ្ញុំម្នាក់ឈ្មោះ ចានេត ។ គាត់បានសួរថា តើខ្ញុំបានត្រៀមខ្លួនរួចរាល់ដើម្បីទទួលបុណ្យគ្រីស្ទម៉ាស់ហើយឬនៅ ។ ខ្ញុំបានឆ្លើយថាខ្ញុំបានត្រៀមខ្លួនតាមដែលខ្ញុំត្រូវត្រៀមហើយ ។ ខ្ញុំបាននិយាយថាយើងតែងតែធ្វើនំឃុកឃីនៃបុណ្យគ្រីស្ទម៉ាស់ជាមួយយាយរបស់ខ្ញុំពីមុនបុណ្យគ្រីស្ទម៉ាស់ ហើយថាខ្ញុំចង់ដេរអៀមមួយចំនួនសម្រាប់កូនស្រីៗ ប៉ុន្តែប្រហែលជាមិនបានធ្វើវាឡើយ ។

មួយសប្ដាហ៍ក្រោយមក ខ្ញុំបានអង្គុយលើកៅអីដែលដាក់ត្រួតលើគ្នានៅក្បែរដើមគ្រីស្ទម៉ាស់របស់យើង ។ កូនស្រីៗបានចូលដេកអស់ហើយ ហើយអែនឌីកំពុងធ្វើការនៅក្នុងការិយាល័យរបស់គាត់ នៅពេលខ្ញុំបានឮកន្តឹងទ្វាររោទិ៍ឡើង ។ ខ្ញុំបានបើកទ្វារ ហើយឃើញ ចានេតនៅមាត់ទ្វារនោះ ដោយមានកាន់អំណោយបីកញ្ចប់ក្នុងដៃ ខណៈដែលព្រិលកំពុងធ្លាក់ពីក្រោយនាង ។

ខ្ញុំបាននិយាយថា « សូមអញ្ជើញចូលមក » ដោយដឹងប្រាកដថានាងអាចឃើញពីភាពភ្ញាក់ផ្អើលរបស់ខ្ញុំ ។

នាងបាននិយាយថា « អរគុណ ប៉ុន្តែខ្ញុំត្រូវត្រឡប់ទៅវិញហើយ » ។ « អំណោយនេះសម្រាប់កូនស្រីៗរបស់អ្នក » ។

ចានេតបានហុចកញ្ចប់ទាំងនោះឲ្យខ្ញុំ ។

នាងបាននិយាយថា « នេះគឺជាអៀម » ។ « វាមិនសូវស្អាតនោះទេ ប៉ុន្តែខ្ញុំទើបដេរវាហើយនៅយប់នេះ »។

នៅពេលដ៏ស្រទន់នោះ ខ្ញុំបាននិយាយដោយរាបទាបថា សូមអរគុណ ។ យើងបានឱបគ្នា ហើយខ្ញុំបានមើលនាងដើរត្រឡប់ទៅផ្ទះវិញ ។

នៅពេលខ្ញុំអង្គុយនៅលើកៅអីវិញ ខ្ញុំបានស្រាយខ្សែបូរបើកកាដូមួយដោយប្រុងប្រយ័ត្ន ។ នៅពេលខ្ញុំបើកវាខ្ញុំបានឃើញអៀម ដែលដេរដោយផ្ទាល់ដៃដែលធ្វើពីក្រណាត់បុណ្យគ្រីស្ទម៉ាស់ ។ ខ្ញុំបានយកដៃខ្ញុំច្បូតលើស្នាមថ្នេរនៃអៀមនោះ នៅពេលខ្ញុំបានគិតពីចានេត ។ នាងមានកូនតូចបួននាក់ រួមទាំងកូនភ្លោះដែលទើបតែមានអាយុជាងមួយខួប ។ នាងបង្រៀនលេងព្យាណូ ហើយនាងមានការហៅបម្រើដែលរវល់និងសំខាន់នៅក្នុងវួដរបស់ខ្ញុំ ។

ខ្ញុំបានគិតពីពេលដែលនាងអាចនឹងមានពេលដើម្បីដេរអៀមទាំងនេះ ហើយខ្ញុំបានដឹងភ្លាមថានាងគ្មានពេលនោះទេ ។ នាងបានឆ្លៀតពេលដេរវា ។

ខ្ញុំបានយំ នៅពេលខ្ញុំទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ពីព្រះវរបិតាសួគ៌តាមរយៈ ចានេត — ជាភាពកក់ក្ដៅ និង ការលួងលោមដែលមិនអាចវាស់វែងបាន នៅពេលខ្ញុំត្រូវបានឱបក្រសោបដោយ « ព្រះពាហុនៃសេចក្ដីស្រឡាញ់របស់[ ទ្រង់ ] » ( គ. និង ស. ៦:២០ ) ។

ពេលវេលាជាច្រើនឆ្នាំកន្លងទៅហើយតាំងពីយើងបានទទួលអៀមទាំងនោះ ។ កូនៗរបស់ខ្ញុំធំជាងអៀមទាំងនោះ ប៉ុន្តែខ្ញុំបានទុកវានៅក្នុងទូរបស់ខ្ញុំ ព្យួរវាដោយប្រើខ្សែរបស់វាចងជាប់នឹងទំពក់លោងស្អាតខាងក្រោមខោអាវថ្មីៗ ។ គ្រប់ពេលដែលខ្ញុំបានឃើញអំណោយរបស់ចានេត ខ្ញុំនឹកឃើញពីភាពកក់ក្ដៅ និងសេចក្ដីស្រឡាញ់ដែលខ្ញុំបានទទួលនៅយប់នោះ ។ អំណោយនោះបានរំឭកខ្ញុំពីអ្វី ដែលខ្ញុំចង់ប្រែក្លាយខ្លួនខ្ញុំ — ជាកូនសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទសក្ដិសមនឹងវិរិយៈ និង មានឆន្ទៈបម្រើ ។ ■

ខេនដាយ អេ ហ្វ្រូជីរ រែងជាហូ ស.រ.អា.

រូបគំនូរដោយ អេរ៉ែន ហ្វ៉ាន

# ខ្ញុំពុំនៅតែឯងឡើយ

អង្គុយក្នុងរណ្ដៅត្រង់សេដោយប្រុងប្រយ័ត្ន ខ្ញុំបានអើតក្បាលរំលងបាវខ្សាច់មើលឆ្ពោះទៅទិសខាងជើង — គឺមើលទៅប្រទេស អ៊ីរ៉ាក់ ។ វាគឺនៅថ្ងៃទី ២៤ខែ ធ្នូ អំឡុងពេលយុទ្ធនាការការពារនៅតំបន់វាលខ្សាច់ ហើយខ្ញុំត្រូវបានចាត់ឲ្យយាមកាមចាប់ពីកណ្ដាលអាធ្រាតទៅ ។

ខ្ញុំគឺជាពួកបរិសុទ្ធថ្ងៃចុងក្រោយតែម្នាក់គត់នៅក្នុងកងវរសេនាតូចរបស់ខ្ញុំ ដូច្នេះថ្ងៃបុណ្យទាននោះវាកាន់តែឯកោ ។ យើងនៅវាលខ្សាច់ អារ៉ាប៊ីសាអូឌីតតាំងពីខែសីហា ហើយឥឡូវនេះជាបុណ្យគ្រីស្ទម៉ាស់នៅទីនេះ ជាមួយនឹងយប់ដ៏ត្រជាក់ដែលមានផ្កាយពេញផ្ទៃមេឃ ។ ជុំវិញមានភាពស្ងាត់ជ្រងំ ហើយខ្ញុំមានពេលពីរបីម៉ោងទៀតជាមួយនឹងផ្នូកខ្សាច់ពណ៌ប្រផេះនេះ និង ជាមួយគំនិតរបស់ខ្ញុំ ។

ខ្ញុំបានគិតពីភរិយា និង កូនប្រុសរបស់ខ្ញុំនៅរដ្ឋចចចារ ស.រ.អា. ហើយខ្ញុំនឹកពីភាពរីករាយនេះនៅឯផ្ទះរបស់ខ្ញុំខ្លាំងណាស់ — នឹកដើមគ្រីស្ទម៉ាស់ អំណោយអាហារពេលល្ងាចដ៏ឆ្ងាញ់នៃបុណ្យគ្រីស្ទម៉ាស់ ។ បន្ទាប់មកខ្ញុំបានចាប់ផ្ដើមពិចារណាពីដំណើររឿងបុណ្យគ្រីស្ទម៉ាស់ ។

ខ្ញុំបានឆ្ងល់ពីយប់ដែលព្រះគ្រីស្ទបានប្រសូត ។ ខ្ញុំឆ្ងល់ថាតើវាងងឹតប៉ុណ្ណា ហើយតើមានព្រះច័ន្ទរះចែងចាំងលើមេឃា ឬ ក៏មានតែពន្លឺផ្កាយតែមួយទេ ។ ដោយសារគ្មានពន្លឺភ្លើងអគ្គិសនីនៅពេលទ្រង់ប្រសូត នោះយប់នោះច្បាស់ជាដូចយប់ដែលខ្ញុំបានជួបនេះហើយ ។ វាគ្មានភាពអធិកអធមឡើយ — គឺវាងងឹត ជាយប់ដ៏ស្ងាត់ជ្រងំ ។

ភ្លាមនោះមានគំនិតមួយដ៏អស្ចារ្យបានផុសក្នុងចិត្តខ្ញុំ ។ ព្រះគម្ពីរប៊ីបបានថ្លែងថា ក្រោយមកពួកហោរាដែលមកពីទិសខាងកើត បានធ្វើដំណើរតាមពន្លឺផ្កាយរះនៅលើមេឃ ។ នៅពេលខ្ញុំមើលទៅលើមេឃដ៏ខ្មៅងងឹត ខ្ញុំបានដឹងថាខ្ញុំនៅភាគខាងកើតនៃទីក្រុងបេថ្លេហិម ហើយមជ្ឈមណ្ឌលនៃការអប់រំមួយនៅពេលនោះគឺទីក្រុង បាដាដ ។ តើពួកហោរាអាចបានចេញមកពីទីកន្លែងមួយដែលនៅមិនឆ្ងាយពីកន្លែងដែលខ្ញុំបាននៅឬទេ ? តើផ្កាយបានបង្ហាញពន្លឺអ្វីខ្លះ ? តើវានឹងនៅលើមេឃឬទេ ? តើខ្ញុំអាចឃើញវាទេ ?

ខ្ញុំមើលទៅលើមេឃដោយឆ្ងល់ពីការបង្កបង្កើតរបស់ព្រះ ហើយមានអារម្មណ៍កក់ក្ដៅដែលចេញមកពីក្នុងចិត្ត ។ វាពុំសំខាន់ឡើយថាខ្ញុំនៅកន្លែងដដែលនោះ ឬ ផ្កាយដដែលនោះនៅតែរះនៅលើមេឃឡើយ ។ អ្វីដែលសំខាន់នោះគឺថា ខ្ញុំបានចែកចាយចំណេះដឹងដូចដែលពួកហោរាបានដឹងពីព្រះឱរសដែលបានប្រសូតនៅភូមិបេថ្លេហិមថាជាស្ដេចនៃអស់ទាំងស្ដេចនោះ ។

ខ្ញុំមិននៅតែឯងឡើយនៅបុណ្យគ្រីស្ទម៉ាស់នេះ ផ្ទុយទៅវិញ ខ្ញុំបានរួបរួមជាមួយអស់អ្នកដែលព្យាយាមស្វែងរកទ្រង់ មិនថាពួកលោកជាហោរា ព្យាការី ឬ ជាទាហានឯកោនៅក្នុងរណ្ដៅនៃវាលខ្សាច់នេះទេ ។ នៅយប់នោះទីបន្ទាល់របស់ខ្ញុំអំពីកំណើតរបស់ព្រះអង្គសង្គ្រោះត្រូវបានពង្រឹង ហើយនៅព្រឹកបន្ទាប់ព្រះវិញ្ញាណបរិសុទ្ធនៅតែគង់នៅជាមួយខ្ញុំ ។

ជំនួសឲ្យបុណ្យគ្រីស្ទម៉ាស់ដ៏កើតទុក្ខនាឆ្នាំនោះ វាបានក្លាយជាបុណ្យគ្រីស្ទម៉ាស់ដ៏មានតម្លៃបំផុតមួយ ។ ■

រ៉ូបឺត ហូវមែន វ៉ាសុីតោន ស.រ.អា.



នៅពេលខ្ញុំមើលទៅលើមេឃ ដ៏ខ្មៅងងឹត ខ្ញុំបានដឹងថាខ្ញុំនៅភាគខាងកើតនៃទីក្រុង បេថ្លេហិម ។



ខ្ញុំបានអធិស្ឋានថានៅចុងបញ្ចប់នៃយប់នោះ សូមឲ្យមានប្រាក់ពេញ « ប្រអប់ជំនួយសម្រាប់លោកតាណូអែល » ។

# ប្រាក់ស្លឹងរបស់ស្ត្រីមេម៉ាយនាសម័យទំនើបនេះ

កម្រាលតុពណ៌ស និង រូបមនុស្សព្រិលដាក់តាំងលើតុដែលខ្ចីគេនោះ បានធ្វើឲ្យសាលវប្បធម៌ក្លាយជាកន្លែងអធិកអធមមួយ ដែលត្រូវបានរៀបចំនាទីចុងក្រោយសម្រាប់ពិធីជប់លៀងបុណ្យគ្រីស្ទម៉ាស់របស់គ្រួសារយើង ។

ខណៈយើងកំពុងរង់ចាំភ្ញៀវនោះ ខ្ញុំបានឃើញប្រអប់ទទេមួយនៅលើតុ — ដោយមានដាក់អក្សរថា — « ប្រអប់ជំនួយសម្រាប់លោកតាណូអែល » ។ ខ្ញុំបានអធិស្ឋានថានៅចុងបញ្ចប់នៃយប់នោះ សូមឲ្យមានប្រាក់ពេញប្រអប់នោះ ។

អំឡុងពេលការរៀបចំពិធីជប់លៀង នោះយើងបានដឹងថា ស្វាមីរបស់បងប្អូនជីដូនមួយខ្ញុំគ្មានការងារធ្វើជាងមួយឆ្នាំកន្លះហើយ ។ ធនធានដែលជាចំណូលចម្បងរបស់គ្រួសារគាត់ រួមមានជាភ្នាក់ងារចែកចាយកាសែតអានចំនួនប្រាំផ្លូវ ដែលតម្រូវឲ្យពួកគេចាប់ផ្ដើមធ្វើការរាល់ថ្ងៃនៅម៉ោង ៣:៣០ នាទីព្រឹក ។ ប្រាក់ចំណូលចម្បងរបស់ពួកគេត្រូវចំណាយលើប្រាក់កម្ចី និង អ្វីៗដែលចាំបាច់ផ្សេងទៀត សល់ប្រាក់តិចតួចសម្រាប់អ្វីដែលពួកគេចង់បាន ដូចជាអំណោយបុណ្យគ្រីស្ទម៉ាស់ជាដើម ។

គ្រួសារជីដូនមួយរបស់ខ្ញុំនេះបានមកដល់កម្មវិធីមុនគេ ។ ខ្ញុំបានមើលពួកគេនៅពេលពួកគេដើរឆ្ពោះទៅកាន់តុអាហារ ដែលនៅហួសពីប្រអប់បុណ្យគ្រីស្ទម៉ាស់នោះ ។ នៅពេលពួកគេទៅដល់តុនោះ ស្វាមីរបស់ជីដូនមួយខ្ញុំបានឈប់ ដើម្បីអានស្លាកនៅលើប្រអប់នោះ ។ ដោយពុំស្ទាក់ស្ទើរ គាត់បានដកយកកាបូបប្រាក់កញ្ចាស់របស់ខ្លួនចេញមក ហើយដកប្រាក់ពីរបីដុល្លារ រួចដាក់វាទៅក្នុងប្រអប់នោះ ដោយភ្លេចថាខ្លួនឯងនេះហើយជាគ្រួសារដែល « ខ្វះខាត » នោះ ។

ខ្ញុំមានអារម្មណ៍អួលដើមក ហើយភ្លាមនោះធ្វើឲ្យចាំពីដំណើររឿងនៅក្នុងព្រះគម្ពីរសញ្ញាថ្មីអំពីស្ត្រីមេម៉ាយ និង ប្រាក់ពីរស្លឹងរបស់គាត់ ។ មានអ្នកមានជាច្រើន បានបង្អួតការបរិច្ចាគដ៏ច្រើនរបស់ខ្លួនទៅក្នុងឃ្លាំងនៅពេល « មានស្ត្រីមេម៉ាយក្រម្នាក់ មកដាក់តែ ២ស្លឹង ដែលត្រូវជាកន្លះសេន » ( សូមមើល ម៉ាកុស ១២:៤១–៤២ ) ។

បន្ទាប់មកព្រះអង្គសង្គ្រោះបានមានបន្ទូលទៅពួកសិស្សរបស់ទ្រង់ ៖

« ស្រីមេម៉ាយក្រនេះ បានថ្វាយលើសជាងអ្នកទាំងអស់ ដែលដាក់ក្នុងឃ្លាំង ៖

« ដ្បិតគេសុទ្ធតែយកពីរបស់ជាសំណល់ខ្លួនមកថ្វាយ តែស្ត្រីនេះបានយកពីសេចក្ដីកំសត់ខ្លួនមកថ្វាយវិញ គឺជារបស់ដែលនាងមានទាំងប៉ុន្មានសម្រាប់ចិញ្ចឹមជីវិតខ្លួនផង » ( ម៉ាកុស ១២:៤៣–៤៤ ) ។

ព្រះយេស៊ូវគ្រីស្ទបានមានព្រះបន្ទូលថាស្ត្រីនោះបានផ្ដល់ពី « សេចក្ដីកំសត់របស់ខ្លួន » ហើយថ្វាយ « របស់ដែលនាងមានទាំងប៉ុន្មានសម្រាប់ចិញ្ចឹមជីវិតខ្លួន » ។ គាត់គួរតែបង់តែមួយស្លឹងប៉ុណ្ណោះ ។ នោះប្រហែលជាអ្វីដែលបំពេញទៅតាមតម្រូវការឲ្យធ្វើ ប៉ុន្តែដួងចិត្តដ៏ស្មោះត្រង់ និង ឆន្ទៈលះបង់របស់គាត់ទាំងអស់នេះបានទាក់ព្រះទ័យរបស់ព្រះរាជបុត្រានៃព្រះ ។

គ្មាននរណាម្នាក់នឹងស្ដីបន្ទោសស្វាមីរបស់ជីដូនមួយខ្ញុំឡើយ បើសិនគាត់ដើរហួសប្រអប់នោះដោយគិតថា « បើសិនខ្ញុំមានខ្ញុំនឹងផ្ដល់ឲ្យ » ( ម៉ូសាយ ៤:២៤ ) ។ គំរូដ៏អស្ចារ្យរបស់គាត់អំពីសេចក្ដីសប្បុរស និង សេចក្ដីស្រឡាញ់ចំពោះបងប្អូនរបស់ខ្លួនពុំគ្រាន់តែដក់ជាប់ក្នុងដួងចិត្តខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែជាមួយនឹងសមាជិកផ្សេងទៀតនៃគ្រួសារខ្ញុំដែលបានមើលគាត់ ។ ខ្ញុំបានដឹងថាគ្រួសាររបស់គាត់នឹងមិនកើតអ្វីឡើយពីព្រោះ « សេចក្ដីសប្បុរសគឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ . . . ហើយអស់អ្នកណាដែលមានសេចក្ដីសប្បុរសនៅក្នុងថ្ងៃចុងក្រោយបង្អស់ នឹងបានស្រួលដល់អ្នកនោះហើយ » ( មរ៉ូណៃ ៧:៤៧ ) ។

យើងសង្ឃឹមថាផ្ដល់អ្វីមួយដល់គ្រួសារគាត់នៅយប់នោះ ប៉ុន្តែយើងបានឲ្យគាត់នៅពេលក្រោយដោយផ្ដល់ឲ្យនៅចំពេលដែលគាត់ត្រូវការ នោះគាត់បានបង្ហាញយើងថាវាជាពេលដែលសំខាន់បំផុត គាត់គឺជាអ្នកមានម្នាក់រួចទៅហើយ ។ ■

ស្តេហ្វានី អេច អូលសិន រដ្ឋយូថាហ៍ ស.រ.អា.

# តើពួកគេបានដឹងពីសេចក្ដីត្រូវការរបស់ខ្ញុំដោយរបៀបណា ?

ជិត២០ ឆ្នាំ មកហើយដែល ខ្ញុំបានទទួលការហៅបម្រើបេសកកម្មទៅប្រទេសជប៉ុន ។ ដោយមានការគិតទុកជាមុនដ៏ល្អព្រមជាមួយនឹង ក្ដីបារម្ភមួយចំនួនខ្ញុំបានរៀបចំខ្លួនចេញបម្រើបេសកកម្មខ្ញុំក្នុងខែមករា ។ អំឡុងពេលនោះឪពុកម្ដាយខ្ញុំទាំងពីរបានបាត់បង់ការងារ ។

ខ្ញុំបានប្រាក់ឧបត្ថម្ភសម្រាប់បេសកកម្មខ្ញុំនៅពេលខ្ញុំបានមកដល់ប្រទេសជប៉ុន ប៉ុន្តែគ្រួសាររបស់ខ្ញុំមានបញ្ហាផ្នែកហិរញ្ញវត្ថុ ។ ខ្ញុំពុំប្រាកដថាតើខ្ញុំបានប្រាក់មកពីណាសម្រាប់ការចំណាយនាពេលខាងមុខដូចជា សម្លៀកបំពាក់បេសកកម្ម វ៉ាលី និង វត្ថុប្រើប្រាស់ចាំបាច់ផ្សេងទៀតនោះទេ ។ ខ្ញុំបានធ្វើការក្រៅម៉ោងប៉ុន្តែនៅតែមិនគ្រប់គ្រាន់ទៀត ។ ជាពិសេសខ្ញុំបារម្ភយ៉ាងខ្លាំងថា តើខ្ញុំអាចបានប្រាក់មកបង់ថ្លៃធ្វើលិខិតឆ្លងដែនភ្លាមយ៉ាងដូចម្ដេចដើម្បីខ្ញុំអាចទទួលបានវាទាន់ពេលចេញទៅប្រទេសជប៉ុន ។



នៅរសៀលមួយ ដោយក្ដីអស់សង្ឃឹម ខ្ញុំបានចូលទៅបន្ទប់របស់ខ្ញុំ ហើយទូលអង្វរព្រះវរបិតាសួគ៌ ។ ខ្ញុំបានចែកចាយពីអារម្មណ៍របស់ខ្ញុំដែលចង់បម្រើនៅប្រទេស ជប៉ុន និង អំណរគុណរបស់ខ្ញុំចំពោះក្ដីសុបិននៃការបម្រើបេសកកម្ម ក្លាយជាការពិតនៅពេលឆាប់ខាងមុខនេះ ។ ខ្ញុំបានយំ ប្រាប់ទ្រង់ពីសេចក្ដីត្រូវការយ៉ាងខ្លាំងនូវប្រាក់ ៧៥ ដុល្លារ សម្រាប់ថ្លៃលិខិតឆ្លងដែនដែលខ្ញុំពិតជាគ្មានសោះនោះ ។ នៅពេលខ្ញុំក្រោកពីអធិស្ឋានរួច ខ្ញុំបានដឹងថាអ្វីៗទាំងអស់នឹងអាចសម្រេចបាន ។ ខ្ញុំពុំដឹងថានឹងកើតឡើងយ៉ាងដូចម្ដេចទេ ប៉ុន្តែខ្ញុំបានទទួលអារម្មណ៍សុខសាន្តដែលអះអាងដល់ខ្ញុំថាព្រះអម្ចាស់នឹងប្រទានឲ្យ ។

ស្អែកឡើង ខ្ញុំបានបើកប្រអប់សំបុត្ររបស់យើង ហើយបានប្រទះឃើញកាតបុណ្យគ្រីស្ទម៉ាស់មួយ ។ បុគ្គលដែលផ្ញើសំបុត្រមកបានព្យាយាមលាក់អត្តសញ្ញាណខ្លួនដើម្បីកុំឲ្យគេស្គាល់ ។ គ្មានតែមនៅលើកាតនោះឡើយ វាត្រូវបានបញ្ជូនមកដោយផ្ទាល់ដៃ ។

នៅលើកាតនោះ មានពាក្យថា « សូមអបអរសាទរ ! អ្នកគឺជាបុគ្គលដែលបានទទួលនូវសេចក្ដីសប្បុរសពីពួកគ្រីស្ទាន ។ រីករាយបុណ្យគ្រីស្ទម៉ាស់ ហានណា ។ សូមសំណាងល្អជាមួយនឹងបេសកកម្មរបស់អ្នក » ។

នៅក្នុងកាតនោះមានទឹកប្រាក់ ១០០ដុល្លារ ។ ខ្ញុំបានឈរនៅមុខទ្វារ ហើយយំ ។ តើអ្នកណាបានធ្វើការណ៍នេះ តើពួកគេបានដឹងពីសេចក្ដីត្រូវការរបស់ខ្ញុំដោយរបៀបណា ?

ច្រើនឆ្នាំក្រោយមក ខ្ញុំពុំដឹងថានរណាបានយកប្រាក់មកផ្ទះខ្ញុំកាលពីថ្ងៃនោះទេ ។ ខ្ញុំបានគិតអំពីមនុស្សម្នាក់នោះ ឬ មនុស្សផ្សេងៗយ៉ាងច្រើនតាំងពីពេលនោះមក ។ ពួកគេបានបង្ហាញពីអ្វីដែលខ្ញុំជឿលើអែលឌើរ យ៉ូសែប ប៊ី.វ៉ឺតលីន ( ១៩១៧–២០០៨ ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលលោកមានប្រសាសន៍ ៖ « សេចក្ដីអាណិតអាសូររបស់មិត្តភក្ដិដែលដូចជាព្រះគ្រីស្ទពិតជាដក់ជាប់ដួងចិត្ត និងផ្លាស់ប្ដូរជីវិតរបស់យើងមែន ។ . . . ក្នុងសាសនាចក្រនេះ ការអធិស្ឋានសុំជំនួយ ជារឿយៗត្រូវបានឆ្លើយតបដោយព្រះអម្ចាស់តាមរយៈការបម្រើជាប្រចាំរបស់បងប្អូនប្រុសស្រី ដែលយកចិត្តទុកដាក់តាមវិធីដ៏សាមញ្ញ ។ នៅក្នុងសេចក្ដីល្អនៃមិត្តភក្ដិដ៏ស្មោះត្រង់ខ្ញុំបានឃើញពីសេចក្ដីមេត្តាករុណាដែលឆ្លុះបញ្ចាំងពីព្រះអម្ចាស់ទ្រង់ផ្ទាល់ » ។[១]

កិច្ចការសប្បុរសនោះបានផ្លាស់ប្ដូរខ្ញុំ ជួយខ្ញុំឲ្យចេញបេសកកម្មរបស់ខ្ញុំទាន់ពេល ហើយបំផុសគំនិតខ្ញុំឲ្យខ្ញុំរកមើលរបៀបផ្សេងៗ ដើម្បីក្លាយជាចម្លើយចំពោះការអធិស្ឋានរបស់មនុស្សដទៃ ។ ■

ហានណា អេសេលីន នៅរដ្ឋអារីស្សូណា ស.រ.អា.

**កំណត់ចំណាំ**

១. យ៉ូសែប ប៊ី.វ៉ឺតលីន « Valued Companions » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៣២ ។

ខ្ញុំបានបើកប្រអប់សំបុត្ររបស់យើង ហើយបានប្រទះឃើញកាតបុណ្យគ្រីស្ទម៉ាស់មួយ ។ គ្មានតែមនៅលើកាតនោះឡើយ វាត្រូវបានបញ្ជូនមកដោយផ្ទាល់ដៃ ។

# ការត្រឡប់មកផ្ទះវិញមុនកំណត់ពីបេសកកម្មរបស់ខ្ញុំ

ដោយ ប្រីថានី រ៉ូម៉ានែឡូ ខាស្ទ្រូ

ការទទួលបានការហៅបេសកកម្មរបស់ខ្ញុំគឺជាឱកាសដ៏អស្ចារ្យ និង រុងរឿងបំផុតនៅក្នុងជីវិតខ្ញុំ ។ ខ្ញុំបានគិតអំពីបេសកកម្មជាច្រើនដង ចាប់តាំងពីខ្ញុំបានទទួលទីបន្ទាល់ពីដំណឹងល្អ កាលខ្ញុំអាយុ ១៨ ឆ្នាំ ។ ខ្ញុំចាំថា នៅពេលខ្ញុំបានទទួលការហៅបម្រើរបស់ខ្ញុំនៅក្នុងបេសកកម្ម តៃវ៉ាន់ តៃឈុន នោះខ្ញុំបានដឹងថាវាត្រូវហើយ ហើយខ្ញុំពិតជារំភើបដើម្បីបម្រើ ។

ខ្ញុំបានអានព្រះគម្ពីររាល់ថ្ងៃ ចូលរៀនថ្នាក់ការរៀបចំអ្នកផ្សព្វផ្សាយសាសនា និង ព្រះវិហារបរិសុទ្ធ ហើយថែមទាំងបានព្យាយាមរៀនភាសាចិនដោយខ្លួនឯងទៀតផង ។ ដោយសារខ្ញុំជាកូនទោលក្នុងគ្រួសារ នោះខ្ញុំបានដឹងថាបេសកកម្មរបស់ខ្ញុំ នឹងមិនត្រឹមតែនាំកិត្តិយសដល់ខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងដល់ឪពុកម្ដាយ និង ព្រះវរបិតាសួគ៌ផងដែរ ។ នៅថ្ងៃដែលខ្ញុំបានចូលទៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ( អិម. ធី. ស៊ី. ) ខ្ញុំបានមានអារម្មណ៍ថានឹងគ្មានបញ្ហាអ្វីកើតឡើងឡើយអំឡុងពេល១៨ខែទៀត ។ ខ្ញុំរំភើបចំពោះរឿងគ្រប់យ៉ាងពេលគិតពីការឃើញពិធីបុណ្យជ្រមុជទឹក ពីការភ្លក់ម្ហូបតៃវ៉ាន់ដែលខ្ញុំធ្លាប់បានឮជាច្រើនដងមកហើយ ។ ខ្ញុំពុំដឹងសូម្បីតែបន្តិចឡើយ នៅពេលខ្ញុំចូលទៅ អិម. ធី. ស៊ី. ថាបេសកកម្មរបស់ខ្ញុំពិតជាខុសប្លែកយ៉ាងខ្លាំងពី អ្វីដែលខ្ញុំរំពឹងទុក ។

**ការធ្លាក់ខ្លួនឈឺ**

ប្រហែលជាបួនខែនៅក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំបានចាប់ផ្ដើមឈឺ — ពុំមែនគ្រាន់តែក្នុងពេលសកម្មភាពធម្មតាដូចជាជិះកង់ ឬ ហាត់ប្រាណនៅពេលព្រឹកឡើយ ប៉ុន្តែខ្ញុំឈឺសូម្បីតែខ្ញុំសម្រាក ឬ សិក្សាផ្ទាល់ខ្លួន ។ ខ្ញុំបានចាប់ផ្ដើមស្រកទម្ងន់យ៉ាងលឿន ។ សូម្បីតែខ្ញុំផឹកទឹកនោះក៏ធ្វើឲ្យខ្ញុំឈឺដែរ ។ ការធ្វើតេស្តរបស់វេជ្ជបណ្ឌិតពុំអាចដឹងថាខ្ញុំឈឺអ្វីឡើយ ។ ខ្ញុំគ្មានប៉ារ៉ាស៊ីត ឬ វីរុសអ្វីឡើយ ។ ប្រធានបេសកកម្មរបស់ខ្ញុំ ដៃគូបេសកកម្មរបស់ខ្ញុំ និង ខ្លួនខ្ញុំផ្ទាល់វង្វេងវង្វាន់ពីសុខភាពដែលកាន់តែទ្រុឌទ្រោមរបស់ខ្ញុំនេះ ។

អំឡុងមួយខែក្រោយមកនោះ ខ្ញុំបានរក្សាសេចក្ដីជំនឿដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ទោះបីជាខ្ញុំមានការលំបាកក្ដី ខ្ញុំនៅតែមានជំនឿថា បើសិនខ្ញុំបន្តព្យាយាមធ្វើការ ធាក់កង់កាន់តែលឿន ហើយនិយាយភាសាចិនដែលខ្ញុំចេះរដិបរដុបនេះ ជាមួយមនុស្សគ្រប់គ្នាដែលខ្ញុំជួប នោះព្រះអាចធ្វើអព្ភូតហេតុដើម្បីព្យាបាលខ្ញុំ ។ ខ្ញុំជឿលើរឿងនៃការព្យាបាលអ្នកឈឺរបស់ព្រះគ្រីស្ទ និង ការប្រោសមនុស្សស្លាប់ ហើយខ្ញុំជឿដោយអស់ពីចិត្តថាទ្រង់នឹងធ្វើការណ៍នោះចំពោះខ្ញុំផងដែរ — ជាអ្នកផ្សព្វផ្សាយសាសនាដែលទន់ខ្សោយម្នាក់ ប៉ុន្តែពេញដោយក្ដីរំភើប ។ នាថ្ងៃអាទិត្យមួយពេលដែលដៃគូរបស់ខ្ញុំ និង ខ្ញុំកំពុងជិះកង់ទៅសាលាប្រជុំសាសនាចក្រដើម្បីជួបសាសនាគន់ការី នោះការឈឺចាប់ និង ការប្រកាច់កន្ត្រាក់ពេញ

**ខ្ញុំពុំដឹងសូម្បីតែបន្តិចឡើយ នៅពេលខ្ញុំចូលទៅក្នុងមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ថា បេសកកម្មរបស់ខ្ញុំពិតជាខុសប្លែកយ៉ាងខ្លាំងពីអ្វីដែលខ្ញុំរំពឹងទុក ។**

រូបថតដោយ MASSONSTOCK/ISTOCK/THINKSTOCK


國語
傳教士
你好

រាងកាយធ្វើឲ្យខ្ញុំពុំអាចទ្រាំបាន ។ នៅពេលយើងទៅដល់សាលាប្រជុំ ខ្ញុំបានសុំឲ្យអែលឌើរផ្ដល់ការប្រសិទ្ធិពរដល់ខ្ញុំដែលការប្រសិទ្ធិពរនោះបានជួយខ្ញុំមែន ។ ពេលវេលាចេះតែកន្លងទៅ ការប្រសិទ្ធពរបព្វជិតភាពបានធ្វើកាន់តែច្រើន ព្រមទាំងការអធិស្ឋានជាច្រើនដើម្បីសុំការជាសះស្បើយផងដែរ ។

វាគឺជាពេលដ៏លំបាកបំផុតនៃបេសកកម្មរបស់ខ្ញុំ នាព្រឹកមួយនៅពេលខ្ញុំក្រោកឡើងនៅក្នុងអាកាសធាតុដ៏ក្ដៅនៃប្រទេសតៃវ៉ាន់ ហើយខ្ញុំដឹងថាខ្ញុំពុំអាចបម្រាស់ខ្លួនចេញពីគ្រែបានឡើយ ។ នៅគ្រានោះ ខ្ញុំបានដឹងថាខ្ញុំពុំអាចធ្វើជាអ្នកផ្សព្វផ្សាយសាសនាយូរទៀតឡើយ ។ ប្រធានបេសកកម្មរបស់ខ្ញុំបានមកសួរសុខទុក្ខ ហើយយើងបានប្រឹក្សាគ្នា ។ យើងបានជជែកពីអ្វីដែលអាចធ្វើបាន ហើយបន្ទាប់ពីការអធិស្ឋានជាច្រើន ព្រមទាំងបានយំផងនោះ ព្រះវិញ្ញាណបានបញ្ជាក់ថាខ្ញុំត្រូវតែត្រឡប់ទៅផ្ទះវិញ ហើយផ្ដោតលើសុខភាពខ្លួន ។

### ការត្រឡប់ទៅផ្ទះវិញមុនកំណត់

ជំនួសឲ្យការត្រឡប់មកផ្ទះដែលមានប៉េតប៉ោង និង ពាក្យថា « សូមស្វាគមន៍ការត្រឡប់មកផ្ទះវិញ » នោះខ្ញុំត្រូវនៅលើរទេះរុញចុះពីលើយន្តហោះ ទៅជួបឪពុកម្ដាយដែលបារម្ភពីខ្ញុំ ដែលបាននាំខ្ញុំទៅកាន់បន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យភ្លាម ។ ជាច្រើនខែបន្ទាប់ពីការធ្វើតេស្ដ វេជ្ជបណ្ឌិតពុំអាចរកឃើញថាខ្ញុំឈឺអ្វីឡើយ ។ ក្រៅពីនោះ មនុស្សដែលមានបំណងល្អនៅជុំវិញខ្លួនខ្ញុំបាននិយាយមកខ្ញុំថា « តើខ្ញុំនឹងត្រឡប់ទៅវិញនៅពេលណា ? » « តើអ្នកនឹងនៅផ្ទះឬ ? » « ប្រហែលជាអ្នកគួរតែរៀបការ » ។ « អ្នកមិនគួរទៅបេសកកម្មទាល់តែសោះ » ។

ខ្ញុំមានអារម្មណ៍ថាខ្មាស់អៀន ហើយច្របូកច្របល់ ។ តើខ្ញុំសក្តិសមនឹងសេចក្ដីស្រឡាញ់របស់ព្រះឬទេ ? ហេតុអ្វីបានការណ៍នេះកើតឡើងសូម្បីតែខ្ញុំព្យាយាមបម្រើយ៉ាងខ្លាំងយ៉ាងនេះ ? តើខ្ញុំមិនមែនជាអ្នកផ្សព្វផ្សាយសាសនាល្អទេឬ ? តើព្រះបានស្ដាប់ខ្ញុំដែរឬទេ ? តើមិត្តភក្តិរបស់ខ្ញុំ នឹងទទួលយកការបម្រើជាអ្នកផ្សព្វផ្សាយដ៏ « ទន់ខ្សោយ » របស់ខ្ញុំដែរឬទេ ?

អស់ពេលជាងប្រាំមួយខែ ខ្ញុំមានការលំបាកយល់ពីទីបន្ទាល់របស់ខ្លួនឯង ដែលខ្ញុំមានអារម្មណ៍ខុសឆ្គង ។ ខ្ញុំបានឆ្ងល់ថាតើខ្ញុំបានធ្លាក់ពីព្រះគុណឬ ហើយតើព្រះវរបិតាសួគ៌ពិតជាស្រឡាញ់ខ្ញុំមែនឬ ។ ទោះបីជាខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ស្រួលខ្លួនបន្តិចម្ដងៗ ខ្ញុំពុំមានអារម្មណ៍ដូចកាលពីមុនបេសកកម្មរបស់ខ្ញុំឡើយ ។ ហើយខ្ញុំនៅតែឃើញថាខ្លួនឯងព្យាយាមគេចវេសចេញពីដំណើរជីវិតប្រក្រតី ។

ល្ងាចមួយមិត្តភក្តិដ៏ល្អរបស់ខ្ញុំ និង ខ្ញុំបានជជែកគ្នា ។ គាត់ក៏មានបទពិសោធន៍នៃការឈឺចាប់ និង ទុក្ខសោកដែលត្រឡប់មកផ្ទះវិញមុនកាលកំណត់បេសកកម្មរបស់ខ្លួន ដោយសារជំងឺ ហើយបានត្រឡប់ទៅបម្រើបេសកកម្មវិញ ។ តាំងពីប្រាំមួយខែមកនេះ ខ្ញុំចាំថាយប់នោះគឺជាលើកទីមួយហើយដែលខ្ញុំមានអារម្មណ៍នៃភាពសុខសាន្តពិត ។ សំឡេងនៃព្រះវិញ្ញាណបានខ្សឹបប្រាប់ខ្ញុំថា « អ្នកត្រូវតែត្រឡប់ទៅវិញ » ។ ខ្ញុំមានអារម្មណ៍ធូរស្បើយដែលទីបំផុតបានដឹងថា ខ្ញុំត្រូវបានណែនាំឲ្យបន្តទៅមុខទៀត ។ ខ្ញុំបានជួបប៊ីស្សពរបស់ខ្ញុំនៅថ្ងៃបន្ទាប់ ។ ក្រោយមកខ្ញុំបានសរសេរលិខិតមួយទៅនាយកដ្ឋានអ្នកផ្សព្វផ្សាយសាសនា ដោយសួរគេថា តើខ្ញុំអាចត្រឡប់ទៅបម្រើបេសកកម្មវិញបានឬទេ ? ខ្ញុំបានទទួលការស្នើសុំរបស់ខ្ញុំ ហើយមួយខែក្រោយមកខ្ញុំបានពាក់ស្លាកឈ្មោះខ្ញុំម្ដងទៀត ។

**ទោះបីជារូបកាយខ្ញុំទាំងមូលពុំបានជាមួយរយភាគរយក៏ដោយ ក៏ដួងចិត្តរបស់ខ្ញុំបានត្រៀមរួចជាស្រេចដើម្បីបម្រើលោកចៅហ្វាយដែរ ។**

ប្រាំមួយខែក្រោយមក ខ្ញុំបានចាប់ផ្ដើមមានបញ្ហាសុខភាពដដែលនោះម្ដងទៀត ។ ខ្ញុំចាំពីការដេកនៅលើគ្រែនៅឯមន្ទីរពេទ្យ ដោយពីវ៉ាយអស់ជាច្រើនម៉ោងដោយការធ្វើតេស្ដ និង ចាក់ថ្នាំ ។ ខ្ញុំមិនចង់ជឿទេថាវាបានកើតឡើងម្ដងទៀត ។ ខ្ញុំដឹងថាលើកនេះ បេសកកម្មរបស់ខ្ញុំចប់ហើយ ។ ដោយការយំទាំងខកចិត្ត ព្រមទាំងសោកស្ដាយ នោះខ្ញុំបានស្ដាប់





ប្រធានបេសកកម្មដ៏វៃឆ្លាតរបស់ខ្ញុំនិយាយ « ស៊ីស្ទើរ រ៉ូម៉ាណែឡូ អ្នកបានស្រឡាញ់ព្រះអម្ចាស់យ៉ាងខ្លាំងពីរដងមកហើយ ដោយសារអ្នកបានត្រឡប់មកវិញ » ។ ខ្ញុំមានអារម្មណ៍កក់ក្ដៅយ៉ាងខ្លាំងដោយសារពាក្យសម្ដីរបស់គាត់ ។ ម្ដងនេះ ខ្ញុំបានជិះយន្តហោះទៅផ្ទះវិញ ខ្ញុំបានសន្យាជាមួយព្រះវរបិតាសួគ៌របស់ខ្ញុំថា ខ្ញុំនៅតែបន្តស្មោះត្រង់ ទោះបីជាខ្ញុំពុំបានទទួលចម្លើយរបស់ខ្ញុំក្ដី ។

## ស្វែងរកការជាសះស្បើយតាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ

ឥឡូវនេះវាអស់រយៈពេលជាងពីរឆ្នាំហើយតាំងពីខ្ញុំត្រឡប់មកផ្ទះវិញ ។ ខ្ញុំនៅតែមានបញ្ហាដដែលនោះ ហើយកម្លាំង និង ថាមពលរបស់ខ្ញុំពុំមានដូចពីមុនការបម្រើបេសកកម្មរបស់ខ្ញុំឡើយ ។ វេជ្ជបណ្ឌិតពុំបានរកឃើញថាខ្ញុំឈឺអ្វីឡើយ ។ វាពុំងាយស្រួលសម្រាប់ខ្ញុំដើម្បីធ្វើជាអ្នកត្រឡប់ពី បេសកកម្មដែលពុំបានបម្រើបេសកកម្មពេញនោះឡើយ ។ ទោះជាយ៉ាងណាខ្ញុំនៅតែស្រឡាញ់អ្នកប្រែចិត្តជឿដ៏ល្អៗរបស់ខ្ញុំគ្រប់គ្នា ។ វាចំណាយពេលយូរដើម្បីឲ្យខ្ញុំមានអារម្មណ៍ថាខ្ញុំបានបំពេញចប់សព្វគ្រប់ ហើយដឹងថាការបម្រើបេសកកម្មដ៏ខ្លីរបស់ខ្ញុំមានតម្លៃដូចជាបេសកកម្ម ១៨ ឬ ២៤ ខែរបស់អ្នកផ្សព្វផ្សាយសាសនាដទៃទៀតផងដែរ ។

ព្រះអម្ចាស់បានប្រទានឱកាសជាច្រើនឲ្យខ្ញុំនិយាយជាមួយមនុស្សដទៃដែលធ្លាប់ជួបពិសោធន៍នៃការឈឺចាប់ដែលបានត្រឡប់មកផ្ទះវិញ ដោយពុំបានរំពឹងទុកជាមុន ។ ខ្ញុំដឹងថាព្រះវរបិតាសួគ៌បាននាំខ្ញុំឲ្យជួបពួកគេចែកចាយទីបន្ទាល់ ព្រមទាំងជួយពួកគេឲ្យដឹងថាការត្រឡប់មកផ្ទះមុនកំណត់ ដោយសារបញ្ហាសុខភាពពុំមែនជាភាពទន់ខ្សោយ ដើម្បីរក្សាវាទុកជារឿងសម្ងាត់នោះទេ ប៉ុន្តែវាជាបទពិសោធន៍មួយដែលត្រូវតែពិភាក្សាគ្នា ។

លើកទីមួយដែលខ្ញុំត្រឡប់ទៅផ្ទះវិញ ខ្ញុំបានជួបបទពិសោធន៍នៃអារម្មណ៍ដែលព្រងើយកន្តើយនឹងសេចក្ដីជំនឿខ្លួន ប៉ុន្តែនៅលើកទីពីរដែលខ្ញុំបានត្រឡប់ទៅផ្ទះ នោះខ្ញុំមានអារម្មណ៍យ៉ាងល្អដើម្បីបន្តនៅស្មោះត្រង់ ។ ខ្ញុំបន្តធ្វើកិច្ចការដែលជាមូលដ្ឋាន ៖ សិក្សាព្រះគម្ពីរ ចូលរួមថ្នាក់វិទ្យាស្ថាន ចូលរួមសាសនាចក្រ ហើយបំពេញការហៅបម្រើរបស់ខ្ញុំ ។ ខ្ញុំបានអធិស្ឋានជាច្រើនដងដើម្បីដឹងពីមូលហេតុដែលរឿងរ៉ាវគ្រប់យ៉ាងបានកើតឡើង ។ ខ្ញុំឈប់បន្ទោសខ្លួនឯង ហើយខ្ញុំឈប់បន្ទោសព្រះវរបិតាសួគ៌ ។ នៅពេលខ្ញុំបានមើលទៅជីវិតរបស់ខ្ញុំ តាំងពីខ្ញុំត្រឡប់មកផ្ទះវិញ ហើយបានទៅលេងបងប្អូនប្រុសស្រីជនជាតិចិនរបស់ខ្ញុំ ដែលរស់នៅក្នុងទីក្រុងរបស់ខ្ញុំ នោះខ្ញុំបន្តឈរយ៉ាងរឹងប៉ឹង ដែលវាជាគោលដៅដ៏អស់កល្បចំពោះអ្វីៗទាំងនោះ ។

ខ្ញុំចូលចិត្តពាក្យពេចន៍នៅក្នុង ម៉ូសាយ ៥:១៥: « ហេតុដូច្នោះហើយ យើងចង់ឲ្យអ្នករាល់គ្នាតាំងចិត្តខ្ជាប់ខ្ជួន ហើយនឹងនរ គឺពោរពេញទៅដោយអំពើល្អជានិច្ច ដើម្បីឲ្យព្រះគ្រីស្ទ ដែលជាព្រះអម្ចាស់ ដ៏ជាព្រះដែលមានគ្រប់ព្រះចេស្ដា ទ្រង់បានភ្ជាប់អ្នកទុកជារបស់ផងទ្រង់ ដើម្បីឲ្យអ្នកបាននាំទៅកាន់ឋានសួគ៌គឺដើម្បីឲ្យអ្នករាល់គ្នាបានសេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ច និង ជីវិតដ៏នៅអស់កល្បជានិច្ចតាមរយៈប្រាជ្ញា និង ព្រះចេស្ដា និង សេចក្ដីយុត្តិធម៌ និង សេចក្ដីមេត្តាករុណារបស់ព្រះអង្គ ដែលបានបង្កើតវត្ថុសព្វសារពើនៅលើឋានសួគ៌ និង នៅលើផែនដីដែលជាព្រះលើអ្វីៗទាំងអស់ » ។

ខ្ញុំជឿថា បើសិនខ្ញុំបន្តរស់នៅដោយការលះបង់ចំពោះព្រះអម្ចាស់ នោះខ្ញុំនឹងទទួលបានពរជ័យជានិរន្តរ៍ ។ តាមរបៀបនេះខ្ញុំបានដឹងថា ខ្ញុំត្រូវបានជាសះស្បើយតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ទោះបីជារូបកាយខ្ញុំទាំងមូលពុំបានជាមួយរយភាគរយក៏ដោយ ក៏ដួងចិត្តរបស់ខ្ញុំបានត្រៀមរួចជាស្រេចដើម្បីបម្រើបុព្វហេតុនៃលោកចៅហ្វាយដែរ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*

**តើជម្រើសរបស់ខ្ញុំមានអ្វីខ្លះ បើខ្ញុំត្រឡប់មកផ្ទះវិញមុនកំណត់ដោយសារតែបញ្ហាសុខភាពនោះ ?**

ចំពោះអស់អ្នកដែលមានបញ្ហាខាងរូបកាយ ផ្លូវចិត្ត ឬ អារម្មណ៍ សូមពិភាក្សាជាមួយប៊ីស្សព ឬ ប្រធានសាខារបស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនៃការបម្រើនៃសាសនាចក្ររបស់អ្នកផ្សព្វផ្សាយសាសនា ។

« ការបម្រើបេសកកម្មអាចក្លាយជាពរជ័យមួយ ធ្វើឲ្យបុគ្គលម្នាក់ៗអាចនៅផ្ទះ ហើយទទួលការព្យាបាលត្រឹមត្រូវខណៈដែលអាចរីកចម្រើន និង មានភាពចាស់ទុំក្នុងការបម្រើព្រះអម្ចាស់ » ។

វេជ្ជបណ្ឌិត ដូណាល់ ប៊ី ដូទី ប្រធាននាយកដ្ឋានសេវាកម្មសុខភាពអ្នកផ្សព្វផ្សាយសាសនា « **Missionary Health Preparation** » ***Ensign,*** ខែ មិនា ឆ្នាំ ២០០៧ ទំព័រ ៦៧ ។

# រស់នៅជាសាក្សីម្នាក់នៅក្នុង ប្រទេសអាល្លឺម៉ង់



ដោយ ចាស្ទីណា ម៉ាកខេនលេស

ដោយចំណាយពេលតែ ៣០ នាទីជិះរថភ្លើងពីទីក្រុង ហាន់ណូវើរ នោះមានទីក្រុងតូចមួយនៃប្រទេសអាល្លឺម៉ង់នៅកណ្ដាលវាល ដែលពោរពេញដោយផ្កាអំឡុងពេលនៃរដូវផ្ការីកគឺទីក្រុង ស្ដាតហាហ្គិន ។ នេះជាកន្លែងដែលនាង អេស្ទើរ ប្រ្គាវ អាយុ ១៩ ឆ្នាំបានធំឡើង ។ វាជាកន្លែងមួយដែលអាចទៅណាក៏បានដោយថ្មើរជើង ឬជិះកង់ ជាកន្លែងដែលមានហាងនំប៉័ង និង ហាងការ៉េមនៅពេញតាមដងផ្លូវ ហើយជាកន្លែងដែលមានមនុស្សអ៊ូអររាល់ថ្ងៃ ។

ស្ដាតហាហ្គិន គឺជាតំបន់នៃសហាគមន៍ពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏សំបូរឧត្ដុងឧត្ដម ។

ទោះបីជាទីក្រុងនេះតូចក្ដី ស្ដាតហាហ្គិនមានវួដមួយដ៏ធំ — វាពិសេសណាស់សម្រាប់ប្រទេសអាល្លឺម៉ង់ ដែលមានសមាជិកតិចជាងប្រាំនាក់ក្នុងចំណោមប្រជាជនអាល្លឺម៉ង់ ១០,០០០ នាក់ ។ ប៉ុន្តែសម្រាប់អេស្ទើរ វាគឺជាកន្លែងដ៏ល្អបំផុតដើម្បីរៀនរស់នៅតាមគោលការណ៍នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និង ប្រើគោលការណ៍ទាំងនោះដើម្បីបម្រើ ហើយប្រទានពរដល់មនុស្សដទៃ ។

កាលអេស្ទើរ អាយុ ១៤ឆ្នាំនាងបានទទួលពររបស់លោកអយ្យកោ ដែលធ្វើឲ្យនាងដឹងពីអ្វីមួយដ៏សំខាន់ ។ នាងនិយាយថា « វាបានប្រែកាន់តែច្បាស់ចំពោះខ្ញុំ ថាខ្ញុំសំខាន់ខ្លាំងប៉ុណ្ណាចំពោះព្រះវរបិតាសួគ៌ » ។ « ខ្ញុំបានរៀនថាយើងម្នាក់ៗសំខាន់ខ្លាំងប៉ុណ្ណាចំពោះទ្រង់ » ។

នាងបានយកចំណេះដឹងនោះ ហើយអនុវត្តវាចំពោះទំនាក់ទំនងរបស់នាងជាមួយមនុស្សដទៃទៀត ។

ឧទាហរណ៍នៅក្នុងការហៅបម្រើរបស់នាង ក្នុងក្រុមប្រឹក្សាយុវមជ្ឈិមវ័យនៅលីវស្តេក នាងទទួលខុសត្រូវលើការធ្វើឲ្យប្រាកដថា មនុស្សគ្រប់គ្នាមានចំណែកនៅក្នុងក្រុម ។ « ខ្ញុំរៀនមិនរិះគន់មនុស្សដទៃឡើយ ប៉ុន្តែរៀនដើម្បីស្គាល់ពួកគេវិញ »។

នាងចាំចំណុចនេះទុកនៅពេលនាងនៅសាលារៀនផងដែរ ។ នាងនិយាយថា « ខ្ញុំត្រូវបានគេសួរជាញឹកញាប់អំពីជំនឿរបស់ខ្ញុំ ប៉ុន្តែខ្ញុំពុំឃើញថាវាអាក្រក់អ្វីឡើយ »។ « មានពេលខ្លះវាធ្វើឲ្យខ្ញុំរីករាយជានិច្ច ដោយសារពេលនោះខ្ញុំអាចរំឭកខ្លួនឯងបន្តិចអំពីការណ៍នេះថា វាពិតជាជួយខ្ញុំយ៉ាងខ្លាំង ព្រមទាំងអ្វីៗជាច្រើនដែលខ្ញុំបានទទួលក្នុងជីវិតនេះ ។ តាមរយៈដំណឹងល្អនោះខ្ញុំបានដឹងយ៉ាងច្រើន ។

នាងនិយាយថា « វានឹងតែងតែមានមនុស្សចំអកដល់ជំនឿរបស់យើង និងអ្នកដែលពុំយល់ពីជំនឿយើង ប៉ុន្តែវាគ្មានបញ្ហាអ្វីឡើយ នៅពេលយើងការពារសេចក្ដីជំនឿដែលយើងជឿនោះ » ។

**ការការពារសេចក្ដីជំនឿរបស់ខ្លួន បានធ្វើឲ្យនាងចែកចាយជំនឿនោះបានយ៉ាងស្រួល ។**

សេចក្ដីស្រឡាញ់ និង ការទុកចិត្តរបស់អេស្ទើរចំពោះព្រះ ជួយនាងបានច្រើនបំផុតដើម្បីរស់នៅតាម និងចែកចាយដំណឹងល្អ ។

នាងបាននិយាយថា « ពីមុនអ្នកព្រួយបារម្ភ សូមទុកចិត្តលើព្រះជាមុនសិន ។ នៅពេលខ្ញុំធ្វើបែបនោះ ហើយខ្ញុំមានសេចក្ដីជំនឿ នោះអ្វីផ្សេងទៀតដូចជាធម្មតា ។ ពេលយើងទុកចិត្តលើព្រះ នោះយើងអាចបន្តឆ្ពោះទៅមុខក្នុងជីវិតយើងដោយសេចក្ដីជំនឿ និង ទំនុកចិត្តក្នុងពេលអនាគត ។ នៅពេលយើងធ្វើបែបនោះ នោះយើងអាចរស់នៅធ្វើជាសាក្សីរបស់ព្រះ » ។ ■

*អ្នកនិពន្ធរស់នៅប្រទេសអាល្លឺម៉ង់ ។*



រូបថតទទួលបានសិទ្ធិអនុញ្ញាតដោយ អេស្ទើរ ហ្វ្រាវ





### សេចក្តីបន្ថែមអំពីអេស្ទើរ

***តើប្រជាជនអាល្លឺម៉ង់ចូលចិត្តបរិភោគអ្វីខ្លះ ?***

ប្រជាជនអាល្លឺម៉ង់ចូលចិត្តបរិភោគដំឡូង ឬ មីក្នុងឆ្នាំង ។ម្ហូបដែលខ្ញុំចូលចិត្តនោះគឺដំឡូងជាមួយបន្លែ និង ទឹកជ្រលក់ ។ ជាពិសេសខ្ញុំចូលចិត្តសណ្ដែកបារាំង និង ស្ពៃក្ដោប ។

***តើអ្នកធ្វើអ្វីសម្រាប់ការកម្សាន្ត ?***

ខ្ញុំស្ដាប់តន្ត្រី ច្រៀង និង លេងព្យាណូ ឬ ហ្គីតា ។ ខ្ញុំចូលចិត្តដុតនំប៉័ង ។ ខ្ញុំកំពុងរៀនធ្វើ នំខេកថ្មីៗដោយខ្លួនឯង ។

***តើការណាត់ជួបជាគូមានលក្ខណៈយ៉ាងដូចម្ដេចដែរនៅក្នុងប្រទេសអាល្លឺម៉ង់ ?***

យើងមិនណាត់ជួបជាគូឡើយ ។ វាចម្លែកបើសិនមានមនុស្សម្នាក់និយាយថា « តើអ្នកចង់ណាត់ជួបជាគូជាមួយខ្ញុំឬទេ ? » នៅទីនេះ អ្នកស្គាល់មនុស្សផ្សេងទៀតនៅក្នុងក្រុម ហើយបើសិនអ្នកចូលចិត្តនរណាម្នាក់ នោះអ្នកនិយាយជាមួយពួកគេតាមទូរសព្ទ ឬ អ៊ិនធើរណែត ។ ក្រោយមកអ្នកជួបគ្នាជាថ្មីម្ដងទៀត ហើយអ្នកអាចចាប់ផ្ដើមទាក់ទងគ្នា ឬក៏មិនទាក់ទងគ្នាឡើយ ។

### សាសនាចក្រនៅក្នុងប្រទេស អាល្លឺម៉ង់

- សមាជិក ៣៩,៤០១ នាក់
- ស្តេក ១៥
- វួដ ៨៩
- សាខា ៨៥
- បេសកកម្ម ៣
- ព្រះវិហារបរិសុទ្ធ ២

### ចំនួនជាតួលេខ

- ប្រជាជន ៨០,៩៩៥,៦៨៥ ( ការសន្មត់ចាប់ពីខែកក្កដា ឆ្នាំ ២០១៤ )
- សារមន្ទីរ ៦,២០០
- សួនសត្វជាង ៤០០ កន្លែងដែលច្រើនជាងគេបំផុតនៅលើពិភពលោកនេះ

### ព័ត៌មានលម្អិតអំពីប្រទេសអាល្លឺម៉ង់

**រដ្ឋធានី ៖** ប៉ែកឡាំង

**ភាសា ៖** អាល្លឺម៉ង់ ( Deutsch )



**ដោយប្រធាន**
**ឌៀថើរ អេហ្វ អុជដូហ្វ**
ទីប្រឹក្សាទីពីរក្នុងគណៈប្រធាន
ទីមួយ

# របៀប
# យល់ពីអត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់



នៅពេលយើងរៀបចំសម្រាប់បុណ្យគ្រីស្ទម៉ាស់ដោយការពិចារណាពីអត្ថន័យដ៏ពិតរបស់វា នោះយើងរៀបចំទទួលបទពិសោធន៍អំពីព្រះគ្រីស្ទ និង សារលិខិតរបស់ទ្រង់ ។ សូមឲ្យខ្ញុំផ្ដល់យោបល់បីដែលអ្នកចង់សិក្សា ពិចារណា ហើយអនុវត្តការរៀបចំនេះនៅក្នុងរដូវកាលនេះ ។

ទីមួយ សូមរីករាយជាមួយនឹងការប្រសូតរបស់ព្រះអង្គសង្គ្រោះរបស់យើង ។ យើងប្រារព្ធខួបកំណើតរបស់ព្រះរាជបុត្រានៃព្រះ ព្រះដ៏បង្កបង្កើត ឬ ព្រះមែស៊ី ។ យើងរីករាយថាស្ដេចនៃអស់ទាំងស្ដេចបានយាងមកផែនដីប្រសូតនៅក្នុងស្នូក ហើយបានរស់នៅក្នុងជីវិតដ៏ល្អឥតខ្ចោះ ។ នៅពេលព្រះយេស៊ូវប្រសូត នោះមានសេចក្ដីអំណរយ៉ាងខ្លាំងនៅលើឋានសួគ៌ដែលពុំអាចកំណត់បាន ( សូមមើល លូកា ២:៨–១៤ ) ។

ទីពីរ សូមពិចារណាពីព្រះចេស្ដារបស់ទ្រង់នៅក្នុងជីវិតរបស់យើងសព្វថ្ងៃនេះ ។ បុណ្យគ្រីស្ទម៉ាស់គឺជាពេលមួយដើម្បីចងចាំដល់ព្រះរាជបុត្រានៃព្រះ ហើយរំឭកការប្ដេជ្ញាចិត្តរបស់យើងដើម្បី លើកដាក់មកលើខ្លួនយើងនូវព្រះនាមរបស់ទ្រង់ ។ វាជាពេលដែលគិតពីជីវិតរបស់យើងឡើងវិញ ហើយពិនិត្យមើលពីគំនិត អារម្មណ៍ និងសកម្មភាពរបស់យើង ។ ចូរឲ្យឱកាសនេះជាពេលមួយនៃការចងចាំ អំណរគុណ និងជាពេលនៃការអភ័យទោស ។ ចូរឲ្យវាក្លាយជាឱកាសមួយដើម្បីពិចារណាពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង អត្ថន័យរបស់វាសម្រាប់យើងផ្ទាល់ខ្លួនម្នាក់ៗ ។ ជាពិសេសចូរឲ្យវាក្លាយជាពេលមួយនៃការរំឭកជាថ្មី និង តាំងចិត្តជាថ្មី ដើម្បីរស់នៅតាមព្រះបន្ទូលព្រះ ហើយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ ធ្វើបែបនេះ យើងនឹងគោរពទ្រង់ខ្លាំងជាង ការដែលយើងធ្លាប់មានជាមួយនឹងពន្លឺ អំណោយ ឬ ពិធីជប់លៀងនានា ។

ទីបី សូមរកមើលយ៉ាងខ្ជាប់ខ្ជួនពីការយាងមកជាលើកទីពីររបស់ទ្រង់ ។ អំឡុងពេលនៃរដូវបុណ្យគ្រីស្ទម៉ាស់នេះគឺជាពេលសាមញ្ញមួយដើម្បីត្រឡប់មើលក្រោយ ហើយប្រារព្ធការប្រសូតរបស់ព្រះអម្ចាស់របស់យើង សម្រាប់ខ្ញុំវាហាក់បីដូចជាពេលមួយនៃការប្រមើលមើលពីអនាគតកាល ។ ចូរឲ្យយើងសម្លឹងឆ្ពោះទៅមុខ ។ ចូរយើងរៀបចំខ្លួនសម្រាប់ថ្ងៃដ៏មានពរនោះ នៅពេលទ្រង់នឹងយាងមកម្ដងទៀត ។ ចូរយើងមានភាពឆ្លាតវៃដូចមនុស្សជំនាន់ដើមដែលចាំមើលការយាងមករបស់ទ្រង់ ។

ខ្ញុំសូមអធិស្ឋានថា អំឡុងពេលនៃរដូវកាលនេះ ហើយបន្តទៅមុខទៀត នោះយើងនឹងឃើញពីភាពច្បាស់លាស់នៃដំណើររឿងនៃការប្រសូតរបស់ព្រះអង្គសង្គ្រោះ ហើយមានអារម្មណ៍នៃអំណរគុណយ៉ាងស្មោះសរសម្រាប់ព្រះជន្មទ្រង់ ការបង្រៀន និង ការបូជានៃសេចក្ដីសង្គ្រោះរបស់ទ្រង់សម្រាប់ពួកយើង ។ សូមឲ្យអំណរគុណនេះ បណ្ដាលឲ្យយើងរំឭកពីការប្ដេជ្ញាចិត្តរបស់យើងដើម្បីធ្វើតាមទ្រង់ជាថ្មី ។ សូមឲ្យឱកាសនេះនាំយើងខិតកាន់តែជិតទៅគ្រួសាររបស់យើង សាសនាចក្ររបស់យើង និង មនុស្សដែលនៅជុំវិញយើង ។ ហើយសូមឲ្យយើងសម្លឹងយ៉ាងខ្ជាប់ខ្ជួននូវថ្ងៃនៃពរជ័យនោះ នៅពេលដែលព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ នឹងយាងមកលើផែនដីម្ដងទៀតក្នុងនាមជាព្រះអម្ចាស់របស់យើង ស្ដេចរបស់យើង និង ព្រះអង្គសង្គ្រោះដែលប្រទានពរដល់យើង ។ ■

*ដកស្រង់ចេញពីការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់របស់គណៈប្រធានទីមួយ ខែធ្នូ ឆ្នាំ ២០១០*

### តើអ្នកធ្លាប់បានអនុវត្តគោលការណ៍នេះដោយរបៀបណា ?

កាលពីបុណ្យគ្រីស្ទម៉ាស់ប៉ុន្មានឆ្នាំមុន ជីដូនខ្ញុំបានសូមឲ្យកូនរបស់គាត់ ព្រមទាំងចៅៗរបស់ខ្លួនបម្រើមនុស្សដទៃជំនួសគាត់ ។ ប្អូនស្រីៗរបស់ខ្ញុំបានចាក់ម្ជុលកូនក្មេង ហើយបានចែកវានៅឯស្នូនសត្វមួយ ហើយប្អូនប្រុសរបស់ខ្ញុំជួយដាក់ភ្លើងបុណ្យគ្រីស្ទម៉ាស់នៅផ្ទះរបស់ស្ត្រីមេម៉ាយម្នាក់ ។ ខ្ញុំបានស្វែងរកឈ្មោះគ្រួសារ ហើយយកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ ។ យើងទាំងអស់បានសរសេរសំបុត្រទៅជីដូនយើងរៀបរាប់ពីបទពិសោធន៍របស់យើង — គាត់បានយំនៅពេលគាត់បានអានសំបុត្រនោះ នៅពេលព្រឹកនៃបុណ្យគ្រីស្ទម៉ាស់ ។ ខ្ញុំមានអារម្មណ៍នៃអំណរគុណសម្រាប់គំរូជីដូនខ្ញុំ ហើយបានដឹងថានៅពេលខ្ញុំបាន « បំរើគ្នាទៅវិញទៅមក ដោយសេចក្ដីស្រឡាញ់វិញ » ( កាឡាទី ៥:១៣ ) នោះ ខ្ញុំបានទទួលសេចក្ដីសប្បុរសកាន់តែច្រើនទៀត ហើយមានអារម្មណ៍ខិតកាន់តែជិតទៅនឹងសមាជិកគ្រួសារទាំងអ្នកនៅរស់ និង អ្នកស្លាប់ ។

***អាមែនដា អេស វ៉េយូថាហ៍ ស.រ.អា.***

# អំណោយដែលផ្លាស់ប្ដូរជីវិត

## នៅឯហាងលក់របស់របរជជុះ

ដោយ គានូ វិល្លាម

មានឆ្នាំណាមួយនោះ យើងគ្មានប្រាក់ច្រើនសម្រាប់បុណ្យគ្រីស្ទម៉ាស់ឡើយ ដូច្នេះខ្ញុំបានអធិស្ឋានសុំជំនួយដើម្បីអាចទិញអំណោយមួយសម្រាប់ឪពុកចុងរបស់ខ្ញុំ គឺ អេគ្រាន ( ដែលបងស្រីខ្ញុំ និង ខ្ញុំហៅគាត់ថា វីហ្គី ) ។ បងស្រីខ្ញុំ និង ខ្ញុំមានប្រាក់តែពីរដុល្លារប៉ុណ្ណោះដើម្បីទិញអំណោយ ។

ពេលម្ដាយរបស់ខ្ញុំបាននិយាយថាយើងនឹងទៅហាងជជុះនៅក្បែរនោះដើម្បីទិញអំណោយ នោះខ្ញុំបានរត់ទៅក្នុងបន្ទប់ខ្ញុំ ហើយអធិស្ឋានសុំជំនួយ ៖ « សូមជួយពួកយើងទិញអំណោយមួយដែលមានតម្លៃពីរដុល្លារបានផង » ។

នៅហាងនោះ អ៊ីឡេនណា និង ខ្ញុំបានរកមើលនៅកន្លែងសៀវភៅ ហើយបានរកឃើញបណ្ដុំព្រះគម្ពីរដែលទើបចេញថ្មី ។ ពួកយើងរីករាយណាស់ដែលបានឃើញវា ។ ខ្ញុំបានកាន់វាយ៉ាងណែន នៅពេលពេលយើងបានរត់តាមច្រកផ្លូវទៅរកម្ដាយរបស់ខ្ញុំ ។ ដោយលោតចុះលោតឡើង យើងបាននិយាយព្រមគ្នាថា « ពួកខ្ញុំរកឃើញអំណោយមួយសម្រាប់វីហ្គីហើយ ! » នៅកន្លែងគិតលុយម្ដាយរបស់ខ្ញុំបានសួរថា « តើវាថ្លៃប៉ុន្មាន ? » អ្នកគិតលុយឆ្លើយថា « ពីរដុល្លារ » ។ ខ្ញុំបានទទួលចម្លើយចំពោះការអធិស្ឋានខ្ញុំហើយ ។

កាលនោះឪពុកចុងរបស់យើងពុំមែនជាសមាជិកឡើយ ។ គាត់ពុំចូលចិត្តពួកមរមនឡើយ គាត់ពុំជឿលើ « ព្រះគម្ពីរមរមន » ឡើយ ហើយគាត់ពុំចូលចិត្តឃើញសមាជិកមកយកពួកខ្ញុំទៅសកម្មភាពយុវជន និង យុវនារីឡើយ ។ គាត់ថែមទាំងបានដេញអែលឌើរចេញទៀតផង ។ ប៉ុន្តែសមាជិកវួដ និង អ្នកផ្សព្វផ្សាយសាសនាពុំបោះបង់គាត់ចោលឡើយ ។

នៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ យើងបានទុកអំណោយនោះឲ្យគាត់ចុងក្រោយគេ ។ អ៊ីឡេនណា និង ខ្ញុំបាននិយាយថា « នេះគឺជាអំណោយដ៏ល្អបំផុតដែលគ្មាននរណាម្នាក់ធ្លាប់ឲ្យប៉ាឡើយ ! វានឹងធ្វើឲ្យលោកប៉ាសប្បាយចិត្ត » ។ វីហ្គីបានទាយពីរបីដង ហើយយើងបានសើចពេលគាត់ឆ្លើយ ។ យើងបានប្រាប់គាត់ថា « វាគឺជាអំណោយដ៏អស្ចារ្យបំផុត » ។ វានឹងផ្លាស់ប្ដូរជីវិតរបស់លោកប៉ា ។ វាបានផ្លាស់ប្ដូរជីវិតរបស់ពួកខ្ញុំ » ។

ម្ដាយរបស់យើងបានបារម្ភថា គាត់នឹងខឹងពេលគាត់ដឹងថាអំណោយដែលជូនគាត់ជាអ្វី ប៉ុន្តែអ៊ីឡេនណា និង ខ្ញុំដឹងថាវាជារឿងត្រឹមត្រូវមួយដើម្បីធ្វើដូច្នេះ ។

នៅពេលគាត់បានបើកអំណោយនោះមើល គាត់បានអរគុណពួកយើងចំពោះអំណោយនោះ ហើយបាននិយាយថាគាត់នឹងអានវា ។

ដោយសារយើងស្រឡាញ់វីហ្គី នោះយើងចង់ឲ្យគាត់រៀនពីព្រះយេស៊ូវគ្រីស្ទ និង អំណោយនៃដង្វាយធួនរបស់ទ្រង់ ។ យើងចង់ឲ្យគាត់ជឿលើអ្វីដែលយើងធ្វើ អធិស្ឋាន និង ប្រែចិត្ត ហើយមានដំណឹងល្អនៅក្នុងជីវិតរបស់គាត់ ។

គាត់បានអាន ហើយអធិស្ឋានអំពីព្រះគម្ពីរមរមន ហើយដោយមានជំនួយពីអែលឌើរ និង សមាជិកវួដ នោះគាត់បានជ្រមុជទឹក ហើយឥឡូវក្លាយជាសមាជិកសាសនាចក្រ ។ យើងមានសេចក្ដីរីករាយដើម្បីផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយយើងដឹងថាយើងនឹងរស់នៅជាមួយគ្នាជារៀងរហូតជាក្រុមគ្រួសារ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អារីស្សូណា ស.រ.អា. ។*



*ខ្ញុំគ្មានប្រាក់ច្រើនទិញអំណោយមួយសម្រាប់ឪពុកចុងរបស់ខ្ញុំឡើយ ដូច្នេះមុនពេលយើងបានទៅទិញទំនិញ ខ្ញុំបានអធិស្ឋាន ។*

រូបគំនូរដោយ ឃើង ផេងស៊ុន

មេរៀនសម្រាប់ថ្ងៃអាទិត្យ

ប្រធានបទសម្រាប់ខែនេះ ៖ ស្ថាបនានគរព្រះនៅថ្ងៃចុងក្រោយនេះ

# មនុស្សបំណូលថ្មី

*ខ្ញុំជាសង្ឃតែម្នាក់ឯងគត់ដែលសកម្មនៅក្នុងវួដថ្មីរបស់ខ្ញុំ ។ តើខ្ញុំនឹងនាំពួកសង្ឃផ្សេងទៀតឲ្យមកព្រះវិហារដោយរបៀបណា ?*

**ដោយ ម៉ាធ្យូ ហ្វិតតុន**
ទស្សនាវដ្ដីសាសនាចក្រ

នៅពេលគ្រួសាររបស់ខ្ញុំបានផ្លាស់ប្ដូរទីលំនៅពីរបីខែក្រោយពី ខ្ញុំចូលអាយុ ១៨ ឆ្នាំ នោះខ្ញុំបានឃើញថា ខ្ញុំគឺជាអ្នកចំណូលថ្មីក្នុងវួដ ហើយជួបនឹងឧបសគ្គមួយ ។ អំឡុងពេលពីរសប្ដាហ៍បន្ទាប់ពីខ្ញុំបានផ្លាស់ចូលទៅនៅនោះ ពួកសង្ឃស្ទើរតែទាំងអស់ត្រូវបានក្លាយជាអែលឌើរ ។ ខ្ញុំក៏ត្រូវបានហៅបម្រើធ្វើជាជំនួយការទីមួយនៅក្នុងកូរ៉ុមសង្ឃ ។

នៅក្នុងការផ្ដល់ការហៅបម្រើនេះ ប៊ីស្សពបានពន្យល់ថាមានសង្ឃជាច្រើននៅលើបញ្ជីឈ្មោះ ប៉ុន្តែគ្មាននរណាម្នាក់បានមកព្រះវិហារឡើយ ។ យើងមានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីលើកទឹកចិត្តឲ្យពួកគេចូលរួម ។

គាត់បាននិយាយថា « គឺត្រូវអញ្ជើញពួកគេឲ្យមកព្រះវិហារ » ។

មានសង្ឃម្នាក់ទៀតតែប៉ុណ្ណោះដែលបានមកព្រះវិហារ គាត់ឈ្មោះរ៉ាយអែន ដែលមកព្រះវិហារពីរបីម្ដងរាល់ខែ ។ ខ្ញុំបានសម្រេចចិត្តទៅគោះទ្វាររបស់សមាជិកកូរ៉ុមដែលមិនសូវសកម្មរបស់យើង ហើយអញ្ជើញពួកគេឲ្យចូលរួមសកម្មភាពរបស់យើង ។ ខ្ញុំមានការព្រួយបារម្ភ ភ័យខ្លាចថាពួកគេអន់ចិត្តនឹងខ្ញុំដែលបានអញ្ជើញពួកគេឲ្យមកព្រះវិហារ ។ ខ្ញុំបានដឹងថា ពួកគេពុំមកព្រះវិហារដោយសារពួកគេមិនចូលចិត្តព្រះវិហារ ។ ប៉ុន្តែខ្ញុំក៏បានឃើញថា វាជាការណ៍ល្អសម្រាប់ខ្ញុំដើម្បីអនុវត្តសម្រាប់បេសកកម្មនាពេលខាងមុខរបស់ខ្ញុំ ដើម្បីព្យាយាមអញ្ជើញមនុស្ស ដូច្នេះខ្ញុំបានតាំងចិត្តដោយអំណត់ ហើយបានចាប់ផ្ដើមទូរសព្ទទៅសង្ឃដទៃផ្សេងទៀត ឬ បានឈប់ចូលលេងផ្ទះរបស់ពួកគេ ។ ខ្ញុំបានអញ្ជើញពួកគេមកការប្រជុំពិសេស សកម្មភាពនានា និងមកព្រះវិហារ ។

អ្វីដែលគួរឲ្យរំភើបនោះគឺថាពួកគេមួយចំនួនបានឆ្លើយតប ហើយបានត្រឡប់មកវិញ ។ ទីបំផុតយើងមានក្រុមមួយដែលមានសង្ឃបួននាក់ ដែលបានចាប់ផ្ដើមមកព្រះវិហារទៀងទាត់ ។ វាពុំមែនដោយសារតែពួកគេពុំចូលចិត្តព្រះវិហារនោះឡើយ — តែពួកគេបានរង់ចាំឲ្យមានការអញ្ជើញដើម្បីត្រឡប់មកវិញ ។ ពួកគេព្រួយបារម្ភអំពីស្ថានភាពថ្មី — ការចូលរួមព្រះវិហារ — ដូចដែលខ្ញុំធ្លាប់បារម្ភផងដែរ ។

សកម្មភាពមួយចំនួនមានភាពជោគជ័យជាងសកម្មភាពផ្សេងទៀត ។ ពួកគេបានមកចូលរួមលេងបាល់ទះ ប៉ុន្តែខ្ញុំពិបាកនាំពួកគេចូលរួមសកម្មភាពផ្សេងៗទៀត ។

សន្និសីទយុវវ័យនាឆ្នាំនោះបានទទួលលទ្ធផលជាពិសេស នៅពេលខ្ញុំបានមើលពួកយុវជនទាំងនេះបានក្រោកឡើង ហើយថ្លែងទីបន្ទាល់របស់ពួកគេ ។ ខ្ញុំបានមានអារម្មណ៍ថាខ្ញុំបានផ្លាស់ប្ដូរជីវិតរបស់ពួកគេ ។

អ្វីដែលប្លែកនោះគឺថាខ្ញុំបានឃើញថា រ៉ាយអែន បានមកចូលរួមព្រះវិហាររាល់សប្ដាហ៍ ហើយយើងបានក្លាយជាមិត្តភក្ដិល្អនឹងគ្នា ។

រ៉ាយអែន និង ខ្ញុំបានទទួលបព្វជិតភាពមិលគីស្សាដែកប្រហែលប្រាំមួយខែ បន្ទាប់ពីខ្ញុំបានផ្លាស់ទៅរស់នៅទីនោះ ។ ខ្ញុំបានជ្រើសរើសរង់ចាំរហូតបន្ទាប់ពីចប់បេសកកម្មទើបចូលរៀនមហាវិទ្យាល័យ ដូច្នេះខ្ញុំអាចធ្វើការសំន្សំប្រាក់ដើម្បីបម្រើបេសកកម្មរបស់ខ្ញុំ ។ រ៉ាយអែនមានការងារមួយធ្វើរួចទៅហើយ ហើយគាត់បានសម្រេចចិត្តពុំទាន់រៀនមហាវិទ្យាល័យផងដែរ ។ បន្ទាប់ពី ការងារយើងឧស្សាហ៍ដើរលេងជាមួយគ្នា ។

មានគ្រាមួយនោះ យើងបាននៅរហូតដល់យប់ជ្រៅព្យាយាមអានគម្ពីរអាលម៉ា ខណៈដែលរ៉ាយអែនអានព្រះគម្ពីរមរមនជាលើកដំបូង ។ យើងអស់កម្លាំងខាងរាងកាយណាស់ ប៉ុន្តែវាពោរពេញដោយកម្លាំងខាងវិញ្ញាណ ។ វាអស្ចារ្យណាស់ដែលឃើញរ៉ាយអែន



រូបគំនូរដោយ ដេវីដ ម៉ាលែន

ធ្វើការផ្លាស់ប្ដូរក្នុងជីវិតរបស់គាត់ ។ គាត់បានបោះបង់ទម្លាប់ចាស់របស់គាត់ចោល បង្កើតទម្លាប់កាន់តែប្រសើរឡើង ហើយគាត់បានផ្លាស់ប្ដូរមិត្តភក្ដិមួយចំនួនរបស់គាត់ ដូច្នេះគាត់អាចនៅជាមួយមនុស្សដែលមានបទដ្ឋានដូចគាត់ ។

ខ្ញុំបានរំពឹងដើម្បីទៅបម្រើបេសកកម្មរបស់ខ្ញុំតាំងតែពីខ្ញុំបានចាប់ផ្ដើមទៅព្រះវិហារពីរបីឆ្នាំមុនម្ល៉េះ ។ រ៉ាយអែនពុំប្រាកដថាគាត់នឹងទៅបម្រើបេសកកម្មដែរឬអត់ទេ ។ នៅពេលដើរលេងជាមួយគ្នានោះ យើងបានពិភាក្សាពីបេសកកម្មរបស់ខ្ញុំ និង ក្ដីរំភើបរបស់ខ្ញុំដើម្បីបម្រើ ។ នៅពេលខ្ញុំបានលើកទឹកចិត្តគាត់ ហើយឆ្លើយសំណួរនៃដំណឹងល្អ នោះខ្ញុំបានទទួលទំនុកចិត្តកាន់តែច្រើនលើសមត្ថភាពរបស់ខ្ញុំដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ រ៉ាយអែនមានអាយុគ្រប់ល្មមដើម្បីបម្រើ ប៉ុន្តែគាត់ពិបាកសម្រេចចិត្ត ។

គាត់បាននិយាយថា « ខ្ញុំពុំប្រាកដថា តើទីបន្ទាល់របស់ខ្ញុំរឹងមាំល្មមដែរឬអត់នោះទេ ទោះជាខ្ញុំមានអារម្មណ៍ល្អអំពី សាសនាចក្រនៅពេលនេះក្ដី » ។ « ខ្ញុំពិតជាចង់ទៅបេសកកម្មណាស់ ប៉ុន្តែវាពិបាកណាស់ដើម្បីចាកចេញពីគ្រួសាររបស់ខ្ញុំ » ។

ទីបំផុតថ្ងៃដែលខ្ញុំអាចបំពេញឯកសារសម្រាប់បេសកកម្មរបស់ខ្ញុំបានមកដល់ ។ នៅពេលខ្ញុំបានប្រាប់រ៉ាយអែន នោះគាត់បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ដោយគាត់បាននិយាយថាគាត់នឹងទៅបម្រើបេសកកម្មដែរ ។ ការហៅបម្រើបេសកកម្មរបស់ពួកយើងបានដល់នាយប់តែមួយដូចគ្នា ។ រ៉ាយអែន បានចាកចេញទៅបម្រើនៅប្រទេសកាណាដាមួយខែ មុនខ្ញុំចាប់ផ្ដើមបេសកកម្មរបស់ខ្ញុំនៅប្រទេសបារាំង ។

នៅពេលខ្ញុំបានត្រឡប់មកផ្ទះវិញក្រោយពីរយៈពេលពីរឆ្នាំ ខ្ញុំបានរកមើលពួកសង្ឃដែលខ្ញុំធ្លាប់បានជួយពួកគេ ។ វាធ្វើឲ្យខ្ញុំកើតទុក្ខដោយដឹងថាពួកគេមួយចំនួនបានឈប់ទៅព្រះវិហារមិនយូរប៉ុន្មានបន្ទាប់ពីខ្ញុំបានចេញទៅបម្រើ ប៉ុន្តែខ្ញុំរីករាយដើម្បីឃើញរ៉ាយអែនម្ដងទៀត ។ គាត់បានបម្រើបេសកកម្មដោយមានកិត្តិយស ហើយដូចជាអាលម៉ា និង បុត្រានៃម៉ូសាយដែរ ខ្ញុំមានសេចក្ដីអំណរយ៉ាងខ្លាំងដែលឃើញថា គាត់នៅតែជាបងប្អូនរបស់ខ្ញុំនៅក្នុងព្រះអម្ចាស់ ( សូមមើល អាលម៉ា ១៧:២ ) ។ ■

***វាពុំមែនដោយសារតែពួកគេពុំចូលចិត្តព្រះវិហារនោះឡើយ — គឺពួកគេបានវង់ចាំឲ្យមានការអញ្ជើញដើម្បីត្រឡប់មកវិញ ។***



# ពួកគេបានស្គាល់ យ៉ូសែប

តើយ៉ូសែប ស្ម៊ីធ ដែលជាព្យាការីនៃការស្ដារឡើងវិញនេះជាមនុស្សបែបណា ? យើងអាចរៀនបន្ថែមទៀតពីលោក តាមរយៈការអាននូវអ្វីដែលអស់អ្នកដែលបានជួបលោក និង អស់អ្នកដែលបានស្គាល់លោកច្បាស់បាននិយាយអំពីលោក ។



## អ្នកមិនមែនជាពួកមរមនដែលបានជួបយ៉ូសែប

មានអ្នកមិនមែនជាពួកមរមនជាច្រើនដែលបានជួបយ៉ូសែប មានការកោតសរសើរជាខ្លាំង ។ ឧទាហរណ៍ ហូសាយ យ៉ូស៊ី ដែលរៀនចប់ពីសាលា ហាវើត ដែលមិនយូរប៉ុន្មានត្រូវបានជ្រើសរើសធ្វើជាចៅហ្វាយក្រុង បូស្តុន បានទៅលេងយ៉ូសែប ស្ម៊ីធ នៅទីក្រុងណៅវូ ។ គាត់បាននិយាយថាយ៉ូសែបគឺជា« មនុស្សម្នាក់ដ៏អស្ចារ្យដែលអាចពន្យល់បានថា » គឺជាមនុស្សម្នាក់ដែលត្រូវបានកើតមកដើម្បីដឹកនាំ « ដ៏មានអំណាច . . . ដែលគួរឲ្យគោរព » ។ គាត់បាននិយាយថាសៀវភៅអាននាពេលខាងមុខអាចនិយាយពី យ៉ូសែប ស្ម៊ីធថាជាអ្នកដែល « មានឥទ្ធិពលខ្លាំងបំផុតលើជោគវាសនានៃប្រជាជនក្នុងប្រទេសរបស់លោក » ។[១]



## អ្នកប្រែចិត្តជឿថ្មីដែលបានជួបលោក

អ្នកប្រែចិត្តជឿដែលបានជួបយ៉ូសែប ស្ម៊ីធ នៅលើកដំបូងក៏បានបង្ហាញការកោតសរសេរចំពោះលោកផងដែរ ។ ប្រាំថ្ងៃបន្ទាប់ពីមកដល់ទីក្រុង ណៅវូ វិលាម ខ្លេតុនដែលមកពីប្រទេសអង់គ្លេស បានសរសេរសំបុត្រទៅផ្ទះ ៖ « យប់មិញនេះ មានគ្នាយើងជាច្រើននាក់ [ បាននៅ ] ជាមួយបងប្រុសយ៉ូសែប ដួងចិត្តរបស់យើងរីករាយដោយបានស្ដាប់គាត់និយាយអំពីនគរព្រះ លោកគឺជាមនុស្សម្នាក់ដែលមានសេចក្ដីស្រឡាញ់ ហើយរួសរាយចំពោះពួកយើងគ្រប់គ្នា ។ យើងមានអារម្មណ៍ថាស្រឡាញ់គាត់ជាខ្លាំង ហើយអ្នកទាំងអស់គ្នាក៏នឹងស្រឡាញ់គាត់ផងដែរ » ។[២]

ម៉ារី អាលីស ខាណាន់ ឡាមបើត ដែលមានអាយុ ១៤ ឆ្នាំពេលនាងបានមកដល់ទីក្រុងណៅវូ បាននិយាយថា « អ្នកដឹកនាំមួយចំនួនបាននៅទីនោះដើម្បីមកជួបពួកបរិសុទ្ធមួយក្រុមដែលបានមកតាមរយៈការជិះ [ ទូក ] ។ ក្នុងចំណោមនោះមានព្យាការីយ៉ូសែប ស្ម៊ីធ ។ ខ្ញុំបានដឹងភ្លាមនៅពេលខ្ញុំបានមើលឃើញលោក ហើយនៅពេលនោះខ្ញុំបានទទួលទីបន្ទាល់របស់ខ្ញុំថាលោកគឺជាព្យាការីរបស់ព្រះ » ។[៣]



*អ្នកអាចអានបន្ថែមទៀតអំពីយ៉ូសែប ស្ម៊ីធ នៅក្នុងជំពូកទី ៤៣ និង ៤៧ នៃ ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖យ៉ូសែប ស្ម៊ីធ ។ សេចក្ដីថ្លែងការណ៍នៅក្នុងមេរៀននោះ នឹងជួយអ្នកឲ្យស្គាល់ព្យាការីយ៉ូសែប ។*

រូបគំនូរដោយ ប្រេក ស្មុីត



## អស់អ្នកដែលបានស្គាល់លោកច្បាស់

យ៉ូហាន អិម បើហ៊ីសែល ជាសមាជិកសាសនាចក្រនាសម័យមុនគឺជាវេជ្ជបណ្ឌិត ។ គាត់ជួលផ្ទះគ្រួសារស្ម៊ីធរស់នៅជាច្រើនខែ ។ គាត់បាននិយាយថា យ៉ូសែប ស្ម៊ីធ មាន « អំណាចដួងចិត្តរឹងមាំ » មានថាមពលច្រើន « មានចំណេះដឹងជ្រៅជ្រះពីលក្ខណៈមនុស្ស » « មានសុភវិនិច្ឆ័យ » « មានទស្សនវិស័យទូលំទូលាយ » និង « ស្រឡាញ់សេចក្ដីយុត្តិធម៌ » ។ « លោកមានចិត្តល្អ ហើយចូលចិត្តយកអាសារគេ ចិត្តទូលាយ ហើយមានចិត្តមេត្តា រាក់ទាក់ ហើយរីករាយ ព្រមទាំងមានចរិតដែលគួរឲ្យកោតសរសើរ និង ចេះគិតចេះគូរ ។ គាត់ស្មោះត្រង់ ទៀងត្រង់ ក្លាហាន និង ឯករាជ្យ ព្រមទាំងគ្មាន [ អាការៈក្លែងបន្លំ ] ដូចជាមនុស្សផ្សេងឡើយ ជាមនុស្សកម្រកបាន » ។[៤]

ហូវើត ខូរ ជាស្មៀនម្នាក់របស់យ៉ូសែប មានការកោតសរសើរចំពោះសមត្ថភាពរបស់ព្យាការីពេលជួបនឹងមនុស្សគ្រប់ប្រភេទ — វេជ្ជបណ្ឌិត មេធាវី ពួកសង្ឃ និង មនុស្សផ្សេងទៀត — ដែលបានមក « សួរសំណួរពិបាកៗ »។ គាត់បានសរសេរថា យ៉ូសែប « មានឆន្ទៈធ្វើអ្វីគ្រប់យ៉ាងដែលតម្រូវឲ្យគាត់ធ្វើ ។ . . . ខ្ញុំពិតជារីករាយ នៅពេលឃើញថាលោកមានទំនាក់ទំនងយ៉ាងរលូនទោះជានៅក្នុងចំណោមពួកអ្នកវិទ្យាសាស្ត្រក្ដី ហើយលោក [ ត្រៀមខ្លួនជាស្រេច ] ដើម្បីឆ្លើយសំណួររបស់ពួកគេ » ។[៥]

ដានីយ៉ែល ឌី ម៉ាក់អរសើរ ដែលក្រោយមកបានដឹកនាំក្រុមរទេះរុញទៅជ្រលងភ្នំ សលត៍ លេក បាននិយាយថា « ទីបន្ទាល់របស់ខ្ញុំ គឺថា លោកគឺពិតជាព្យាការីនៃព្រះដ៏មានព្រះជន្មរស់ ហើយកាលណាខ្ញុំកាន់តែស្ដាប់ពាក្យសម្ដីរបស់លោក ហើយឃើញកិច្ចការដែលលោកធ្វើ នោះខ្ញុំកាន់តែជឿថា លោកពិតជាបានជួបព្រះគឺព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទមែន » ។[៦]

## ព្យាការីដែលបានស្គាល់លោក

យ៉ូហាន ថេល័រ ដែលក្លាយជាប្រធានទីបីនៃសាសនាចក្របានមានប្រសាសន៍ថា « បើសិនអ្នកសួរយ៉ូសែប . . . ពីលក្ខណៈរបស់អ័ដាម នោះលោកនឹងប្រាប់អ្នកភ្លាម លោកនឹងប្រាប់អ្នកពីទំហំ និង រូបរាង ព្រមទាំងអ្វីៗទាំងអស់របស់អ័ដាម ។ អ្នកអាចសួរលោកពីលក្ខណៈរបស់ ពេត្រុស យ៉ាកុប និង យ៉ូហាន នោះលោកអាចប្រាប់អ្នកបានទាំងអស់ ។ ហេតុអ្វី ? ដោយសារលោកបានឃើញពួកគេ » ។[៧]

ក្មួយប្រុសរបស់ព្យាការីគឺ យ៉ូសែប អែហ្វ ស្ម៊ីធ បានក្លាយជាប្រធានទីប្រាំមួយនៃសាសនាចក្រ ។ លោកបានសរសេរថាយ៉ូសែប ស្ម៊ីធ « ពោរពេញទៅដោយសេចក្ដីថ្លៃថ្នូរ និង បរិសុទ្ធបំផុតក្នុងលក្ខណៈជាមនុស្ស ដែលតែងតែបង្ហាញភាពរីករាយដោយស្មោះស — ក្នុងការលេងបាល់ វាយចំបាប់ជាមួយបងប្អូនរបស់លោក . . . និងរីករាយចំពោះខ្លួនឯង . . . លោកពោរពេញដោយសេចក្ដីអំណរ លោកពេញដោយសេចក្ដីរីករាយ លោកពេញដោយសេចក្ដីស្រឡាញ់ ហើយគ្រប់ចរិតថ្លៃថ្នូរផ្សេងៗទៀតដែលធ្វើឲ្យមនុស្សប្រែជាអស្ចារ្យ ហើយល្អ ព្រមទាំងមានភាពសាមញ្ញ និង បរិសុទ្ធស្របពេលជាមួយគ្នានោះ . . . ដោយព្រះគុណនៃព្រះ លោកមានអំណាច ដើម្បីយល់ដឹងពីគោលបំណងនៃព្រះដ៏មានគ្រប់ព្រះចេស្ដាផងដែរ ។ នោះគឺជាអត្តចរិតរបស់ព្យាការីយ៉ូសែប ស្ម៊ីធ » ។[៨] ■



កំណត់ចំណាំ

១. ហូសាយ ឃ្វីនស៊ី « Joseph Smith at Nauvoo » *Figures of the Past from the Leaves of Old Journals,* ការបោះពុម្ពលើកទី ៣ ( ឆ្នាំ ១៨៨៣ ) ទំព័រ ៣៧៦–៤០០ សូមមើលផងដែរ Richard L. Bushman, « The Character of Joseph Smith » *BYU Studies,* ភាគទី ៤២ លេខ ២ ( ឆ្នាំ ២០០៣ ) ទំព័រ ២៩–៣០ ។
២. Bushman « The Character of Joseph Smith » ទំព័រ ៣៣ ។
៣. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ( ឆ្នាំ ២០០៧ ) ទំព័រ ៤៩៦ ។
៤. *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ៤៩៨–៩៩ ។
៥. Bushman « The Character of Joseph Smith» ទំព័រ ២៩ ។
៦. *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ៤៩៦ ។
៧. *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ១០៣ ។
៨. *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ,* ទំព័រ ៤៩៩ ។




## តើអ្នក

# គឺជាអ្នកទទួល ឬ ជាអ្នកឲ្យ ?

តើ អ្នកធ្លាប់ឈប់មួយសន្ទុះហើយគិតថា *តើហេតុអ្វី* បានជាអ្នកបម្រើមនុស្សដទៃ និង រក្សាព្រះបញ្ញត្តិដែរឬទេ ? ខែនេះគឺជាឱកាសដ៏ល្អដើម្បីធ្វើកិច្ចការនេះ នៅពេលអ្នកសិក្សាអំពីការកសាងនគរព្រះនៅក្នុងមេរៀនរបស់អ្នកនៅព្រះវិហារ ។ អ្នកអាចសួរខ្លួនឯងថា តើខ្ញុំត្រូវបានជម្រុញទឹកចិត្តកាន់តែខ្លាំងតាមរយៈអ្វីដែលខ្ញុំអាច *ទទួលបាន* ឬ តាមរយៈអ្វីដែលខ្ញុំ *ផ្ដល់ដល់គេ ?*

សំណួរខាងលើនេះនឹងជួយអ្នកឲ្យឃើញថា តើអ្នកនឹងទទួលបាន ( គិតតែពីខ្លួនឯង ) ឬ ផ្ដល់ឲ្យគេ ( គិតពីមនុស្សដទៃ ) ។

វាមិនថ្មីឡើយ ដើម្បីគិតពីពរជ័យដែលអ្នកនឹងទទួល ប៉ុន្តែបើសិនអ្នកឃើញថាអ្នកគិតតែចង់បានជាងការផ្ដល់ឲ្យគេនោះសូមគិតពីព្រះ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀន ៖ « សូមចាំថា កិច្ចការនេះមិនមែនជារបស់អ្នក ឬខ្ញុំតែឯងនោះទេ ។ យើងអាចសម្លឹងមើលទៅព្រះហើយសុំជំនួយដ៏ទេវភាព » ( « Do Your Duty — That Is Best » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៥៨ ) ។ ■

រូបគំនូរដោយ ឆេរ ដេវីតសុន



# ប្រើវា

## ឬ បាត់បង់វា

បោះចោលការដោះសារ ហើយពង្រីកទេពកោសល្យរបស់អ្នក ។ អ្នកអាចដើរតួយ៉ាងសំខាន់
ដើម្បីធ្វើឲ្យពិភពលោកនេះក្លាយជាកន្លែងមួយដែលកាន់តែប្រសើរជាងនេះ ។

រចនាលម្អរូបថតដោយ ជីអូវ៉ាន់ណា ផុនតេស ខាសឹស

# « ខ្ញុំមានអារម្មណ៍ថាអសមត្ថភាពធ្វើជាប្រធានថ្នាក់យុវនារី ។ តើខ្ញុំអាចក្លាយជាអ្នកដឹកនាំល្អប្រសើរម្នាក់ដោយរបៀបណា ? »

បើសិនអ្នកមានអារម្មណ៍ថាអ្នកអសមត្ថភាព នៅពេលអ្នកទទួលការហៅបម្រើអ្វីមួយ នោះវាជារឿងសាមញ្ញទៅហើយ ។ យេរេមា អេណុក និង យ៉ូសែប ស្ម៊ីធ សុទ្ធតែនៅក្មេង ហើយទាំងអស់គ្នាមានអារម្មណ៍ថាអសមត្ថភាពនៅពេលពួកលោកបានទទួលការហៅមបម្រើធ្វើជាព្យាការី ប៉ុន្តែព្រះអម្ចាស់នៅតែប្រើពួកលោកដើម្បីពង្រីកនគររបស់ទ្រង់ ។ គឺដូចជាអ្វីដែលព្រះអម្ចាស់បានប្រើពួកព្យាការីពីបុរាណដើម្បីសម្រេចបាននូវរឿងអស្ចារ្យនានា នៅពេលអ្នកអធិស្ឋាន ហើយពឹងផ្អែកលើទ្រង់ នោះទ្រង់អាចប្រើអ្នក ។

ប្រហែលជាអ្វីមួយដ៏ល្អបំផុតដែលអ្នកអាចធ្វើបានសម្រាប់សមាជិកក្នុងថ្នាក់របស់អ្នកនោះគឺជាធ្វើជាមិត្តភក្តិរបស់ពួកគេ ។ សូមរៀនស្គាល់ឈ្មោះរបស់ពួកគេ ។ អ្នកអាចអធិស្ឋានសម្រាប់ពួកគេរាល់ថ្ងៃ ហើយប្រហែលជាតមអាហារសម្រាប់ពួកគេ បើសិនពួកគេមានការលំបាក ។ សូមគិតពី ការសួរសំណួរអំពីជីវិតរបស់ពួកគេក្រៅពីជីវិតនៅក្នុងព្រះវិហារ ញញឹម ហើយស្វាគមន៍ពួកគេ នៅទីណាដែលអ្នកជួបពួកគេ ហើយអង្គុយជាមួយពួកគេនៅព្រះវិហារ ឬ នៅសាលារៀន ។ សូមព្យាយាមរកមើលឲ្យឃើញនូវអស់អ្នកដែលត្រូវការសេចក្តីស្រឡាញ់ និង ការគាំទ្របន្ថែម ។

ហើយសូមកុំខ្លាចដើម្បីសុំជំនួយឡើយ ។ ព្រះវរបិតាសួគ៌នឹងមិនទុកឲ្យអ្នកនៅតែឯងឡើយ — ទ្រង់បានប្រទានទីប្រឹក្សា និង អ្នកប្រឹក្សាពួកយុវមជ្ឈិមវ័យដល់អ្នក ។ ពួកគេនឹងជួយអ្នក ហើយទ្រង់ក៏នឹងជួយអ្នកដែរ ។

ដូចប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) បានមានប្រសាសន៍ ៖ « សូមលុតជង្គង់ចុះ ហើយសុំពរជ័យពីព្រះអម្ចាស់ បន្ទាប់មកឈរយ៉ាងរឹងប៉ឹង ហើយធ្វើនូវអ្វីដែលអ្នកត្រូវបានស្នើឲ្យធ្វើ ។ បន្ទាប់មកសូមទុកបញ្ហានោះនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ចុះ ។ អ្នកនឹងឃើញថាអ្នកបានសម្រេចនូវអ្វីៗជាច្រើនដែលលើសពីតម្លៃ » ( « To the Women of the Church » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ១១៤ ) ។

**ធ្វើជាមិត្តភក្តិនឹងគ្នា**

ក្នុងនាមជាប្រធានថ្នាក់ ខ្ញុំក៏មានអារម្មណ៍អសមត្ថភាពផងដែរ។ ប៉ុន្តែវាសំខាន់ដើម្បី ព្យាយាមធ្វើឲ្យយុវនារីមានអារម្មណ៍នៃសេចក្តីស្រឡាញ់ និង រួមចំណែក ។ សូមធ្វើជាមិត្តភក្តិដែលគាំទ្រ ហើយស្តាប់ទីប្រឹក្សារបស់អ្នកនៅពេលធ្វើការសម្រេចចិត្តនានា ។ សូមធ្វើជាគំរូសុចរិត ហើយព្យាយាមរស់នៅតាមគុណសម្បត្តិនៃក្រុមយុវនារី ប៉ុន្តែកុំរំពឹងថាខ្លួនឯងក្លាយជាល្អឥតខ្ចោះឡើយ ។ អ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌រំពឹងចង់បានពីអ្នកនោះ គឺព្យាយាម ។ បើសិនអ្នកអំពាវនាវដល់ទ្រង់ នោះទ្រង់នឹងផ្តល់កម្លាំងដល់អ្នក និង ការណែនាំដែលអ្នកត្រូវការ ។

*រ៉េបេកា អ៊ែន អាយុ ១៦ ឆ្នាំ រដ្ឋ នូវ ហាំស្បៀរ ស.រ.អា.*



**បម្រើដោយមានឆន្ទៈ**

ខ្ញុំមានអារម្មណ៍ដូចគ្នាផងដែរ ចាប់តាំងពីខ្ញុំបានក្លាយជាប្រធានថ្នាក់ ម៉ៃម៉េត ។ ខ្ញុំនៅតែចាំពីអារម្មណ៍ដែលខ្ញុំបានមាននៅពេលខ្ញុំចូលទៅការិយាល័យរបស់ប៊ីស្សពសម្រាប់ការសម្ភាសន៍ ។ ខ្ញុំអាចបដិសេធបាន ប៉ុន្តែខ្ញុំបានដឹងថាវាមិនមែនជាការចាត់តាំងមកពីប៊ីស្សពរបស់ខ្ញុំឡើយ — វាគឺជាការហៅបម្រើមកពីព្រះ ។ ព្រះវរបិតាសួគ៌នឹងជួយយើងបំពេញការហៅបម្រើរបស់យើង បើសិនយើងមានឆន្ទៈចុះចូលខ្លួនយើងចំពោះទ្រង់ ហើយបន្ទាបខ្លួន ។

*នីខូល ភី អាយុ ១៦ ឆ្នាំ ប្រទេស ហ្វីលីពីន*

**ស្រឡាញ់អ្នកទាំងឡាយដែលអ្នកបម្រើ**

ដើម្បីក្លាយជាអ្នកដឹកនាំកាន់តែប្រសើរ នោះអ្នកត្រូវតែស្រឡាញ់មនុស្សដែលអ្នកបម្រើ ។ សូមបោះបង់ចោលនូវការច្រណែនឈ្នានីស ហើយមានការអភ័យទោសគឺជារឿងចំបាច់ណាស់ ។ អ្នកអាចអធិស្ឋានដើម្បីឃើញពីភាពសក្តិសមរបស់ពួកគេដូចដែលព្រះទតឃើញ ។ សូមអធិស្ឋានសុំសេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះអ្នក ព្រមទាំងចំពោះសមាជិកក្នុងថ្នាក់របស់អ្នកផងដែរ ។ ខ្ញុំដឹងពី



*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

បទពិសោធន៍នេះថា ការអភិវឌ្ឍន៍ខ្លួនអាចជួយអ្នកបង្កើនគុណសម្បត្តិ និង គុណតម្លៃដ៏ចាំបាច់ដើម្បីបំពេញការហៅរបស់អ្នក ។ ព្រះនឹងប្រទានអំណាចដល់អ្នក បើសិនអ្នកនឹងសុំជំនួយនោះ ។

*ម៉ារី ប៊ី អាយុ ១៦ ឆ្នាំ រដ្ឋ វ៉ាស៊ីនតោន ស.រ.អា.*



**សូមចាប់ផ្ដើមពីខ្លួនអ្នក**

អ្នកអាចក្លាយជាអ្នកដឹកនាំកាន់តែប្រសើរ ដោយអនុវត្តគុណសម្បត្តិនានាដែលអ្នកចង់មាន ។ សូមអធិស្ឋានសុំព្រះវិញ្ញាណឲ្យគង់នៅជាមួយនឹងអ្នកនៅពេលអ្នកធ្វើការសម្រេចចិត្ត ។ សូមអធិស្ឋានដើម្បីផ្ដល់ការយកចិត្តទុកដាក់លើតម្រូវការរបស់ពួកយុវនារី ។ មានអ្វីជាច្រើនដែលអ្នកអាចធ្វើដើម្បីក្លាយជាអ្នកដឹកនាំកាន់តែប្រសើរ ប៉ុន្តែខ្ញុំយល់ថាជំហានដំបូងនោះគឺការជឿថាអ្នកអាចធ្វើបានជានិច្ច ។

*សាវ៉ាន់ណា ភី អាយុ ១៥ ឆ្នាំ នៅ រដ្ឋ តិចសាស ស.រ.អា.*

**ចូលរួមព្រះវិហារបរិសុទ្ធ**

កាលខ្ញុំទើបតែបានហៅជាប្រធានក្លូរ៉ុមឌីកុន នោះខ្ញុំពុំប្រាកដឡើយពីរបៀបដើម្បីបង្កើនសមត្ថភាពខាងវិញ្ញាណរបស់ខ្ញុំ ។ ខ្ញុំបានចាប់ផ្ដើមធ្វើកិច្ចការពង្សប្រវត្តិជាធម្មតានៅរាល់ថ្ងៃអាទិត្យ ។ ខ្ញុំបានទៅព្រះវិហារបរិសុទ្ធរាល់ពេលព្រឹកថ្ងៃសៅរ៍ ។ គោលដៅរបស់ខ្ញុំគឺយកឈ្មោះបុរសៗ ធ្វើបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់ឲ្យកាន់តែញឹកញាប់តាមដែលខ្ញុំអាចធ្វើបាន ។ ក្រោយពីខ្ញុំបានទៅព្រះវិហារបរិសុទ្ធរាល់សប្ដាហ៍មកខ្ញុំមានអារម្មណ៍ខាងវិញ្ញាណកាន់តែច្រើនជាងមុន ហើយថាតាមការធ្វើរបៀបនោះខ្ញុំអាចជួយក្លូរ៉ុមរបស់ខ្ញុំបានកាន់តែល្អ ។

*ចូស ប៊ី អាយុ ១៣ ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.*

**សូមធ្វើតាមការបំផុសគំនិត**

បើសិនព្រះអម្ចាស់បានផ្ដល់ការហៅបម្រើមួយដល់អ្នក វាគឺដោយសារមានកិច្ចការមួយដែលអ្នកអាចធ្វើបាន ។ យើងត្រូវតែទូលសុំដល់ព្រះ ដូច យ៉ាកុប ១:៥ បាននិយាយ ។ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះវានឹងត្រូវបានបើកបង្ហាញដល់ពួកយើងនូវអ្វីដែលពួកយើងគួរតែធ្វើ ( សូមមើល នីហ្វៃទី ២ ៣២:៥ ) ។ ដោយមានជំនួយពីទ្រង់ នោះយើងអាច « នឹងដឹងនូវសេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ » ( មរ៉ូណៃ ១០:៥ ) ។ បន្ទាប់មកយើងត្រូវតែធ្វើតាមការបំផុសគំនិតដែលយើងទទួលបាននោះ ។ ខ្ញុំមានការជឿជាក់យ៉ាងជ្រាលជ្រៅថា ដោយសារព្រះអម្ចាស់ជាអង្គដែលដឹកនាំពួកយើង នោះយើងអាចតម្កើងការហៅរបស់យើងទាំងអស់បាន ។

*លូស៊ី ឌី អាយុ ១៧ នៅប្រទេស បារាំង*



**ដាក់ផែនការធ្វើសកម្មភាពដែលស្អាងគ្នា**

សូមធ្វើការប្រជុំជាទៀងទាត់ជាមួយគណៈប្រធានរបស់អ្នក ហើយដាក់ផែនការធ្វើសកម្មភាពដែលស្អាងគ្នា ដែលបំពេញសេចក្ដីត្រូវការ និង ចំណាប់អារម្មណ៍របស់យុវនារី ។ នៅពេលយុវនារីម្នាក់នៅក្នុងថ្នាក់របស់អ្នកពុំបានចូលរួមថ្នាក់ សូមឲ្យនាងដឹងថាអ្នកនឹកនាង ។ ខគម្ពីរមួយដែលបានជួយខ្ញុំនោះគឺ ម៉ូសាយ ១៨:៩ ។

*ការ៉ែន ភី អាយុ ១៦ ឆ្នាំ ប្រទេស ម៉ិកស៊ិកូ*



**ព្រះអម្ចាស់បានរើសអ្នក**

« ព្រះបានហៅអ្នក ។ ព្រះអម្ចាស់ស្គាល់អ្នក ។ ទ្រង់ស្គាល់អ្នកដែលទ្រង់មានព្រះទ័យឲ្យបម្រើ នៅក្នុងគ្រប់តួនាទីក្នុងសាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានរើសអ្នក ។ . . . បុគ្គលដែលត្រូវបានបំផុតគំនិតឲ្យស្នើដល់អ្នកចំពោះការហៅនេះ ពុំបានធ្វើដូច្នោះដោយសារតែ ពួកគាត់ចូលចិត្តអ្នក ឬ ពួកគាត់ត្រូវការនរណាម្នាក់ឲ្យធ្វើកិច្ចការជាក់លាក់ណាមួយឡើយ ។ ពួកគាត់បានអធិស្ឋាន ហើយបានទទួលចម្លើយថា អ្នកគឺជាបុគ្គលដែលត្រូវតែបានហៅ ។ . . .

« អ្នកត្រូវបានហៅឲ្យតំណាងព្រះអង្គសង្គ្រោះ ។ សំឡេងថ្លែងទីបន្ទាប់របស់អ្នកក្លាយជាសំឡេងរបស់ទ្រង់ដូចគ្នា ដៃរបស់អ្នកលើកឡើងដូចជាព្រះហស្តទ្រង់លើកឡើងដូចគ្នា » ។

ប្រធាន ហិនរី ប៊ី. អាវរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ « Rise to Your Call » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ៧៦ ។

## សំណួរបន្ទាប់

« ខ្ញុំចង់អញ្ជើញបងប្អូនជីដូនមួយរបស់ខ្ញុំមកព្រះវិហារ ប៉ុន្តែខ្ញុំខ្លាចឪពុកម្ដាយរបស់ពួកគេខឹងនឹងខ្ញុំ ។ តើខ្ញុំអាចចែកចាយទីបន្ទាល់របស់ខ្ញុំជាមួយជីដូនមួយរបស់ខ្ញុំដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹក ត្រឹម ថ្ងៃទី ១៥ខែ មករា ឆ្នាំ ២០១៦ នៅគេហទំព័រ liahona.lds.org ឬ អ៊ីម៉ែលទៅកាន់ liahona@ldschurch.org ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ ( ១ ) នាមត្រកូលទាំងមូល ( ២ ) ថ្ងៃខែឆ្នាំកំណើត ( ៣ ) វួដ ឬ សាខា ( ៤ ) ស្តេក ឬ មណ្ឌល ( ៥ ) លិខិតអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានមានអាយុក្រោម ១៨ ឆ្នាំ នោះត្រូវមានលិខិតអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬ មិនសូវច្បាស់លាស់ ។





ដោយ អែលឌើរ ដ៏គ
ក្លេបឹនហ្គាត
នៃពួកចិតសិបនាក់

## *អ្វីៗដែលខ្ញុំបានរៀនក្នុងនាមជា*

# អ្នកប្រែចិត្តជឿវ័យក្មេង

*កាលខ្ញុំទើបតែក្លាយសមាជិកថ្មីនៅក្នុងសាសនាចក្រ ខ្ញុំបានឃើញគំរូអស្ចារ្យនៃពលិកម្មពីយុវវ័យផ្សេងទៀតនៅក្នុងវួដរបស់ខ្ញុំ ។ ចាប់តាំងពីនោះមក ខ្ញុំបានរៀនមេរៀនដ៏អស្ចារ្យជាច្រើន ។*

ខ្ញុំបានចូលរួមសាសនាចក្រកាលខ្ញុំអាយុ ១៧ ឆ្នាំ ។ មានពួកអាមេរិកដែលមកពីបន្ទាយទាហាននៅក្នុងទីក្រុងរបស់ខ្ញុំក្នុងប្រទេសអាល្លឺម៉ង់ បានណែនាំខ្ញុំឲ្យស្គាល់ព្រះវិហារនេះ ។ គ្មានវួដដែលនិយាយភាសាអាល្លឺម៉ង់នៅក្នុងតំបន់របស់ខ្ញុំឡើយ ដូច្នេះខ្ញុំបានចូលរួមព្រះវិហារជាមួយពួកអាមេរិកាំងនោះនៅឯបន្ទាយទាហាននៅក្នុងសាលាជំនុំពហុនិកាយសាសនាដ៏តូចមួយរបស់ពួកទាហាន ។

នៅថ្ងៃអាទិត្យមួយមិនយូរប៉ុន្មានក្រោយពី ខ្ញុំបានទទួលបុណ្យជ្រមុជទឹក នៅចប់ម៉ោងប្រជុំ ប៊ីស្សព បានក្រោកឡើង ហើយនិយាយថា « តើឪពុកម្ដាយទាំងអស់ដែលមានកូនរៀនក្នុងសិក្ខាសាលាសូមអង្គុយសិនបានទេ ? » គាត់ក៏បានសុំឲ្យខ្ញុំចូលរួមជាមួយពួកគេផងដែរ ។

នៅពេលមានតែគ្រួសារទាំងនេះ ប៊ីស្សព និង ខ្ញុំដែលបន្តនៅក្នុងសាលាជំនុំ ប៊ីស្សពបានពន្យល់ថាខ្ញុំអាចចូលរួមថ្នាក់សិក្ខាសាលារបស់ពួកគេនៅឆ្នាំក្រោយ ។ ប៉ុន្តែខ្ញុំបានចូលរៀនសាលាអាល្លឺម៉ង់ក្នុងមូលដ្ឋាន ដែលចាប់ផ្ដើមជាងមួយម៉ោងមុនសាលាអាមេរិកាំងដែលមានយុវវ័យទាំងអស់មកពីបន្ទាយទាហានចូលរួមរៀន ។ ដើម្បីឲ្យខ្ញុំមានពេលគ្រប់គ្រាន់ធ្វើដំណើរទៅសាលារៀនទាន់ពេល ពួកគេត្រូវតែប្ដូរថ្នាក់សិក្ខាសាលាទៅម៉ោង ៦ ព្រឹកវិញ គឺមួយម៉ោងមុនពួកគេប្រជុំ ។

ក្រោយមកប៊ីស្សព បានសូមឲ្យពួកគេបោះឆ្នោតថា តើពួកគេព្រមធ្វើពលិកម្មនេះដែរឬទេ ដើម្បីឲ្យខ្ញុំអាចចូលរួមថ្នាក់នោះបាន ។ ភ្លាមនោះ ឪពុកម្ដាយ និង សិស្សទាំងអស់បានលើកដៃពួកគេឡើងហើយនិយាយថាយល់ព្រម ។

នោះគឺជាពេលមួយដ៏រំភើបចំពោះខ្ញុំ ។ វាបានបង្រៀនខ្ញុំនូវមេរៀននៃការលះបង់ ។



ប៊ីស្សព បានសូមឲ្យពួកគេបោះឆ្នោតឲ្យមានថ្នាក់សិក្ខាសាលាមួយម៉ោងមុន ដើម្បីឲ្យខ្ញុំអាចចូលរួមថ្នាក់នោះបាន ។ ពួកគេទាំងអស់គ្នាបាននិយាយថាយល់ព្រម ។



សិស្សវ័យក្មេងទាំងនេះមានឆន្ទៈលះបង់ផ្ទាល់ខ្លួននូវភាពស្រណុកសុខស្រួលរបស់ខ្លួន — មិនមែនតែមួយថ្ងៃ ឬ មួយសប្ដាហ៍ឡើយ ប៉ុន្ដែគឺសម្រាប់មួយឆ្នាំពេញ — ជំនួសឲ្យអ្នកប្រែចិត្តជឿថ្មីម្នាក់ដែលពុំអាចនឹងចូលរួមថ្នាក់សិក្ខាសាលាបានឡើយ បើគ្មានការលះបង់នោះ ។

ខ្ញុំនៅតែមានអំណរគុណចំពោះការលះបង់របស់ពួកគេ ដោយដឹងថា មួយឆ្នាំសិក្សានៃថ្នាក់សិក្ខាសាលា ( សិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា ) សំខាន់ខ្លាំងប៉ុណ្ណាសម្រាប់ជីវិតនៃការចូលព្រះវិហារដំបូងរបស់ខ្ញុំ ។ បើគ្មានថ្នាក់សិក្ខាសាលាទេ ខ្ញុំពុំមានការទាក់ទងជាមួយសាសនាចក្រឡើយលើកលែងតែថ្ងៃអាទិត្យ ។ ថ្នាក់សិក្ខាសាលាប្រចាំថ្ងៃគឺជាការរៀបចំដ៏អស្ចារ្យមួយសម្រាប់បេសកកម្ម ។ វាបានបង្រៀនខ្ញុំជាច្រើនអំពីការដាក់វិន័យ ហើយពិតមែនហើយ វាបានប្រទានពរដល់ខ្ញុំនូវចំណេះដឹងយ៉ាងច្រើនអំពីដំណឹងល្អ និង ព្រះគម្ពីរ ។ បើសួរខ្ញុំពីចំណេះចំណានខគម្ពីរទាំងអស់នៃគោលលទ្ធិ និង សេចក្ដីសញ្ញា តាំងពីមុនមកដល់ឥឡូវនេះខ្ញុំនៅតែចេះខគម្ពីរទាំងនោះ ។ បទពិសោធន៍ទាំងនេះបានជួយខ្ញុំឲ្យខិតកាន់តែជិតទៅព្រះវរបិតាសួគ៌ ហើយក៏បានជួយខ្ញុំឲ្យដោះស្រាយឧបសគ្គនានា ដោយសារខ្ញុំគឺជាសមាជិកសាសនាចក្រតែម្នាក់ឯងគត់ដែលនិយាយភាសាអាល្លឺម៉ង់នៅក្នុងទីក្រុងរបស់ខ្ញុំ ។

## ទំនាក់ទំនងជាមួយព្រះ

បន្ទាប់ពី ខ្ញុំរៀនចប់ ហើយពីមុនខ្ញុំបានទៅបេសកកម្ម ខ្ញុំបានបញ្ចប់វគ្គបម្រើទាហានដែលតម្រូវដោយច្បាប់ ។ ខណៈដែលខ្ញុំនៅក្នុងជួរទាហាន ខ្ញុំបានចាប់យកទម្លាប់មួយផ្ញើមកដល់សព្វថ្ងៃនេះ ៖ គឺអធិស្ឋានជានិច្ច ។

ពិតណាស់ ស្ថានភាពនៅក្នុងជួរកងទ័ពពុំមានបទពិសោធន៍ខាងវិញ្ញាណជានិច្ចនោះទេ — ទូរដាក់ខោអាវ រូបភាព ការនិយាយស្តី និងរឿងកុននានាដែលពួកគេមើលនៅពេលយប់ ។ ប៉ុន្តែខ្ញុំដឹងថាខ្ញុំនឹងបានទៅបម្រើបេសកកម្ម ។ ខ្ញុំចង់បន្តនៅតែរឹងមាំ ។ ខ្ញុំមិនចង់ទន់ជ្រាយឡើយ ។ ខ្ញុំមិនចង់បណ្ដោយខ្លួនទៅតាមសំពាធនៃមនុស្សជុំវិញខ្លួនឡើយ ។ ដូច្នេះខ្ញុំបានបង្កើនទម្លាប់នៃការអធិស្ឋាននៅក្នុងចិត្តខ្ញុំគ្រប់ពេល ។

ដោយដើរពីអគារមួយទៅអគារមួយទៀត ដើរចុះឡើងលើកូនភ្នំនៅក្នុងព្រៃ ដេកនៅក្នុងត្រង់សេ លេងល្បែងសង្គ្រាម — គ្រប់កន្លែងដែលខ្ញុំនៅនោះ ខ្ញុំបានទំនាក់ទំនងជាមួយព្រះវរបិតាសួគ៌ក្នុងការអធិស្ឋានតាមដែលខ្ញុំអាចធ្វើបាន ទោះគ្រប់នាទី ហើយពេលខ្លះជាច្រើនម៉ោង ដោយទាក់ទង ឬ ទូលទៅព្រះវរបិតាសួគ៌ដើម្បីខិតកាន់តែជិតទ្រង់ ហើយបន្តរឹងមាំ ។ ភាគច្រើនខ្ញុំបានអធិស្ឋានថ្លែងអំណរគុណ ។

ទម្លាប់នេះនៅជាប់នឹងខ្ញុំនៅឡើយ ។ នៅពេលខ្ញុំបើកបរទៅទីណា ឬ អង្គុយក្នុងឡានក្រុង ឬដើរទៅកន្លែងផ្សេងៗ វាក្លាយជារឿងសាមញ្ញសម្រាប់ខ្ញុំដើម្បីអធិស្ឋានរហូតនៅក្នុងចិត្ត ឬ « អធិស្ឋានជានិច្ច » ដូចដែលខគម្ពីរនិយាយ ( ឧទាហរណ៍ សូមមើល នីហ្វៃទី ២ ៣២:៩ ) ។ នោះគឺជាទម្លាប់ល្អមួយដើម្បីបង្កើតវាតាំងពីនៅក្មេងមក ។

យើងដឹងថាយើងគួរតែអធិស្ឋាន ប៉ុន្តែនោះពុំមែនគ្រាន់តែមានន័យថាជាការលុតជង្គង់មួយសន្ទុះនៅពេលព្រឹក និង ពេលយប់ដើម្បីបំពេញព្រះទ័យព្រះវរបិតានោះទេ ។ ការអធិស្ឋានគួរតែជាការធ្វើវាដោយស្មោះត្រង់ ជ្រាលជ្រៅ និង ជាទំនាក់ទំនងឥតដាច់ជាមួយព្រះវរបិតារបស់អ្នក ដែលជារឿងនឹងជួយអ្នកខិតកាន់តែជិតទ្រង់ ។ ការបង្កើតទម្លាប់នៃការអធិស្ឋាននេះ នឹងជួយអ្នកឲ្យដោះស្រាយការល្បួងទាំងអស់នៅក្នុងពិភពលោកនេះ ( សូមមើល នីហ្វៃទី ៣ ១៨:១៥, ១៨ ) ។ ដូច្នេះនៅពេលអ្នកចេញពីចំណុចក ទៅ ចំណុចខ ឬ នៅពេលណាដែលអ្នកទំនេរ សូមគិតចំណាយពេលតិចតួចបានហើយដើម្បីស្តាប់តន្ត្រី ឬ ផ្ញើសារ ហើយបន្ថែមពេលខ្លះទៀតដើម្បីអធិស្ឋានក្នុងចិត្តរបស់អ្នក ។

## អនុវត្តដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទគ្រប់ពេលវេលាទាំងអស់

នៅពេលយើងបន្តអធិស្ឋាន ហើយរៀនពីដំណឹងល្អ នោះយើងនឹងឃើញថាដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទមានសម្រាប់យើងគ្រប់ពេលរាល់ថ្ងៃដើម្បីជួយអ្នក « ទទួលការផ្ដាច់បាបទាំងឡាយរបស់អ្នក » ( សូមមើល ម៉ូសាយ ៤:១១–១២ ) ។ អ្នកអាចទាក់ទងទ្រង់ដើម្បីទទួលបានអំណាចនេះ ហើយធ្វើឲ្យខ្លួនបានជ្រះស្អាតគ្រប់ពេលទាំងអស់ មិនមែនគ្រាន់តែថ្ងៃអាទិត្យនោះទេ មិនមែនគ្រាន់តែនៅពេលពេលអ្នកទៅជួបប៊ីស្សពសារភាពកំហុសធ្ងន់ៗនោះទេ ។

ព្រះអម្ចាស់ផ្ដល់ផ្លូវនានាសម្រាប់អ្នកឲ្យផ្ដោតលើដង្វាយធួនរាល់ថ្ងៃ ដូច្នេះអ្នកអាចប្រែកាន់តែជ្រះស្អាត ហើយសក្តិសម ទទួលអារម្មណ៍នៃព្រះវិញ្ញាណ ព្រមទាំង

ត្រូវបានដឹកនាំគ្រប់ពេល ជាជាងម្ដងមាន ម្ដងគ្មានព្រះវិញ្ញាណទ្រង់ ។ តាមរយៈការផ្ដោតលើដង្វាយធួនរាល់ថ្ងៃ នោះអ្នកអាចមានពរជ័យនេះមិនថាអ្នកមានកំហុសអ្វី ដែលអ្នកបានធ្វើកាលពីអតីតកាលនោះទេ ។ យុវវ័យជាច្រើនមានអារម្មណ៍ថាការប្រែចិត្តគឺគ្រាន់តែជាការទៅជួបប៊ីស្សព ហើយប្រាប់គាត់ពីអំពើបាបធ្ងន់ធ្ងរនោះប៉ុណ្ណោះ ។ ប៉ុន្តែការប្រែចិត្តមានអត្ថន័យច្រើនជាងនេះឆ្ងាយណាស់ ។ វាមានន័យថាជាការខិតខំរាល់ថ្ងៃដោយបន្ទាបខ្លួន ភាពខ្ជាប់ខ្ជួន ពោរពេញដោយការអធិស្ឋានខិតខំរាល់ថ្ងៃដើម្បី ( ១ ) សិក្សាព្រះគម្ពីរ ជាពិសេស ខគម្ពីរដែលបង្រៀនអំពីដង្វាយធួនរបស់ព្រះគ្រីស្ទ ហើយបន្ទាប់មក ( ២ ) រៀនពីរបៀបដើម្បីអនុវត្តវាដោយពិតប្រាកដនៅក្នុងជីវិតរបស់អ្នកគ្រប់ពេលវេលាប្រចាំថ្ងៃ ។ នោះគឺជាអ្វី ដែលយើងត្រូវធ្វើ ។ សូមឲ្យព្រះវរបិតាសួគ៌ជ្រាបរាល់ថ្ងៃថានេះគឺជាអ្វីដែលអ្នកចង់បាន — គឺក្លាយខ្លួនកាន់តែប្រសើរជាងពីថ្ងៃម្សិលមិញ ។

សូមកុំបណ្ដោយឲ្យឧបសគ្គធ្វើឲ្យអ្នកមានគម្លាតពីព្រះវរបិតាសួគ៌ដោយធ្វើឲ្យអ្នកមានអារម្មណ៍ថាអ្នកមិនល្អគ្រប់គ្រាន់ឡើយ ថាមានមនុស្សផ្សេងទៀតល្អប្រសើរជាងខ្លួន — ឬថាដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និង សេចក្ដីស្រឡាញ់របស់ទ្រង់ ព្រមទាំងការពេញចិត្តរបស់ទ្រង់ដែលមាននៅចំពោះមុខអ្នក ប៉ុន្តែអ្នកពុំអាចឈោងចាប់បាន ។ នោះគឺពុំពិតទេ ។ ព្រះវរបិតាសួគ៌ស្រឡាញ់អ្នកដូចដែលអ្នកជាខ្លួនអ្នកនាពេលនេះ ប៉ុន្តែពិតណាស់ អ្នកត្រូវតែបន្តកែលម្អ និង ព្យាយាមគោរពតាមព្រះបញ្ញត្តិ *ជានិច្ច* ហើយអនុវត្តដង្វាយធួនរាល់ថ្ងៃ *គ្រប់ពេលវេលាទាំងអស់* ។ ដូចសាវកប៉ុលបាននិយាយ « ពិចារណាខ្លួនឯងមើល » ( កូរិនថូសទី ២ ១៣:៥ ) ។ ប៉ុន្តែនៅពេលអ្នករៀនពីដង្វាយធួន និង របៀបផ្ដោតលើវា នោះអ្នកនឹងឃើញថាអ្នកអាចមានអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ទោះបីជាអ្នកមានកំហុសក៏ដោយ ។

សូមស្គាល់ខ្លួនឯងឲ្យច្បាស់ ហើយស្គាល់ថាព្រះគ្រីស្ទជានរណា ហើយថាទ្រង់បានធ្វើអ្វីខ្លះសម្រាប់អ្នក ។ បន្ទាប់មកដាក់ចំណុចទាំងពីរនោះជាមួយគ្នា ដូច្នេះអ្នកអាចត្រូវបានជ្រះស្អាតគ្រប់ពេល ហើយមានទំនុកចិត្តលើខ្លួនឯង និង លើព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះ ។ បន្ទាប់ពីនោះអ្នកនឹងមានអារម្មណ៍ល្អនៃភាពសក្ដិសមផ្ទាល់ខ្លួន និង មានទំនុកចិត្តលើខ្លួនឯង ។

ទាំងនេះគឺជាអ្វីៗដែលខ្ញុំបានចាប់ផ្ដើមរៀនកាលខ្ញុំនៅជាអ្នកប្រែចិត្តជឿវ័យក្មេង ហើយវាបានប្រទានពរយ៉ាងច្រើនដល់ជីវិតខ្ញុំ ។ នៅពេលអ្នកធ្វើការលះបង់ សិក្សា ហើយព្យាយាមនៅជិតព្រះវរបិតាសួគ៌ នោះទ្រង់នឹងប្រទានពរដល់អ្នកផងដែរ ។ សូមកុំចុះចាញ់ឡើយ ! ■

## ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទមានសម្រាប់អ្នកគ្រប់ពេល និង រាល់ថ្ងៃ ។



ព័ត៌មានលម្អិតពេញពី នៅក្នុងច្បារគែតសេម៉ានី ដោយហារី អែនឌើរសុន

# ការអភិវឌ្ឍន៍ខ្លួនជាមួយ
# កម្មវិធីមែកធាងគ្រួសាររបស់ខ្ញុំ

*បងប្រុសខ្ញុំ និង ខ្ញុំគឺជាសមាជិកសាសនាចក្រតែពីរនាក់ក្នុងគ្រួសាររបស់ខ្ញុំ — យ៉ាងហោចណាស់ នោះគឺជាអ្វីដែលខ្ញុំបានគិតពីមុនការចាប់ផ្ដើមកិច្ចការពង្សប្រវត្តិរបស់ខ្ញុំ ។*

ដោយ រៀសា ម៉ាខុនដេស



ខ្ញុំបានពន្យាពេលធ្វើពង្សាវតារបស់ខ្ញុំជានិច្ច ។ ប៉ុន្តែបំណងប្រាថ្នារបស់ខ្ញុំដើម្បីបម្រើបេសកកម្មបាននាំខ្ញុំឲ្យដាក់គោលដៅជួយរៀបចំខ្លួនខ្ញុំឲ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏ល្អ ។ ដោយមានជំនួយពីប៊ីស្សពដ៏បំផុសគំនិត ខ្ញុំបានសម្រេចចិត្តបំពេញសៀវភៅ ការអភិវឌ្ឍន៍ខ្លួន ។ ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ ព្រមទាំងគម្រោងកិច្ចការល្អ នោះខ្ញុំត្រូវតែធ្វើកិច្ចការពង្សាវតា ។ ដូច្នេះខ្ញុំបានទៅធ្វើកិច្ចការនោះ ។

ខ្ញុំដឹងថាព្រះវិញ្ញាណបានដឹកនាំខ្ញុំ ដោយសារនៅយប់ថ្ងៃអាទិត្យមួយនោះ បន្ទាប់ពីធ្វើកិច្ចការនោះអស់បីម៉ោងមក មានហេតុដ៏អស្ចារ្យមួយបានកើតឡើង ។

នៅពេលខ្ញុំបានចាប់ផ្ដើម ខ្ញុំបានចាំថាជីតាលួតរបស់ខ្ញុំគឺជាអភិបាលរដ្ឋ អាម៉ាហ្សូនណាស់ ប្រទេសប្រេស៊ីល ។ ដូច្នេះខ្ញុំបានវាយឈ្មោះរបស់គាត់លើអ៊ិនធើរណែតស្រាវជ្រាវរកគាត់ ហើយខ្ញុំមានការភ្ញាក់ផ្អើល ខ្ញុំបានឃើញគេហទំព័រ Wikipedia ទាំងអំពីជីតាលួត និងជីដូនលួតខ្ញុំផងដែរ ! ភ្លាមនោះខ្ញុំបានដឹងពីទេពកោសល្យ និងអំណោយទានដែលខ្ញុំមានពីពួកលោក ហើយខ្ញុំមានអារម្មណ៍ក្ដុកក្ដួលក្នុងចិត្តឡើង ។ ប៉ុន្តែ មានអ្វីជាច្រើនទៀតដែលខ្ញុំបានរកឃើញ ។

ដោយការមើលតាមតំណភ្ជាប់នៃគេហទំព័រនោះ ខ្ញុំបានឃើញថាមានតំណភ្ជាប់មួយដាក់ថា « មែកធាងគ្រួសារ » ។ ខ្ញុំបានចុចលើវា ហើយខ្ញុំបានឃើញមែកធាងនៃគ្រួសាររបស់ខ្ញុំដែលខ្ញុំមិនធ្លាប់ដឹងថាមានសោះ ។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍បំផុតនោះគឺឈ្មោះរបស់យាយខ្ញុំគឺ រ៉ូសាលីណា មើរលេស បានបង្ហាញថាបានរស់នៅរដ្ឋ យូថាហ៍ ។

ខ្ញុំមានការភ្ញាក់ផ្អើលណាស់ ។ ខ្ញុំបានគិតថាមានតែបងប្រុសខ្ញុំ និង ខ្ញុំប៉ុណ្ណោះ ដែលជាសមាជិកសាសនាចក្រ ។ តើអាចមានសមាជិកផ្សេងទៀតក្នុងគ្រួសាររបស់ខ្ញុំជាសមាជិកសាសនាចក្រដែរឬអត់ ? នៅពេលខ្ញុំបានចុចលើឈ្មោះរបស់គាត់ ខ្ញុំបានឃើញតំណភ្ជាប់មួយទៅគេហទំព័រ Facebook ដូច្នេះខ្ញុំបានទាក់ទងគាត់ ។ ក្នុងពេលតែពីរថ្ងៃប៉ុណ្ណោះ ខ្ញុំបានទទួលសារមួយពីគាត់ ដោយបញ្ជាក់ថាយើងគឺជាសាច់ញាតិនឹងគ្នា ហើយថាគាត់ក៏ជាសមាជិកសាសនាចក្រផងដែរ ។

ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះព្រះវរបិតាសួគ៌ដែលបានធ្វើឲ្យខ្ញុំមាននូវសេចក្ដីអំណរដ៏ធំបែបនេះនៅក្នុងពេលនោះ ។

ខ្ញុំបានចាប់ផ្ដើមស្វែងរកជីដូនជីតារបស់ខ្ញុំដែលបានស្លាប់ទៅ ហើយព្រះវរបិតាសួគ៌បានប្រទានពរខ្ញុំដោយបានឃើញឈ្មោះគ្រួសារជាច្រើនទៀតដែលខ្ញុំអាចយកទៅព្រះវិហារបរិសុទ្ធ ។ ប៉ុន្តែទ្រង់ក៏បានជួយខ្ញុំឲ្យរកឃើញសមាជិកគ្រួសារដែលកំពុងរស់នៅផងដែរដែលស្មោះត្រង់នៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលត្រូវបានស្ដារឡើងវិញ ។ ហើយខ្ញុំជំពាក់គុណទាំងនេះចំពោះសៀវភៅការអភិវឌ្ឍន៍ខ្លួន កិច្ចការពង្សប្រវត្តិ និង បំណងប្រាថ្នារបស់ខ្ញុំដើម្បីបម្រើបេសកកម្ម ។

*អ្នកនិពន្ធរស់នៅម៉ាណាអុស ប្រទេសប្រេស៊ីល ។* ■

រូបគំនូរដោយ ជីម ម៉េឌស៊ីន



**ដោយអែលឌើរ ម៉ាកឹស ប៊ី ណាស**
នៃពួកចិតសិបនាក់

# ព្រះគម្ពីរសម្រាប់ ស្ដែនសើរ

« *ខ្ញុំចូលចិត្តអានគម្ពីរបរិសុទ្ធ ហើយរាល់ពេលដែលខ្ញុំអាន ខ្ញុំមានអារម្មណ៍ព្រះវិញ្ញាណចម្រើនក្នុងបេះដូង* » ( ចម្រៀងកុមារ *ទំព័រ ៦៦* ) ។

នៅពេលភរិយាខ្ញុំ និង ខ្ញុំបានរៀបការថ្មីថ្មោង ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល ( ១៨៩៥–១៩៨៥ ) បានលើកទឹកចិត្តសមាជិកសាសនាចក្រទាំងឡាយឲ្យអានព្រះគម្ពីររាល់ថ្ងៃជាមួយគ្រួសារពួកគេ ។ យើងចង់ធ្វើតាមព្យាការី ដូច្នេះយើងបានសម្រេចចិត្តថាយើងនឹងអានវាជាមួយគ្នាជាស្វាមីភរិយា និងក្រោយមកជាមួយកូនៗនាពេលអនាគតរបស់យើង ។

ជាច្រើនឆ្នាំក្រោយមក គ្រួសាររបស់យើងមានកូនប្រាំនាក់ រួមទាំងកូនពៅរបស់យើង ឈ្មោះស្ពែនសើរ ។

មានពេលមួយនោះ នៅពេលស្ពែនសើរអាយុប្រាំមួយឆ្នាំ ភរិយារបស់ខ្ញុំ និង ខ្ញុំត្រូវទៅឆ្ងាយពីផ្ទះពីរបីថ្ងៃ ហើយទុកកូនៗឲ្យនៅជាមួយអ្នកមើលក្មេង ។ នៅពេលយើងត្រឡប់មកផ្ទះវិញ នោះខ្ញុំបានអង្គុយជាមួយស្ពែនសើរ ហើយបានសួរគេពីអ្វីៗដែលបានកើតឡើងខណៈដែលពួកយើងមិននៅផ្ទះ ។

គាត់បានប្រាប់ខ្ញុំថាគាត់ពិបាកក្នុងការគេង ។ នៅពេលខ្ញុំបានសួរគាត់ពីមូលហេតុដែលគាត់ពុំបានគេងលក់ស្រួល នោះគាត់បានគិតពីវា ហើយបាននិយាយថាគាត់ពុំដឹងឡើយ ។

ក្រោយមកនៅល្ងាចនោះ គ្រួសាររបស់យើងបានចាប់ផ្ដើមធ្វើតាមទម្លាប់អានព្រះគម្ពីរមរមនរាល់យប់ជាមួយគ្នា ។

ភ្លាមនោះស្ពែនសើរបានស្រែកឡើងថា « ហ្នឹងហើយ ! » ខ្ញុំបានសួរថាគាត់កំពុងតែនិយាយអ្វី ។ « នោះហើយជាមូលហេតុដែលខ្ញុំពុំអាចគេងលក់ស្រួលនៅពេលយប់ » ។

« ហេតុអ្វីបានជាកូនពុំអាចគេងលក់ស្រួល ? » ខ្ញុំបានសួរ ។

« យើងពុំបានអានព្រះគម្ពីរនៅពេលយប់ឡើយ ពេលប៉ាម៉ាក់អត់នៅផ្ទះ ហើយខ្ញុំចូលចិត្តអារម្មណ៍ដែលព្រះគម្ពីរបានផ្ដល់ដល់ខ្ញុំយ៉ាងខ្លាំង » ។

ស្ពែនសើរ បានរៀនថាការអានព្រះគម្ពីររាល់ថ្ងៃនាំឲ្យពួកយើងមានភាពកក់ក្ដៅ មានសន្តិភាព និង ការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ។

យើងអាចរៀនស្រឡាញ់ព្រះគម្ពីរ នៅពេលយើងអានវារាល់ថ្ងៃ ។ នៅពេលយើងអានព្រះគម្ពីរ នោះយើងនឹងត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងត្រូវបានពង្រឹងតាមរយៈព្រះវរបិតាសួគ៌របស់យើង ។ ■



រូបគំនូរ ដោយ ជេរី ជូនស៍



# មេរៀនមួយពីឪពុកខ្ញុំ

**ដោយអែលឌើរ ដាវីឌ អេ បែដណា**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់



ខ្ញុំបានរៀនមេរៀនអស្ចារ្យមួយពីឪពុកខ្ញុំអំពីសិទ្ធិអំណាច និង អំណាចបព្វជិតភាព ។

ខ្ញុំបានចម្រើនវ័យធំឡើងក្នុងផ្ទះដែលមានម្ដាយដ៏ស្មោះត្រង់ និង ឪពុកដ៏អស្ចារ្យ ។ ឪពុកខ្ញុំមិនមែនជាសមាជិកសាសនាចក្រយើងទេ ប៉ុន្តែនៅតែមកការប្រជុំនានារបស់សាសនាចក្រយើងជាមួយគ្រួសារខ្ញុំ ។ គាត់បានបង្រៀនក្រុមបាល់បោះរបស់វួដយើង ហើយបានជួយសកម្មភាពក្រុមកាយរិទ្ធ ។

កាលនៅតូចខ្ញុំបានសួរឪពុកខ្ញុំជាច្រើនដងរៀងរាល់សប្ដាហ៍ថា ពេលណាគាត់នឹងទទួលបុណ្យជ្រមុជទឹក ។ ឪពុករបស់ខ្ញុំបានឆ្លើយរាល់លើក « ដាវីឌប៉ានឹងចូលជាសមាជិកសាសនាចក្រពេលប៉ាដឹងថាវាជារឿងត្រឹមត្រូវដើម្បីធ្វើវា » ។

នាថ្ងៃអាទិត្យមួយ ខ្ញុំបានសួរឪពុកខ្ញុំថាពេលណាគាត់នឹងទទួលបុណ្យជ្រមុជទឹក ។ គាត់គ្រាន់តែញញឹម ហើយបានសួរខ្ញុំសំណួរនេះ ។ « ដាវីឌ សាសនាចក្រកូនបង្រៀនថាបព្វជិតភាពត្រូវបានដកចេញពីផែនដីក្នុងគ្រាបុរាណ ហើយត្រូវបានស្ដារឡើងវិញដោយសារទូតសួគ៌ា ។ ប្រសិនបើសាសនាចក្ររបស់កូនពិតជាបានស្ដារនូវបព្វជិតភាពរបស់ព្រះឡើងវិញមែននោះហេតុអ្វីបុរសជាច្រើនក្នុងសាសនាចក្រកូនពុំបានធ្វើកាតព្វកិច្ចបព្វជិតភាពរបស់ពួកគេ ឲ្យខុសប្លែកពីបុរសៗនៅក្នុងសាសនាចក្ររបស់ប៉ាអញ្ចឹង ? »

ខ្ញុំគ្មានគំនិតអ្វីឡើយ ។ ខ្ញុំគ្មានចម្លើយសម្រាប់ឪពុកខ្ញុំទេ ។

ខ្ញុំបានដឹងថាបុរសដែលកាន់បព្វជិតភាព *គួរតែ* ធ្វើអ្វីមួយខុសពីបុរសដទៃទៀត ។ អ្នកកាន់បព្វជិតភាពមិនគួរគ្រាន់តែទទួលសិទ្ធិអំណាចបព្វជិតភាពប៉ុណ្ណោះទេ តែត្រូវស្មោះត្រង់ និង សក្ដិសមដើម្បីអនុវត្តអំណាចនៃព្រះផងដែរ ។

ខ្ញុំបានសម្រេចចិត្តថាខ្ញុំនឹងមិនចង់ធ្វើជាគំរូអាក្រក់ដល់ឪពុកខ្ញុំឡើយ ។ និយាយសាមញ្ញទៅគឺខ្ញុំចង់ក្លាយជាក្មេងល្អ ។ ព្រះអម្ចាស់ត្រូវការយើងទាំងអស់គ្នាដែលជាអ្នកកាន់បព្វជិតភាពឲ្យក្លាយជាមនុស្សប្រកបដោយកិត្តិយស គុណធម៌ និង ជាក្មេងល្អនៅគ្រប់ពេល និង គ្រប់ទីកន្លែង ។

ជាច្រើនឆ្នាំក្រោយមក ឪពុករបស់ខ្ញុំ *ត្រូវ* បានជ្រមុជទឹក ។ ខ្ញុំបានមានឱកាសប្រគល់បព្វជិតភាពអើរ៉ុន និង មិលគីស្សាដែកដល់គាត់ ។ បទពិសោធន៍ដ៏អស្ចារ្យមួយក្នុងជីវិតខ្ញុំគឺការឃើញឪពុកខ្ញុំទទួលសិទ្ធិអំណាច និង ទីបំផុតគឺអំណាចនៃបព្វជិតភាព ។ ■

**ព្រះគម្ពីរមរមន អំណោយមួយមកពីព្រះវរបិតាសួគ៌**
យ៉ូសែប ស្មីធ — ប្រវត្តិ ១:២៩–៣៥, ៤២–៥៤, ៥៩–៦០



យ៉ូសែប ស្មីធ



ទេវតាម៉ូរ៉ូណៃ





សូមកាត់រូបភាពទាំងនេះចេញ ហើយបិទវាដោយកាវ ឬ ស្កុត ឲ្យជាប់ទៅនឹងក្រដាសកាតុង ក្រដាសរឹង ថង់ក្រដាសតូចៗ ឬបន្ទះឈើស្ដើងៗ ។ សូមដាក់រូបទាំងនេះនៅក្នុងស្រោមសំបុត្រ ឬ ថង់មួយព្រមទាំងបិទស្លាកដែលមានខគម្ពីរលើនោះ ។

រូបគំនូរដោយ បេត វិយថេកឃើរ

# យប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ ជាមួយគ្រួសារក័រដូបាស់



*ម៉ារីសេឡូ និង ខ្ញុំមានតែអំណោយមួយគត់ ។ តើយើងអាចចែកគ្នាយ៉ាងដូចម្ដេចទៅ ?*



**ដោយ ហាន់នី ថាលា កាបិល ឡូស្ហ**
ផ្អែកទៅលើដំណើររឿងពិត

« *ដែលអ្នកបាល់គ្នាធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ* » ( *ម៉ាថាយ ២៥:៤០* ) ។

នៅយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់មានអំណោយតែពីរគត់នៅក្រោមដើមគ្រីស្ទម៉ាស់តូចរបស់យើង ។ មួយសម្រាប់ប្អូនស្រីអាយុពីរឆ្នាំរបស់ខ្ញុំ ម៉ារីសេឡូ ហើយមួយទៀតសម្រាប់ខ្ញុំ ។ ម្ដាយខ្ញុំបាននិយាយថា គាត់មានលុយតិច ដូច្នេះមានអំណោយតែប៉ុណ្ណឹងដែលយើងមាន ។

នៅយប់នោះម្ដាយយើងបានអានរឿងមួយក្នុង *លីអាហូណា* អំពីបុណ្យគ្រីស្ទម៉ាស់មួយដោយគ្មានអំណោយអ្វីសោះ ។ នៅពេលគាត់បានអាន ខ្ញុំមានអារម្មណ៍រីករាយ និង មានភាពសុខសាន្តក្នុងចិត្ត ។ ប្រហែលជាការមានអំណោយតែមួយនោះវាមិនអន់នោះឡើយ ។ បន្ទាប់មកម្ដាយបាននិយាយថា « ជំនួសឲ្យការលេងល្បែងកម្សាន្តដូចដែលយើងធ្លាប់ធ្វើសម្រាប់យប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ តើយើងអាចយកអំណោយមួយទៅឲ្យគ្រួសារមួយនៅក្នុងវួដរបស់យើងវិញយ៉ាងម៉េចដែរ ? »

« ប៉ុន្តែតើយើងអាចឲ្យអ្វីដល់ពួកគេ ? » ខ្ញុំបានសួរ ។

« យើងមានអំណោយដែលអាចលៃលកបាន » ។

ខ្ញុំបានក្រឡេកមើលទៅអំណោយទាំងពីររបស់យើង បន្ទាប់មកមើលរូបព្រះយេស៊ូវនៅលើជញ្ជាំង ។ « ខ្ញុំគិតថាព្រះយេស៊ូវនឹងចែកចាយអ្វីដែលទ្រង់មាន » ។

ពួកយើងបានអធិស្ឋានអំពីគ្រួសារដែលយើងគួរទៅសួរសុខទុក្ខ ។ គ្រួសារជាច្រើនដែលយើងស្គាល់ពុំសូវមានអ្វីច្រើនឡើយ ។ បន្ទាប់ពីអធិស្ឋានហើយយើងមានអារម្មណ៍ថាយើងគួរទៅសួរសុខទុក្ខគ្រួសារគ័រដូបាស់ ។ ពួកគាត់មានកូនបីនាក់ ហើយឪពុករបស់ពួកគាត់គ្មានការងារធ្វើឡើយ ។

យើងបានទៅហាង ហើយទិញ *ប៉ាណេតុន* ( ជានំប៉័ងនៅរដូវបុណ្យនោះ ) មានដុតមួយព្រមទាំងអំណោយតូចៗបី ។ យើងសប្បាយចិត្តដែលបានទិញវាមក ។ ម៉ាក់បានចំណាយប្រាក់ទាំងអស់ដែលគាត់មានប្រហែល ៣០ ពេសូ *តែឯង* ( ប្រហែល១០ ដុល្លារស. រ. អា. ) ។

ពេលយើងបានទិញវារួចហើយ យើងបានជិះឡានទៅផ្ទះគ្រួសារគ័រដូបាស់ ។ ខ្ញុំបានកាន់ដៃរបស់ម៉ារីសេឡូ នៅពេលយើងដើរទៅមាត់ទ្វារ ។

បងស្រី គ័រដូបាស់ បានឃើញពួកយើង ហើយបានចេញមកឱបយើង ។ « ឱជាការភ្ញាក់ផ្អើលអ្វីម្ល៉េះ ! សូមចូលមក ! គាត់បាននិយាយថា សូមអង្គុយមក » ។ នៅពេលយើងដើរចូលក្នុងផ្ទះ គាត់បានក្ដាប់ដៃរបស់ម្ដាយ ហើយបានអង្អែលសក់របស់ខ្ញុំ ។ គាត់បានប្រាប់ខ្ញុំថា « រ៉ូឡែនដូ និង ពួកស្រីៗនឹងសប្បាយចិត្តពេលឃើញអ្នកទាំងអស់គ្នា » ។

ផ្ទះគ្មានកម្រាលឥដ្ឋឡើយគឺជាកម្រាលដី ។ គ្មានភ្លើងអគ្គិសនីឡើយ មានតែភ្លើងទានទេ ។ ខ្ញុំមានអារម្មណ៍អាណិតគ្រួសារគ័រដូបាស់ ។ ខ្ញុំប្រាថ្នាថាយើងអាចធ្វើអ្វីជាច្រើនទៀតដើម្បីជួយពួកគេ ។ ប៉ុន្តែម្ដាយខ្ញុំហាក់បីដូចជាពុំចាប់អារម្មណ៍នឹងដី ឬ ភ្លើងទានឡើយ ។ គាត់សប្បាយចិត្តណាស់ ដែលបាននៅទីនេះជាមួយបងស្រីគ័រដូបាស់ ។

« ពួកយើងមកជូនពរអ្នក *ហ្វេលីស្ស ណាវីដាដ* ( *រីករាយថ្ងៃបុណ្យណូអែល* ) ! » ម៉ាក់បាននិយាយ ។ « យើងរីករាយណាស់ដែលយើងគឺជាមិត្តភក្ដិនឹងគ្នា » ។ គាត់បានជូនអាហារ និងអំណោយដល់បងស្រី គ័រដូបាស់ ដែលគាត់បានញញឹមយ៉ាងខ្លាំង ហើយបានថ្លែងអរគុណ ។

រ៉ូឡែនដូ ម៉ាដេលីន និង វ៉ាឃ្សី បានរត់ចេញពីបន្ទប់ផ្សេងចូលមកហើយនិយាយថាសួស្ដី ។ ម៉ារីសេឡូ បានផាក្បែរជើងរបស់ខ្ញុំហើយញញឹម ។ នាងបានសើចនៅពេលរ៉ូឡែនដូបានធ្វើមុខកំប្លែងដាក់នាង ។ មិនយូរប៉ុន្មានគ្រប់គ្នាបានជជែកគ្នានិយាយរឿងកំប្លែង ហើយសើចសប្បាយ ។

ខ្ញុំបានគិតថា « នេះវាសប្បាយជាងការលេងល្បែងកម្សាន្តតែខ្លួនយើងទៅទៀត » ។ ខ្ញុំសប្បាយចិត្តដែលយើងបានមកទីនោះ ។ វាគ្មានបញ្ហាអ្វីឡើយទោះបីជាយើងពុំមានអ្វីច្រើនចែកចាយជាមួយពួកគេក្ដី ។ ហើយវាគ្មានបញ្ហាអ្វីឡើយ ទោះបីជាវាជាកម្រាលដីក្ដី ។ បុណ្យគ្រីស្ទម៉ាស់គឺពុំមែនពីអ្វីដែលយើងមាននោះឡើយ ។ វាគឺជាការជួបជុំគ្នាទាំងអស់គ្នា ។

នៅពេលយើងរៀបនឹងចេញមកវិញ បងស្រីគ័រដូបាស់ បានឱបយើងម្ដងទៀត ។ គាត់ពោលថា « អរគុណខ្លាំងណាស់ » ។ សំឡេងរបស់គាត់ញ័រ ហើយខ្ញុំបានឃើញថាគាត់បានយំ ។ ខ្ញុំបានឈរចំអើតជើង ហើយថើបថ្ពាល់បងស្រី គ័រដូបាស់ ។

ខ្ញុំបាននិយាយថា « ហ្វេលីស្ស ណាវីដាដ ( រីករាយថ្ងៃបុណ្យណូអែល ) » ។ ■

*អ្នកនិពន្ធរស់នៅប្រទេសប៉េរូ ។*

រូបគំនូរដោយ ក្រែក ណឺវើ

# ល្បែងផ្គុំរូប ការស្ដារឡើងវិញ




*តើពាក្យថា ការស្ដារ ឡើងវិញ មានន័យដូចម្ដេច ?*


**ដោយ ហៃឌី ផ្ទូលមេន**
ផ្អែកទៅលើដំណើររឿងពិត


« *ដ្បិតយើងបានដាក់មកលើអ្នកនូវកូនសោទាំងឡាយ និង អំណាចនៃបព្វជិតភាព ដែលយើងសាងឡើងវិញនូវការណ៍គ្រប់យ៉ាង* » ( *គ. និង ស. ១៣២:៤៥* ) ។

នៅតាមផ្លូវពីព្រះវិហារត្រឡប់ទៅផ្ទះវិញ អាណាបានចាំពីក្រដាសតូចមួយដែលគ្រូរបស់នាងបានឲ្យនាង ។ « ម៉ាក់ សូមទាយមើល ! ខ្ញុំនឹងឡើងនិយាយនៅក្នុងថ្នាក់បឋមសិក្សានៅថ្ងៃអាទិត្យក្រោយ » ។

ម៉ាក់បានតបថា « ល្អណាស់ » ។ « និយាយពីអ្វីទៅកូន ? »

« កូនត្រូវនិយាយអំពីការស្ដារឡើងវិញ ។ ប៉ុន្តែកូនមិនប្រាកដថាតើការស្ដារឡើងវិញនោះជាអ្វីឡើយ » ។

ម៉ាក់បាននិយាយថា « *ការស្ដារឡើងវិញ* មានន័យថាព្រះបាននាំត្រឡប់មកវិញ ឬ ស្ដារឡើងវិញ នូវអ្វីគ្រប់យ៉ាងដែលទ្រង់ចង់ឲ្យសាសនាចក្រទ្រង់មាន » ។ « តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ទ្រង់បាននាំត្រឡប់មកនូវព្រះវិហារបរិសុទ្ធ បព្វជិតភាព បុណ្យជ្រមុជទឹក និង អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ បើគ្មានការស្ដារឡើងវិញទេ នោះយើងនឹងគ្មានសាសនាចក្រនេះឡើយ ! »

អណាបានងក់ក្បាល ។ « កូនគិតថាកូនយល់វាហើយ ។ ប៉ុន្តែកូនគិតថា កូនពុំអាចពន្យល់វាដូចម៉ាក់ពន្យល់ឡើយ » ។

ម្ដាយបាននិយាយនៅពេលពួកគេមកដល់ផ្ទះថា « កូន ម៉ាក់មានយោបល់មួយ » ។ « តោះមកតាមម៉ាក់ » ។

អាណា បានដើរតាមម្ដាយទៅកាន់បន្ទប់គ្រួសារ ។ ពួកគេបានចាប់ផ្ដើមលេងល្បែងផ្គុំរូបយប់មិញ ហើយបំណែកទាំងនោះនៅរប៉ាត់រប៉ាយនៅលើតុតូចនោះ ។

« សូមគិតអំពីដំណឹងល្អឲ្យដូចជាល្បែងផ្គុំរូបដែលរៀបហើយ » ។ ម៉ាក់បានរើសយកបំណែកមួយឡើង ។ « បំណែកជាច្រើននៃរូបភាពនេះនៅលើផែនដីក្នុងសម័យកាលផ្សេងៗគ្នា ។ ប៉ុន្តែបន្ទាប់ពីព្រះយេស៊ូវគ្រីស្ទ និង ពួកសាវករបស់ទ្រង់បានទទួលមរណភាពទៅ សេចក្ដីពិតនៃដំណឹងល្អជាច្រើនត្រូវបានបាត់បង់ ឬផ្លាស់ប្ដូរ ។ បំណែកនៃសេចក្ដីពិតទាំងនោះត្រូវតែនាំត្រឡប់មកវិញ » ។

« ដូច្នេះតើអ្វីបានកើតឡើងបន្ទាប់ពីនោះ ? » អាណាបានសាប់បំណែកមួយចំនួនដែលបាត់នោះ ។

« ជាច្រើនឆ្នាំក្រោយមកព្រះបានហៅក្មេងប្រុសនៅកសិដ្ឋានម្នាក់ ឲ្យនាំយកបំណែកទាំងអស់ត្រឡប់មកវិញ ហើយដាក់វាជាមួយគ្នាដូចកាលព្រះយេស៊ូវបានគង់នៅលើផែនដី ។ តើកូនគិតថាម្នាក់នោះគឺជានរណា ? »

« យ៉ូសែប ស្ម៊ីធ ! » អាណាបាននិយាយ ដោយញញឹម ។ « កូនគិតថាចាប់ផ្ដើមយល់វាហើយ » ។ នាង និង ម្ដាយបាននិយាយគ្នាបន្ថែមពី យ៉ូសែប ស្ម៊ីធ និង បំណែកផ្សេងទៀតនៃដំណឹងល្អដែលព្រះបាននាំត្រឡប់មកវិញតាមរយៈលោក ។

អាណាបានសរសេរ ហើយអនុវត្តការឡើងនិយាយរបស់ខ្លួននៅប៉ុន្មានថ្ងៃនោះ ។ នាងបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ថានាងអាចមានភាពក្លាហាន ហើយចែកចាយសារលិខិតរបស់នាងនៅក្នុងថ្នាក់បឋមសិក្សា ។

រូបគំនូរដោយ ប្រាយអិន បឹច



**ព្យាការីនៃការស្តារឡើងវិញ**

« យ៉ូសែប ស្ម៊ីធ . . . គឺជាឧបករណ៍នៅក្នុងព្រះហស្ត របស់ព្រះ ក្នុងការនាំយកគម្ពីរពិសិដ្ឋចេញមក បើកសម្តែង គោលលទ្ធិដែលត្រូវបានបោះបង់ចោល និងស្តារឡើងវិញ នូវបព្វជិតភាព » ។

**អែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « យ៉ូសែប ស្ម៊ីធ »** ***Liahona,*** **ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ២៨ ។**

នៅថ្ងៃអាទិត្យ នៅពេលដល់ម៉ោងដែលអាណា និយាយ នាងបានក្រោកឡើង ដកដង្ហើមធំ ហើយ បានកាន់រូបផ្គុំដាក់លើក្តារខៀនដូច្នេះមនុស្សគ្រប់គ្នា អាចមើលឃើញ ។ បំណែកទាំងអស់នៅជាមួយគ្នា ក្នុងរូបផ្គុំនោះ ។

« ជាយូរយារមកហើយ មានបំណែកនៃដំណឹងល្អដ៏សំខាន់ៗលើផែនដីនេះ ។ បន្ទាប់ពីព្រះយេស៊ូវ និង សាវករបស់ទ្រង់បានទទួលមរណភាព នោះ បំណែកមួយចំនួនបានបាត់បង់ » ។ អាណា បាន យកបំណែកមួយចំនួនចេញពីរូបផ្គុំ ហើយដាក់វាចុះ ។ « បន្ទាប់មកព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ បានហៅយ៉ូសែប ស្ម៊ីធ ជាព្យាការីឲ្យនាំត្រឡប់មកវិញនូវបំណែកនៃដំណឹងល្អដែលបានបាត់នោះ ។ នេះគឺហៅថាការស្តារឡើងវិញ » ។ នាង បានចាប់យកបំណែកនៃរូបផ្គុំដើម្បីបង្ហាញថ្នាក់បឋមសិក្សា ។ នៅខាងខ្នងវាមានពាក្យ « អំណាចបព្វជិតភាព » ។

បន្ទាប់មកអាណា បានបង្ហាញបំណែកទាំងអស់ដែលនៅសល់ ។ នាងបានអាននៅខ្នងបំណែកនិមួយៗ ពីមុននាងដាក់វាចូលទៅក្នុងកន្លែងវាក្នុងរូបផ្គុំ ។ « ព្យាការីដែលរស់នៅ . . . សាវកដប់ពីរនាក់ . . . កិច្ចការព្រះវិហារបរិសុទ្ធសម្រាប់គ្រួសារអស់កល្បជានិច្ច . . . បុណ្យជ្រមុជទឹកដោយការពន្លិច . . . ការដាក់ដៃលើក្បាលសម្រាប់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ » ។

អាណា បានចាប់រូបផ្គុំដែលរៀបហើយនោះឡើង ។ « ឥឡូវនេះយើងមានបំណែកទាំងអស់នៃដំណឹងល្អហើយ ។ នោះមានន័យថា យើងអាចឃើញយ៉ាងច្បាស់ពីរបៀបដែលយើងអាចរីករាយហើយរស់នៅជាមួយនឹងព្រះវរបិតាសួគ៌នៅថ្ងៃណាមួយម្តងទៀត ។ ខ្ញុំមានអំណរគុណចំពោះការស្តារឡើងវិញ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*

# ព្រះយេស៊ូវគ្រីស្ទ នឹងយាងមកម្ដងទៀត !

ដោយ អ៊ែរិន សាន់ដឺសុន

នៅពេលបុណ្យគ្រីស្ទម៉ាស់ មនុស្សនៅជុំវិញពិភពលោកប្រារព្ធធ្វើបុណ្យនៃការប្រសូតរបស់ព្រះអង្គសង្គ្រោះ គឺព្រះយេស៊ូវគ្រីស្ទ ។ ថ្ងៃណាមួយយើងនឹងប្រារព្ធថ្ងៃដ៏អស្ចារ្យមួយផ្សេងទៀត — គឺការយាងមកជាលើកទីពីរ នៅពេលដែលព្រះយេស៊ូវយាងត្រឡប់មកផែនដីវិញ ! ព្យាការីទាំងឡាយបានបង្រៀនអំពីអ្វីដែលនឹងកើតមានឡើងពីមុនព្រះយេស៊ូវយាងមកម្ដងទៀត ។ រឿងមួយនៃការណ៍ទាំងនោះគឺដំណឹងល្អរបស់ទ្រង់នឹងត្រូវបានផ្សព្វផ្សាយនៅទូទាំងពិភពលោក ។

ការមានសេចក្ដីជំនឿលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទជួយយើងឲ្យមានភាពសុខសាន្ត ទោះបីជាអ្វីៗដែលកើតឡើងនៅក្នុងពិភពលោកនេះហាក់បីដូចជាគួរឲ្យខ្លាចក្ដី ។ ព្រះយេស៊ូវ មានបន្ទូលថា « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ ។ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ » ( យ៉ូហាន ១៤:២៧ ) ។

នៅពេលអ្នកគិតអំពីព្រះយេស៊ូវក្នុងបុណ្យគ្រីស្ទម៉ាស់នេះ សូមចាំថាទ្រង់នឹងត្រឡប់មកវិញម្ដងទៀតនៅថ្ងៃណាមួយ មិនមែនជាព្រះឱរសទៀតឡើយប៉ុន្តែជាស្ដេចនៃអស់ទាំងស្ដេច ។ បន្ទាប់មកមនុស្សគ្រប់គ្នានឹងដឹងថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



ដកស្រង់ចេញពី *ការយាងមកជាលើកទីពីរ* ដោយ ហារី អែនឌើរសិន រូបគំនូរដោយ ប៉ុល ម៉ាន

## រៀនបន្ថែមទៀត

នៅពេលព្រះយេស៊ូវយាងត្រឡប់មកវិញ នោះទ្រង់នឹងគ្រងរាជ្យនៅលើផែនដីរយៈពេល ១០០០ ឆ្នាំ ។ ពេលនោះនឹងត្រូវបានហៅថា សហស្សវត្សរ៍ ។ អំឡុងពេលនៃសហស្សវត្សរ៍ មនុស្សនឹងក្លាយជាសុចរិត រហូតដល់សាតាំងមិនអាចល្បួងពួកគេបានទៀតឡើយ ។ ពេលនោះនឹងគ្មានការកើតទុក្ខឡើយ ហើយមនុស្សដែលធ្វើតាមព្រះគ្រីស្ទនឹងមានអារម្មណ៍សន្តិភាព ហើយរីករាយ ។

## ការជជែកគ្នាក្នុងក្រុមគ្រួសារ

គេនសម្បត្តិគឺជាអ្វីមួយដ៏ពិសេសដែលមានតម្លៃបំផុត ។ សូមអាន យ៉ូសែប ស្ម៊ីធ–ម៉ាថាយ ១:៣៦–៣៧ ។ និយាយអំពីរបៀបនៃ« ការរក្សា » ព្រះបន្ទូលរបស់ព្រះគ្រីស្ទ ជួយយើងឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ តើយើងរកព្រះបន្ទូលទ្រង់នៅឯណា ?

**ចម្រៀងបទ ៖** « ពេលទ្រង់យាងមកម្ដងទៀត » ( *សៀវភៅចម្រៀងកុមារ* ទំព័រ ៤៦ )

**ខគម្ពីរ ៖** យ៉ូហាន ១៤:២៧

**វីដេអូ ៖** សូមចូលទៅកាន់គេហទំព័រ Biblevideos.org ដើម្បីមើល « Glad Tidings of Great Joy: The Birth of Jesus Christ » ។

## ខ្ញុំអាចត្រៀមខ្លួនរួចជាស្រេច

សូមធ្វើកូនសៀវភៅមួយដើម្បីរំឭកអ្នកពីរបៀបនានាដែលអ្នកអាចរៀបចំខ្លួនក្នុងពេលឥឡូវនេះសម្រាប់ការយាងមកម្ដងទៀតរបស់ព្រះយេស៊ូវ ។

សូមកាត់សលាកប័ត្រទាំងនោះ ហើយតម្រួតវាលើគ្នា ។ សូមចោះប្រហោង ហើយយកខ្សែចងប្រហោងទាំងពីរនេះ ។

ខ្ញុំអាចត្រៀមខ្លួនរួចជាស្រេចពេលព្រះយេស៊ូវយាងមកម្ដងទៀត





ខ្ញុំអាចអធិស្ឋានជារៀងរាល់ថ្ងៃ ។



ខ្ញុំអាចអានព្រះគម្ពីរ ។



ខ្ញុំអាចរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ ។



ខ្ញុំអាចគោរពតាមព្រះបញ្ញត្តិ ។



ខ្ញុំអាចធ្វើតាមព្យាការី ។

### ព័ត៌មានពីព្រះគម្ពីរ

នេះគឺជារបៀបបីយ៉ាង ដែលអ្នកអាចយល់ព្រះគម្ពីរបានកាន់តែប្រសើរ ៖

១. មុនពេលអ្នកចាប់ផ្ដើមអានព្រះគម្ពីរ សូមអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌សុំជំនួយយល់ពីខគម្ពីរទាំងនោះ ។
២. សូមចំណាយពេលដើម្បីគិតពីអ្វីដែលអ្នកបានអាន ។
៣. ប្រាប់នរណាម្នាក់ពីអ្វី ដែលអ្នកបានរៀន និង បានទទួលអារម្មណ៍ ហើយសរសេរអ្វីទាំងនោះនៅក្នុងសៀវភៅកំណត់ហេតុ ។

# ដំណើររឿងនៃព្រះប្រសូតិកម្ម

ជាយូរលង់ណាស់មកហើយ មានស្ត្រីម្នាក់ឈ្មោះថា ម៉ារី និងមានបុរសម្នាក់ឈ្មោះថា យ៉ូសែប ដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ។ ម៉ារី និង យ៉ូសែប គឺមនុស្សល្អ ដែលបានធ្វើអ្វីៗដែលព្រះបានមានព្រះទ័យចង់ឲ្យពួកគេធ្វើ ។





នៅថ្ងៃមួយ មានទេវតាមួយអង្គបានយាងមកជួបម៉ារី ហើយប្រាប់គាត់ថា គាត់នឹងមានកូន ! ទេវតានោះបានប្រាប់គាត់ថា គាត់គួរដាក់ឈ្មោះបុត្រនោះថាយេស៊ូវ ។ បុត្រនោះគឺជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះ ។

រូបគំនូរដោយ ស៊ីមីនី ប្លូកឃើរ



ម៉ារី និង យ៉ូសែប ត្រូវធ្វើដំណើរទៅទីក្រុងមួយហៅថា បេថ្លេហិម ដើម្បីបង់ពន្ធ ។



ទីក្រុងនោះ មានមនុស្សកកកុញ ។ ដូច្នេះម៉ារី និង យ៉ូសែប បានសម្រាកនៅកន្លែងមួយដែលគេទុកឲ្យសត្វដេក ។ នៅយប់នោះព្រះឱរសយេស៊ូវ បានប្រសូតមក !



ផ្កាយថ្មីមួយបានរះឡើង
នៅលើមេឃ ។

អ្នកគង្វាលកំពុងថែទាំចៀមនៅវាលជិត
នោះ ។ ទេវតាបានយាងមក ហើយប្រាប់
អ្នកគង្វាលថាព្រះអង្គសង្គ្រោះបានប្រសូត
ហើយ ។ អ្នកគង្វាលបានទៅជួប ហើយ
ថ្វាយបង្គំព្រះឱរសយេស៊ូវ ។





នៅទីដ៏សែនឆ្ងាយ ពួកហោរាបានឃើញផ្កាយថ្មីនោះ ។ ពួកគេបានដឹងច្បាស់ថា នោះគឺជាសញ្ញាដែលបង្ហាញថាព្រះអង្គសង្គ្រោះបានប្រសូតហើយ ។ ពួកគេបានធ្វើដំណើរតាមផ្កាយនោះរហូតដល់ពួកគេបានជួបព្រះយេស៊ូវ ។ ពួកគេបានថ្វាយអំណោយដល់ទ្រង់ ហើយបានថ្វាយបង្គំទ្រង់ ។

បន្ទាប់ពីពួកហោរាបានចាកចេញទៅ នោះទេវតាបានយាងមកជួបយ៉ូសែប ។ ទេវតានោះបាននិយាយថា ស្ដេចអាក្រក់មួយអង្គចង់ធ្វើបាបព្រះយេស៊ូវ ។ ទេវតានោះបាននិយាយថា គ្រួសាររបស់ពួកគេគួរតែប្ដូរទីលំនៅទៅប្រទេសអេស៊ីបដើម្បីមានសុវត្ថិភាព ។





យ៉ូសែប ម៉ារី និង ព្រះយេស៊ូវ បានរស់នៅក្នុងប្រទេសអេស៊ីបរហូតដល់មានសុវត្ថិភាពដើម្បីអាចត្រឡប់មកប្រទេស អ៊ីស្រាអែលវិញបាន ។ ព្រះយេស៊ូវបានចម្រើនវ័យធំឡើងនៅក្នុងទីក្រុងមួយហៅថា ណាសារ៉ែត ។ ទ្រង់បានរៀន ដើម្បីជួយមនុស្ស មានចិត្តសប្បុរស និង ចេះគោរពប្រតិបត្តិ ។ ទ្រង់បានរៀនអ្វីៗគ្រប់យ៉ាងដែលទ្រង់ត្រូវតែរៀន ដើម្បីធ្វើជាព្រះអង្គសង្គ្រោះរបស់ពួកយើង ។ ទ្រង់ធ្វើតាមផែនការរបស់ព្រះសម្រាប់ទ្រង់ជានិច្ច ។



នៅពេលបុណ្យគ្រីស្ទម៉ាស់យើងប្រារព្ធពិធីបុណ្យប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមចង្អុលរូបភាពនៃមនុស្សទាំងនេះ ដែលមាននៅក្នុងរឿងព្រះប្រសូតិកម្ម ។

យើងអាចធ្វើដូចជា **ម៉ារី និង យ៉ូសែប** តាមរយៈការធ្វើអ្វីៗដែលព្រះមានព្រះទ័យចង់ឲ្យពួកយើងធ្វើ ។

យើងអាចធ្វើដូចជា **អ្នកគង្វាល** និង **ពួកហោរា** ដោយដើរតាមព្រះយេស៊ូវគ្រីស្ទ ។

យើងអាចធ្វើដូចជា **ទេវតា** តាមរយៈការប្រាប់មនុស្សដទៃពីរឿងពិតនៃបុណ្យគ្រីស្ទម៉ាស់ ។

ហើយយើងអាចធ្វើដូចជា **ព្រះយេស៊ូវ** តាមរយៈការធ្វើតាមគំរូរបស់ទ្រង់ ! ■

**ចេញពីព្រះគម្ពីរ**

អ្នកអាចអានរឿងព្រះប្រសូតិកម្មនៅក្នុង ម៉ាថាយ ១:១៨–២៥; ២; លូកា ១:២៦–៣៨; ២:១–២០ ។



ដោយប្រធាន ហាវើដ ដបុលយូ ហឹនធើរ ( ១៩០៧–៩៥ )
ប្រធានទីដប់បួននៃសាសនាចក្រ

# បុណ្យគ្រីស្ទម៉ាស់ដ៏ពិត

*បុណ្យគ្រីស្ទម៉ាស់ដ៏ពិតមានដល់អស់អ្នកដែលបានយាងព្រះគ្រីស្ទមកក្នុងជីវិតរបស់ខ្លួន ។*



នៅក្នុងសំបុត្រខ្លីមួយរបស់ប៉ុលទៅកាន់ពួកកាឡាទី លោកបានបង្ហាញពីកង្វល់យ៉ាងធំលើការបង្ហាញក្តីឥតជំនឿរបស់ពួកគេ និង ការបោះបង់ចោលនូវការបង្រៀននានារបស់លោកអំពីព្រះគ្រីស្ទ ។ លោកបានសរសេរទៅពួកគេថា « គួរឲ្យមានសេចក្តីសង្វាត ខាងការល្អជាដរាបទៅ មិនមែនតែក្នុងកាលដែលខ្ញុំនៅជាមួយប៉ុណ្ណោះឡើយ ។ កូនចៅអើយ ខ្ញុំលំបាកក្នុងចិត្តជាពន់ពេក ដោយព្រោះអ្នករាល់គ្នាម្តងទៀត ទាល់តែព្រះគ្រីស្ទបានកមានរូបរាង ក្នុងអ្នករាល់គ្នាឡើង » ( កាឡាទី ៤:១៨–១៩ ) ។ និយាយម្យ៉ាងទៀតថា ប៉ុល បានបញ្ជាក់ថាខ្លួនគាត់មានការឈឺចាប់ហើយព្រួយបារម្ភរហូតដល់ព្រះគ្រីស្ទបាន « កមានរូបរាង » ក្នុងពួកគេ ។ នេះគឺជារបៀបមួយផ្សេងទៀតនៃការនិយាយថា « នៅក្នុងព្រះគ្រីស្ទ » ដូចដែលបានបង្ហាញនេះត្រូវបានប៉ុលប្រើវាដដែលៗនៅក្នុងការសរសេររបស់លោក ។

វាអាចធ្វើបានដើម្បីឲ្យព្រះគ្រីស្ទប្រសូតនៅក្នុងជីវិតរបស់មនុស្សទាំងឡាយ ហើយនៅពេលបទពិសោធន៍បែបនោះពិតជាកើតឡើងមែន នោះមនុស្សម្នាក់គឺ « នៅក្នុងព្រះគ្រីស្ទ » — ព្រះគ្រីស្ទគឺបាន « កមានរូបរាង » នៅក្នុងខ្លួនបុគ្គលនោះ ។ នេះត្រូវសន្មត់ជាមុនថា យើងយកព្រះគ្រីស្ទដាក់មកក្នុងដួងចិត្តរបស់យើង ហើយធ្វើឲ្យទ្រង់មានឥទ្ធិពលរស់រវើកនៅក្នុងជីវិតរបស់យើង ។ ទ្រង់មិនគ្រាន់តែជាសេចក្តីពិតទូទៅមួយ ឬ ជារឿងពិតនៅក្នុងប្រវត្តិសាស្ត្រឡើយ ប៉ុន្តែទ្រង់ជាព្រះអង្គសង្គ្រោះនៃមនុស្សគ្រប់ទីកន្លែង និងគ្រប់ពេលទាំងអស់ ។ នៅពេលយើងព្យាយាមប្រែក្លាយដូចជាព្រះគ្រីស្ទ នោះទ្រង់ « កមានរូបរាង » នៅក្នុងខ្លួនយើង បើសិនយើងបើកទ្វារ នោះទ្រង់នឹងចូលមក បើសិនយើងស្វែងរកការទូន្មានរបស់ទ្រង់ នោះទ្រង់នឹងទូន្មានយើង ។ ដើម្បីឲ្យព្រះគ្រីស្ទ « កមានរូបរាង » ក្នុងយើង នោះយើងត្រូវតែមានជំនឿលើទ្រង់ និង ដង្វាយធួនរបស់ទ្រង់ ។ ការមានជំនឿបែបនោះលើព្រះគ្រីស្ទ និង ការរក្សាព្រះបញ្ញត្តិរបស់ទ្រង់គឺ មិនពុំដាក់កំហិតលើយើងឡើយ ។ តាមរយៈព្រះបញ្ញត្តិទាំងនេះ មនុស្សទទួលបានសេរីភាព ។ ម្ចាស់នៃមេត្រីភាពនេះរង់ចាំប្រទាននូវភាពសុខសាន្តនៃដួងចិត្ត ដែលធ្វើឲ្យយើងម្នាក់ៗអាចចែកចាយនូវភាពសុខសាន្តនោះ ។

បុណ្យគ្រីស្ទម៉ាស់ដ៏ពិតមានដល់អស់អ្នកដែលបានយាងព្រះគ្រីស្ទមកក្នុងជីវិតរបស់ខ្លួន ជាកម្លាំងចលករថាមពល និង ភាពក្លៀវក្លា ។

ក្នុងការអង្កេតមើលរបស់ខ្លួនអំពីរដូវកាលបុណ្យគ្រីស្ទម៉ាស់ ដេម វ៉ាលីងហ្វត បានសរសេរឃ្លានេះ ៖

*បុណ្យគ្រីស្ទម៉ាស់មិនមែនមួយថ្ងៃ ឬ មួយរដូវឡើយ ប៉ុន្តែវាជាលក្ខខណ្ឌនៃដួងចិត្ត និងគំនិតទៅវិញទេ ។*
*បើសិនយើងស្រឡាញ់អ្នកជិតខាងរបស់យើងដូចយើងស្រឡាញ់ខ្លួនឯង*
*បើសិនយើងមានទ្រព្យសម្បត្តិ តែយើងមានសេចក្តីកំសត់ខាងវិញ្ញាណ ហើយបើសិនយើងក្រទ្រព្យសម្បត្តិ តែយើងមានព្រះគុណយ៉ាងច្រើន*
*បើសិនយើងមានសេចក្តីសប្បុរសដោយពុំចេះអួតខ្លួន តែជាដែលសេចក្តីស្រឡាញ់អត់ធ្មត់ហើយសប្បុរស*
*បើសិននៅពេលបងប្អូនរបស់យើងសុំអាហារបរិភោគ តែយើងចំអែតតែខ្លួនឯងនោះ បើសិនរាល់ថ្ងៃចាប់ផ្តើមជាមួយនឹងឱកាស ហើយបញ្ចប់ទៅវិញដោយសម្រេចបានស្នាដៃទោះជាវាតិចតួចក្តី —*
*នោះរាល់ថ្ងៃនេះគឺជាថ្ងៃរបស់ព្រះគ្រីស្ទ ហើយបុណ្យគ្រីស្ទម៉ាស់គឺនៅក្បែរយើងជានិច្ច ។*
*( នៅក្នុង Charles L. Wallis, បានបោះពុម្ព* Words of Life *[ ឆ្នាំ ១៩៦៦ ] ទំព័រ ៣៣ ) . . .*

បើសិនអ្នកមានបំណងប្រាថ្នាស្វែងរកវិញ្ញាណពិតនៃបុណ្យគ្រីស្ទម៉ាស់ ហើយទទួលទាននូវភាពផ្អែមល្ហែមរបស់វា សូមឲ្យខ្ញុំផ្តល់យោបល់នេះដល់អ្នក ។ អំឡុងពេលដ៏ខ្លីនៃឱកាសបុណ្យគ្រីស្ទម៉ាស់នេះ សូមឆ្លៀតពេលបង្វែរដួងចិត្តរបស់អ្នកទៅកាន់ព្រះ ។ ប្រហែលជានៅក្នុងពេលដ៏ស្ងប់ស្ងាត់ជាច្រើនម៉ោង និង ក្នុងទីកន្លែងដ៏ស្ងាត់ និង ដោយលុតជង្គង់របស់អ្នក — តែឯង ឬ ជាមួយមនុស្សជាទីស្រឡាញ់របស់ខ្លួន — ថ្លែងអំណរគុណចំពោះរឿងល្អៗដែលមានក្នុងជីវិតរបស់អ្នក ហើយសុំឲ្យព្រះវិញ្ញាណរបស់ទ្រង់គង់នៅក្នុងខ្លួនអ្នក នៅពេលអ្នកព្យាយាមយ៉ាងខ្លាំងដើម្បីបម្រើទ្រង់ និង កាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។ ទ្រង់នឹងដឹកដៃអ្នក ហើយការសន្យានានារបស់ទ្រង់នឹងត្រូវបានរក្សាទុក ។ ■

*ដកស្រង់ចេញពី « The Real Christmas »* Liahona, *ខែ ធ្នូ ឆ្នាំ ២០០៥ ទំព័រ ១២–១៥ ។*

# ការយល់ដឹង



សមាជិកនៅទីក្រុង ណាតាល់ ប្រទេសប្រេស៊ីល ។

**តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យថ្ងៃឈប់សម្រាកទុកជាទីរីករាយចិត្ត ?**

« ថ្ងៃឈប់សម្រាកផ្ដល់ឲ្យយើងនូវឱកាសពង្រឹងទំនាក់ទំនងក្នុងគ្រួសារ ។ . . . យើងធ្វើឲ្យថ្ងៃឈប់សម្រាក ជាទីរីករាយចិត្ត នៅពេលយើងបង្រៀនដំណឹងល្អដល់កូនៗយើង ។ . . . បន្ថែមលើពេលវេលាជាមួយគ្រួសារ អ្នកអាចធ្វើឲ្យថ្ងៃឈប់សម្រាកជាទីរីករាយចិត្តបាន ដោយការធ្វើពង្សប្រវត្តិ ។ . . . សូមធ្វើឲ្យថ្ងៃឈប់សម្រាកជាទីរីករាយចិត្ត ដោយការបម្រើដល់មនុស្សដទៃ ជាពិសេសដល់អស់អ្នកដែលមានអារម្មណ៍មិនល្អ ឬ អ្នកដែលឯកោ ឬ កំសត់ទុរគត » ។

**ប្រធាន រ័សុល អិម ណិលសុន** ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ថ្ងៃឈប់សម្រាកជាទីរីករាយចិត្ត » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៣០, ១៣១ ។

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ

### ការត្រឡប់មកផ្ទះវិញ **មុនកំណត់** នៃបេសកកម្មរបស់ខ្ញុំ

បន្ទាប់ពីខ្ញុំត្រឡប់មកផ្ទះវិញ ខ្ញុំមានការលំបាកជាមួយនឹងទីបន្ទាល់របស់ខ្ញុំ ។ ប៉ុន្តែទីបំផុតខ្ញុំបានសន្យាជាមួយព្រះវរបិតាសួគ៌របស់ខ្ញុំថា ខ្ញុំនៅតែបន្តស្មោះត្រង់ ទោះបីជាខ្ញុំពុំបានទទួលចម្លើយរបស់ខ្ញុំក្តី ។



ទំព័រ ៤៤

## សម្រាប់យុវវ័យ



ទំព័រ ៦០

### អ្វីៗ **ដែលខ្ញុំបានរៀន** ក្នុងនាមជាអ្នកប្រែចិត្តជឿវ័យក្មេង

សូមស្រមៃថាអ្នកចូលរួមក្នុងសាសនាចក្រនៅអាយុ ១៧ ឆ្នាំ ហើយគ្មាននរណាម្នាក់សោះនៅក្នុងទីក្រុងនោះនិយាយភាសារបស់អ្នកឡើយ ។ សូមអានអំពីអ្វី ដែលអែលឌើរ ក្លេប៊ីនហ្គាតនៃពួកចិតសិបនាក់បានរៀននៅក្នុងស្ថានភាពនោះ !

## សម្រាប់កុមារ

### ដំណើររឿងនៃ ព្រះប្រសូតិកម្ម

រីករាយនឹងរូបគំនូរប្រាំមួយនៃដំណើររឿងនៃការប្រសូតរបស់ព្រះឱរសយេស៊ូវ !



ទំព័រ ៧៤

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02125 72258 2